សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal university of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កាលានុវត្តភាព នៃការចោទប្រកាន់របស់អយ្យការ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


តាក់តែងឡើងដោយ
និស្សិតឈ្មោះ កញ្ញា **ប៉េង សោភ័ណ្ឌ**

សាស្ត្រាចារ្យណែនាំ
លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ប៉េង សោភ័ណ្ឌ** ជានិស្សិតផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា ២០១៥-២០១៩ ជំនាន់ទី១៩នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាដំបូង នាងខ្ញុំ សូមថ្លែងអំណរគុណ ចំពោះលោកឪពុក អ្នកម្ដាយទាំងទ្វេរ ដែលបានបង្កើតរូបកាយ និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន និងឧបត្ថម្ភគ្រប់បែបយ៉ាងតាំងពីតូចរហូតដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត មិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ ថែមទាំងបាន ឱ្យកូនបានរៀនសូត្រ មានចំណេះដឹង រហូតដល់បញ្ចប់បរិញ្ញាបត្រដោយជោគជ័យ។ គុណយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណ ទាំងពីរជាម្លប់ដ៏ប្រពៃ ត្រជាក់ត្រជុំសម្រាប់កូនមានទំហំធំធេងរកអ្វីមកប្រៀបផ្ទឹមមិនបានឡើយ ។ ទង្វើរបស់លោកទាំងពីរធ្វើឱ្យកូនចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបានហើយ នឹងស្ថិតក្នុងដួងព្រលឹងរបស់កូនជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ។

នាងខ្ញុំក៏សូមថ្លែអំណរគុណចំពោះសាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី លោកគ្រូសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រា និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្ដល់នូវពុទ្ធិល្អៗ សម្រាប់ជាប្រទីបបំភ្លឺដល់ជីវិតនាងខ្ញុំ។

ជាពិសេស នាងខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឱ្យដំណើរការនៃការតាក់តែងសារណានេះឡើងប្រកដដោយជោគជ័យ។ លោកសាស្ត្រាចារ្យបានចំណាយទាំងកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មាន តម្លៃក្នុងការណែនាំផ្ដល់អនុសាសន៍ល្អៗ និងជួយកែលម្អនូវចំនុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យសារណានាងខ្ញុំទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរ។

ជាចុងបញ្ចប់ នាងខ្ញុំគោរពជូនដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោក លោកស្រី សាស្រាចារ្យទាំងអស់ជួបតែសេចក្ដីសុខ មានសុខភាពល្អ អាយុយឺនយូរ ជៀសផុតពី រោគាព្យាធិ និង សត្រូវប៉ុនប៉ងធ្វើបាបឆ្ងាយជិតសូមឱ្យវិនាសបាត់បង់។

# អារម្ភកថា

ឆ្លងកាត់ការសិក្សាអស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្ត្រសេដ្ឋកិច្ច គឺជាពេលវេលាដែលមានអត្ថន័យបំផុតសម្រាប់និស្សិតទាំងអស់ ដែលបាន សិក្សានៅ ក្នុងជំនាន់ទី១៩ និងជាពិសេសសម្រាប់នាងខ្ញុំឈ្មោះ **ប៉េង សោភ័ណ្ឌ** ។ ការដែលទទួលបានឱកាសក្លាយខ្លួនជានិស្សិតនៃសាកលវិទ្យាល័យនេះ គឺជាកិត្តិយសដ៏ក្រៃលែង សម្រាប់នាងខ្ញុំ ហើយអ្វីដែលកាន់តែពិសេសទៀតនោះគឺ សាកលវិទ្យាល័យបានផ្តល់នូវឱកាស ដល់នាងខ្ញុំដើម្បីសសេរសារណាបញ្ចប់ការ សិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តនេះ។ហេតុដូច្នេះហើយនាងខ្ញុំក៏បានជ្រើសរើសនូវប្រធានបទ **"កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ"** ។

នៅក្នុងការសិក្សាលើប្រធានបទនេះ នាងខ្ញុំអាចសន្និដ្ឋានបានថាអង្គការអយ្យការអមសាលាដំបូងរាជធានី/ខេត្តក្រុង បានដើរតួរនាទីយ៉ាងសំខាន់នៅក្នុងលំហូរនីតិវិធីចោទប្រកាន់ខាងបទព្រហ្មទណ្ឌ ឬមិនចោទប្រកាន់ទៅលើបទលើបទល្មើសណាមួយ ហើយយើងក៏អាចសង្កេតឃើញយ៉ាងច្បាស់ពីតួនាទីរបស់អយ្យការ ដែលត្រូវបានផ្តល់សិទ្ធិតាមរយៈរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងជាពិសេស មានចែងក្នុងនីតិវិធីច្បាប់។ អយ្យការធ្វើការចោទពីបទល្មើសព្រហ្មទណ្ឌ ហើយការចោទប្រកាន់នេះទៀតសោធច្បាប់នៃប្រទេសកម្ពុជាយើងបានប្រកាន់យកនូវគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដែលព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់ នូវរាល់បទល្មើសដែលកើតមានឡើង មិនថាអំពើនោះបង្កព្យសនកម្មដល់សណ្តាប់ធ្នាប់សាធារណៈមានកម្រិតធ្ងន់ធ្ងរ ឬតិចតួចយ៉ាងណាក៏ដោយ។ ការកំណត់យកគោលការណ៍នេះដើម្បីបញ្ឈប់រាល់បទល្មើសកុំឲ្យកើតមានឡើង ប៉ុន្តែវាហាក់ដូចជាព្រៃផ្សៃចំពោះទង្វើដែលមានកម្រិតគ្រោះថ្នាក់តិចតួច ហើយធ្វើការចោទប្រកាន់លើសពីនេះ ទៅទៀតវាក៏កើតមាននូវផលវិបាកយ៉ាងច្រើនផងដែរនៅក្នុងសង្គម។ ហេតុនេះហើយ បានជាកម្ពុជាធ្វើការផ្លាស់ប្តូរទៅតាមបរិបទសង្គមដោយងាកមកយកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ មានន័យថាព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើគួរចោទប្រកាន់ ឬយ៉ាងណាចំពោះអំពើដែលបង្កើតជាបទល្មើស ។ គោលការណ៍នេះផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនក្នុងការជួយសម្រេចដល់ដំណើរការរឿងក្តីក្នុងតុលា

ការ ឲ្យបានឆាប់រហ័សដើម្បីជៀសវាងការកកស្ទះសំណុំរឿង បន្ថែមពីលើនេះទៅទៀតវាក៏ជួយសម្រួលដល់បទល្មើសណាមួយ ដើម្បីធ្វើការផ្តន្ទាទោសជនល្មើសក្នុងគោលបំណងធ្វើការអប់រំ និងកែប្រែជនល្មើសនោះឲ្យត្រលប់មករស់នៅក្នុងស្ថានភាពដែល សង្គមទទួលស្គាល់វិញ ប៉ុណ្ណោះទេ មិនមានការសងសឹកគ្នា។

ប្រធានបទនេះត្រូវបានស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩។ ក្នុងរយៈពេលនេះ នាងខ្ញុំបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ដើម្បី ស្រាវជ្រាវនូវឯកសារសំខាន់ៗជាច្រើនដែលពាក់ព័ន្ធ ដែលមានទាំងច្បាប់ជាតិ និងអន្តរជាតិ សំណុំរឿងនៅក្នុងសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ចៅក្រម ក្រឡាបញ្ជី ហើយបានចងក្រងឯកសារ ទាំងនោះបញ្ចូលគ្នាដោយទទួលបានការផ្តល់ប្រឹក្សាយោបល់ពីលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ទើបសារណាបញ្ចប់ការសិក្សានេះត្រូវបានបញ្ចប់ដោយជោគជ័យ។

ក្រោយពីបានស្រាវជ្រាវប្រធានបទនេះហើយ នាងខ្ញុំសង្ឃឹម និងជឿជាក់ថាចំណេះដឹង និងបទពិសោធន៍ទាំងឡាយដែលទទួលបានពីការស្រាវជ្រាវនេះ អាចឱ្យនាងខ្ញុំយកមកប្រើប្រាស់បានដើម្បីជាប្រយោជន៍សម្រាប់ផ្ទាល់ខ្លួន និងសង្គមជាតិទាំងមូលនាថ្ងៃអនាគត។ ម៉្យាងវិញទៀត ស្នាដៃនេះបានបន្សល់ទុកជាឯកសារបន្ត នឹងអាចក្លាយជាឯកសារជំនួយ ក្នុងការស្រាវជ្រាវរបស់សិស្ស និស្សិតជំនាន់ក្រោយ ឬ បុគ្គលទាំងឡាយណាដែលមានបំណងចង់សិក្សាស្វែងយល់ និងទទួលបានចំណេះដឹងបន្ថែមលើប្រធានបទនេះ ក៏ដូចជាប្រធានបទដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។

ជាទីបញ្ចប់ក្នុងការសិក្សាស្រាវជ្រាវរបស់ខ្ញុំនេះ សូមសំណូមពរដល់មិត្តអ្នកអាន ក៏ដូចជានិស្សិត ព្រះសង្ឃ ដែលបានសិក្សា ឬស្រាវជ្រាវសារណារបស់នាងខ្ញុំ សូមមេត្តាផ្តល់យោបល់ដល់ការសិក្សាស្រាវជ្រាវរបស់ខ្ញុំផងដើម្បីបានកែសម្រួល និងបំពេញបន្ថែមនូវចំណុចខ្វះខាត ក៏ដូចជាកំហុសដែលកើតមានក្នុងសារណានេះ។

# មាតិកា


សេចក្តីផ្តើម

១. បុព្វហេតុនៃការស្រាវជ្រាវ..............................................................................០១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ.......................................................................០២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ.................................................................០២

៤. ផលប្រយោជន៍នៃការសិក្សាស្រាវជ្រាវ..............................................................០៣

៥. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ.........................................................០៣

៦. ផែនការ និងរចនាបទនៃការសិក្សាស្រាវជ្រាវ.......................................................០៤

ជំពូកទី ១

និយមន័យ និងប្រវត្តិអយ្យការ

ផ្នែកទី១ៈអយ្យការ

១.និយមន័យ ៖របស់អយ្យការ

១.១ប្រវត្តិស្ថាប័នអយ្យការ.....................................................................................០៨

១.២.ការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ និងផ្តាច់ពីមុខងារព្រះរាជអាជ្ញា...............................១១

២.សញ្ញាណទូទៅនៃអង្គការអយ្យការ

២.១. រចនាសម្ព័ន្ធនៃស្ថាប័នអយ្យការ.....................................................................១៣

២.២.រចនាសម្ព័ន្ធមហាអយ្យការអមតុលាការកំពូល....................................................១៣

២.៣. រចនាសម្ព័ន្ធមហាអយ្យការអមសាលាឧទ្ធរណ៍......................................................១៤

២.៤. រចនាសម្ព័ន្ធអយ្យការអមតុលាការជំបូងរាជធានី-ខេត្តក្រុង.......................................១៤

២.៥. រចនាសម្ព័ន្ធអយ្យការអមតុលាការយោធា...........................................................១៥

៣.សមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អង្គការអយ្យការ

៣.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា.........................................................................១៦

៣.២. តួនាទីរបស់ព្រះរាជអាជ្ញា...............................................................................១៧

៣.៣.ភារកិច្ចរបស់ព្រះរាជាអាជ្ញា..............................................................................១៨

៣.៤.សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា.........................................................................១៨

ផ្នែកទី២ៈគោលការណ៍របស់អង្គការអយ្យការ

១.គោលការណ៍ឯករាជ្យ

១.១.គោលការណ៍អវិភាគ.......................................................................................១៨

១.២. គោលការណ៍ឯកភាព.....................................................................................១៩

១.៣. គោលការណ៍នៃការមិនទទួលខុសត្រូវ……………………………… ……………..១៩
១.៤. គោលការណ៍មិនអាចប្ដឹងជិតចិត្ត..…………………………………………………………១៩
២.ទ្រឹស្ដីនៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ
២.១. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់…………………………………… ២០
២.២. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់..………………………………………..២១
២.៣.ក្របខ័ណ្ឌក្រមពិភាក្សាព្រហ្មទណ្ឌឆ្នាំ១៩៦២..…………………………………………….២២
២.៤.ក្របខណ្ឌស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣(UNTAC) ……………………………… ២៣
២.៥. បច្ចុប្បន្នកម្មអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧. …………………………..២៣
៣. ការទទួលខុសត្រូវរបស់ស្ថាប័នអយ្យការ
៣.១. ការដំឡើងឋានៈដល់ព្រះរាជអាជ្ញា…..…………………………………………………… ២៣
៣.២. ការដាក់ទណ្ឌកម្មដល់ព្រះរាជអាជ្ញារង…………………………………………………..២៤
៤. ទំនាក់ទំនងព្រះរាជអាជ្ញាជាមួយបុគ្គលដែលពាក់ព័ន្ធ
៤.១. ទំនាក់ទំនងព្រះរាជអាជ្ញាជាមួយមន្ត្រីនគរបាលយុត្តិធម៌………………………………..២៥
៤.២. ទំនាក់ទំនងព្រះរាជអាជ្ញាជាមួយចៅក្រមស៊ើប………………………………………….. ២៦

## ជំពូកទី ២

## គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់តំណាងអយ្យការ

ផ្នែកទី១.សញ្ញាណនៃការតំកល់រឿងទុកឥតចាត់ការ
១.ការតម្កល់រឿងទុកឥតចាត់ការ
១.១. មូលហេតុ នីតិវិធី និង អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ………………..……..៣០
១.១.១. ការរំលត់បណ្ដឹងអាជ្ញា………………………………………………………………. ៣០
១.១.២. ស្ថានភាពនៃអំពើ……………………………………………………………….. ៣៥
២. នីតិវិធី និង អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ
២.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ………………………………………… ៣៨
២.២ .អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ……………………………………… ៣៩
៣. ការប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
៣.១. បុគ្គលដែលជាអ្នកដាក់ពាក្យប្ដឹង…………………………………………… ៤៤
៣.២. នីតិវិធីនៃការប្ដឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍……………………… ៤៥
៣.៣. អយ្យការដែលមានសមត្ថកិច្ចលើការសម្រេចសេចក្ដី…………………………..៤៦
៣.៤. រយៈពេលដែលអាចធ្វើបណ្ដឹងតវ៉ា………………………………………………. ៤៦
៤. អំណាចអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ

៤.១. លក្ខខណ្ឌនៃការប្រើអំណាចអធិបញ្ញា……………………………………………… ៤៨
៤.២. អំណាចអធិបញ្ញា………………………………………………………………… ៤៩
៤.២.១. ទម្រង់និងខ្លឹមសារនៃអំណាចអធិបញ្ញា……………………………………… ៤៩
៤.២.២. អានុភាពនៃអំណាចអធិបញ្ញា……………………………………………… ៥០
៤.២.៣.គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការ……………………………… ៥០
៤.២.៤. គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការចំពោះសង្គម……………… ៥១
ផ្នែកទី២ៈការបើកការស៊ើបសួរ
១. នីតិវិធីនៃការបើកការស៊ើបសួរ
១.១. លក្ខខណ្ឌនៃការបើកការស៊ើបសួរក្នុងបទល្មើសព្រហ្មទណ្ឌ……………………… ៥៥
១.២. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ……………………………………… ៥៧
១.៣. ការចូលរួមរបស់អង្គការអយ្យការក្នុងការស៊ើបសួរ……………………………… ៥៨
១.៣.១. ការសួរ និង ស្តាប់ចម្លើយ……………………………………………………… ៥៩
១.៣.២. ការប្រគល់វត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ………………………………… ៦១
១.៣.៣. ដំណើរការនៃការឃុំខ្លួន………………………………………………………… ៦២
១.៣.៤ .ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ……………………… ៦២
១.៣.៥. ដីកាសន្និដ្ឋានស្តាពរបញ្ចប់ការស៊ើបសួររបស់អង្គការមហាអយ្យការ…… ៦២
២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់
២.១. លក្ខខណ្ឌនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់……………………………… ៦៤
២.២.លក្ខខណ្ឌនៃបទល្មើស………………………………………………………………… ៦៦
២.៣. នីតិវិធីនៃកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់………………………………… ៦៧
៣. លក្ខខណ្ឌ និងនីតិវិធីបង្ហាញខ្លួនភ្លាម
៣.១. លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម…………………………………………………… ៧១
៣.២.
នីតិវិធីនៃការបង្ហាញខ្លួនភ្លាម…………………………………………………………… ៧២
៣.៣.ភាពមិនអាចដំណើរការទៅបាននៃនីតិវិធីបង្ហាញខ្លួនភ្លាម…………………………… ៧៤
សេចក្តីសន្និដ្ឋាន ……………………………………………………………………………… ៧៦
ការផ្តល់អនុសាសន៍……………………………………………………………………………… ៧៨
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

## ១. បុព្វហេតុនៃការស្រាវជ្រាវ

ជាទូទៅយើងបានដឹងរួចមកហើយថា ដើម្បីគ្រប់គ្រងប្រទេសមួយ ឬសង្គមជាតិមួយប្រកបទៅដោយសន្តិសុខ សណ្តាប់ធ្នាប់ និងការអភិវឌ្ឍន៍សង្គមនោះត្រូវតែមានច្បាប់គ្រប់គ្រង និងការអនុវត្តមួយប្រកបដោយប្រសិទ្ធភាព។ ច្បាប់គឺជាវិធាននៃបណ្តុំទាំងឡាយណាដែលរដ្ឋបានបង្កើតឡើងដើម្បីគ្រប់គ្រង ថែរក្សាសណ្តាប់ធ្នាប់ ឲ្យមានរបៀបរៀបរយនៅក្នុងសង្គម។ ហើយការបង្កើត ការអនុវត្តច្បាប់ដែលប្រកបដោយភាពត្រឹមត្រូវ មានប្រយោជន៍ និងប្រសិទ្ធភាពក្នុងរដ្ឋមួយនោះ ត្រូវបានគេឲ្យឈ្មោះថាជាសង្គមនីតិរដ្ឋ។ ពាក្យថា នីតិរដ្ឋ គឺជារដ្ឋមួយដែលប្រជាពលរដ្ឋទាំងអស់រស់នៅដោយភាពស្មើភាពគ្នា ហើយត្រូវបានគ្រប់គ្រងដោយច្បាប់។ ទន្ទឹមនឹងនេះ កម្ពុជាគឺជារដ្ឋមួយដែលប្រកាន់យកទម្រង់នៃការគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យសេរីពហុបក្ស ដែលទម្រង់នៃការគ្រប់គ្រងរដ្ឋនេះ ទាមទារជាចាំបាច់ នៃការវិវឌ្ឍន៍ខ្លួនទៅជាសង្គមនីតិរដ្ឋមួយ។ មិនតែប៉ុណ្ណោះ កម្ពុជាបានខិតខំធ្វើកំណែទម្រង់ច្បាប់ និងវិស័យតុលាការរបស់ខ្លួនជាបន្តបន្ទាប់ តាមរយៈការបង្កើតនូវបទបញ្ញត្តិច្បាប់ថ្មីៗ និងធ្វើវិសោធនកម្មនូវវិធានច្បាប់មួយចំនួន។ នៅក្នុងវិធាននៃច្បាប់ដែលត្រូវបានធ្វើកំណែទម្រង់ទាំងនោះ បទបញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌត្រូវបានលើកយកមកអនុវត្តជាចាំបាច់ ពីព្រោះវិធានទាំងនោះ វាបានផ្សារភ្ជាប់ទៅនឹងការរស់នៅរបស់ប្រជាពលរដ្ឋ។

ការវិវឌ្ឍន៍នៃវិធាននីតិវិធីព្រហ្មទណ្ឌ បានលុបចោលនូវគោលការណ៍មួយចំនួន ហើយក៏បានរំលេចឲ្យមានគោលការណ៍មួយចំនួនទៀតសម្រាប់អយ្យការផងដែរ។ ស្ថាប័នអយ្យការ គឺជាស្ថាប័នមួយដែលនៅអមគ្រប់សាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយអយ្យការដែលបម្រើការនៅស្ថាប័ននេះគឺរួមមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ។ ស្ថាប័ននេះមានអំណាចនៅក្នុងការធ្វើចំណាត់ការលើបណ្តឹងអាជ្ញា ដែលធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថា "មានតែព្រះរាជអាជ្ញាទេដែលជាម្ចាស់នៃបណ្តឹងអាជ្ញា"។ ហើយអង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យអយ្យការអនុវត្តច្បាប់។ ដោយឆ្លងកាត់ការអនុវត្តកន្លងមក បានប្រកាន់យកប្រព័ន្ធនៃការចោទប្រកាន់ពីរប្រភេទគឺ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

និងគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់។ នៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាន់យកគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដែលកំណត់ដាក់ជាកាតព្វកិច្ចនៃការចោទប្រកាន់ដល់ស្ថាប័នអយ្យការត្រូវតែចោទប្រកាន់គ្រប់បទល្មើស។ រីឯក្រមនីតិវិធីព្រហ្មទណ្ឌដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៧ ហើយកំពុងតែមានអានុភាពជាធរមានសព្វថ្ងៃនេះ បាននាំមកនូវប្រព័ន្ធនៃការចោទប្រកាន់តាមរយៈគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់វិញ ដែលជាប្រព័ន្ធមួយដែលមានភាពបទបែន និងទន់ភ្លន់ ដោយផ្តល់សិទ្ធិឲ្យស្ថាប័នអយ្យការអាចចោទប្រកាន់ក៏បាន មិនចោទក៏បាន ឬជ្រើសរើសជាជម្រើសអនុវត្តតាមនីតិវិធីផ្សេងពីនេះក៏បានក្នុងករណីដែលមានបទល្មើសព្រហ្មទណ្ឌកើតឡើង។ ហើយក្នុងនេះដែរ នាងខ្ញុំនឹងធ្វើការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទគឺ "**កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ**" ឲ្យកាន់តែស៊ីជម្រៅជាងនេះ។ បុព្វហេតុដែលនាំឲ្យនាងខ្ញុំ ជ្រើសរើសនូវប្រធានបទនេះមកធ្វើការសិក្សា គឺដើម្បីទទួលបាននូវចំណេះដឹង ស្វែងយល់បទពិសោធន៍ល្អៗព្រមទាំងនីតិវិធីក្នុងការអនុវត្តចំពោះជម្រើសនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញានៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលយោងតាមហេតុផលនេះហើយ ទើបនាងខ្ញុំសម្រេចជ្រើសរើសប្រធានបទនេះឡើង។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថានៅក្នុងរឿងក្តីព្រហ្មទណ្ឌព្រះរាជអាជ្ញា បានដើរតួនាទីយ៉ាងសំខាន់បំផុតក្នុងការការពារផលប្រយោជន៍សាធារណៈ។ បើយើងនិយាយពីការធ្វើបណ្តឹងអាជ្ញា ឬការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌ គឺជាតួនាទីតែមួយគត់របស់តំណាងអយ្យការ ដូច្នេះយើងគួរតែសិក្សាស្វែងយល់ថា៖

- តើមានមូលហេតុអ្វីខ្លះដែលតំណាងអយ្យការមិនអាចធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការនៅក្នុងរឿងក្តីព្រហ្មទណ្ឌ?
- តើព្រះរាជអាជ្ញាមានតួនាទីអ្វីខ្លះក្នុងដឹកនាំការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ឬមិនជាក់ស្តែង (អង្កេតបឋម)?

- តើការអនុវត្តគោលការណ៍ទាំងនេះ ធានាថាអង្គការអយ្យការអាចអនុវត្តបណ្តឹងអាជ្ញារបស់ខ្លួនប្រកបដោយតម្លាភាព យុត្តិធម៌ និងប្រសិទ្ធភាពដែរឬទេ?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

រាល់ការសិក្សាស្រាវជ្រាវនីមួយៗ គឺតែងតែមានគោលបំណងជាក់លាក់សម្រាប់មកធ្វើការអនុវត្តជាក់ស្តែងយ៉ាងណាមិញ នាងខ្ញុំក៏មានគោលបំណងនៃការសិក្សា គឺដើម្បីជាការពង្រីកនូវចំណេះដឹង និងផ្សារភ្ជាប់ជាមួយការអនុវត្តជាក់ស្តែងព្រមទាំងចូលរួមចំណែក កែលម្អទៅលើចំណុចខ្វះខាត ដើម្បីសម្រេចបាននូវប្រសិទ្ធភាព និងប្រកបដោយសក្តានុពល។

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវដែលទាក់ទងទៅនឹងប្រធានបទ "**កាលានុវត្តភាពនៃការចោទប្រកាន់របស់អយ្យការ**" មាននូវចំណុចដូចខាងក្រោម៖

- ស្វែងយល់ពីដំណើរការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌក្នុងដំណាក់កាលអយ្យការ
- ស្វែងយល់ពីដំណើរការជម្រើសចោទប្រកាន់របស់តំណាងអយ្យការដូចជា៖
  - ការបើកការស៊ើបសួរ
  - នីតិវិធីបង្ហាញខ្លួនភ្លាម
  - ការបញ្ជូនទៅជំនុំជម្រះផ្ទាល់
- លក្ខខណ្ឌនៃការតម្កល់រឿងទុកឥតចាត់ការ
- បញ្ហាប្រឈមនៅក្នុងការអនុវត្តជាក់ស្តែង។

## ៤. ផលប្រយោជន៍នៃការសិក្សាស្រាវជ្រាវ

ចំពោះផលប្រយោជន៍នៃការស្រាវជ្រាវនេះ នាងខ្ញុំនឹងធ្វើការផ្តោតសំខាន់ទៅលើអត្ថប្រយោជន៍ទទួលបាន បី ផ្នែកសំខាន់ៗដូចជា៖

- ចំពោះនាងខ្ញុំ
  - ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
  - ពង្រឹងនូវចំណេះដឹងរបស់ខ្លួនឯងដើម្បីឲ្យកាន់តែល្អប្រសើរ
  - យល់ដឹងអំពីនីតិវិធីក្នុងការអនុវត្ត
  - យល់ដឹងឲ្យកាន់តែច្បាស់ពីតួនាទីរបស់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ
  - អាចទទួលបានបទពិសោធន៍ក្នុងការបំពេញការងារក្នុងពេលអនាគត
- ចំពោះស្ថាប័នអយ្យការ

អាចចូលរួមក្នុងការផ្តល់អនុសាសន៍សម្រាប់ស្ថាប័នអយ្យការ ដែលជាសារមួយសម្រាប់កែលម្អនូវរាល់ចំណុចអវិជ្ជមាន និងបញ្ហាដែលអាចកើតមានឡើង ដើម្បីឲ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពជាងមុន។

- ចំពោះអ្នកសិក្សាស្រាវជ្រាវ
  - ជាប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវបន្ថែម
  - បង្កើតនូវគំនិតអ្វីដែលថ្មី

## ៥. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយសារតែតុលាការមាននៅគ្រប់បណ្តាខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ហើយនាងខ្ញុំមិនអាចធ្វើការសិក្សាស្រាវជ្រាវនៅគ្រប់តុលាការ (សាលាដំបូង) នៃបណ្តាខេត្តទាំងអស់បានឡើយ។ ដូចនេះនាងខ្ញុំក៏បានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវចំពោះប្រធានបទស្តីពី "**កាលានុវត្តភាពនៃការចោទប្រកាន់របស់តំណាងអយ្យការនៅអយ្យការអមសាលាឧទ្ធរណ៍**"។ ហើយការសិក្សាស្រាវជ្រាវនេះដែរ គឺផ្តោតតែទៅលើជម្រើសនៃការចោទប្រកាន់ដែលកើតមានក្នុងដែនសមត្ថកិច្ចនៃអយ្យការអមសាលាឧទ្ធរណ៍។ មួយវិញទៀត នាងខ្ញុំសិក្សាស្រាវជ្រាវផ្អែកទៅលើច្បាប់ដែលមានចែងជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងការអនុវត្តជាក់ស្តែងនៅ អយ្យការអមសាលាឧទ្ធរណ៍។

## ៦. ផែនការ និង រចនាបទនៃការសិក្សាស្រាវជ្រាវ

### .គ្រោងខ័ណ្ឌនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើស្ថាប័នអយ្យការ ដោយផ្តោតជាពិសេសទៅលើតួនាទីរបស់អយ្យការក្នុងការចោទប្រកាន់ទៅលើបទល្មើសព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍។

- ដំណាក់កាលទី ១ ៖ ការសិក្សាស្រាវជ្រាវរៀបចំបង្កើតគម្រោងផែនការស្រាវជ្រាវ កំណត់គោលដៅកម្មវត្ថុ ទំហំ និង ដែនកំណត់នៃការសិក្សាស្រាវជ្រាវ ។ ការសិក្សាស្រាវជ្រាវទៅលើទ្រឹស្តីដែលពាក់ព័ន្ធដើម្បីរកគន្លឹះឆ្ពោះទៅរកដំណោះស្រាយ ។

- ដំណាក់កាលទី ២ ៖ ចុះហាត់ការ នៅសាលាឧទ្ធរណ៍ដើម្បីធ្វើការប្រមូលទិន្នន័យនានាដើម្បីបំពេញបន្ថែមទៅលើការសិក្សាស្រាវជ្រាវ ។
- ដំណាក់កាលទី ៣ ៖ ធ្វើការរៀបចំ និង វាយតម្លៃទៅលើទិន្នន័យដែលទទួលបានពីការចុះហាត់ការ នៅសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

**១.ការប្រមូលទិន្នន័យ**

ដើម្បីឲ្យដំណើរការនៃការសិក្សាស្រាវជ្រាវប្រកបដោយភាពជោគជ័យ គឺត្រូវកំណត់ទិន្នន័យចំនួន ២ (ពីរ) គឺ៖

- ទិន្នន័យចម្បង
- ទិន្នន័យបន្ទាប់បន្សំ ។

**២ .ទិន្នន័យចម្បង**

រាល់ព័ត៌មានទាំងឡាយណាបានមកពីការចុះហាត់រៀន ឬការសាកសួរពីព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងដោយផ្ទាល់ដែលបម្រើការងារនៅសាលាឧទ្ធរណ៍។

**៣. ទិន្នន័យបន្ទាប់បន្សំ**

ទិន្នន័យនេះ គឺជាទិន្នន័យដែលបានមកពី៖

- ឯកសារដែលបានបន្សល់ទុកជាយូរនៅសាលាឧទ្ធរណ៍ ។
- សារណាបញ្ចប់របស់និស្សិតគ្រប់ជំនាន់ ។
- សៀវភៅដែលពាក់ព័ន្ធមាននៅក្នុងបណ្ណាល័យនានា ។
- តាមរយៈប្រព័ន្ធអ៊ីនធើណែត )Internet) ។
- សៀវភៅរបស់សាស្ត្រាចារ្យមួយចំនួន ។

**៤. វិធីសាស្ត្រនៃការវិភាគទិន្នន័យ**

បើនិយាយពីវិធីសាស្ត្រនៃការវិភាគទិន្នន័យ គឺបែងចែកជា ២ (ពីរ) គឺវិភាគទិន្នន័យតាមបរិមាណ និងវិភាគទិន្នន័យបែបគុណភាព។ ការវិភាគតាមបែបបរិមាណ គឺជាការវិភាគមួយប្រភេទដែលមានប្រើនូវទិន្នន័យជាតួលេខច្បាស់លាស់។ រីឯតាមបែបគុណភាពវិញ ជាវិធីមួយដែលធ្វើការវិភាគទិន្នន័យដែលមាន ឬ ទិន្នន័យ

ដែលទទួលបានពីការចុះកម្មសិក្សា ឬបានពីការសាកសួរដោយប្រើកម្រងសំណួរដើម្បីចេញជាលទ្ធផលណាមួយ ។

សម្រាប់ការវិភាគទិន្នន័យ គឺនាងខ្ញុំធ្វើការវិភាគដោយប្រមូលទិន្នន័យតាមវិធីសាស្ត្រាចារ្យ ថៅក្រម ព្រះរាជអាជ្ញារង ក្រឡាបញ្ជី ខាងលើ រួចធ្វើការវិភាគឲ្យចេញនូវលទ្ធផល និង ចក្ខុវិស័យ។ ជាដំបូងប្រមូលទិន្នន័យឲ្យបានគ្រប់គ្រាន់ បន្ទាប់មកពេលដែលទទួលបានគ្រប់អស់ហើយ នាងខ្ញុំនឹងធ្វើការវិភាគដោយធ្វើការប្រៀបធៀបជាមួយ ៖

- អត្ថបទច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧)។
- ទ្រឹស្តីនានាដែលបានសិក្សាជាមួយសាស្ត្រាចារ្យ ដែលមានបទពិសោធន៍ជាច្រើនឆ្នាំខាងផ្នែកព្រហ្មទណ្ឌ។
- កម្មវិធីផ្សព្វផ្សាយច្បាប់ និង យុត្តិធម៌ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

ការវិភាគទិន្នន័យ ការសិក្សាស្រាវជ្រាវនាងខ្ញុំ បានធ្វើការប្រៀបធៀបជាមួយការអនុវត្តន៍ជាក់ស្តែងនៅក្នុងការអនុវត្តន៍ក្នុងនីតិវិធីថា តើការអនុវត្តន៍និងទ្រឹស្តីមានលក្ខណៈយ៉ាងដូចម្តេច(ដូចគ្នា ឬខុសគ្នា) ។

# ជំពូកទី ១
# និយមន័យ និងប្រវត្តិអយ្យការ

ផ្នែកទី១: អយ្យការ

**១.និយមន័យ៖ របស់អយ្យការ**

អយ្យការគឺជាអ្វី? ដែលហៅថាអយ្យការ គឺជាស្ថាប័នមួយរបស់រដ្ឋសម្រាប់ដំណើរការបណ្តឹងសាធារណៈ ឬបណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ ដើម្បីឲ្យមានសកម្មភាពងាយស្រួលក្នុងការស្វែងរកយុត្តិធម៌ជូនសង្គមជាតិ។

ហើយនៅក្នុងអង្គការមួយនេះមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងជាច្រើនបំពេញការងារនៅក្នុងស្ថាប័នមួយនេះ។ តាមន័យសាមញ្ញ ពាក្យថាព្រះរាជអាជ្ញា គឺសំដៅឲ្យបុគ្គលមួយដែលតំណាងឲ្យព្រះមហាក្សត្រព្រោះនៅសម័យមុនៗ គឺនៅបណ្តាប្រទេសទាំងអស់លើពិភពលោកគេច្រើនប្រកាន់យករបបរាជាធិបតេយ្យផ្តាច់ការ ដោយឲ្យព្រះមហាក្សត្រមានអំណាចអធិបតេយ្យភាព ដោយកាន់កាប់អំណាចទាំង៣ គឺអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ព្រោះថានៅសម័យនោះ គឺប្រជាពលរដ្ឋយល់ឃើញថាព្រះមហាក្សត្រជាអាទិទេពដែលព្រះប្រទានមកដើម្បីគ្រប់គ្រងប្រទេសរបស់ខ្លួន ឲ្យមានសុខសន្តិភាព និងភាពសម្បូរសប្បាយសម្រាប់ប្រទេសរបស់ខ្លួន។ ប៉ុន្តែដោយសារពេលវេលាដើរទៅមុន ការស្រាវជ្រាវកាន់តែមានភាពរីកចម្រើន ហើយការយល់ដឹងរបស់មនុស្សកាន់តែជ្រៅជ្រះទៅៗ ទើបនៅសម័យក្រោយៗមកទៀត នៅបណ្តាប្រទេសមួយចំនួន គឺគេលែងប្រគល់អំណាចឲ្យព្រះមហាក្សត្រហើយ ដោយប្រគល់អំណាចទាំងនោះទៅឲ្យប្រជារាស្ត្រគ្រប់គ្រងវិញម្តង។

ក្នុងប្រទេសមួយចំនួនគេគិតថា ព្រះរាជអាជ្ញាជាអ្នកចាត់ការបណ្តឹងអាជ្ញាក្នុងនាមសង្គម និងដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋទាំងមូល ដែលជាម្ចាស់អំណាច អធិបតេយ្យ និងអាចនិយាយបានម្យ៉ាងទៀតថា ព្រះរាជអាជ្ញាធ្វើបណ្តឹងអាជ្ញាក្នុងសង្គមទាំងមូល គឺមិនមែនតំណាងឲ្យបុគ្គលម្នាក់នោះទេ។

ប៉ុន្តែមានប្រទេសខ្លះគិតថាព្រះរាជអាជ្ញាតំណាងឲ្យនីតិប្រតិបត្តិ ឬក៏ជាមេធាវីរបស់រាជរដ្ឋាភិបាល ព្រោះថាប្រទេសខ្លះបានដាក់ឲ្យអង្គការអយ្យការ គឺស្ថិតនៅក្រោមការគ្រប់គ្រងក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌ស្ថិតនៅ ក្រោមស្ថាប័នមួយតំណាងឲ្យអង្គការនីតិប្រតិបត្តិ ដូចនេះគេយល់ឃើញថាអំណាចនីតិប្រតិបត្តិ គឺជាអ្នកគ្រប់គ្រងលើអង្គការអយ្យការ។ ប៉ុន្តែនៅមានប្រទេសខ្លះទោះបីដាក់អយ្យការឲ្យស្ថិតនៅក្រោមអង្គការនីតិប្រតិបត្តិក៏ដោយ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងធ្វើខុស គឺមិនមែនស្ថាប័ននីតិប្រតិបត្តិជាអ្នកដាក់ទោសនោះទេ គឺការដាក់ទោសចំពោះព្រះរាជអាជ្ញា និងព្រះរាជអាជ្ញរង គឺស្ថិតនៅក្រោមតុលាការកំពូល ឬព្រះមហាក្សត្រ ទៅតាមប្រទេសនីមួយៗ។ តួយ៉ាងដូចនៅក្នុងប្រទេសកម្ពុជាជាដើម ប្រសិនបើព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងធ្វើខុស គឺដាក់ទោសដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺព្រះមហាក្សត្រ។ ដូចនេះទោះបីជាអង្គការអយ្យការស្ថិតនៅក្រោមក្រសួងយុត្តិធម៌ ដែលជាអំណា

ចនីតិប្រតិបត្តិក៏ដោយ តែព្រះរាជអាជ្ញានៅតែបំពេញតួនាទីក្នុងនាមតំណាងឲ្យព្រះមហាក្សត្រដដែល។

នៅក្នុងប្រទេសមួយចំនួនគឺគេមិនហៅព្រះរាជអាជ្ញា ថាជាព្រះរាជអាជ្ញានោះទេ គឺគេហៅថារដ្ឋអាជ្ញា ហើយប្រទេសខ្លះទៀតហៅថាព្រះរាជអាជ្ញា ។ សម្រាប់ប្រទេសដែលគ្រប់គ្រងតាមបែបសង្គមនិយម គឺគេហៅថាព្រះរាជអាជ្ញាជា "រដ្ឋអាជ្ញា" គឺមានន័យថា រដ្ឋអាជ្ញាតំណាងឲ្យរដ្ឋរបស់ពួកគេទាំងមូលតែម្តង ព្រោះថាប្រទេសរបស់គេគ្រប់គ្រងដោយ ប្រធានាធិបតី គឺមិនមែនគ្រប់គ្រងដោយព្រះមហាក្សត្រនោះទេ។ ចំណែកប្រទេសដែលគ្រប់គ្រងតាមបែបរាជានិយម គឺគេហៅថា "ព្រះមហាក្សត្រ" គឺមានន័យថាជាអ្នកតំណាងឲ្យ ព្រះមហាក្សត្រសម្រាប់ស្វែងរកយុត្តិធម៌ជូនសង្គមហើយប្រទេស គឺមានព្រះមហាក្សត្រជាអ្នកគ្រប់គ្រង។

ព្រះរាជអាជ្ញាជារូបវន្តបុគ្គល មិនមែនជានីតិបុគ្គលនោះទេ។ ព្រះរាជអាជ្ញាជាចៅក្រមវិជ្ជាជីវៈដែលមានភារកិច្ចបំពេញមុខងារជាចៅក្រមខាងចៅក្រមអយ្យការ។ តាមគោលការណ៍ព្រះរាជអាជ្ញាជាមន្ត្រីសាធារណៈដែលមានសិទ្ធិអំណាចធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ដើម្បីការពារច្បាប់ការពារប្រយោជន៍សាធារណៈ និងប្រយោជន៍សង្គម។ អង្គការអយ្យការជាយន្តការជាតិមួយសម្រាប់ជួយស្ថាប័នតុលាការ ក្នុងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ ដើម្បីធានាឲ្យបាននូវអត្ថប្រយោជន៍ជាតិជាទូទៅរបស់សង្គមតាមរយៈ ការអនុវត្តបណ្តឹងអាជ្ញាចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ធ្វើសេចក្តីសន្និដ្ឋានវាយតម្លៃបទល្មើស ដោយទាមទារឲ្យតុលាការពិនិត្យបទល្មើស រកឲ្យឃើញពិរុទ្ធភាពនៃបទល្មើស និងផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់។

ជាមួយគ្នានេះផងដែរ អង្គការអយ្យការក៏មានតួនាទីសំខាន់មួយទៀត គឺការធានានូវការអនុវត្តនូវគ្រប់សេចក្តីសម្រេចខាងបទល្មើសព្រហ្មទណ្ឌរបស់តុលាការ ជម្រុញការផ្សព្វផ្សាយ និងអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់តុលាការ ដើម្បីធានាបានថាគ្រប់បុគ្គលត្រូវបានចាប់ខ្លួន ត្រូវបាននាំទៅកាន់តុលាការដើម្បីផ្តន្ទាទោសតាមច្បាប់។ ក្នុងករណីដែលអង្គការអយ្យការមានការលំបាកក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនក្នុងកាលៈទេសៈណាមួយនោះ អង្គការនេះមានសិទ្ធិកេណ្ឌកម្លាំងសាធារណៈ ដោយផ្ទាល់ជាជំនួយ

ដើម្បីធានានូវប្រសិទ្ធិភាពក្នុងការអនុវត្តភារកិច្ចរបស់ខ្លួនឲ្យបានជោគជ័យតាមបញ្ញត្តិច្បាប់ ។ ហើយការអនុវត្តភារកិច្ចរបស់ខ្លួនអង្គការអយ្យការ គឺការអនុវត្តភារកិច្ចតាមឋានានុក្រមរបស់ខ្លួនពីខ្ពស់ទៅទាបតាមគោលការណ៍គតិយុត្តិ។

១.១.ប្រ**វត្តិស្ថាប័នអយ្យការ**[1]

អង្គការអយ្យការ ត្រូវបានបង្កើតឡើងលើកដំបូងបង្អស់នៅឆ្នាំ ១៩៣៧ នៅសម័យអាណានិគមនិយមបារាំង ដោយការបញ្ចូលតំណែងនេះទៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌ (ភាសាសម័យនេះគេហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ តែនៅមុនឆ្នាំ១៩៣៧ គេហៅថាលក្ខណៈពិភាក្សាព្រហ្មទណ្ឌ)។ យោងតាមក្រមនេះ នៅអមសាលាដំបូងនីមួយៗមានព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ហើយនៅសាលាជាន់ខ្ពស់មាន (ព្រះរាជបម្រើ) និង (ភូឈួយព្រះរាជបម្រើ)។ មន្ត្រីអយ្យការនៅអមសាលាដំបូងមានឈ្មោះថា ព្រះរាជអាជ្ញា ចំណែកនៅសាលាឧទ្ធរណ៍មន្ត្រីនេះមានឈ្មោះថា **ព្រះរាជបម្រើ** ហើយនៅសាលាវិនិច្ឆ័យចីតិស្រមមូល និងតុលាការកំពូលយើងសព្វថ្ងៃវិញពុំមានព្រះរាជអាជ្ញានៅអមទេ។ ប៉ុន្តែនៅសម័យក្រោយមកទៀត តំណែងព្រះរាជាអាជ្ញាអមសាលាវិនិច្ឆ័យត្រូវបានរកឃើញនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈ ស្តីពីយុត្តាធិការ ចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៥៥។

ចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ថ្វីបើប្រទេសកម្ពុជាប្តូររបបពីរាជានិយមទៅជាសាធារណៈរដ្ឋនិយម ប៉ុន្តែប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាពុំបានផ្លាស់ប្តូរដូចនៅក្នុងសម័យមុនៗទេ។ របបសាធារណៈរបស់សេនាប្រមុខ **លន់ នល់** បន្តនិរន្តរភាពនៃប្រព័ន្ធតុលាការរហូតដល់ពេលត្រូវបានកម្លាំងប្រដាប់អាវុធរបស់ខ្មែរក្រហមផ្តួលរំលំ និងឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ចំនួនរដ្ឋអាជ្ញានៅសម័យសាធារណៈរដ្ឋនេះដែលបន្តពីសម័យមុនមក មានចំនួន ៣៨ នាក់ ក្នុងនោះមានស្ត្រីម្នាក់ជាភរិយារបស់លោក **អ៊ឹង មីង** ដែលមាននាមដើម **យល់ ឡាម្វែល**។

ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គឺជាសម័យមួយដែលប្រទេសខ្មែរគ្មានប្រព័ន្ធច្បាប់អាចនិយាយបានថាគ្មានប្រព័ន្ធតុលាការអ្វីទាំងអស់។ លើកលែងតែរដ្ឋធម្មនុញ្ញតែមួយគត់ដែលអនុម័តដោយសភាខ្មែរក្រហម ប្រទេសកម្ពុជាក្នុងរយៈពេលនេះគ្មានអត្ថបទច្បាប់អ្វីទាំងអស់ដើម្បីអនុវត្តន៍

[1] សៀវភៅក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ បោះពុម្ពនៅខែកុម្ភៈ ឆ្នាំ២០០៦

ថ្មីបើរបបកម្ពុជាប្រជាធិបតេយ្យមិនបានប្រកាសនិរាករណ៍ច្បាប់ពីសម័យមុនៗក៏ដោយ។ ពួកខ្មែរក្រហមបានបង្កើតរដ្ឋធម្មនុញ្ញមួយយ៉ាងចម្លែក ដែលមិនបានទទួលស្គាល់សិទ្ធិ និងសេរីភាពរបស់បុគ្គលអ្វីទាំងអស់។

ចំពោះប្រព័ន្ធតុលាការវិញរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យបានបង្កើតប្រព័ន្ធតុលាការមួយដែលមានឈ្មោះថា (**តុលាការប្រជាជន**)។ គ្មាននរណាម្នាក់យល់ពីសញ្ញាណនៃតុលាការប្រជាជនក្រៅពីអ្នកតាក់តែងរដ្ឋធម្មនុញ្ញនោះទេ ។ ពាក្យ "**តុលាការប្រជាជន**" នេះត្រូវបានប្រើដោយកម្មាភិបាល ឬប្រជាពលរដ្ឋស្លូលខ្មែរក្រហម ដែលអាចប្រដូចទៅនឹងប្រព័ន្ធយុត្តិធម៌មួយដែលធ្វើអ្វីទៅតាមទំនើងចិត្ត និងអមនុស្សធម៌។ សរុបមកប្រព័ន្ធចោទប្រកាន់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺស្ថិតនៅលើបុគ្គលម្នាក់ៗជាកម្មាភិបាល (ជាមន្ត្រីរបស់របបនេះ) ជាអ្នកសម្រេចដោយផ្អែកលើការសង្ស័យតែម្យ៉ាង។ អ្នកចោទប្រកាន់ក៏ជាអ្នកកាត់សេចក្តីផងដែរ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ វាជារយៈពេលមួយដែលកម្ពុជាបានផ្លលរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏ជារយៈពេលមួយដែលប្រទេសកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសវៀតណាម។ អង្គការអយ្យការត្រូវបានបង្កើតឡើងក្នុងរយៈពេល ៣ឆ្នាំ ក្រោយពេលដែលកងទ័ពវៀតណាមចូលកាន់កាប់ប្រទេសកម្ពុជា។

ដូចបានបញ្ជាក់ខាងលើប្រទេសកម្ពុជាបានបាត់បង់ស្ថាប័នច្បាប់របស់ខ្លួនក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ ធនធានមនុស្សក៏រលាយស្ទើរទាំងអស់ក្នុងរបបនេះ។ ក្នុងចំណោមរដ្ឋអាជ្ញាចំនួន ៣៨ នាក់ក្នុងសម័យសាធារណរដ្ឋខ្មែរ ប្រហែលជា ៣នាក់ប៉ុណ្ណោះដែលនៅសល់ជីវិតនៅក្រោយពីការរលំ នៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសាររដ្ឋអាជ្ញាមានចំនួនតិចតួចនៅឡើយ ទើបនៅសម័យនោះនាំឲ្យមានការបង្កើតនូវរដ្ឋអាជ្ញា និងរដ្ឋអាជ្ញារងដើម្បីធ្វើការហ្វឹកហាត់ ឲ្យមកបំពេញការងារនៅតាមតុលាការខេត្ត-ក្រុង។ គណៈកម្មាធិការប្រជាជនបដិវត្ត ខេត្ត-ក្រុងជាអ្នកជ្រើសរើសរដ្ឋ អាជ្ញាអមតុលាការខេត្តក្រុង រួចស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្រោយពីការយល់ព្រមពីរដ្ឋមន្ត្រីហើយរដ្ឋអាជ្ញានោះ នឹងត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋ ចំណែករដ្ឋអាជ្ញាវិញ ការតាក់តែងមានបែបបទខ្លីជាងរដ្ឋអាជ្ញា។ គណៈកម្មាធិការប្រជាជនខេត្ត-ក្រុងជាអ្នកជ្រើសរើសរួច ហើយស្នើសុំការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លុះបានការយល់ព្រមហើយ រដ្ឋអាជ្ញារងនោះត្រូវបានតែងតាំង ដោយគណៈកម្មការនោះតែម្តង។ បន្ទាប់ពីការតែងតាំងមក

រដ្ឋអាជ្ញា និងរដ្ឋអាជ្ញារងត្រូវបានបញ្ជូលមកហ្វឹកហ្វឺន ពីរវគ្គនៅសាលាកម្មាភិបាលរដ្ឋបាល និងនីតិសាស្ត្រ។ វគ្គហ្វឹកហ្វឺននេះ ត្រូវចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៨៥វគ្គទីមួយមានរយៈពេល ៣ ខែបង្រៀនដោយសាស្ត្រចារ្យវៀតណាម និងអាល្លឺម៉ង់ និងសាស្ត្រាចារ្យខ្មែរខ្លះ ដូចជាលោក **វ៉ាន់ឌីការយុន** លោក **អ៊ុង ផន** លោក **អ៊ុក សារី** លោក **ឈូរ លាងហួក** និងលោក **លឿង ឆៃ** ដែលពេលនោះជានាយកសាលានេះជាដើម។ វគ្គទីមួយរៀបចំឡើងសម្រាប់រដ្ឋអាជ្ញា និងប្រធានតុលាការ ។ ចំណែកទី ២ ប្រមូលផ្តុំ ប្រធានតុលាការ រដ្ឋអាជ្ញា ចៅក្រម ក្រឡាបញ្ជី ប្រធានកម្មាធិការប្រជាជនបដិវត្ត ខេត្ត-ក្រុង ប្រធាននគរបាល និងប្រធានមន្ទីរក្រសួង នៅភ្នំពេញក្នុងវគ្គសិក្សារួមគ្នាដែលមានរយៈពេល ៦ (ប្រាំមួយ) ខែ។ មុខវិជ្ជាមានដូចនៅក្នុងវគ្គទីមួយដែរ ប៉ុន្តែផ្តោតលើវិជ្ជាច្បាប់ និងលើការអនុវត្តជាច្រើន។

ចាប់ពីឆ្នាំ ១៩៩៣ ដល់ពេលបច្ចុប្បន្ន តុលាការខ្មែរត្រូវបានរៀបចំ និងកែប្រែទៅតាមគំរូថ្មី ដោយមានការបង្កើតចៅក្រមស៊ើបអង្កេត និងការលុបចោលនូវទីប្រឹក្សាប្រជាជន ការបង្កើតសាលាឧទ្ធរណ៍ ការអនុម័តច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ការអនុម័តដោយអាជ្ញាធរ អន្តរកាលនៃអង្គការសហប្រជាជាតិ ការបង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងការបង្កើតក្រុមប្រឹក្សាធម្មនុញ្ញជាដើម។ អយ្យការដែលបានបម្រើនៅក្នុងសម័យរដ្ឋកម្ពុជា បានបន្តមុខងាររបស់ខ្លួនតទៅទៀត ហើយវគ្គបណ្តុះបណ្តាលអយ្យការក៏ចាប់ផ្តើមតាំងពីឆ្នាំ ១៩៩៤ មកម្ល៉េះ។ វគ្គបណ្តុះបណ្តាលលើកទីមួយត្រូវបានរៀបចំឡើងនៅឆ្នាំ ១៩៩៤ ដោយក្រសួងយុត្តិធម៌ក្រោមការដឹកនាំនៃរដ្ឋមន្ត្រី **ចែម ស្គួន**។ ក្នុងវគ្គទីមួយនេះមានសិស្សចំនួន ៨១ នាក់ ក្នុងនោះមានទាំងចៅក្រម និងអយ្យការជ្រើសរើសចេញពីការប្រឡងវិញ្ញាសាសរសេរ និងផ្ទាល់មាត់។ ការសិក្សាមានរយៈពេល ១៩ខែ រួចឆ្លងកាត់ការធ្វើកម្មសិក្សាចំនួន ៦ខែ តាមតុលាការកំពូល តុលាការខេត្តក្រុង និងស្ថាប័នរដ្ឋមួយចំនួនដូចជា រដ្ឋសភា ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម ក្រសួងហិរញ្ញវត្ថុ ធនាគារជាតិ ។ល។ មុខវិជ្ជាដែលរៀនមានច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់រដ្ឋបាល ច្បាប់ពាណិជ្ជកម្ម ច្បាប់ភូមិបាលច្បាប់សិទ្ធិមនុស្សច្បាប់អន្តរជាតិនិងការចូលរួមក្នុងសិក្ខាសាលាផ្សេងៗ។

នៅពេលជាប់វគ្គសិក្សានេះហើយកម្មសិក្សាការីត្រូវប្រលងចេញម្តងទៀត ដោយធ្វើវិញ្ញា សាសរសេរ និងផ្ទាល់មាត់។

តមកការចាត់តាំងនៅបំពេញមុខងារតាមតុលាការត្រូវធ្វើទៅតាមចំណាត់ថ្នាក់នៅពេលរៀន។ អ្នកដែលរៀនបានលេខ ១ ដល់លេខ ១៥ អាចជ្រើសរើសយកសាលាឧទ្ធរណ៍ និងតុលាការភ្នំពេញបាន ចំណែកអ្នកដែលបានលេខចាប់ពីបានលេខ ១៦ ឡើងទៅ

អាចជ្រើសរើសតាមលេខរៀងនៅតុលាការដែលខ្លួនចង់បាន។ អ្នកបន្តមិនអាចរើសយកតុលាការណាដែលត្រូវបានជ្រើសរើសហើយនោះទេ គឺត្រូវចាប់យកតុលាការ ដែលអ្នកមុនមិនទាន់បានជ្រើសរើស។ សម្រាប់តុលាការនីមួយៗ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអ្នកចង្អុលប្រាប់ថាអ្នកណាដែលត្រូវធ្វើជាចៅក្រម ឬអ្នកណាដែលត្រូវធ្វើព្រះរាជអាជ្ញា អាស្រ័យលើតុលាការនេះមានចៅក្រមគ្រប់ ឬព្រះរាជអាជ្ញាគ្រប់ ឬមិនទាន់គ្រប់។ នៅក្នុងឆ្នាំ ២០០២ សាលាភូមិន្ទចៅក្រមត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ០៥ កុម្ភៈ ឆ្នាំ ២០០២។ យោងតាមអនុក្រឹត្យនេះមានមនុស្សបីប្រភេទអាចចូលរៀននៅក្នុងសាលានេះតាមរយៈការ ប្រលង និងការចាត់តាំង។ បេក្ខជនដែលត្រូវប្រឡងចូលរួមមាន៖

- បេក្ខជនដែលមានសញ្ញាបត្រច្បាប់ និង មានអាយុមិនលើសពី ៣០ ឆ្នាំ។ បើបេក្ខជនមានសញ្ញាបត្រជាន់ខ្ពស់ជាងបរិញ្ញាប័ត្រ អាយុអាចបន្ធូរបន្ថយរហូតដល់ទៅ ៣៥ ឆ្នាំ។
- បេក្ខជនជាមន្ត្រីរាជការដែលមានបរិញ្ញាប័ត្រ និងអាយុមិនលើសពី ៣៨ ឆ្នាំ។ បើបេក្ខជននោះមានបទពិសោធន៍ការងារក្នុងរាជការ ចាប់ពី ៥ឆ្នាំឡើងទៅគេបន្ថែមពិន្ទុឲ្យ ១០ ភាគរយលើពិន្ទុដែលធ្វើបាន។
- ជាងនេះទៀត រដ្ឋាភិបាលមានសិទ្ធិចាត់តាំងឲ្យរាជការ ៥នាក់ទៀតដែលមានបរិញ្ញាប័ត្រច្បាប់ឲ្យចូលរៀនដោយមិនចាំបាច់ប្រលង ។ ប៉ុន្តែក្រោមមកសាលាភូមិន្ទចៅក្រមត្រូវបានរដ្ឋាភិបាលដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ហើយក្រោយមកបន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្តអាណត្តិទី៥ ឆ្នាំ២០១៣ រដ្ឋាភិបាលកម្ពុជាបានដាក់ឲ្យ សាលាភូមិន្ទចៅក្រមនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌វិញតាមរយៈអនុក្រឹត្យ នស/រកត/០១-០៥-០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥ ។

## ១.២.ការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ និងផ្តាច់ពីមុខងារព្រះរាជអាជ្ញា

ការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌនិងការលាឈប់គឺចង់សំដៅដល់ការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ តាមការស្នើសុំរបស់សាមីខ្លួន ឬការស្នើដោយស្ថាប័នរបស់សាមីខ្លួន ដោយមានការយល់ព្រមពីសាមីខ្លួន ក្នុងករណីដែលព្រះរាជអាជ្ញាមានមុខងារមួយផ្សេងទៀត។

យោងតាមគោលការណ៍គតិយុត្តបានកំណត់ថា៖ [2] ព្រះរាជអាជ្ញាអាចត្រូវបានអនុញ្ញាតឲ្យផ្អាច់ពីមុខងារ ឬឲ្យដាក់នៅក្រៅក្របខ័ណ្ឌព្រះរាជអាជ្ញាបាន តាមការស្នើសុំរបស់ខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។ ការអនុញ្ញាតឲ្យផ្អាច់ពីមុខងារនេះត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬរបស់ស្ថាប័នផ្សេងដោយមានការយល់ព្រមរបស់សាមីខ្លួន។

ក្នុងករណីចាំបាច់ដែលត្រូវទៅបំពេញការងារជាបណ្ដោះអាសន្ននៅក្នុងតំណែងមុខងារសាធារណៈ តំណាងរាស្ត្រ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋាភិបាល អនុរដ្ឋលេខាធិការ មុខងារទទួលអាណត្តិដោយការបោះឆ្នោតដទៃទៀត ឬតំណែងទីប្រឹក្សាគ្រប់ឋានានុក្រម ព្រះរាជអាជ្ញាអាចសុំផ្អាច់ពីមុខងារបាន។ ការអនុញ្ញាតឲ្យផ្អាច់ពីមុខងារនេះត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន។ ក្នុងរយៈពេលនៃការអនុញ្ញាតឲ្យផ្អាច់ពីមុខងារ ព្រះរាជអាជ្ញានោះត្រូវបានបន្តដល់ប្រាក់បៀវត្សព្រមទាំងសិទ្ធិឡើងថ្នាក់ ឬឋានន្តរសក្តិ និងសិទ្ធក្នុងការចូលនិវត្តន៍របស់ខ្លួន ប៉ុន្តែពុំមានប្រាក់បំណាច់មុខងារ និង ប្រាក់រង្វាន់ផ្សេងៗទៀតនៃមុខងាររបស់ខ្លួនទេ។

ករណីចាំបាច់ដែលត្រូវទៅបំពេញការងារបណ្ដោះអាសន្ននៅក្នុងសហគ្រាសសាធារណៈ ឬនៅតាមអង្គការអន្តរជាតិព្រះរាជអាជ្ញាអាចសុំនៅក្របខ័ណ្ឌព្យួរក្របខណ្ឌមុខងារ។ ការអនុញ្ញាតឲ្យនៅក្រៅក្របខ័ណ្ឌនេះ ត្រូវធ្វើឡើងតាមសំណើរបស់សាមីខ្លួន ឬស្ថាប័នផ្សេងដោយមានការយល់ព្រមពីសាមីខ្លួន។ ព្រះរាជអាជ្ញាដែលដាច់ឲ្យនៅក្រៅក្របខ័ណ្ឌពុំមានសិទ្ធិទទួលប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ និងប្រាក់បំណាច់ផ្សេងៗឡើយ។

យោងតាមបញ្ញត្តិនៃគោលការណ៍នេះ យើងឃើញថាការផ្អាច់ពីមុខងារ និងការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌ គឺមានលក្ខណៈខុសគ្នា គឺខុសគ្នាត្រង់ការផ្អាច់ពីមុខងារ ព្រះរាជអាជ្ញានៅតែទទួលបានប្រាក់បៀវត្សប្រចាំខែ ហើយត្រូវបានបន្តឡើងឋានៈជាបន្តបន្ទាប់ ហើយនៅពេលដែលព្រះរាជអាជ្ញាចង់ចូលមក បម្រើការងារនៅក្នុងស្ថាប័នអយ្យការវិញក៏អាចដាក់ពាក្យស្នើសុំចូលបម្រើការងារជាព្រះរាជអាជ្ញាវិញដដែល។ ចំណែកការដាក់ឲ្យក្រៅក្របខ័ណ្ឌ គឺព្រះរាជអាជ្ញាមិនទទួលបានប្រាក់បៀវត្សប្រចាំខែ និងមិនបានឡើងឋានៈក្នុងក្របខ័ណ្ឌអយ្យការនោះទេ។

[2] មាត្រា ៩០ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និង ព្រះរាជអាជ្ញា

ប៉ុន្តែមានពេលខ្លះព្រះរាជអាជ្ញាក៏អាចដាក់ពាក្យសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីសុំនៅភាពទំនេរដោយសារតែបញ្ហាអ្វីមួយដែលបានកើតឡើងហើយការនៅភាពទំនេរនេះក៏មានចែងនៅក្នុងច្បាប់ផងដែរ។ ដោយយោងតាមច្បាប់បានកំណត់ថា៖ ក្នុងករណីចាំបាច់ ដោយសារមូលហេតុផ្ទាល់ខ្លួន គ្រួសារ ឬវិសមិតភាព ព្រះរាជអាជ្ញាអាចស្នើសុំនៅទំនេរគ្មានបៀវត្សសម្រាប់រយៈពេលកំណត់ណាមួយតាមពាក្យសុំរបស់ខ្លួន។ ការអនុញ្ញាតឲ្យនៅទំនេរ គ្មានបៀវត្សអាចធ្វើឡើងសម្រាប់រយៈពេលម្តង ១ឆ្នាំ ឬ២ឆ្នាំ។ ការអនុញ្ញាតឲ្យនៅទំនេរនេះ អាចធ្វើបានតែពីរដងគត់ ហើយរយៈពេលសរុបនៃការអនុញ្ញាតនេះមិនត្រូវឲ្យលើសពី ៨ឆ្នាំឡើយ។ លក្ខខណ្ឌដែលអនុញ្ញាតឲ្យនៅទំនេរគ្មានបៀវត្សតាមការស្នើសុំរបស់សាមីខ្លួនបានលុះត្រាតែព្រះរាជអាជ្ញានោះបំពេញមុខងារក្នុងក្របខ័ណ្ឌព្រះរាជអាជ្ញាយ៉ាងតិច ៨ឆ្នាំសិនដោយមិនគិតពីព្រះរាជអាជ្ញាដែលត្រូវទទួលទណ្ឌកម្មជាវិន័យថ្នាក់ទី២ ឡើយ។ ពាក្យសុំនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយសាមីខ្លួន។ ពាក្យសុំនេះត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងចាត់ការតាមនីតិវិធី។

តាមអត្ថន័យចង់បង្ហាញថាព្រះរាជអាជ្ញាអាចសុំនៅភាពទំនេរដោយមូលហេតុត្រឹមត្រូវតាមច្បាប់បានឲ្យតែព្រះរាជអាជ្ញានោះបំពេញការងារនៅក្នុងស្ថាប័នអយ្យការរយៈពេល ៨ឆ្នាំគិតចាប់ពីពេលកម្មសិក្សា ហើយការសុំនេះមិនឲ្យលើសពី ២ដង និង៨ឆ្នាំ ឡើយ ។ ហើយការសុំនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ធ្វើការពិនិត្យ និងធ្វើការសម្រេចតាមក្រោយប្រសិនបើមើលឃើញថាការសុំនៅភាពទំនេររបស់អយ្យការមានភាពត្រឹមត្រូវស្របតាមច្បាប់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចឲ្យព្រះរាជអាជ្ញានោះនៅភាពទំនេរ បានតែមូលហេតុដែលលើកឡើងរបស់ព្រះរាជអាជ្ញានោះមិនត្រឹមត្រូវតាមច្បាប់ទេ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នោះធ្វើការច្រានចោលពាក្យសុំភាពទំនេររបស់ព្រះរាជអាជ្ញា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវតែអនុវត្តតាមនីតិវិធីច្បាប់។

ហើយចំពោះព្រះរាជអាជ្ញាដែលកំពុងស្ថិតនៅភាពទំនេរគ្មានបៀវត្សលើកទី១បើមានបំណងចង់បន្ត ឬចូលបម្រើការងារវិញត្រូវដាក់ពាក្យសុំឲ្យបាន ២ខែមុនពេលផុតកំណត់នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ។ ព្រះរាជអាជ្ញាណាដែលមិនបានដាក់ពាក្យសុំបន្តភាពទំនេរគ្មានបៀវត្ស

ឬពុំបានចូលបំពេញមុខងាររបស់ខ្លួនវិញយ៉ាងយូរ ៣០ថ្ងៃចាប់ពីផុតរយៈពេលនៃភាពទំនេរគ្មានបៀវត្សទេនោះ ត្រូវចាត់ទុកថាបានបោះបង់ការងារ និងត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌចាប់ពីថ្ងៃនោះតទៅ។

## ២. សញ្ញាណទូទៅនៃអង្គការអយ្យការ

### ២.១ រចនាសម្ព័ន្ធនៃស្ថាប័នអយ្យការ

រចនាសម្ព័ន្ធរបស់ស្ថាប័នអយ្យការ គឺចង់សំដៅដល់ឋានានុក្រមនៃស្ថាប័នអយ្យការពីខ្ពស់ទៅទាប ព្រោះនៅក្នុងស្ថាប័នអយ្យការក៏មានការបែងចែកដូចថៅក្រមដែរ។ នៅក្នុងស្ថាប័នអយ្យការក៏មានការបែងចែកស្ថាប័នជាន់ខ្ពស់ និងស្ថាប័នអយ្យការជាន់ទាប ដែលស្ថាប័នជាន់ខ្ពស់មានឋានៈខ្ពស់ជាងស្ថាប័នអយ្យការជាន់ទាប។

បានជាគេធ្វើការបែងចែកស្ថាប័នអយ្យការ ឲ្យមានច្រើនថ្នាក់បែបនេះ គឺដើម្បីឲ្យមានភាពយុត្តិធម៌នៅក្នុងសង្គមព្រោះបើស្ថាប័នអយ្យការជាន់ទាបធ្វើខុស ឬមិនគោរពតាមកាតព្វកិច្ចរបស់ខ្លួន ស្ថាប័នអយ្យការជាន់ខ្ពស់មានសិទ្ធិបញ្ជាទៅស្ថាប័នអយ្យការជាន់ទាបបាន។ ហើយការបែងចែកស្ថាប័នអយ្យការនេះ ក៏ដើម្បីងាយស្រួលក្នុងការធ្វើការព្រោះស្ថាប័នអយ្យការនីមួយៗមានតួនាទី និងភារកិច្ចផ្សេងពីគ្នាតាម អ្វីដែលកំណត់ដោយច្បាប់។ ហើយការបែងចែកស្ថាប័នអយ្យការក៏ជាហេតុធ្វើឲ្យមានការបែងចែកឋានៈ និងអំណាចផងដែរ តាមឋានៈពីខ្ពស់ទៅទាប។

### ២.២. រចនាសម្ព័ន្ធមហាអយ្យការអមតុលាការកំពូល

មហាអយ្យការអមតុលាការកំពូល គឺជាស្ថាប័នអយ្យការដែលនៅអមតុលាការកំពូលហើយធ្វើការនៅក្នុងតុលាការកំពូលនោះតែម្តង។ បើផ្អែកតាមមាត្រា ៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងមហាអយ្យការអមតុលាការកំពូល គឺគេបែងចែកឋានានុក្រមជាបីគឺៈ

- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល និង
- ព្រះរាជអាជ្ញាតុលាការកំពូល។

អគ្គព្រះរាជអាជ្ញាតុលាការកំពូល គឺជាប្រធានស្ថាប័នអយ្យការអមតុលាការកំពូល។ ហើយគាត់គឺជាអ្នកគ្រប់គ្រងលើអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលទាំងអស់។ នៅក្នុងមហាអយ្យការអមតុលាការកំពូលមានអគ្គព្រះរាជអាជ្ញាតែមួយរូបគត់ដែលជាប្រធានស្ថាប័ន។ ចំណែកឯអគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល គឺមានឋានៈទាបជាងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល តែមានឋានៈខ្ពស់ជាងព្រះរាជអាជ្ញាអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូលអាចមានមួយរូប ឬច្រើនរូបតាមសេចក្តីត្រូវការរបស់តុលាការកំពូល។

ឯព្រះរាជអាជ្ញាអមតុលាការកំពូល គឺជាអ្នកដែលមានឋានៈទាបជាងគេនៅក្នុងមហាអយ្យការអមតុលាការកំពូល។ ហើយព្រះរាជអាជ្ញាអមតុលាការកំពូលមានច្រើនរូបតាមតម្រូវការរបស់តុលាការកំពូល។

**២.៣. រចនាសម្ព័ន្ធមហាអយ្យការអមសាលាឧទ្ធរណ៍**

មហាអយ្យការអមសាលាឧទ្ធរណ៍ គឺជាស្ថាប័នដែលនៅអមសាលាឧទ្ធរណ៍ហើយធ្វើការ និងបំពេញការងារនៅក្នុងសាលាឧទ្ធរណ៍នោះតែម្តង។ ផ្អែកតាមមាត្រា ៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងសាលាឧទ្ធរណ៍មហាអយ្យការត្រូវបានបែងចែកជា ៣ ដូចនៅក្នុងតុលាការកំពូល ដែរគឺរួមមានៈ

- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

នៅក្នុងមហាអយ្យការអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាជាប្រធានស្ថាប័នអយ្យការហើយមានតែមួយរូបតែប៉ុណ្ណោះ ចំណែកឯអគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអាចមានច្រើនរូបទៅតាមតម្រូវការ។ មហាអយ្យការអមសាលាឧទ្ធរណ៍មានឋានៈទាបជាងមហាអយ្យការអមតុលាការកំពូល ហើយឋានៈខ្ពស់ជាងអយ្យការអមសាលាដំបូងខេត្តរាជធានី។ ហើយនៅពេលថ្មីៗនេះតាមប្រសាសន៍របស់រដ្ឋមន្រ្តីក្រសួងយុត្តិធម៌ ដែលបានឆ្លើយបំភ្លឺនៅសភាបានបញ្ជាក់ថារដ្ឋាភិបាលមានគម្រោងបង្កើតសាលាឧទ្ធរណ៍នៅតាមតំបន់មួយចំនួន ដែលគេហៅថា 'សាលាឧទ្ធរណ៍តាមតំបន់' នៅសាលាឧទ្ធរណ៍ដែលគ្រោងនឹងបង្កើតឡើងនោះ គឺមានរចនាសម្ព័ន្ធរបស់អយ្យការ គឺដូចគ្នាទៅនឹងសាលាឧទ្ធរណ៍ដែលមានទីតាំងដូចគ្នានៅរាជធានីភ្នំពេញដែរ។

ហើយការបង្កើតសាលាឧទ្ធរណ៍តាមតំបន់
គឺដើម្បីជួយសម្រួលដល់សាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញ
ព្រោះនៅសាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញសម្បូរសំណុំរឿងដែលប្ដឹងមកខ្លាំងណាស់
ដែលជាហេតុនាំឲ្យមានការយឺតយ៉ាវក្នុងការដោះស្រាយរឿងក្ដី
ហើយនៅពេលដែលមានការយឺតយ៉ាវនោះក៏នាំឲ្យមានការប៉ះពាល់ដល់សិទ្ធិ
និងសេរីភាពរបស់បុគ្គលផងដែរ។
ហើយម្យ៉ាងទៀតការបង្កើតសាលាឧទ្ធរណ៍តាមតំបន់ក៏ជាការងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើបណ្ដឹង កុំឲ្យត្រូវធ្វើដំណើរផ្លូវឆ្ងាយចំណាយពេលវេលាច្រើន និងចំណាយថវិកាច្រើនក្នុងពេលប្ដឹង។ ហើយនៅពេលដែលបង្កើតសាលាឧទ្ធរណ៍តាមតំបន់ហើយ បើមានការវិវាទសមត្ថកិច្ចសាលាឧទ្ធរណ៍
គឺមានតែតុលាការកំពូលទេជាអ្នកដោះស្រាយវិវាទសមត្ថកិច្ចនេះ។

### ២.៤. រចនាសម្ព័ន្ធអយ្យការអមតុលាការដំបូង រាជធានី- ខេត្តក្រុង

អយ្យការអមតុលាការខេត្ត-រាជធានី គឺជាស្ថាប័នអយ្យការ ដែលអមសាលាដំបូងរាជធានី ហើយធ្វើការនៅក្នុងសាលាដំបូងរាជធានី ខេត្តក្រុង រាជធានីនោះតែម្ដង។ ផ្អែកតាមមាត្រា ៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៅក្នុងអយ្យការអមតុលាការដំបូងត្រូវបានគេបែងចែកឋានៈជាពីរគឺ៖

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញារង។

អយ្យការអមសាលាដំបូង មានឋានៈទាបជាងគេនៅក្នុងស្ថាប័នអយ្យការ។ ហើយនៅក្នុងអយ្យការអមសាលាដំបូង មានព្រះរាជអាជ្ញាតែមួយរូបតែប៉ុណ្ណោះជាប្រធានស្ថាប័ន ហើយមានព្រះរាជអាជ្ញារងជាច្រើនរូបទៀត។
ហើយនៅពេលបច្ចុប្បន្នរដ្ឋាភិបាលកម្ពុជាកំពុងតែរៀបចំសាលាដំបូងនៅខេត្តមួយចំនួនដែលទើបនឹងបង្កើតដូចជា ខេត្តប៉ៃលិន ខេត្តកែប ខេត្តត្បូងឃ្មុំ ជាដើម។ ប៉ុន្តែខេត្តព្រះសីហនុមានតុលាការរបស់គេតាំងពីដើមរួចទៅហើយ ចំណែកតុលាការខេត្តប៉ៃលិនទើបធ្វើការជួសជុល ហើយបានដាក់ឲ្យដំណើរការនាពេលបច្ចុប្បន្នរួចទៅហើយ។ ចំណែកខេត្តកែប និងខេត្តត្បូងឃ្មុំ គឺពុំទាន់មានសាលាដំបូងនៅឡើយទេ។ ដូចនេះនៅពេលដែលមានរឿងដែលកើតឡើងនៅក្នុងទឹកដីខេត្តកែប
គឺត្រូវដោះស្រាយវិវាទនៅសាលាដំបូងខេត្តកំពត។
ហើយបើមានករណីណាមួយដែលកើតឡើងនៅក្នុងទឹកដីខេត្តត្បូងឃ្មុំ

គឺត្រូវដោះស្រាយនៅសាលាដំបូងខេត្តកំពង់ចាម។ ហើយប្រសិនបើគេបង្កើតសាលាដំបូងនៅក្នុងខេត្តទាំងពីរនាពេលអនាគត គឺរចនាសម្ព័ន្ធអមសាលាដំបូងនោះ ក៏មិនខុសពីរចនាសម្ព័ន្ធសាលាដំបូងផ្សេងៗនោះទេ។

### ២.៥. រចនាសម្ព័ន្ធអយ្យការអមតុលាការយោធា

តុលាការយោធា គឺជាតុលាការមួយដែលដោះស្រាយ ករណីបទល្មើសយោធាតែប៉ុណ្ណោះ ហើយបទល្មើសយោធាដែលត្រូវយកទៅដោះស្រាយនៅក្នុងតុលាការយោធានោះគឺៈ

- បទល្មើសបង្កឡើងដោយយោធិន
- បទល្មើសមិនគោរពវិន័យកងទ័ព
- បទល្មើសលួចសម្ភារៈយោធា ។ល។

ហើយស្ថាប័នអយ្យការអមតុលាការយោធាក៏គេបែងចែកជាពីរដែរគឺៈ

- ព្រះរាជអាជ្ញា និង
- ព្រះរាជអាជ្ញារង

នៅក្នុងអយ្យការអមតុលាការយោធាមានព្រះរាជ្ញាតែ ១ រូបប៉ុណ្ណោះជាប្រធានស្ថាប័ន ហើយមានព្រះរាជអាជ្ញារងជាច្រើនរូបទៀត តាមតម្រូវការរបស់តុលាការ។ យោងតាមអនុក្រិត្យលេខ០៥,០៦ "០៩ការបង្កើតតុលាការ យោងចុះថ្ងៃទី១២,០៨,១៩៨៩" ដកស្រងអនុក្រិត្យ០៦,ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។

## ៣. សមត្ថកិច្ច តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់អង្គការអយ្យការ

### ៣.១. សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា

សមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញាមានដូចជាៈ[3]

- ព្រះរាជអាជ្ញានៃទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត
- ព្រះរាជអាជ្ញានៃទីលំនៅរបស់ជនសង្ស័យបានប្រព្រឹត្តបទល្មើស
- ព្រះរាជអាជ្ញានៃទីកន្លែងចាប់ខ្លួនជនដែលត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។

- **តួនាទីរបស់អង្គការអយ្យការ ឬ ស្ថាប័នអយ្យការ**

ដោយផ្អែកតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាក្រកម្ពុជាត្រង់មាត្រា ១៣១ថ្មី បានផ្តល់អំណាចផ្តាច់មុខទៅឲ្យអង្គការអយ្យការសម្រាប់ធ្វើបណ្តឹងអាជ្ញា។ អង្គការអយ្យការជាម្ចាស់នៃបណ្តឹងអាជ្ញា ឬបណ្តឹងព្រហ្មទណ្ឌ បានន័យថាមានតែស្ថាប័នអយ្យការ

[3] មាត្រា ៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

នៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ទេ ដែលអាចធ្វើការបណ្តឹងអាជ្ញាទាំងឡាយឲ្យដំណើរការបាន (ជាគោលការណ៍) ។ និយាយម្យ៉ាងទៀតគឺថា ម្ចាស់នៃបណ្តឹងអាជ្ញានេះគឺមានសិទ្ធិក្នុងការប្រើប្រាស់នូវជម្រើសនៃការចោទប្រកាន់របស់ខ្លួនបាន។

ដោយយោងតាមរដ្ឋធម្មនុញ្ញនេះ ហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិនូវតួនាទីបំពេញបន្ថែមទៀតទៅឲ្យអង្គការអយ្យការ។ ក្នុងនោះមាត្រា៤ បានចែងថា **"បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅដោយអយ្យការ"** ។ អយ្យការធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។ ម្យ៉ាងទៀតមាត្រា ២៧ ក៏បានបញ្ជាកបន្ថែមពីតួនាទីរបស់អង្គការអយ្យការមួយចំនួនដូចជា ៖

- អង្គការអយ្យការ ធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឲ្យតុលាការអនុវត្តច្បាប់។
- អង្គការអយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ
- យកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួន ។

### ៣.២. តួនាទីរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាដើរតួនាទីយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ រួមទាំងអង្គការអយ្យការដែលច្បាប់អនុញ្ញាត ឬក៏ស្របតាមការអនុវត្តន៍ក្នុងស្រុក ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌពិនិត្យមើលនីត្យានុកូលភាពក្នុងការស៊ើបអង្កេតនានា ពិនិត្យមើលការអនុវត្តន៍សាលក្រម និងតួនាទីផ្សេងៗទៀតដោយតំណាងឲ្យផលប្រយោជន៍សាធារណៈ។

ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវហ្មត់ចត់ និងឲ្យបានឆាប់រហ័សស្របតាមច្បាប់ដែលបានកំណត់ ហើយត្រូវគោរព និងការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់សិទ្ធិមនុស្ស។ ដូច្នេះព្រះរាជអាជ្ញាត្រូវរួមវិភាគទាន ក្នុងការធានាដល់កិច្ចដំណើរការដល់ប្រព័ន្ធយុត្តិធម៌ឲ្យបានត្រឹមត្រូវ និងភាពរលូន[4] ។

### ៣.៣. ភារកិច្ចរបស់ព្រះរាជអាជ្ញា

[4] គោលការណ៍ណែនាំស្តីពី "តួនាទីព្រះរាជអាជ្ញា" ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៨ ចាប់ពីថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា ។

ភារកិច្ចរបស់ព្រះរាជអាជ្ញាមាន[5]៖

- ជំហរការងាររបស់ព្រះរាជអាជ្ញាត្រូវអនុវត្តដោយមិនលម្អៀង និងជៀសវាងការប្រកាន់និន្នាការនយោបាយ វប្បធម៌ ភេទ សាសនា និង ការរើសអើងដទៃទៀត ។
- ព្រះរាជអាជ្ញាការពារផលប្រយោជន៍សាធារណៈ យកចិត្តទុកដាក់ចំពោះជនសង្ស័យ និង ជនរងគ្រោះដែលមិនលម្អៀងព្រមទាំង ប្រុងប្រយ័ត្នគ្រប់ស្ថានភាព ដែលពាក់ព័ន្ធទាំងអស់ទោះបីជាស្ថានភាពនោះមានប្រយោជន៍ ឬមិនមានប្រយោជន៍ដល់សង្គ ក៏ដោយ ។
- ព្រះរាជអាជ្ញារក្សារឿងក្តីនៃការសម្ងាត់ លើកលែងតែបំពេញភារកិច្ច ឬ បើពុំដូច្នោះទេគឺជាតម្រូវការរបស់តុលាការដើម្បីបញ្ជាក់ពីភាពយុត្តិធម៌ ។
- ព្រះរាជអាជ្ញាត្រូវត្រួតពិនិត្យមើលទិដ្ឋភាពទូទៅ និងក្តីបារម្ភរបស់ជនរងគ្រោះនៅពេលដែលមានការប៉ះពាល់ ដល់ផលប្រយោជន៍របស់ពួកគេ និងបញ្ជាក់ពីសិទ្ធិដល់ជនរងគ្រោះឲ្យស្របតាមសេចក្តីប្រកាសពីគោលការណ៍យុត្តិធម៌ ជាមូលដ្ឋានរបស់ជនរងគ្រោះក្នុងរឿងព្រហ្មទណ្ឌ និងការរំលោភអំណាច។
- ព្រះរាជអាជ្ញាត្រូវផ្តល់ការ យកចិត្តដាក់លើការធ្វើបណ្តឹងអាជ្ញា ចំពោះមន្ត្រីរាជការសាធារណៈ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ ជាពិសេសអំពើពុករលួយ ការរំលោភអំណាច ការរំលោភសិទ្ធិយ៉ាងធ្ងន់ធ្ងរ ។

ការបំពេញភារកិច្ចរបស់ព្រះរាជអាជ្ញា ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ៣.៤ .សិទ្ធិអំណាចរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិ របស់ខ្លួនស្របតាមច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដែលបានចែងកំណត់ដោយថាបានផ្តល់ឲ្យ គ្រប់ព័ត៌មានទាក់ទងនឹងបណ្តឹង ព្រះរាជអាជ្ញាមានសិទ្ធិជាគោលការណ៍ ក្នុងការដឹងនិងផ្តើមធ្វើបណ្តឹងអាជ្ញា។ យ៉ាងណាមិញ ព្រះរាជអាជ្ញាបំពេញដោយខ្លួនឯង ឬបញ្ជាឲ្យបំពេញគ្រប់កិច្ចការចាំបាច់ចំពោះការស្វែងរក និងចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ។

---

[5] គោលការណ៍ណែនាំស្តីពី "តួនាទីព្រះរាជអាជ្ញា" ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៨ ចាប់ពីថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩០ នៅប្រទេសគុយបា ទីក្រុងហាវ៉ាណា ។

ស្វែងរកជនល្មើស បច្ចុប្បន្នភាពនៃការនីតិកម្មកម្ពុជា ចំពោះដំណើរការរឿងក្តីព្រហ្មទណ្ឌ បានអនុញ្ញាតឲ្យព្រះរាជអាជ្ញាមានសិទ្ធិក្នុងការតម្កល់ទុករឿងឥតចាត់ការ បើទុកទោះជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ឬអាចធ្វើការចោទប្រកាន់ជាថ្មី ដែលហៅថា "**គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**"។ ព្រះរាជអាជ្ញាក៏អាចធ្វើការចោទប្រកាន់បានផងដែរក្នុងរូបភាពនៃការចោទប្រកាន់ដែលមានលក្ខណៈវិនិច្ឆ័យជា ៣ សណ្ឋាន គឺការបើកការស៊ើបសង្កេត ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម[6] ក្នុងនោះព្រះរាជអាជ្ញាមានសិទ្ធិក្នុងការបង្វិលរូបកាយ លើកលែងទោស ត្រួតពិនិត្យការព្យួរទោស និង ការអនុវត្តទោសបានដែរ។

ផ្នែកទី២:**គោលការណ៍របស់អង្គការអយ្យការ**

**១. គោលការណ៍ឯករាជ្យ**

អង្គការអយ្យការដែលបង្កើតឡើងនៅអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ គឺមានភាពឯករាជ្យពីផ្នែកតុលាការ។ តុលាការមិនអាចបង្គាប់បញ្ជាអយ្យការបានទេ ព្រោះវាបំពានដល់គោលការណ៍បែងចែកមុខងារ និងអំណាចរបស់ស្ថាប័នបីសំខាន់ ដែលអនុវត្តតួនាទីទីទៃពីគ្នា។ មិនត្រឹមតែប៉ុណ្ណោះ នៅពេលសវនាការព្រះរាជអាជ្ញាអាចនិយាយបានដោយសេរី នៅក្នុងអង្គហេតុនៃការសាកសួរដេញដោល ដើម្បីរកភស្តុតាងដាក់បន្ទុកក្នុងការចោទប្រកាន់លើជនជាប់ចោទ ។ លើសពីនេះទៀត បើទោះជាស្ថាប័ននេះ មានឋានានុក្រមរដ្ឋបាលក៏ដោយ ក៏អំណាចអធិបញ្ជាមិនអាចរារាំងតំណាងអយ្យការមិនឲ្យនិយាយស្តីពាក់ព័ន្ធនឹងអង្គហេតុផងដែរ គឺព្រះរាជអាជ្ញាអនុវត្ត សិទ្ធិក្នុងនាមផលប្រយោជន៍សង្គម និងសាធារណៈ។

**១.១ .គោលការណ៍អវិភាគ**

គោលការណ៍អវិភាគ បានសេចក្តីថាសមាជិកនៃអង្គការអយ្យការតែមួយអាចឡើងជំនួសគ្នាបាននៅពេលសវនាការ ប្រសិនបើសមាជិកណាម្នាក់មានធុរៈ ដែលខុសពីចៅក្រមជំនុំជម្រះដែលមិនអាចជំនួសគ្នានៅពេលសវនាការ ករណីបើមានការជំនួស នឹងនាំឲ្យមានមោឃភាពនៃសេចក្តីសម្រេចនោះ ។

**១.២ គោលការណ៍ឯកភាព**

[6] មាត្រា ៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

តាមរយៈគោលការណ៍នេះ តំណាងអយ្យការអនុវត្តមុខងាររបស់ខ្លួនក្នុងនាម និងតាមបង្គាប់របស់អ្នកដែលមានឋានានុក្រមខ្ពស់ជាង ។ ឋានានុក្រមនេះត្រូវបានកំណត់ដោយមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ដែលផ្តល់ជូននូវអំណាចអធិបញ្ញា ទៅលើព្រះរាជអាជ្ញាដោយបុគ្គលមួយចំនួនមានជាអាទិ៍ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ យ៉ាងណាមិញ ព្រះរាជអាជ្ញាក៏មានអំណាច អធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅលើឋានានុក្រមថ្នាក់ក្រោមរបស់ខ្លួនបានដែរ គឺសំដៅដល់ព្រះរាជអាជ្ញារង តែសិទ្ធិអំណាចកម្រិតត្រឹមតែបញ្ជាឲ្យចោទប្រកាន់ចំពោះបទល្មើសតែប៉ុណ្ណោះ ។

### ១.៣ គោលការណ៍នៃការមិនទទួលខុសត្រូវ

ព្រះរាជអាជ្ញារងក្នុងនាមជាអ្នកតំណាងឲ្យរដ្ឋ និងធ្វើការចោទប្រកាន់ចំពោះអង្គហេតុណាមួយដែលខ្លួនយល់ថាជាបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីខ្លះអង្គហេតុដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់នោះនឹងអាចធ្វើការច្រានចោល ដោយចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលនៃការស៊ើបសួរ ឬដោយចៅក្រមជំនុំជម្រះប្រសិនបើចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះយល់ថាអង្គហេតុនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬមិនមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីកំណត់ឲ្យគ្រប់ធាតុផ្សំនៃបទល្មើសបាន។ ប្រសិនបើមានករណីនេះកើតឡើងព្រះរាជអាជ្ញាមិនអាចទទួលខុសត្រូវនូវរាល់ការខូចខាតទាំងឡាយណាដែលកើតឡើងចំពោះភាគី ជាពិសេសជនជាប់ចោទ ឬជនត្រូវចោទនៅក្នុងសំណុំរឿងចោទប្រកាន់របស់គាត់បានទេ។ ប៉ុន្តែចំពោះគោលការណ៍មិនទទួលខុសត្រូវ នៃអង្គការអយ្យការនៃការចោទប្រកាន់របស់ខ្លួននេះមិនមានន័យថា ព្រះរាជអាជ្ញាមិនអាចរួចផុតពីការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌទេ គឺរួចផុតពីការទទួលខុសត្រូវត្រឹមតែផ្នែករដ្ឋប្បវេណីតែប៉ុណ្ណោះ ហេតុនេះ ប្រសិនបើព្រះរាជអាជ្ញាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយនៅក្នុងការអនុវត្តកិច្ចចោទប្រកាន់របស់ខ្លួន នោះព្រះរាជអាជ្ញាត្រូវតែទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌដែលគាត់បានប្រព្រឹត្តជានិច្ច។

### ១.៤ .គោលការណ៍មិនអាចប្ដឹងជំទាស់

ខុសប្លែកពីចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ អង្គការអយ្យការដែលមានព្រះរាជអាជ្ញា និងអាជ្ញារងដែលជាតំណាងអយ្យការនៅអមសាលាដំបូងរាជធានីខេត្តក្រុង

មិនត្រូវបានភាគីពាក់ព័ន្ធណាមួយអាចប្តឹងជិតចិត្តបានទេ ទោះបីជាព្រះរាជអាជ្ញាមានពាក់ព័ន្ធជាសាច់ញាតិ ឬមានផលប្រយោជន៍ក្នុងបណ្តឹងក៏ដោយក៏ភាគីមិនអាចប្តឹងជិតចិត្តបានដែរ ព្រោះថាព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ក្នុងនាមអ្នកតំណាងឲ្យរដ្ឋហើយគាត់មិនតំណាងឲ្យខ្លួនឯងនោះទេ ម្យ៉ាងវិញទៀត ការចោទប្រកាន់នេះមិនមានន័យថា បុគ្គលដែជាជនត្រូវចោទ ឬជនជាប់ចោទនឹងត្រូវរងការផ្តន្ទាទោសដូចទៅនឹងការចោទប្រកាន់ ឬជនជាប់ចោទនឹងត្រូវរងការផ្តន្ទាទោសដូចទៅនឹងការចោទប្រកាន់របស់អង្គការអយ្យការឡើយ។ ហេតុដូច្នេះ ចៅក្រមអយ្យការមិនអាចចាត់ចូលជាកម្មវត្ថុនៃបណ្តឹងជិតចិត្តសម្រាប់ភាគីបណ្តឹងបានឡើយ។

## ២. ទ្រឹស្តីនៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ

ការសិក្សាទៅលើសញ្ញាណទូទៅ នៃអង្គការអយ្យការគឺជាមូលដ្ឋានដែលនាំឲ្យយើងងាយស្រួលក្នុងការស្វែងយល់ពីទ្រឹស្តីនៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ ។ តាមរយៈនេះដើម្បីរក្សាបាននូវការមិនបំពានអំណាចច្បាប់បានផ្តល់ជំហរជាគោលការណ៍ដល់ព្រះរាជអាជ្ញារងក្នុងការចោទប្រកាន់ដែលមានដូចជាគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ និងគោលកាណ៍ការលានុវត្តភាពនៃការចោទប្រកាន់ ដែលធានាបាននូវយុត្តិធម៌យ៉ាងពិតប្រាកដក្នុងដំណើរការចោទប្រកាន់របស់អង្គការអយ្យការក្នុងរឿងព្រហ្មទណ្ឌ។

### ២.១. គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ជាគោលការណ៍មូលដ្ឋានមួយដែលចាំបាច់ និងសំខាន់បំផុតមិនអាចខ្វះបានដែលអ្នកនីតិនិពន្ធបានបញ្ចូលសញ្ញាណនេះចូលទៅក្នុងការបង្កើតក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ពីព្រោះគោលការណ៍នេះមានទំនាក់ទំនងយ៉ាងជិតស្និតក្នុងការពង្រឹងនីតិរដ្ឋ សំដៅឈានដល់ស្ថានភាពមួយដែលអាជ្ញាធរ និងពលរដ្ឋក្នុងសង្គមធ្វើសកម្មភាពទាំងឡាយដោយយកច្បាប់ជាធំ។ និយាយរួមនីតិរដ្ឋនឹងពុំមានអត្ថិភាពបានឡើយដរាបណាការអនុវត្តច្បាប់គ្មានប្រសិទ្ធភាព ដូច្នេះគោលការណ៍នីត្យានុកូលភាពមិនត្រូវបានពង្រឹង។

ជាសញ្ញាណទូទៅ គោលការណ៍នីត្យានុកូលភាពសំដៅដល់ការប្រតិបត្តិឲ្យបានខ្ជាប់ខ្ជួនត្រឹមត្រូវទៅតាមបទបញ្ញត្តិ។ ដើម្បីធានានីត្យានុកូលភាពបានប្រព័ន្ធច្បាប់

ដែលជាបុព្វហេតុនៃការកសាងប្រទេសត្រូវសមស្របទៅតាមសេចក្តីត្រូវការជាក់ស្តែងរបស់សង្គមនីមួយៗ។ មូលហេតុមួយក្នុងចំណោមមូលហេតុផ្សេងទៀតនាំឲ្យគោលការណ៍នីត្យានុកូលធ្លាក់ចុះគឺការខ្វះខាតប្រព័ន្ធច្បាប់សម្រាប់គ្រប់គ្រងលើគ្រប់វិស័យ ឬមានបញ្ញត្តិច្បាប់ដែលតែបញ្ញត្តិច្បាប់នោះមិនសមស្របតាមសភាពការណ៍ជាក់ស្តែងក្នុងសង្គម ។

គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអ្វីដែលជាសញ្ញាណនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ ជាគោលការណ៍ដែលកើតចេញពីទ្រឹស្តីជាភាសាឡាតាំងបកប្រែជាខេមរភាសាថា គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង យើងក៏អាចនិយាយម្យ៉ាងទៀតបានថា ករណីគ្មានច្បាប់ចែង នាំឲ្យគ្មានការចោទប្រកាន់ជាហេតុនាំឲ្យអត្ថិភាពនៃទោសមិនត្រូវបានអនុវត្ត។ ផ្ទុយទៅវិញ គោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់សំដៅដល់ថា កាលបើមានបទល្មើស អយ្យការដែលជាស្ថាប័នដែលមានអំណាចចោទប្រកាន់ត្រូវតែធ្វើការចោទប្រកាន់ចំពោះអំពើដែលជាបទល្មើសព្រហ្មទណ្ឌ ដោយមិនអនុញ្ញាតពិចារណាថ្លឹងថ្លែងលើសញ្ញាណណាមួយក្រៅពីបញ្ញត្តិច្បាប់ឡើយ។ និយាយជារួមប្រការដែលច្បាប់បញ្ញត្តិបែបនេះបានប្រៀបព្រះរាជអាជ្ញា ដូចជាម៉ាស៊ីនក្នុងការចោទប្រកាន់ទៅលើបទល្មើសបើទោះបីជាការអនុវត្តបែបនេះវាផ្ទុយនឹងសតិសម្បជញ្ញៈរបស់ខ្លួនក៏ដោយ ។

**២.២. គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់**

នៅក្នុងរឿងព្រហ្មទណ្ឌ ម្ចាស់នៃបណ្តឹងអាជ្ញាសំដៅដល់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ប៉ុន្តែមិនមែនមានន័យថា ព្រះរាជអាជ្ញាត្រូវប្រើសិទ្ធិអំណាចនេះនៅក្នុងការចោទប្រកាន់ទៅលើអំពើដែលបង្កើតបានជាបទល្មើសព្រហ្មទណ្ឌទាំងអស់នោះទេ។

ផ្អែកលើមូលដ្ឋាននៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ បានបង្កើតឲ្យមានគោលការណ៍កាលានុវត្តភាពមួយដែលផ្តល់សិទ្ធិសេរីភាពដល់ព្រះរាជអាជ្ញាមានជម្រើសនៅក្នុងការចោទប្រកាន់។ តាមរយៈនេះព្រះរាជអាជ្ញាត្រូវច្បាប់បញ្ញត្តិ បើកសិទ្ធិសេរីភាពក្នុងការធ្វើសេចក្តីសម្រេចលើការចោទប្រកាន់លើអំពើណាមួយថាជាបទល្មើស ឬមិនធ្វើការចោទប្រកាន់ចំពោះអំពើដែលខ្លួនបានដឹងនោះ ដោយផ្អែកលើស្ថានភាពដែលពាក់ព័ន្ធទៅនឹងអំពើល្មើស ដោយពិចារណាទៅលើអំពើដែលបង្កឲ្យមានភាព

រឹកវរដល់សណ្តាប់ធ្នាប់សាធារណៈក្នុងកម្រិតណាមួយ និងភស្តុតាងដែលប្រមូលបាននៅក្នុងដំណាក់កាល នៃការស៊ើបអង្កេត ។ គោលការណ៍នេះក៏អនុញ្ញាតឲ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការចំពោះបណ្តឹងមួយចំនួន ដែលខ្លួនទទួលបានពីជនរងគ្រោះ ឬតាមរយៈការបញ្ជូនរបស់មន្ត្រីនគរបាលយុត្តិធម៌ផងដែរ។

ការប្រកាន់យកនូវគោលការណ៍កាលានុវត្តភាព ឬគោលការណ៍នៃការចោទប្រកាន់ជាដាច់ខាតនោះគឺអាស្រ័យទៅតាមបរិបទនៃសង្គមនិងឆន្ទៈនយោបាយនៃប្រទេសនីមួយក្នុងពិភពលោក។ បើពិនិត្យឲ្យស៊ីជម្រៅទៅឃើញថា គោលការណ៍កាលានុវត្តភាពផ្ទុយ ពីគោលការណ៍នីត្យានុកូលភាពនៃបណ្តឹង ដោយគោលការណ៍នីត្យានុកូលភាពនៃបណ្តឹងនេះតម្រូវឲ្យ ព្រះរាជអាជ្ញារងត្រូវតែធ្វើការចោទប្រកាន់នូវគ្រប់អំពើទាំងឡាយណា ដែលបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ ដើម្បីទប់ទល់នឹងភាពអសកម្មរបស់ព្រះរាជអាជ្ញា ដែលមិនចាត់ការរឿងក្តីរបស់ខ្លួនបានដឹង ឬត្រូវបានរាយការណ៍មក។ ចំណែកឯគោលការណ៍កាលានុវត្តភាពវិញ គឺមិនបង្ខំ ឬដាក់គំនាបឲ្យព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ចំពោះគ្រប់បទល្មើសនោះទេ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា បទល្មើសនោះជាអំពើតូចតាចមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមទេ ព្រះរាជអាជ្ញអាចមិនធ្វើការចោទប្រកាន់ចំពោះអំពើនោះដោយឆន្ទានុសិទ្ធិ ។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជា តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌចង្អុលបង្ហាញពីការអនុវត្តនូវគោលការណ៍កាលានុវត្តភាព អាស្រ័យហេតុនេះដើម្បីឲ្យយល់បានស៊ីជម្រៅ និងពិស្តារទៅនឹងគោលការណ៍នេះ ជាបឋមគប្បីយល់ពីប្រភពនៃគោលការណ៍កាលានុវត្តភាព ក៏ដូចជាដំណើរការវិវត្តនៃគោលការណ៍នេះក្នុងបរិបទច្បាប់ខ្មែរជាមុនសិន។

### ២.៣. ក្របខ័ណ្ឌក្រមពិនាក្យាព្រហ្មទណ្ឌឆ្នាំ ១៩៦២

ផ្អែកតាមស្ថានភាពប្រទេសកម្ពុជា ឃើញថាកាលានុវត្តភាពនេះត្រូវបានគេប្រទះឃើញមានជាសញ្ញាណបន្តិចបន្តួចខ្លះៗក្នុងការអនុវត្តតាំងពីឆ្នាំ ១៩៦២ នៅក្នុងក្រមពិភាក្សាព្រហ្មទណ្ឌខ្មែរនាសម័យសង្គមរាស្ត្រនិយមមកម្លះ។ ជាក់ស្តែង កាលណាព្រះរាជអាជ្ញាទទួលពាក្យបណ្តឹងពាក្យចោទ ឬកំណត់ហេតុណាមួយ ហើយយល់ថារឿងដែលប្តឹងមកខ្លួនពិតជាបទលហុ នោះព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ ឬបញ្ជូនទៅសាលាលហុដើម្បីជំនុំជម្រះ។

ការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញានេះ មិនមានអំណាចជាសេចក្តីសម្រេចដាច់ខាតឡើយ មានន័យថាព្រះរាជអាជ្ញានឹងប្រែប្រួលសេចក្តីសម្រេចនោះបាន ដរាបណាបណ្តឹងអាជ្ញាមិនទាន់រលត់ ដោយការផុតអាជ្ញាយុកាល ឬដោយមូលហេតុផ្សេងទៀត។

ប៉ុន្តែយើងឃើញថា គោលការណ៍នៅមិនទាន់ជាគោលការណ៍ឯករាជ្យនៅឡើយ ដែលផ្តល់សេរីភាពឲ្យព្រះរាជអាជ្ញាក្នុងការជ្រើសរើសចោទប្រកាន់ដោយសេរីទេ ព្រះរាជអាជ្ញាគ្រាន់តែអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ បានតែចំពោះតែរឿងជាបទលហុ ឬរឿងរដ្ឋប្បវេណីសុទ្ធសាធតែប៉ុណ្ណោះ។ ព្រះរាជអាជ្ញាមានកាតព្វកិច្ចជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួនភ្លាមៗទៅគូក្តីដើមបណ្តឹង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និង សាលាក្រុមចោទ ព្រមទាំងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ផងដែរ[7]។

ចំពោះការជូនដំណឹងនេះ មានប្រយោជន៍ឲ្យគូក្តីដើមបណ្តឹង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ សាលាក្រុមចោទ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្តឹងឧទ្ធរណ៍ទៅសាលាក្រុមចោទអំពីសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញានោះ ។ ហេតុនេះហើយទើបបានជាយើងថាមិនមានលក្ខណៈឯករាជ្យ ព្រោះតែក្រមកំណត់បទល្មើសឲ្យព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកឥតចាត់ការតែបទល្មើសលហុតែប៉ុណ្ណោះហើយព្រះរាជត្រូវគោរពអំណាចឋានុក្រមដោយធ្វើការជូនដំណឹងទៅថ្នាក់លើពីសេចក្តីសម្រេចនោះទៀតផង។

### ២.៤. ក្របខណ្ឌស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ (UNTAC)

ក្រោយពេលដែលកម្ពុជាទទួលបានសន្តិភាព តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស រដ្ឋសភានីតិកាលទី១ បានអនុម័តច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ បានលុបចោលគោលការណ៍នេះ ដោយមិនអនុញ្ញាតឲ្យអនុវត្តនូវគោលការណ៍កាលានុវត្តភាពនេះទៀតទេ តែតម្រូវឲ្យព្រះរាជអាជ្ញាអនុវត្តតាមគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ពោលគឺរាល់អំពើដែលបង្កើតបានជាបទល្មើស ព្រះរាជអាជ្ញាត្រូវតែចោទប្រកាន់ជាដាច់ខាត ។

[7] មាត្រា ១៩៥ នៃក្រមពិភាក្សាព្រហ្មទណ្ឌ ឆ្នាំ ១៩៦២

និយាយរួម ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការចំពោះតែអំពើដែលមិនចាត់ចូលជាបទល្មើសព្រហ្មទណ្ឌតែប៉ុណ្ណោះ[8] ។

### ២.៥ បច្ចុប្បន្នកម្មអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ជាសមិទ្ធិផលនៃកំណែទម្រង់ប្រព័ន្ធច្បាប់ និងយុត្តិធម៌របស់រាជរដ្ឋាភិបាល ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដោយបង្កើតឲ្យមានគោលការណ៍នេះជាថ្មីម្តងទៀត។ តាមរយៈកំណែទម្រង់មួយនេះ គោលការណ៍កាលានុវត្តភាពត្រូវបានបើកទូលាយជាងការអនុវត្ត សម័យសង្គមរាស្រ្តនិយម ដោយក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បើកសិទ្ធិសេរីភាពពេញលេញដល់ព្រះរាជអាជ្ញារងធ្វើការថ្លឹងថ្លែងថាគួរចោទប្រកាន់ចំពោះអំពើណាមួយ ឬមិនចោទប្រកាន់ ទោះបីជាអំពើនោះបង្កើតបានជាបទល្មើសក៏ដោយ។ និយាយរួម ក្រមនេះផ្តល់ឲ្យព្រះរាជអាជ្ញានូវសេរីភាពក្នុងការវាយតម្លៃថាគួរដាក់ពាក្យបណ្តឹងអាជ្ញា ឬមិនដាក់ដោយផ្អែកលើទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្តភាពរីករាលដល់សណ្តាប់ធ្នាប់សាធារណៈ និងភស្តុតាងដែលប្រមូលបានពីការស៊ើបអង្កេតនោះ។ នៅក្នុងជម្រើសនៃការចោទប្រកាន់ ព្រះរាជអាជ្ញាអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់តាមជម្រើស បីជាអាទិ៍ ការបើកការស៊ើបសង្កេតការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ និងតាមនីតិវិធីបង្ហាញខ្លួនភ្លាម ។

សញ្ញាណនេះគ្រាន់តែជាគោលការណ៍ ដែលមិនទាន់បានពិនិត្យមើលលើលទ្ធភាពក្នុងការអនុវត្តនៅឡើយ ដូច្នេះនៅក្នុងផ្នែកបន្ទាប់នឹងធ្វើការបកស្រាយលម្អិត ។

## ៣. ការទទួលខុសត្រូវរបស់ស្ថាប័នអយ្យការ

### ៣.១. ការដំឡើងឋានៈដល់ព្រះរាជអាជ្ញា

ការដំឡើងឋានៈដល់ព្រះរាជអាជ្ញា គឺសំដៅដល់ការដំឡើងថ្នាក់ ឬឋានន្តរសក្តិដល់ព្រះរាជអាជ្ញាណាដែលបំពេញការងារបានល្អក្នុងការងាររបស់ខ្លួន។ ហើយការដំឡើងឋានៈដល់ព្រះរាជអាជ្ញា គឺមានព្រះរាជអាជ្ញាដែលត្រូវមានឈ្មោះនៅក្នុងតារាងវាយតម្លៃដាក់ពិន្ទុ ហើយមុននឹងវាយតម្លៃដាក់ពិន្ទុដល់

[8] មាត្រា ៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣

ព្រះរាជអាជ្ញាណាមួយនោះបាន លុះត្រាតែ ព្រះរាជអាជ្ញានោះបានបំពេញការងាររយ:ពេល ២ (ពីរ) ឆ្នាំចាប់តាំងពីថ្ងៃតាំងស៊ប់នៅក្នុងមុខងារ ។

ព្រះរាជអាជ្ញាដែលត្រូវបានតម្លើងឋាន:បានលុះត្រាតែព្រះរាជអាជ្ញានោះ[9]៖

- ការគោរពវិន័យការងារឲ្យបានត្រឹមត្រូវ
- ការសម្រេចចិត្តភារកិច្ចបានល្អ
- កិរិយាមាយាទ និង សីលធម៌មិនធ្វើឲ្យប៉ះពាល់ដល់កិត្តិយសនៃស្ថាប័នអយ្យការ
- ឆ្លងកាត់វគ្គបណ្តុះបណ្តាលនានា ឬបានបញ្ចប់ការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា ។ ក្នុងរយ:ពេលនៃការបំពេញការងារអយ្យការដែលបានខិតខំសិក្សាបន្ថែមហើយទទួលសញ្ញាបត្រក្រោយឧត្តមសិក្សាត្រូវបានលើកទឹកចិត្តដោយធ្វើតម្លើងថ្នាក់១(មួយ)ទៀត ។

ចំណែកសមាសភាពនៃគណ:កម្មការតម្លើងថ្នាក់ និង ឋានន្តរសក្តិ រួមមាន៖

- រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ០១ (មួយ) រូប - ប្រធាន
- អនុប្រធានតុលាការកំពូល ០១ (មួយ) រូប អនុប្រធាន
- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល ០១ (មួយ)រូប អនុប្រធាន
- ប្រធានសាលាឧទ្ធរណ៍សាលាឧទ្ធរណ៍ភ្នំពេញ សមាជិក
- ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ សមាជិក
- អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លេខាធិការ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចតែងតាំងសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ដើម្បីជាជំនួយការឲ្យគណ:កម្មការនេះ។

### ៣.៣ .ការដាក់ទណ្ឌកម្មដល់ព្រះរាជអាជ្ញារង

ការដាក់ពិន័យដល់ព្រះរាជអាជ្ញារង គឺសំដៅដល់ការដាក់ទណ្ឌកម្មដល់ព្រះរាជអាជ្ញាដែលប្រព្រឹត្តខុសក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវ: និងធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ និងសេចក្តីថ្លៃថ្នូរ ប្រាសចាកពីក្រមសីលធម៌របស់ព្រះរាជអាជ្ញា ដែលជាហេតុនាំឲ្យមានការដាក់ទណ្ឌកម្ម ។

ទណ្ឌកម្មខាងវិន័យដែលដាក់ចំពោះព្រះរាជអាជ្ញា ដែលប្រព្រឹត្តខុសមាន ០២ (ពីរ)ថ្នាក់គឺ[10]៖

១. ទណ្ឌកម្មថ្នាក់ទី ០១ (មួយ)

ក. ការស្តីបន្ទោសដោយផ្ទាល់មាត់

[9] មាត្រា ៨៦ នៃច្បាប់ស្តីពី លក្ខន្តិក:នៃចៅក្រម និង ព្រះរាជអាជ្ញា អនុម័តឆ្នាំ២០១៤

[10] មាត្រា ៩៩ នៃច្បាប់ស្តីពីលក្ខន្តិក:នៃចៅក្រម និង ព្រះរាជអាជ្ញា អនុម័តឆ្នាំ២០១៤

ខ. ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ. ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាង តម្លើងថ្នាក់ ឬ ឋានន្តរសក្តិមួយរយៈ តែមិនត្រូវឲ្យលើសពី ០២ (ពីរ) ឆ្នាំទេ ឬ លុបឈ្មោះចេញពីតារាងតម្លើងថ្នាក់ ឬ ឋានន្តរសក្តិវិញ ក្នុងករណីមានចុះឈ្មោះរួចហើយ ។

២. ទណ្ឌកម្មថ្នាក់ទី ០២ (ពីរ)

ក. ការផ្លាស់ដោយបង្ខំអាចតម្រូវឲ្យមានការបណ្តុះបណ្តាលបន្ថែម

ខ. ការភ្នួរពីការងារមិនឲ្យមានប្រាក់បៀវត្សក្នុងរយៈពេលមិនលើសពី ០១ (មួយ) ឆ្នាំ

គ. ការបន្ថយមួយថ្នាក់ ឬ ច្រើនថ្នាក់ ឬ បន្ថយឋានន្តរសក្តិ

ឃ. ការដាក់ឲ្យចូលនិវត្តដោយបង្ខំ

ង.ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច. ការបណ្តេញចេញពីក្របខណ្ឌ

ទណ្ឌកម្មថ្នាក់ទី ០២ (ពីរ) ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

## ៤.ទំនាក់ទំនងព្រះរាជអាជ្ញាជាមួយបុគ្គលដែលពាក់ព័ន្ធ

### ៤.១. ទំនាក់ទំនងព្រះរាជអាជ្ញាជាមួយមន្ត្រីនគរបាលយុត្តិធម៌

យើងឃើញថាគោលបំណង នៃទំនាក់ទំនងនៃព្រះរាជអាជ្ញា ជាមួយនឹងចៅក្រមស៊ើបសួរ និងទំនាក់ទំនងរបស់ព្រះរាជអាជ្ញាជាមួយមន្ត្រីនគរបាលយុត្តិធម៌ គឺមានវត្ថុបំណងប្រហាក់ប្រហែលគ្នា ដោយខុសគ្នានូវចំណុចបន្តិចបន្តួចត្រង់សមត្ថកិច្ចតួនាទីតែប៉ុណ្ណោះ។

ចំពោះលក្ខណៈដែលប្លែកគ្នាពីទំនាក់ទំនងរបស់ព្រះរាជអាជ្ញា ជាមួយចៅក្រមស៊ើបសួរនោះត្រង់ថាទំនាក់ទំនង រវាងព្រះរាជអាជ្ញា ជាមួយនឹងនគរបាលយុត្តិធម៌គឺមានលក្ខណៈស្និតស្នាលជាង បើផ្អែកតាមគោលការណ៍ច្បាប់ដែលប្រគល់សិទ្ធិឲ្យ ពីព្រោះក្នុងមាត្រា ៣៧ ស្តីពីអំណាចរបស់ព្រះរាជអាជ្ញានៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ជាក់យ៉ាងច្បាស់ថាព្រះរាជអាជ្ញាជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ទំនាក់ទំនងរបស់អ្នកដឹកនាំរបស់សមាជិកថ្នាក់ដឹកនាំ ត្រូវបានគេដឹកនាំឲ្យមានភាពស្និទ្ធស្នាលជាងទំនាក់ទំនងរបស់អ្នកដឹកនាំ និងអ្នកដឹកនាំដូចគ្នា។

ក្នុងទំនាក់ទំនងរបស់មន្ត្រីនគរបាលយុត្តិធម៌ និង ព្រះរាជអាជ្ញា ក្នុងទំនាក់ទំនងមួយក្នុងទិសដៅធ្វើយ៉ាងណាឲ្យមានការទទួលព័ត៌មានដែលពាក់ព័ន្ធនឹងបទល្មើស ឬអំពើល្មើសឆាប់បានមកដល់ដៃរបស់ព្រះរាជអាជ្ញា។ នេះបើយោងតាមខ្លឹមសារច្បាប់ត្រង់មាត្រា ៩៤ និង ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ហើយមូលហេតុដែលនាំឲ្យមានទំនាក់ទំនងរវាងមន្ត្រីនគរបាលយុត្តិធម៌និងព្រះរាជអាជ្ញា គឺដោយសារមន្ត្រីនគរបាលយុត្តិធម៌ គឺជាអាជ្ញាធររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងរក្សាយុត្តិធម៌សង្គម តាមគោលការណ៍ច្បាប់ ដែលគ្រប់គ្រងបញ្ហាទាំងនេះនៅថ្នាក់មូលដ្ឋានតាមសមត្ថកិច្ចលើដែនដីរបស់ខ្លួន ដូចនេះបើសិនជាមានការកើតមាននូវរាល់បទល្មើសក្នុងដែលសមត្ថកិច្ចរបស់ខ្លួន ទាំងក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង ឬមិនជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែចុះកិច្ចអន្តរាគមន៍ពិនិត្យ សិក្សាស្រាវជ្រាវ ស៊ើបអង្កេតលើអំពើល្មើសនោះភ្លាម ដោយត្រូវរៀបចំសំណុំបែបបទ ជូនទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ និងចាត់វិធានការបន្តតាមផ្លូវច្បាប់។ ហើយក្នុងនោះដែលព្រះរាជអាជ្ញា មានសិទ្ធិអំណាចក្នុងការកេណ្ឌកម្លាំងសាធារណៈផងដែរ បើយោងតាមមាត្រា ២៧ នៃក្រមនេះដដែល។

មន្ត្រីនគរបាលយុត្តិធម៌ជាកម្លាំងការពារសង្គម ទប់ស្កាត់ និង បង្ក្រាបបទល្មើសរបស់ព្រះរាជអាជ្ញា ។ ហើយមន្ត្រីនគរបាលយុត្តិធម៌ក៏ជាជំនួយការពិសេសរបស់ព្រះរាជអាជ្ញាក្នុងការជួយសម្រួលឲ្យកិច្ចប្រតិបត្តិការបំពេញមុខងាររបស់ព្រះរាជអាជ្ញា តាមគោលការណ៍ច្បាប់ ឲ្យប្រកបដោយភាពជោគជ័យផងដែរ។ ហើយបើសិនជាគ្មានកម្លាំងមន្ត្រីនគរបាលយុត្តិធម៌ ជាជំនួយរបស់ព្រះរាជអាជ្ញាក្នុងការបំពេញតួនាទីទេនោះ ព្រះរាជអាជ្ញាមិនអាចបំពេញមុខងាររបស់ខ្លួនបានល្អប្រសើរឡើយ។

### ៤.២. ទំនាក់ទំនងព្រះរាជអាជ្ញា ជាមួយចៅក្រមស៊ើប

ឆ្លងតាមរយៈការសិក្សាលើទ្រឹស្តី និងអត្ថបទច្បាប់ យើងកត់សម្គាល់ឃើញថាទំនាក់ទំនងព្រះរាជអាជ្ញា និង ចៅក្រមស៊ើបសួរត្រូវបានធ្វើឡើងតែក្នុងករណីបទល្មើសព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ក្នុងនីតិវិធីព្រហ្មទណ្ឌចំពោះ ទំនាក់ទំនងរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរដោយគិតផ្តើមពីដំបូងក្នុងការឈានដល់នីតិវិធីអន្តរាគមន៍ លើករណីបទល្មើសព្រហ្មទណ្ឌ គឺជាទំនាក់ទំនងក្នុងការសិក្សាស្រាវជ្រាវស៊ើបអង្កេតលើបទល្មើស

ក្នុងគោលបំណងស្វែងរកការពិត និងទប់ស្កាត់និទណ្ឌភាពនៃបទល្មើស ព្រមទាំងប្រមូលនូវរាល់ភស្តុតាងដែលមានការពាក់ព័ន្ធ ដើម្បីឲ្យព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់លើជនល្មើសបានដោយមានសម្អាងហេតុ និង ភស្តុតាងច្បាស់លាស់ត្រឹមត្រូវ ។

ក្នុងទំនាក់ទំនងនេះនៅពេលដែលព្រះរាជអាជ្ញាទទួលបានបណ្តឹង និង ពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយក្នុង ករណីបទល្មើសជាបទឧក្រិដ្ឋ ឬមជ្ឈិមព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងទៅឲ្យចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរក្នុងកិច្ចស្វែងរកធាតុផ្សំនៃបទល្មើសដែលរួមមាន ធាតុនីត្យានុកូលដែលទាក់ទងបទល្មើស ធាតុសត្យានុម័តដែលទាក់ទងបទល្មើស និងធាតុចុងក្រោយដែលជាធាតុអត្តនោម័ត។ ក្នុងកិច្ចបញ្ជូនរឿងឲ្យស៊ើបសួរពីសំណាក់ព្រះរាជអាជ្ញាទៅចៅក្រមស៊ើបសួរនេះ ជាកិច្ចសហការក្នុងគោលបំណងសុំជំនួយពីចៅក្រមស៊ើបឲ្យចាត់វិធានការប្រមូលភស្តុតាង ទាក់ទងនឹងបទល្មើសដែលកើតមាននោះជូនមកព្រះរាជអាជ្ញា ដើម្បីធ្វើការចោទប្រកាន់ តាមវិធានច្បាប់ដែលប្រគល់សិទ្ធិឲ្យ។ ហើយក្នុងទំនាក់ទំនងនេះ គឺយើងសង្កេតឃើញមានបញ្ជាក់ក្នុងមាត្រា ៨៣ និង មាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ ។ ចំពោះទំនាក់ទំនងរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរត្រង់ករណីបញ្ជូនរឿងឲ្យស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ដែលក្នុងដីកានេះប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាខ្លាចក្រែងជនល្មើសមានការរត់គេច ឬខ្លាចជនល្មើសមានការគម្រាមកំហែងដល់ជនរងគ្រោះ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការឃុំខ្លួនជនល្មើសតាមរយៈដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។ តែការសម្រេចឃុំខ្លួនជនល្មើស ឬមិនឃុំ វាជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ដែលព្រះរាជអាជ្ញាគ្មានសិទ្ធិក្នុងការបង្ខំឲ្យចៅក្រមស៊ើបសួរធ្វើតាមការស្នើសុំរបស់ខ្លួនឡើយ ប៉ុន្តែត្រង់បញ្ហានេះប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជនល្មើស ព្រះរាជអាជ្ញាមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចមិនឃុំខ្លួនជនល្មើសទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ដើម្បីធ្វើការដោះស្រាយបាន ដោយយោងតាមមាត្រា ៨៣ -៨៤ ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧។

# ជំពូកទី ២

# គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់របស់តំណាងអយ្យការ

ដូចដែលបានបញ្ជាក់ខាងលើ គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ជាគោលការណ៍ ពិសេសមួយ អនុវត្តន៍ចំពោះតែប្រទេសដែលមានការបើកចំហរនូវសិទ្ធិសេរីភាពជូនដល់ប្រជាពលរដ្ឋ ដែលមានលក្ខណៈទូលំទូលាយ ហើយគេអនុវត្តន៍បាននៅក្នុងដំណាក់កាលនៃការចោទប្រកាន់តែប៉ុណ្ណោះ។ គោលការណ៍នេះស្តែងឡើងតាមរយៈ ការតម្កល់រឿងទុកឥតចាត់ការ ដែលផ្អែកលើការវាយតម្លៃរបស់ព្រះរាជអាជ្ញាតែមួយមុខគត់។ ដើម្បីឲ្យយល់កាន់តែច្បាស់អំពីមូលហេតុ នីតិវិធីគុណសម្បត្តិក៏ដូចជាគុណវិបត្តិរបស់គោលការណ៍នេះ សូមពិនិត្យមើលលើចំណុចលម្អិតដូចខាងក្រោម៖

ផ្នែកទី១ៈសញ្ញាណនៃការតម្កល់រឿងទុកឥតចាត់ការ

ព្រះរាជអាជ្ញាត្រូវបានកំណត់ថាជាម្ចាស់បណ្តឹងអាជ្ញា សំរាប់ការធ្វើបណ្តឹងក្នុងគោលដៅចោទប្រកាន់ជនល្មើសពីបទព្រហ្មទណ្ឌ។ ជាជំហានដំបូងព្រះរាជអាជ្ញាអាចទទួលបណ្តឹងដោយពាក្យប្តឹង ឬពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ជាធម្មតាក្នុងនាមខ្លួនជាម្ចាស់បណ្តឹងអាជ្ញាព្រះរាជអាជ្ញា តែងតែប្រកាន់ភ្ជាប់នូវតួនាទីរបស់ខ្លួនក្នុងការធានានូវសណ្តាប់ធ្នាប់សាធារណៈ ដូចនេះខ្លួននឹងមិនព្រងើយកន្តើយ លើសំណុំរឿងណាមួយឡើយ។ ការមិនព្រងើយកន្តើយលើសំណុំរឿងមិនមែនបានន័យថា ព្រះរាជអាជ្ញាត្រូវតែចោទប្រកាន់គ្រប់ករណីនោះទេ គឺមានករណីមួយចំនួន ដែលព្រះរាជអាជ្ញាអាចនឹងមិនចោទប្រកាន់ដែលគេអាចនិយាយថាជាចំណាត់ការ ដោយមិនមានការចោទប្រកាន់របស់អយ្យការ លើបណ្តឹងអាជ្ញា។

ដោយយោងតាមស្ថានភាព ផលប្រយោជន៍របស់សង្គម រដ្ឋនីមួយៗមិនចង់ឲ្យពន្ធនាគាររបស់ខ្លួនពោលពេញដោយទណ្ឌិតនោះទេ ព្រោះកាលណាពោរពេញដោយទណ្ឌិតនោះសង្គមនឹងទទួលរងនូវការប៉ះពាល់ផលប្រយោជន៍ដោយសារបាត់បង់កំលាំងចលកររបស់សង្គម។ ម្យ៉ាងទៀតយោងទៅតាមស្ថានភាពជាក់ស្តែងរបស់សង្គម ព្រះរាជអាជ្ញាចាំបាច់ត្រូវត្រួតពិនិត្យនិងពិចារណាឲ្យបានគ្រប់ករណីទាំងអស់ មុននឹងខ្លួនសំរេចចោទប្រកាន់ ព្រោះការចោទប្រកាន់មួយចំនួននឹងធានាបាននូវសណ្តាប់ធ្នាប់របៀបរៀបរយសង្គម ឯការចោទប្រកាន់មួយចំនួនទៀតនឹងធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងសង្គមទៀតផង។ ដូចនេះហើយ ទើបក្រមនីតិវិធីព្រហ្មទណ្ឌ២០០៧បានអះអាងថា ព្រះរាជអាជ្ញាថ្លឹងថ្លែងលើចំណាត់ការរបស់ខ្លួន។ យើងឃើញ ក្រៅពីនេះមានគោលការណ៍ណែនាំស្តីអំពីតួនាទីរបស់ព្រះរាជអាជ្ញា ត្រង់ចំនុចជំរើសផ្សេងៗក្នុងការធ្វើបណ្តឹងអាជ្ញាក៏ដូចជាច្បាប់ ស្តីនីតិវិធីព្រហ្មទណ្ឌ ១៩៩៣ និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ សុទ្ធតែអះអាងអំពីឆន្ទានុសិទ្ធិ លើការតម្កល់រឿងទុករឿងទុកឥតចាត់ការ។ ការតម្កល់រឿងទុកឥតចាត់ការជានីតិវិធីទន់ភ្លន់មួយដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាថ្លឹងថ្លែងថា តើកាលៈទេសៈណាដែលខ្លួនគួរចោទប្រកាន់ និងកាលៈទេសៈណាដែលខ្លួនមិនគួរ ចោទប្រកាន់។

ទោះជានីតិវិធីនេះអាចអនុញ្ញាតឲ្យព្រះរាជអាជ្ញា "**មានឱកាសក្នុងការតម្កល់រឿងទុកឥតចាត់ការដើម្បី**" ផលប្រយោជនិមួយចំនួនក៏ពិតមែន តែមិនមែនបានន័យថាវាមិនមានគុណវិបត្តិតបមកវិញនោះទេ ព្រោះក្នុងស្ថានភាពមួយចំនួនព្រះរាជអាជ្ញាចាំបាច់ត្រូវតែចោទប្រកាន់។ អីចឹងហើយការតម្កល់រឿងទុកឥតចាត់ការមិនមែន គួរចេះតែប្រើតាមការយល់ឃើញរបស់ព្រះរាជអាជ្ញានោះទេ ដូចនេះហើយចាំបាច់ ត្រូវគោរពនីតិវិធីក្នុងគោលដៅធានាដល់ ផលប្រយោជន៍របស់សង្គមជាតិ និងបុគ្គលដែលជាជនរងគ្រោះផងដែរ។

## ១. ការតម្កល់រឿងទុកឥតចាត់ការ

ជាទូទៅព្រះរាជអាជ្ញារង ត្រូវបានច្បាប់ទទួលស្គាល់ថា ជាម្ចាស់បណ្ដឹងអាជ្ញាសម្រាប់ធ្វើបណ្ដឹងក្នុងគោលដៅចោទប្រកាន់ជនល្មើសពីបទល្មើសព្រហ្មទណ្ឌ។ ជាជំហានដំបូងព្រះរាជអាជ្ញាអាចទទួលបណ្ដឹងដោយពាក្យប្ដឹង ឬពាក្យបរិហារដោយខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក [11] ។ ព្រះរាជអាជ្ញាតែងតែប្រកាន់ភ្ជាប់នូវតួនាទីរបស់ខ្លួន ក្នុងការធានានូវសណ្ដាប់ធ្នាប់សាធារណៈដូច្នេះនៅពេល ដែលគាត់ទទួលបានពាក្យបណ្ដឹងដែលបញ្ជាក់ថាមានបទល្មើស គាត់នឹងធ្វើការថ្លឹងថ្លែងទៅលើពាក្យប្ដឹងនោះថា ចោទប្រកាន់ ឬមិនចោទប្រកាន់។

ឈរលើមូលដ្ឋាននៃផលប្រយោជន៍របស់សង្គម ហើយដូចជាមិនចង់ឲ្យពន្ធនាគាររបស់ខ្លួន ពោរពេញទៅដោយទណ្ឌិតនោះទេព្រោះវា នឹងនាំឲ្យសង្គមទទួលរងនូវការប៉ះពាល់ដល់កម្លាំងចលករសង្គមដែលជាធនធានមិនអាចខ្វះបានក្នុងការរុញច្រាននាវាកម្ពុជាឲ្យអភិវឌ្ឍន៍ទៅមុខ។ យោងតាមស្ថានភាពជាក់ស្ដែង ព្រះរាជអាជ្ញាត្រូតពិនិត្យនិងពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចចោទប្រកាន់ព្រោះវាមានលទ្ធផលពីរកើតឡើងចេញពីការចោទនេះ។ ការចោទប្រកាន់មួយចំនួននឹងធានាបាននូវសណ្ដាប់ធ្នាប់របៀបរៀបរយសង្គម ការចោទប្រកាន់មួយចំនួនទៀតវាបែរជាផ្ទុយនឹងផលប្រយោជន៍សង្គម ធ្វើឲ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋទៅវិញ។ តាមរយៈនេះក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានអះអាងអំពីចំណាត់ការរបស់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងលើសំណុំរឿងដែលបានប្ដឹងមកខ្លួន។ ក្រៅពីនេះ យើងឃើញមានគោលការណ៍ណែនាំស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញា [12] បានបញ្ជាក់ពីជម្រើសផ្សេងៗក្នុងការធ្វើបណ្ដឹងអាជ្ញា ដូចមានចែងនៅក្នុងច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ [13] ដែលមានផ្ដល់សិទ្ធិតូចចង្អៀតក្នុងការថ្លឹងថ្លែងលើបទល្មើសតែក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ [14] បានអះអាងអំពីឆន្ទានុសិទ្ធិដ៏ទូលាយដល់ព្រះរាជអាជ្ញា ក្នុងការតម្កល់រឿងទុកឥតចាត់ការ។ ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីទន់ភ្លន់មួយដែលអនុញ្ញាតឲ្យព្រះរាជអាជ្ញាអាចថ្លឹងថ្លែង

[11] មាត្រា ៤០ កថាខណ្ឌទី១នៃក្រមនីតិព្រហ្មទណ្ឌឆ្នាំ ២០០៧

[12] គោលការណ៍ស្ដីពីតួនាទីរបស់ព្រះរាជអាជ្ញានាឆ្នាំ ១៩៩០ នៅទីក្រុងហាវ៉ាណា ប្រទេសគុយបា

[13] មាត្រា ៥៩ នៃច្បាប់ស្ដីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣

[14] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ថាតើកាលៈទេសៈណា ដែលខ្លួនគួរចោទប្រកាន់ និងកាលៈទេសៈណាដែលខ្លួនមិនគួរចោទប្រកាន់។

បើទោះបីជានីតិវិធីនេះ អនុញ្ញាតឲ្យព្រះរាជអាជ្ញាមានឱកាសក្នុងការតម្កល់រឿងទុកឥតចាត់ការដើម្បីផលប្រយោជន៍សង្គមតាមរូបភាពណាមួយក៏ពិតមែនតែវាក៏មានគុណវិបត្តិដែរ។ ដូច្នេះហើយការតម្កល់រឿងទុកឥតចាត់ការ មិនមែនចេះតែប្រើតាមការយល់ឃើញរបស់ព្រះរាជអាជ្ញាតែត្រូវឈរលើមូលហេតុគតិយុត្តដោយគោរពនីតិវិធីឲ្យបានច្បាស់លាស់។

## ១.១. មូលហេតុ នីតិវិធី និង អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ដំបូងឡើយស្មារតីមាត្រា ៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ បានកំណត់ថារដ្ឋអាជ្ញា ត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ បើខ្លួនយល់ឃើញថាអំពើដែលបានប្តឹងមកមិនចូលជាបទល្មើសព្រហ្មទណ្ឌ។ មានមូលហេតុតែមួយគត់ ដែលនាំឲ្យរដ្ឋអាជ្ញាសម្រេចជ្រើសយកនីតិវិធីនេះមកប្រើ គឺអំពើនោះមិនចាត់ចូលជាបទល្មើសព្រហ្មទណ្ឌ។

ប៉ុន្តែបើផ្អែកលើមូលដ្ឋាននៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មិនបានអះអាងអំពីមូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការនោះទេ គ្រាន់តែបានកំណត់ថា ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ[15]។ នេះសបញ្ជាក់ថា ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ហាក់សង្កត់ធ្ងន់លើនីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការជាជាងប្រាប់ពីមូលហេតុរបស់វា។ ដូច្នេះយើងអាចសន្និដ្ឋានបានថា មូលហេតុដែលនាំឲ្យព្រះរាជអាជ្ញាជ្រើសរើសយកនីតិវិធីនេះមកប្រើ សំដៅដល់គ្រប់មូលហេតុដែលព្រះរាជអាជ្ញាសម្រេចដោយឆន្ទានុសិទ្ធិ ថាមិនចោទប្រកាន់ដោយឈរលើមូលហេតុដូចខាងក្រោមៈ

### ១.១.១ .ការរំលត់បណ្តឹងអាជ្ញា

**ក. មរណភាពនៃជនល្មើស**

[15] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ជនល្មើសដែលបានបាត់បង់ជីវិត មិនត្រូវបានកំណត់ជាប្រធាននៃនីតិក្នុងការទទួលយកនូវសិទ្ធិនិងកាតព្វកិច្ចទៀតទេ។ ក្នុងករណីនេះជនល្មើសនឹងមិនត្រូវបានចោទប្រកាន់ពីសំណាក់ព្រះរាជអាជ្ញាដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមានទេ។ ចំពោះរឿងក្តីព្រហ្មទណ្ឌការដាក់ទណ្ឌកម្មធ្វើឡើងដើម្បីអប់រំមិនមែនសងសឹកទេ។ ការចោទប្រកាន់ទៅលើសាកសព ហើយតុលាការក៏បានសម្រេចផ្តន្ទាទោសលើសាកសពទៀត វាគ្មានអ្វីក្រៅតែពីធ្វើឲ្យមហាជនយល់ថាអំពើរបស់តុលាការជារឿងដែលឃោរឃៅ និងអមនុស្សធម៌ទៅវិញទេ។

**ខ.ការផុតអាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹង**

អាជ្ញាយុកាលនៃបទល្មើស ក៏ដូចជាអាជ្ញាយុកាលនៃបណ្តឹង សំដៅដល់កំឡុងពេលណាមួយកំណត់ដោយច្បាប់ដែលការចោទប្រកាន់ និងការដាក់ទណ្ឌកម្មលើបទល្មើសព្រហ្មទណ្ឌអាចធ្វើបាន។ កាលណាចិរវេលានេះបានកន្លងផុត វានឹងបង្កើតអានុភាពនាំឲ្យព្រះរាជអាជ្ញាមិនអាចធ្វើឲ្យការចោទប្រកាន់អំពើល្មើសបានទៀតទេ។

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់ចិរវេលាអាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមានជាអាទិ៍[16] ១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ៥ ឆ្នាំ ចំពោះបទមជ្ឈិម និង ១ឆ្នាំចំពោះបទលហុ។ តែអាជ្ញាយុកាលនេះមិនត្រូវបានយកមកប្រើប្រាស់ចំពោះបទល្មើសមួយចំនួនដែលមានចរឹកលក្ខណៈឃោរឃៅ យង់ឃ្នង និងគ្រោះថ្នាក់ដល់សង្គមធ្ងន់ធ្ងរដូចជា [17] បទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និង បទឧក្រិដ្ឋសង្គ្រាម (មាត្រា ១៨៣ ១៨៨ ១៩៣ នៃក្រមព្រហ្មទណ្ឌ)។

ជាទូទៅ ចិរវេលានៃអាជ្ញាយុកាលត្រូវបានចាប់ផ្តើមគិតពីពេលដែលបទល្មើសដែលត្រូវបានប្រព្រឹត្ត។ បទល្មើសអាចស្តែងក្នុងរូបភាព ៤ សណ្ឋានដូចជា៖

- បទល្មើសភ្លាមៗ
- បទល្មើសអូសបន្លាយ
- បទល្មើសលំដាប់លំដោយ

[16] មាត្រា ១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[17] មាត្រា ៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

- បទល្មើសរួមបញ្ចូលគ្នា។

ដូច្នេះការរៀបចិរវេលានៃអាជ្ញាយុកាលនេះមិនផ្តោតលើពេលចាប់ផ្តើមឬបញ្ចប់អំពើល្មើសទេ អ្វីដែលសំខាន់លើរូបរាងនៃបទល្មើសដែលបានកើតមាន។

អាជ្ញាយុកាលត្រូវបានផ្តាច់ដោយគ្រប់កិច្ចនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ឬកិច្ចស៊ើបសួរក្នុងករណីដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ ការបញ្ចប់កិច្ចចោទ ប្រកាន់នាំឲ្យចាប់ផ្តើមគិតចិរវេលាជាថ្មីតាមការវែកញែកនៃរយៈពេលកំណត់ខាងលើ។ ក្នុងន័យនេះ កិច្ចចោទ ប្រកាន់ ឬកិច្ចស៊ើបសួរបញ្ចប់អាចធ្វើដោយដីកា ឬសាលដីកាសម្រេចលើកលែងការចោទដែលចេញដោយចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរ។ កិច្ចចោទប្រកាន់ក៏អាចបញ្ចប់ដោយសារការបង្វិលសំណុំរឿងរបស់តុលាការទៅព្រះរាជអាជ្ញាក្នុងគោលដៅបើកកិច្ចចោទប្រកាន់ជាថ្មី ដែលមិននាំឲ្យមានមោឃភាពនៃកិច្ចនីតិវិធីមុន ដូចនេះ មិនមែនអាជ្ញាយុកាលត្រូវផ្តាច់ដោយសារកិច្ចស៊ើបសួរបញ្ចប់ តែដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅមុខតុលាការជំនុំជម្រះដែលចេញដោយចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ ចេញដោយសភាស៊ើបសួរនោះទេ។

**គ. ការលើកលែងទោសជាទូទៅ**

យោងស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ មាត្រា ៩០ ថ្មីកថាខណ្ឌទី៤ បានបញ្ជាក់ថា រដ្ឋសភាអនុម័តច្បាប់ស្តីពីលើកលែងទោសជាទូទៅ បានសេចក្តីថាច្បាប់ស្តីពីការលើកលែងទោសជាទូទៅ សម្រេចថាបទល្មើសណាមួយ ឬស្ថានភាពកំណត់ណាមួយដោយច្បាប់បានកំណត់ថាត្រូវបានលើកលែងទោសនោះ ព្រះរាជអាជ្ញារង និងមិនធ្វើការចោទប្រកាន់ចំពោះស្ថានភាពនៃអំពើនោះទេ។ បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននោះ តែដោយសារមានការលើកលែងទោសជាទូទៅ ដែលមានអានុភាពលុបចោលទណ្ឌកម្មដែលពាក់ព័ន្ធ[18] ដូចនេះការផ្តន្ទាទោសមិនអាចធ្វើទៅបានទេ។ បើការផ្តន្ទាទោសធ្វើមិនកើតផង នោះការចោទប្រកាន់រឹតតែគ្មានន័យសម្រាប់សង្គមទៅទៀតហើយ ព្រោះថាសង្គមសុខចិត្តលើកលែងទោសឲ្យហើយ។ លើសពីនេះ

[18] មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ ក៏មានអានុភាពចំពោះទោសដែលប្រកាសរួចផងដែរ ដែលវានាំសេចក្តីសម្រេចនោះមិនត្រូវយកមកអនុវត្តន៍ ។ ដោយឡែកករណីដែលទោសកំពុងអនុវត្តន៍ត្រូវតែបញ្ឈប់ការអនុវត្ត។ សូមបញ្ជាក់ជូនថា ការកំណត់នេះមិនមានអានុភាពប៉ះពាល់ដល់ប្រាក់ពិន័យ និងប្រាក់ប្រដាប់ក្តីដែលបង់រួចឡើយ[19] ។

**ឃ. ការនិរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ**[20]

និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ ជាការច្រានចោលនូវបទបញ្ញត្តិតាមច្បាប់ព្រហ្មទណ្ឌចាស់ដែលផ្ទុយនឹងបទបញ្ញត្តិនៃច្បាប់ថ្មីដែលចូលជាធរមាន ដែលកំពុងអនុវត្តន៍ដែលមានការពាក់ព័ន្ធគោលការណ៍នីត្យានុកូលសុទ្ធសាធ ព្រោះថាច្បាប់កំណត់អំពើណាមួយជាបទល្មើស លុះត្រាតែច្បាប់នោះនៅជាធរមាន។ ដោយហេតុថាច្បាប់ចាស់ត្រូវនិរាករណ៍ នោះគោលការណ៍អំពើជាបទល្មើសត្រូវបានបដិសេធដោយច្បាប់ថ្មី នាំឲ្យអំពើនោះមិនអាចត្រូវបានចោទប្រកាន់ម្តងទៀតទេ [21] ព្រមទាំងបញ្ចប់នូវការចោទប្រកាន់ និងការប្រកាសទោស ក្នុងករណីទោសកំពុងអនុវត្តន៍ត្រូវបានបញ្ឈប់ភ្លាម។

**ង. អាជ្ញាអស់ជំនុំ**

គោលការណ៍អាជ្ញាអស់ជំនុំ ធានាចំពោះជំនឿរបស់ប្រជាពលរដ្ឋលើតុលាការ និងធានាដល់សិទ្ធិរបស់ប្រជាពលរដ្ឋ ដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនាឆ្នាំ ១៩៦៦ មាត្រា ១៧ ចំណុចទី ៧ ដែលអះអាងថាគោលការណ៍ជំនុំជម្រះតែមួយលើក និងភាពមិនអាចមានការផ្តន្ទាទោសចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរួចហើយ។

ការចោទប្រកាន់ចំពោះអំពើណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួនស្ថាពរ ជាគោលការណ៍ ជននេះមិនត្រូវបានធ្វើការចោទប្រកាន់ចំពោះអំពើដដែលនោះទៀតទេ ទោះបីស្ថិតក្រោមការកំណត់ឈ្មោះបទល្មើថ្មីក៏ដោយ។ ចំពោះប្រទេសកម្ពុជា បានអនុវត្តន៍គោលការណ៍អាជ្ញាអស់ជំនុំដែលទាញចេញពីគោលការណ៍ជំនុំជម្រះតែមួយលើក ចំពោះអង្គហេតុតែមួយ មានន័យថាបើជនណាដែលត្រូវបានតុលាការសម្រេចឲ្យរួចខ្លួន

---

[19] មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

[20] មាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[21] មាត្រា ៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ២០០៩

ជាស្ថាពរហើយជននោះមិនអាចត្រូវបានចោទប្រកាន់ទៀតទេ ចំពោះអំពើដដែលនោះ ទោះបីជាការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ។ ប៉ុន្តែចំពោះការសម្រេចតម្កល់ទុកឥតចាត់ការរបស់អង្គការអយ្យការ និងដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរ ពុំមានអានុភាពនាំឲ្យមានអាជ្ញាអស់ជំនុំទេ។

**ច. មូលហេតុផ្សេងទៀត**

ក្រៅពីជម្រើសនៃការចោទប្រកាន់ និងតម្កល់រឿងទុកឥតចាត់ការ សំណុំរឿងអាចត្រូវបានគេដោះស្រាយតាមរូមភាពផ្សេងៗ ក្នុងករណីដែលពាក្យបណ្តឹងជា លក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទ ព្រហ្មទណ្ឌ។

ដើម្បីប្រើមូលហេតុលើចំណុចនេះ ចាំបាច់ត្រូវមានការកំណត់ដោយឡែកក្នុងច្បាប់ណាមួយដោយជាក់លាក់ថា ក្នុងស្ថានភាពណាមួយនេះបណ្តឹងអាជ្ញានឹងរលត់។

ស្ថានភាពដែលកំណត់នេះមានជាអាទិ៍៖

- **ការសម្របសម្រួលជាមួយរដ្ឋ៖**
  អាចធ្វើបានគ្រប់ពេលវេលាបើសិនបើមានចែងនៅក្នុងច្បាប់ដោយឡែក។ ការសម្របសម្រួលនេះអាចធ្វើទៅបានលុះត្រាតែអំពើនោះមិនធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ ជនដែលបានប្រព្រឹត្តទទួលស្គាល់កំហុស ហើយមានការសន្យាណាមួយ។ ការសម្របសម្រួលជាមួយរដ្ឋនេះ យើងសង្កេតឃើញថាអាចមានការប្រមានជាលាយលក្ខណ៍អក្សរជាដើម។
- **ការដកពាក្យបណ្តឹង ក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់នៃបទល្មើសព្រហ្មទណ្ឌ៖**
  ការដកពាក្យបណ្តឹងដោយជនរងគ្រោះអាចធ្វើទៅបានចំពោះបទល្មើសមួយចំនួនបើសិនជាមូលហេតុនៃបណ្តឹង គឺលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ ក្នុងលក្ខខណ្ឌនេះ យើងឃើញមានបទល្មើសមួយចំនួនជាអាទិ៍ បទរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារជាដើម។ ក្នុងបទរំលោភសេពសន្ថវៈ ប្រសិនបើជនរងគ្រោះដកពាក្យបណ្តឹង ដោយអះអាងថាខ្លួនបានយល់ព្រមនឹងបុរសនោះនាពេលរួមភេទ

ព្រះរាជអាជ្ញានឹងមិនអាចធ្វើការចោទប្រកាន់បានទៀតទេ ក៏ប៉ុន្តែចំពោះការរួមភេទចំពោះអនីតិជនក្រោមអាយុ ១៥ឆ្នាំទោះបីជាមានការសម្តែងឆន្ទៈយល់ព្រមក៏ដោយ ក៏អំពើនោះនៅតែជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានជាកម្មវត្ថុនៃការចោទប្រកាន់របស់អង្គការអយ្យការដដែល។ ចំណែកឯរឿងអំពើហិង្សាក្នុងគ្រួសារវិញ ប្រសិនបើប្រពន្ធ ឬប្តីដែលជាអ្នករងគ្រោះដកពាក្យបណ្តឹង ចំពោះសហព័ទ្ធរបស់ខ្លួនវិញនោះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់បានទេ[22]។ មួយវិញទៀតចំពោះករណីទ្វេរពន្ធភាពក៏ដោយប្រសិន បើភរិយាព្រមដកពាក្យបណ្តឹងវិញរឿងនេះក៏ត្រូវបានបញ្ចប់ដែរ។

- **ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល**[23]៖ បទល្មើសមួយចំនួនអាចបញ្ចប់បានដោយមិនចាំបាច់ធ្វើបណ្តឹងអាជ្ញា គឺគ្រាន់តែបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួលតែប៉ុណ្ណោះ។ ករណីប្រភេទនេះ ភាគច្រើនគេសង្កេតឃើញមានអនុវត្តន៍ចំពោះបទល្មើសចរាចរណ៍។

ផ្អែកលើមូលដ្ឋាននៃមាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌពុំអាចធ្វើបានឡើយ បើមានសំណើរពីជនរងគ្រោះជានីតិជនដែលបទល្មើសនេះជាបទមជ្ឈិមស្រាល ឬបទលហុ។ ប្រសិនបើមានសំណើពីជនរងគ្រោះដើម្បីកុំឲ្យមានការចោទប្រកាន់នេះ ព្រះរាជអាជ្ញានឹងមិនធ្វើការចោទប្រកាន់ចំពោះអំពើនោះឡើយ។ សំណើត្រូវបានចាត់ទុកថាជាការដកពាក្យបណ្តឹង កាលបើព្រះរាជអាជ្ញាបានចោទប្រកាន់រួច។

### .១.១.២ .ស្ថានភាពនៃអំពើ

### ក. អំពើមិនចាត់ជាបទល្មើស

ដើម្បីកំណត់អំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌចាំបាច់ត្រូវគោរពធាតុផ្សំនៃបទល្មើសដែលជាគោលការណ៍នៃក្រមព្រហ្មទណ្ឌមានធាតុបីគឺ ធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត និងធាតុផ្សំអត្តម័ត។ ការតម្កល់រឿងទុកឥតចាត់ការអាចមានមូលហេតុមកពីវត្តមាននូវធាតុផ្សំណាមួយនៃបទល្មើស បទល្មើសមានលក្ខណៈមិនគ្រប់គ្រាន់ ធាតុ នៃសំណុំរឿងមិនអនុញ្ញត

[22] មាត្រា ៣៦ នៃច្បាប់ស្តីពីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ ២០០៥
[23] មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ឲ្យកំណត់ពីធាតុផ្សំនៃបទល្មើស ដែលបានរាយការណ៍មកនោះ ពោលគឺពិនិត្យទៅធាតុផ្សំដែលបង្កើតឲ្យមានវិមតិសង្ស័យជាអាទិ៍៖

- **ធាតុនីត្យានុកូល៖** សំដៅដល់ធាតុច្បាប់ បើបទល្មើសនោះច្បាប់ពុំបានចែងថាជាបទល្មើសព្រះរាជអាជ្ញាមិនចាំបាច់ពិនិត្យមើលលើធាតុផ្សំដទៃទៀតឡើយ។
- **សមត្ថភាពជនល្មើស៖** សំដៅដល់បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ។

**ខ. អំពើល្មើសហុចផលព្យសនកម្ម ឬការរំខានតិចតួច**

ការចោទប្រកាន់លើបទព្រហ្មទណ្ឌ មិនមែនចេះតែចោទនោះទេ ដោយហេតុថាអំពើមួយចំនួនទាមទារឲ្យព្រះរាជអាជ្ញាថ្លឹងថ្លែងជាមុនចំពោះបទល្មើសនោះ ដោយត្រូវសិក្សាលើចរិតគ្រោះថ្នាក់របស់អំពើ និងព្យសនកម្មដែលប៉ះពាល់ដល់ជនរងគ្រោះ និងសង្គមក្នុងគោលបំណងមួយ ដើម្បីធានាបានថា ការសម្រេចតម្កល់រឿងទុកឥតចាត់ការជាមធ្យោបាយតែមួយគត់ដែលផ្តល់ផលប្រសើរដល់សង្គម។ ម្យ៉ាងទៀត បើសម្រេចចោទប្រកាន់ចំពោះអំពើនោះ បែរជាមិនអាចធានាបាននូវវឌ្ឍនៈភាពរបស់សង្គមទេ ដូច្នេះការចោទប្រកាន់នោះមិនគួរកើតមានឡើយ។

**គ. អត្ថិភាពនៃបទល្មើស ដែលមិនអាចចោទប្រកាន់បាន**

- **គ្មានពាក្យបណ្តឹងពីជនដែលច្បាប់កំណត់**

អំពើជាបទល្មើសដរាបណាច្បាប់បានកំណត់ដោយជាក់លាក់ថាវាបានធ្វើឲ្យសង្គមល្អក់កករ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម ។ដោយឡែក អំពើមួយចំនួនទាក់ទងនឹងកិត្តិយស និងភាពថ្លៃថ្នូររបស់មនុស្សដូចជាបទបរិហាកេរ្តិ៍ជាសាធារណៈ[24]អំពើបរិហាកេរ្តិ៍តាមសារព័ត៌មាន[25]បទជេរប្រមាថជាសាធារណៈ[26] និងអំពើជេរប្រមាថតាមសារព័ត៌[27] ដែលចាំបាច់ត្រូវមានបណ្តឹងរបស់ជនមួយចំនួនកំណត់ដោយច្បាប់ ទើបការចោទប្រកាន់អាចធ្វើឡើងបាន[28] ។ ជាក់ស្តែង ករណីដែលមានការបរិហាកេរ្តិ៍ ឬជេរប្រមាថសមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការសាធារណៈ

[24] មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
[25] មាត្រា ៣០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
[26] មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
[27] មាត្រា ៣០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
[28] មាត្រា ៣០៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩

ឬពលរដ្ឋដែលទទួលបន្ទុកបេសកកម្មសាធារណៈ ឬអាណត្តិសាធារណៈ ការចោទប្រកាន់នឹងត្រូវធ្វើឡើង តាមបណ្តឹងរបស់សាមីខ្លួន ឬបណ្តឹងរបស់ប្រធានស្ថាប័នសាមី។ ចំពោះអំពើនោះស្តែងចំពោះបុគ្គលឯកជនវិញ ការចោទប្រកាន់អាចធ្វើទៅបាន ដរាបណាមានបណ្តឹងពីសាមីបុគ្គល។

- **អភ័យឯកសិទ្ធិ**

ទោះបីជា អត្ថិភាពនៃបទល្មើសត្រូវបានរកឃើញក៏ពិតមែន ប៉ុន្តែលក្ខខណ្ឌនៃការចោទប្រកាន់នៅតែមិនអាចធ្វើទៅបាន ដោយហេតុផលថា បុគ្គលដែលបានប្រព្រឹត្តបទល្មើសជាបុគ្គល ដែលត្រូវបានការពារដោយអភ័យឯកសិទ្ធិពិសេសជាអាទ៍ អភ័យឯកសិត្ធិព្រះមហាក្សត្រមហាក្សត្រីយ៍ អភ័យឯកសិទ្ធិរដ្ឋសភា អភ័យឯកសិទ្ធិព្រឹទ្ធសភា និងអភ័យឯកសិទ្ធិការទូត។

បុគ្គលដូចបានរៀបរាប់ខាងលើនេះមិនអាចត្រូវបានគេចោទប្រកាន់ក្នុងពេលដែលខ្លួនអនុវត្តតួនាទីរបស់ខ្លួនឡើយ តួយ៉ាងជាក់ស្តែងខណៈពេលដែលតំណាងរាស្ត្របញ្ចេញមតិរបស់ខ្លួននៅក្នុងកិច្ចការប្រជុំណាមួយដែលធ្វើឡើងជាសាធារណៈគេមិនអាចធ្វើការចោទប្រកាន់បទណាមួយលើការបញ្ចេញមតិនោះបានឡើយ។

**ឃ. អំពើដែលជាបទល្មើស តែមិនទទួលខុសត្រូវដែលកំណត់ដោយក្រមព្រហ្មទណ្ឌ**

ទោះបីជាធាតុផ្សំបានបំពេញគ្រប់គ្រាន់បញ្ជាក់ថាជាបទល្មើសក៏ដោយ ក៏ប៉ុន្តែមិនមែនមានន័យថា គ្រប់បទល្មើសត្រូវបានទទួលការផ្តន្ទាទោសឡើយ ព្រោះត្រូវឈរលើភាពត្រឹមត្រូវ និងភាពអនុគ្រោះពីច្បាប់ចំពោះអំពើទាំងនោះ ដែលគេហៅថាយុត្តិកម្មនៃបទល្មើស។

ការមិនទទួលខុសត្រូវដោយសារមូលហេតុ៖

- **វិបល្លាសស្មារតី៖** ភាពមិនយល់ដឹងពីលទ្ធផលនៃអំពើរបស់ខ្លួន។ ការទទួលយកចំពោះភាពមិនទទួលខុសត្រូវ មិនសំដៅដល់ការកើតវិបល្លាសស្មារតីដែលកាត់បន្ថយភាពយល់ដឹង ព្រោះជននោះមានភាពយល់ដឹងតែតុលាការនឹងគិតគូរដល់ការកំណត់លើបញ្ហានេះ។ ការកើតមានវិបល្លាសស្មារតីដោយសារការសេពគ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនត្រូវបានគាំទ្រដោយច្បាប់ថាវាជាយុត្តិកម្មនៃបទល្មើសនោះទេ។

- **ការអនុញ្ញាតដោយអាជ្ញាធរ ឬច្បាប់៖** អំពើដែលអនុញ្ញាតដោយច្បាប់ ឬបទប្បញ្ញត្តិនានា និងតាមការបញ្ជារបស់អាជ្ញាធរស្របច្បាប់ ទោះមានរូបភាពជាបទល្មើសក៏ដោយ ក៏នោះមិនមែនជាបទល្មើសដែលត្រូវទទួលទោសនោះដែរ លើកលែងតែជាបទល្មើសប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម និងអំពើខុសច្បាប់ជាក់លាក់មួយ។
- **ការការពារស្របច្បាប់៖** ការការពារស្របច្បាប់ឬកិច្ចការពារធម្មានរូបចាំបាច់ត្រូវគោរពនូវលក្ខខណ្ឌបីជាអាទិ៍ ភាពចាំបាច់ដើម្បីការពារខ្លួន អ្នកដទៃ ឬទ្រព្យសម្បត្តិដែលប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។ បទល្មើស និងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា។ គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ ដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន។
- **ស្ថានភាពចាំបាច់៖** ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌចំនួនពីរគឺ ទី១ ស្ថានភាពចាំបាច់ដើម្បីការពារខ្លួនការពារអ្នកដទៃ ឬទ្រព្យសម្បត្តិប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមានដែលបណ្តាលមកពីធម្មជាតិ ឬអំពើរបស់មនុស្ស។ ទី២ សមាមាត្ររវាងកម្លាំង មធ្យោបាយ និងទម្ងន់នៃគ្រោះថ្នាក់។
- **អានុភាពនៃកម្លាំង ឬបង្ខំ៖** ជាព្រឹត្តិការណ៍ដែលកើតមានក្រៅឆន្ទៈរបស់មនុស្ស ដែលមិនមែនរបស់មនុស្សដែលទទួលរងពីវាទេ។ ករណីឆន្ទៈរបស់ជនរងគ្រោះក្នុងគោលដៅឲ្យមានបទល្មើសនោះ គេថាជនរងគ្រោះមានឆន្ទៈជាឱកាសប្រព្រឹត្តបទល្មើសទៅវិញ។ ការបង្ខំនោះត្រូវតែមិនអាចដឹងមុន ឬមិនអាចមើលឃើញ និងមិនអាចជៀសវាងបានតែបើជននោះមើលឃើញក្តី មើលមិនឃើញក្តី ហើយមិនជៀសវាងបាន មានន័យថាជននោះមានឆន្ទៈឲ្យព្រឹត្តិការណ៍នោះកើតឡើង។ បុគ្គលដែលប្រព្រឹត្តដោយសារកម្លាំងបង្ខំ ឬបង្ខំបែបនេះ បុគ្គលនោះនឹងមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។
- **បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ៖** យោងតាមស្មារតីនៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានទទួលយកនូវនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ ជាអញ្ញត្រកម្មសម្រាប់អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ក្រមមិនអនុញ្ញាតឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌណាមួយ ត្រូវបានអនុវត្តលើនោះទេ។

ជាងនេះទៅទៀត ជាអញ្ញត្រកម្មពិសេស ព្រះមហាក្សត្រជាបុគ្គលដែលមាននូវបុព្វសិទ្ធិពិសេស កំណត់ដោយស្មារតីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ ថាគ្មាននរណាអាចរំលោភបំពានទ្រង់បានឡើយ[29] ដូចនេះអង្គព្រះមហាក្សត្រក៏មិនត្រូវបានចាត់ចូលជាកម្មវត្ថុនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែរ។

ក្រៅពីមូលហេតុចម្បងៗទាំងនេះ ក៏មានមូលហេតុផ្សេងទៀតដូចជា អភ័យឯកសិទ្ធិនិយ័តកម្មដោយឯកឯង ការស្វែងរកមិនបានផលជាដើម សុទ្ធតែជាមូលហេតុនាំឲ្យព្រះរាជអាជ្ញា សម្រេចតម្កល់រឿងទុកឥតចាត់ការ។

## ២ .នីតិវិធី និង អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

### ២.១. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ

នៅពេលដែលព្រះរាជអាជ្ញាទទួលបានពាក្យប្តឹង ឬពាក្យបរិហារ គាត់នឹងធ្វើចំណាត់ការលើពាក្យប្តឹងនោះដោយ ធ្វើការថ្លឹងថ្លែងទៅលើមូលដ្ឋាននៃអង្គហេតុដែលបានបំពេញនូវធាតុផ្សំគួរដល់ការចោទប្រកាន់ ឬមិនចោទប្រកាន់។ ប្រសិនបើព្រះរាជអាជ្ញាសម្រេចមិនចោទប្រកាន់ទៅលើពាក្យប្តឹងដែលខ្លួនបានទទួលនោះ គាត់នឹងធ្វើដីកាសម្រេចមួយដែលគេហៅថា ដីកាតម្កល់រឿងទុកឥតចាត់ការ។ស្របតាមការសម្រេចនេះព្រះរាជអាជ្ញាដំបូងគាត់ត្រូវចុះនិទ្ទេសលើបណ្តឹងឬកំណត់ហេតុព្រមទាំងលើបញ្ជីចុះបណ្តឹង។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងទៅដើមបណ្តឹងអំពីសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេល ២ (ពីរ) ខែយ៉ាងយូរចាប់តាំងពីថ្ងៃទទួលពាក្យប្តឹង។

ការជូនដំណឹងអំពីការតម្កល់រឿងទុកឥតចាត់ការ គឺជាលក្ខខណ្ឌចាំបាច់មួយដែលព្រះរាជអាជ្ញាត្រូវបំពេញ ដើម្បីឲ្យអ្នកប្តឹងដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញានេះ ធ្វើការដាក់ពាក្យប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញា។

---

[29] មាត្រា ៧ កថាខណ្ឌទី៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

ការតម្កល់រឿងទុកឥតចាត់ការ ជានីតិវិធីទន់ភ្លន់របស់អយ្យការក្នុងការមិនចោទប្រកាន់ជនល្មើសពីបទព្រហ្មទណ្ឌ។ ការសម្រេចមិនចោទប្រកាន់អាចជាការថ្លឹងថ្លែង ប្រកបដោយភាពត្រឹមត្រូវតែក៏អាចជាភាពខុសឆ្គងលើការសម្រេចមិនចោទប្រកាន់ខាងបទព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាដែរ ដូច្នេះដើម្បីធានាថា ទោះជាមានការតម្កល់រឿងទុកឥតចាត់ការយ៉ាងណាក៏ដោយ ត្រូវយកមកដោះស្រាយដោយនីតិវិធីផ្សេងៗលើចំណាត់ការបែបនេះ។ ការជៀសវាងហានីភ័យកម្រិតខ្ពស់សម្រាប់សង្គម ក្នុងការការពារនូវផលប្រយោជន៍ជាចាំបាច់របស់ជនរងគ្រោះ និងសង្គមក៏មិនមានន័យថាការចោទប្រកាន់មិនអាចធ្វើបាននោះទេ ។ ការកំណត់នីតិវិធីសម្រាប់ជាឧបសគ្គនេះទោះជានាំឲ្យស្ថាប័នអយ្យការ បាត់បង់នូវឯករាជ្យភាពរបស់ខ្លួនមួយផ្នែកក្នុងការអនុវត្តន៍ច្បាប់ក៏ដោយ ឬក៏វាមិនមានការប៉ះពាល់ដល់សង្គម ឬហុចផលវិបត្តិដល់ស្មារតីយុត្តិធម៌ដែរ ព្រោះជាទូទៅការចោទប្រកាន់ មិនមែនជាការដាក់ទណ្ឌកម្មនោះទេ គ្រាន់តែជាការប្តឹងទៅតុលាការ និងដើម្បីឲ្យយុត្តាធិការជំនុំជម្រះកំណត់អំពីពិរុទ្ធភាពកើតមានចំពោះជននោះតែប៉ុណ្ណោះ។

២.២. អានុភាពនៃការតម្កល់រឿងទុកឥតចាត់ការ

ផ្អែកលើមាត្រា ៤១ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ អះអាងថាការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ។ ចំពោះការសម្រេចតម្កល់រឿងទុកឥតចាត់ការ ជាការសម្រេចមួយដោយឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញា។ ការកំណត់អាជ្ញាអស់ជំនុំមិនអាចស្តែងឡើងបានទេ ដោយគ្រាន់តែពឹងលើការយល់ឃើញរបស់ព្រះរាជអាជ្ញា។ ភាពគ្មានអាជ្ញាអស់ជំនុំនាំឲ្យព្រះរាជអាជ្ញាអាចសម្រេចចោទប្រកាន់សាជាថ្មីលើអង្គហេតុដដែល ករណីដែលខ្លួនយល់ថាអង្គហេតុនោះបង្កើតជាបទល្មើសព្រហ្មទណ្ឌ លើកលែងតែផុតរលត់បណ្តឹងអាជ្ញា។

ករណីជាក់ស្តែងនៃការអនុវត្តទៅលើ ដីកាដំកល់រឿងទុកឥតចាត់ការនៃអយ្យការមសាលាដំបូងខេត្តកណ្តាល គឺតំណាងអយ្យការអមសាលាដំបូង ក្រោយពីបានពិនិត្យឯកសារលើសំណុំរឿង បានយល់ឃើញថា៖

ក. អវត្តមានបទល្មើសៈ មានន័យថានៅក្នុងសំណុំរឿងបន្ទាប់ពីតំណាងអយ្យការធ្វើការពិនិត្យ និងស្រាវជ្រាវរួចហើយតំណាងអយ្យការយល់ឃើញថាអង្គហេតុពុំមែនបទល្មើសព្រហ្មទណ្ឌ ហើយវាជារឿងរដ្ឋប្បវេណីសុទ្ធសាធ។ ដូចជា ៖ បុគ្គល ក និង ខ បានប្តឹងបុគ្គល គ អំពីបទឆបោកទាក់ទងនឹងការម៉ៅចំការឪឡឹក មិនព្រមបំពេញកាតព្វកិច្ចរបស់ខ្លួនតាមការព្រមព្រៀង។ ប៉ុន្តែបន្ទាប់ពីអយ្យការធ្វើការពិនិត្យ និង ស្រាវជ្រាវលើសំណុំរឿង បានយល់ឃើញថាសំណុំរឿងនេះអវត្តមាននៃបទល្មើស ដោយហេតុថាវាគឺជារឿងរដ្ឋប្បវេណីទាក់ទងនឹងកិច្ចសន្យាម៉ៅការចំការឪឡឹក ហើយទាក់ទងនឹងការអនុវត្តកាតព្វកិច្ចផ្តល់កម្រៃមិនពេញលេញចំពោះលទ្ធផលការងារដែលបានធ្វើរវាងភាគី។

ខ .ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់ៈ មានន័យថាជាបទល្មើសដែលបានប្តឹងមកពុំមានធាតុផ្សំគ្រប់គ្រាន់ណាមួយក្នុងចំណោមធាតុផ្សំទាំងបីដូចជា អវត្តមាននៃធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័តនៃបទល្មើស។

គ. មូលហេតុគតិយុត្តៈ គឺមូលហេតុមួយដែលមិនអាចធ្វើការចោទប្រកាន់ទៅលើបទល្មើសបានដែលមូលហេតុទាំងនោះមានដូចជាៈ

- ការដកពាក្យប្តឹង
- ការលើកលែងទោសជាទូទៅ
- មរណភាពជនល្មើស
- ផុតអាជ្ញាយុកាល
- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ
- អាជ្ញាអស់ជំនុំ
- ការសម្របសម្រួលជាមួយរដ្ឋ
- ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល
- អភ័យឯកសិទ្ធិ
- អនិយ័តភាពនៃនីតិវិធី

- ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[30]

**ឃ** .ការចោទប្រកាន់មិនផ្តល់ប្រយោជន៍៖ គឺជាមូលហេតុមួយចំនួនដែលមានដូចខាងក្រោម៖

- ការស្វែងរកមិនបានផល
- ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[31]
- ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ
- ការខកខានរបស់ដើមបណ្តឹង
- អាកប្បកិរិយារបស់ជនរងគ្រោះ
- ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស
- និយ័តកម្មដោយឯកឯង[32]
- ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**ង** .នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា៖ ជាផ្នែកមួយនៃនីតិវិធីដែលតំណាងអយ្យការអាចជ្រើសរើសនូវចំណុចណាមួយដូចខាងក្រោម៖

- ការជួសជុលការខូចខាតដោយ ឬដល់អនីតិជន
- សន្ធានកម្ម[33]
- អធិបញ្ញាផ្តល់ការព្យាបាល
- ជនរងគ្រោះ ឬដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា
- និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា
- ការរំលឹកពីអត្ថបទច្បាប់ ឬការព្រមាន[34]
- ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬនៃវិជ្ជាជីវៈ
- ការសម្រុះសម្រួលព្រហ្មទណ្ឌ[35]

**ច** .នីតិវិធីជាជម្រើដែលអនុវត្តដោយអាជ្ញាធរផ្សេងទៀត

**ឆ** .ជនល្មើសមិនត្រូវបានស្គាល់

**ជ** .ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

---

[30] មូលហេតុវិបល្លាសស្មារតី ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[31] ដើមបណ្តឹងឈប់ប្តឹង

[32] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[33] ករណីចែងដោយច្បាប់

[34] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[35] ករណីដែលចែងដោយច្បាប់

❖ **លក្ខខណ្ឌនៃការចោទប្រកាន់**

ក្រោយពីការទទួលបណ្ដឹងទាមទារ ឬបណ្ដឹងបរិហារពីជនណាម្នាក់ ឬទទួលរបាយការណ៍ពីមន្ត្រីនគរបាលយុត្តធម៌ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ ប្រសិនបើយល់ឃើញថាពុំទាន់មាន ភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់នៅឡើយ អយ្យការអាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ស្វែង រកភស្តុតាងបន្ថែម ឬបើកការស៊ើបអង្កេតបឋមបាន មាត្រា ៤០ កថាខណ្ឌ ទី ២ វាក្យខណ្ឌ ទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។ ដោយហេតុថា ព្រះរាជអាជ្ញាជាម្ចាស់បណ្ដឹងអាជ្ញា គាត់អាចទទួលពាក្យបណ្ដឹងពីរឿងព្រហ្មទណ្ឌមួយបាន ។ ពាក្យបណ្ដឹងនោះអាចធ្វើឡើងដោយ: ជនរងគ្រោះ ឬ សាច់ញាតិរបស់ជនរងគ្រោះ មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីផ្សេងទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌដូចជា មន្ត្រីគយជាដើម ឬក៏ តតិយជនដែលដឹងឮពីបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ ។

❖ **ការពិនិត្យទោសលើកាលានុវត្តភាពនៃការចោទប្រកាន់**

ជាដំបូង ព្រះរជអាជ្ញាត្រូវធានាឲ្យបានថា ធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌដូចជាមានសព្វគ្រប់ហើយ គាត់ត្រូវវាយតម្លៃកំណត់បទល្មើសសមស្របទៅនឹងអំពើ ដោយពិនិត្យទៅលើធាតុផ្សំសត្យានុម័ត និងពិនិត្យថាតើករណីនេះមានអភ័យឯកសិទ្ធិដែរឬទេ ហើយជនល្មើសត្រូវចោទប្រកាន់ក្នុងនាម ជាអ្វី (ចារី អ្នកសមគំនិត) ជាដើម។ ក្រៅពីនេះ ព្រះរាជអាជ្ញាក៏ត្រូវពិនិត្យទៅលើបញ្ហាទម្រង់ ដូចជា ករណីរំលត់បណ្ដឹងអាជ្ញា បញ្ហាសមត្ថកិច្ច ឬក៏ករណីនេះចាំបាច់ត្រូវមានបណ្ដឹងពីជនរងគ្រោះដែរទេ ។ ល ។

ទាក់ទិននឹងបទល្មើសប្រើប្រាស់គ្រឿងញៀនច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងមានបទបញ្ញត្តិពិសេសពាក់ព័ន្ធនឹងវិធានការព្យាបាល ។ មាត្រា ៩០ ថ្មី នៃច្បាប់ចែងថា " ការចោទប្រកាន់មិនត្រូវធ្វើ លើជនណាដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រ ៩៨ ថ្មី កថាខណ្ឌ ទី ២ )ប្រើប្រាស់គ្រឿងញៀនត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ ថ្ងៃដល់ ១ ខែ) ហើយបានចូលខ្លួនដោយខ្លួនឯងទៅទទួល ការចោទប្រកាន់ " ។

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីបានជ្រើសរើសយក គោលការណ៍នៃកាលានុវត្តភាពនៃការចោទប្រកាន់ពុំមែនគោលការណ៍នីត្យានុកូលភាពនៃការចោទ ដូចក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ១៩៩៣ ឡើយ ។ មាត្រា ៤០ កថាខណ្ឌ ទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា: **ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ**

**ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ** ។ បទបញ្ញត្តិនេះ ជាបទបញ្ញត្តិគោលដែលនាំឲ្យមានការបកស្រាយថា ក្រមនីតិវិធីព្រហ្មទណ្ឌប្រកាន់យកគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ។

❖ សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា

ជាគោលការណ៍ ព្រះរាជអាជ្ញាមានសេរីភាពពេញលេញក្នុងការសម្រេចពីការចោទប្រកាន់ មិនចោទប្រកាន់ ប៉ុន្តែដោយសារហេតុថា ព្រះរាជអាជ្ញាស្ថិតក្នុងអង្គដែលមានឋានានុក្រម ដូច្នេះព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់ របស់ថ្នាក់លើតាមឋានានុក្រមរបស់ខ្លួនដែលបង្គាប់បញ្ជាឲ្យធ្វើការចោទ ប្រកាន់លើអំពើអ្វីមួយ ទោះបីជាព្រះរាជអាជ្ញាខ្លួនឯងយល់ថាពុំត្រូវចោទប្រកាន់ក៏ដោយ។ គួរបញ្ជាក់ថា មានតែបញ្ជាឲ្យចោទប្រកាន់ប៉ុណ្ណោះដែលព្រះរាជអាជ្ញាត្រូវអនុវត្តតាម។តែប្រសិនបើមានបញ្ជាមិនឲ្យចោទប្រកាន់ តែព្រះរាជអាជ្ញាបានចោទប្រកាន់រួចទៅហើយ គឺព្រះរាជអាជ្ញាពុំត្រូវអាចដកហូតការចោទប្រកាន់របស់ខ្លួនបានឡើយ។ ទន្ទឹមនឹងនេះដែរ ត្រូវគូសបញ្ជាក់ផងដែរថា ពេលខ្លះការចោទប្រកាន់ទាមទារចាំបាច់ឲ្យមានជាមុននូវ ៖

-បណ្ដឹងរបស់ជនរងគ្រោះ ដូចជា បទផិត (តាមច្បាប់ស្ដីពីឯកពន្ធភាព ) ។

-ការអនុញ្ញាតពិសេស: ករណី ជនមានអភ័យឯកសិទ្ធិសភា ។

សេចក្ដីសម្រេចរបស់អយ្យការទាក់ទង នឹងការចោទប្រកាន់ក្រោយពីបានពិនិត្យឯកសារសំណុំរឿងចប់សព្វគ្រប់ហើយអង្គការអយ្យការ ត្រូវធ្វើការសម្រេចសេចក្ដី ថាត្រូវចោទប្រកាន់ឬមិនចោទប្រកាន់ ។

ក-ដីកាតំកល់ទុកមិនចាត់ការ

ប្រសិនបើព្រះរាជអាជ្ញាយល់ថា អំពើដែលគេប្ដឹង មកមិនមែនជាបទល្មើសព្រហ្មទណ្ឌ ឬគ្មានភស្តុតាង ណាមួយគួរឱ្យជឿថាពិតជាមានបទល្មើសកើតឡើងមែននោះ ព្រះរជអាជ្ញានឹងចេញ **ដីកាតម្កល់រឿងទុកឥតចាត់ការ** មាត្រា ៤១ ដោយមានសំអាងច្បាប់ និងសំអាងហេតុ ។ ដីកាតម្កល់រឿងទុកឥតចាត់ការ អាចប្ដឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល ២ ខែ គិតពីថ្ងៃទទួលដំណឹងពីដីកានេះ ដោយអ្នកប្ដឹងដាក់ពាក្យនៅអង្គការអយ្យការពាក់ព័ន្ធ ។ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់។ ទោះជាយ៉ាងណាក្ដី សេចក្ដីសំរេចនេះពុំមានអាជ្ញាអស់ជំនុំទេ ដោយព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្ដីសម្រេចរបស់ខ្លួនវិញ នៅពេលដែលបណ្ដឹងអាជ្ញាមិនទាន់រលត់ ។

ខ-សេចក្ដីសម្រេចក្នុងការចោទប្រកាន់

នៅពេលដែលមានភស្តុតាងធ្ងន់ល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេ ប្តឹងមកនោះមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់ ។

ក្នុងករណីដែលមន្ត្រីរាជការណាម្នាក់ ត្រូវបានតុលាការធ្វើកាតប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានស្ថាប័នសាមី ក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ មាត្រា ៥១ នៃច្បាប់ពីសហលន្និកៈមន្ត្រីរាជការស៊ីវិល ។ ការចាប់ផ្តើមចោទប្រកាន់ចំពោះអនីតិជន ត្រូវជូនដំណឹងទៅអនីតិជនជាប់សង្ស័យ និងឪពុកម្តាយ អាណាព្យាបាលរបស់អនីតិជននោះ។ ទាក់ទងនឹងអនីតិជន ដែលជាជនជាប់សង្ស័យ សេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទង នឹងយុត្តិធម៌អនីតិជន ចេញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០០៥ បានកំណត់ថា ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុ របស់អនីតិជនដែល ជាប់សង្ស័យនោះ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេត បន្ថែមដើម្បីស្វែងរកការពិតនៃអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះ។

ប្រសិនបើលទ្ធផល នៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យតិចជាង ១៣ ឆ្នាំ ព្រះរាជអាជ្ញាគប្បីចេញ ដីកាតំកល់រឿងទុកឥតចាត់ការ ហើយឲ្យដំណឹងទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យនោះចាប់ពី ១៣ ឆ្នាំឡើងទៅ តែតិចជាង ១៨ ឆ្នាំ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់បាន ។

ប្រសិនបើរកឃើញអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបអង្កេតស៊ើបសួរពីបញ្ហាអាយុការចាប់ផ្តើមធ្វើការចោទប្រកាន់នេះអាចធ្វើតាមវិធីបីយ៉ាង តាមមាត្រា ៩៣ ។

### ៣. ការប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជានីតិវិធីមួយដែលអនុញ្ញាតឲ្យជនរងគ្រោះ អាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងករណីដែលខ្លួនមិនសុខចិត្តនឹងការសម្រេចលើពាក្យប្តឹងរបស់ខ្លួនដោយសម្រេចតម្កល់រឿងទុកឥតចាត់ការដោយព្រះរាជអាជ្ញា។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឃ្លាំមើលការអនុវត្តច្បាប់ក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន[36] ដោយសារតែតួនាទីនេះ ទើបបានជាច្បាប់អនុញ្ញាតឲ្យគាត់ជាអ្នកទទួល និងសម្រេចលើបណ្តឹងនោះ។ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ក៏ដូចគ្នានឹងស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដែរ តែខុសគ្នាត្រង់ថាបណ្តឹងតវ៉ាត្រូវប្តឹងទៅសាលាឧទ្ធរណ៍[37] មិនមែនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នោះទេ។ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ មានលក្ខណៈខុសគ្នាមួយចំនួនដែលមិនមានចែងត្រង់ចំណុចជនរងគ្រោះ ដែលមិនបានទទួលដំណឹងពីព្រះរាជអាជ្ញា តែត្រូវទទួលយកដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ បណ្តឹងនេះគ្រាន់តែចង់ប្រាប់ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយគោរពលក្ខខណ្ឌនិងនីតិវិធីមួយចំនួនភ្លាមៗថា មានការតម្កល់រឿងទុកឥតចាត់ការ ហើយដោយមិនចាំបាច់រងចាំការធ្វើអធិការកិច្ចរបស់ខ្លួន[38] ទើបដឹងពីរឿងនេះហើយចាំអន្តរាគមន៍ទេ។ ប្រសិនបើមានការប្តឹងតវ៉ា អំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់អង្គការអយ្យការសាលាដំបូង អ្នកប្តឹងត្រូវដាក់ពាក្យប្តឹងសាមញ្ញមួយនៅអង្គការអយ្យការពាក់ព័ន្ធ (អង្គការអយ្យការដែលចេញសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ) ក្នុងរយៈពេលយ៉ាងយូរបំផុត ២ (ពីរ) ខែគិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនេះ។ បន្ទាប់មក អង្គការអយ្យការដែលទទួលបណ្តឹងនេះ ត្រូវបញ្ជូនសំណុំរឿងបន្តភ្លាមទៅអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដើម្បីសម្រេចនិងចេញអធិបញ្ញា។ បណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍មួយនេះ ចាំបាច់ត្រូវគោរពនូវលក្ខខណ្ឌជាសារវន្តចំនួនបីដូចតទៅះ

### ៣.១. បុគ្គលដែលជាអ្នកដាក់ពាក្យប្តឹង

[36] មាត្រា ៣៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[37] មាត្រា៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣

[38] មាត្រា ៣៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អ្នកដែលអាចដាក់ពាក្យប្តឹង មានតែជនដែលតាំងខ្លួនជាជនរងគ្រោះ [39] សំដៅដល់ជនដែលបានដាក់ពាក្យប្តឹងជំហានដំបូង មុននឹងមានការសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការអះអាងបែបនេះ គឺមានមូលដ្ឋានពីរ៖

**ក. មូលដ្ឋានច្បាប់**

យោងតាមមាត្រា ៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានប្រើពាក្យថាជនរងគ្រោះ អាចដាក់ពាក្យប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងករណីពាក្យប្តឹងរបស់ខ្លួនស្ថិតក្នុងស្ថានភាពគ្មានចម្លើយ ឬត្រូវតម្កល់ទុកឥតចាត់ការ។ ជនរងគ្រោះចាំបាច់ត្រូវតែជាជនដែលរងព្យសនកម្មពីបទល្មើសដោយផ្ទាល់[40] ។

**ខ. មូលដ្ឋានផ្សេងទៀតដែលកំណត់ថាត្រូវតែជាជនរងគ្រោះ**

មូលដ្ឋានជាគោលបំណងបន្ទាប់បន្សំរបស់បណ្តឹងតវ៉ា គឺមិនត្រឹមតែចង់បានការផ្តន្ទាទោសចំពោះជនល្មើសប៉ុណ្ណោះទេ តែមានគោលបំណងចម្បងមួយទៀត គឺដើម្បីផលប្រយោជន៍របស់ជនរងគ្រោះក្នុងការទទួលបាននូវយុត្តិធម៌ចំពោះសំណងរដ្ឋប្បវេណី [41] ដោយមិនចាំបាច់ដាក់ពាក្យប្តឹងចំពោះមុខតុលាការរដ្ឋប្បវេណីទៀតទេ កាលបើសេចក្តីសម្រេចរបស់តុលាការបានប្រកាសទោសលើជននោះ។ នីតិវិធីបែបនេះ ផ្តល់ផលវិជ្ជមានដល់ផលប្រយោជន៍របស់ជនរងគ្រោះជាអាទិ៍ មិនបាច់បង់ប្រាក់ប្រដាប់ក្តីករណីដែលខ្លួនចាញ់ក្តី [42] ក៏ដូចជាមិនជាប់កាតព្វកិច្ចក្នុងការទទួលរ៉ាបរងលើកិច្ចនីតិវិធីទាំងមូលចំពោះភស្តុតាង [43] ព្រមទាំងបន្ទុកចំណាយផ្សេងទៀតកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណី។

**៣.២. នីតិវិធីនៃការប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

យោងតាមស្មារតីមាត្រា ៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ យើងអាចអះអាងនូវនីតិវិធីចំនួនពីរលើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍គឺ៖

**ក. នីតិវិធីនៃការដាក់ពាក្យប្តឹង**

---

[39] មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[40] មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[41] មាត្រា ៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[42] មាត្រា៦៤ ចំណុច១ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[43] មាត្រា ៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

អ្នកប្តឹងត្រូវធ្វើបណ្តឹងសាមញ្ញមួយ ទៅអង្គការអគ្គព្រះរាជអាជ្ញាដែលពាក់ព័ន្ធ គឺអង្គការអយ្យការអមសាលាដំបូងដែលបានទទួលពាក្យប្តឹងរបស់ខ្លួនលើកទី១ មិនមែនសំដៅដល់បុគ្គលជាព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងនោះទេ។

**ខ. ចំណាត់ការលើបណ្តឹងតវ៉ា**

នៅពេលបណ្តឹងត្រូវបានដាក់រួច តំណាងអយ្យការអមសាលាដំបូងត្រូវបញ្ជូនសំណុំរឿងនេះមកឲ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីធ្វើការសម្រេចលើបណ្តឹងនោះ។ ការសម្រេចអាចមានរូបភាពចំនួនពីរះ

- បើបណ្តឹងនោះមានមូលហេតុត្រឹមត្រូវអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអំណាចអធិបញ្ញាជាលាយលក្ខណ៍អក្សរ ដល់ព្រះរាជអាជ្ញាអមសាលាដំបូង ដើម្បីធ្វើការចោទប្រកាន់។ ព្រះរាជាអាជ្ញាត្រូវតែចោទប្រកាន់ គាត់គ្មានសិទ្ធិអំណាចក្នុងការសម្រេចដោយខ្លួនឯងដូចពីមុននោះទេ។
- ក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាទុកជាបានការ ហើយជូនព័ត៌មាន អំពីការសម្រេចនេះទៅអ្នកប្តឹង ដោយមិនអនុញ្ញាតធ្វើការប្តឹងតវ៉ាទៀតទេ។ ការជូនដំណឹងនេះដើម្បីជាឱកាសក្នុងការប្រើនីតិវិធីផ្សេងទៀតដូចជាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។

**២.៣. អយ្យការដែលមានសមត្ថកិច្ចលើការសម្រេចសេចក្តី**

អយ្យការទាំងអស់មិនសុទ្ធតែមានសមត្ថកិច្ចចំពោះពាក្យបណ្តឹងនោះទេ មានតែអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តែមួយគត់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌប្រគល់សិទ្ធិអំណាចលើការសម្រេចសេចក្តី។ ការផ្តល់សិទ្ធិនេះមានភាពសមរម្យជាការទទួលយកសាលាឧទ្ធរណ៍ ដែលជាតុលាការជំនុំជម្រះសុទ្ធសាធ។ សាលាឧទ្ធរណ៍ជាតុលាការដែលមានសមត្ថកិច្ចជំនុំជម្រះក្តី ដែលមិនអាចចូលខ្លួនដើរតួជាអ្នកសម្រេចបញ្ហាឲ្យមានការចោទប្រកាន់ និងជំនុំជម្រះ។ គោលការណ៍នេះបានកំណត់ថា កាលណាចៅក្រមអយ្យការណាមួយ ដែលជាអ្នកសម្រេចពីការចោទប្រកាន់នេះ ចៅក្រមអយ្យការនោះមិនចូលខ្លួនក្នុងការជំនុំជម្រះជាចៅក្រមជំនុំជម្រះទៀតទេ ដើម្បីធានាបាននូវយុត្តិធម៌ គ្មានស្ថានភាពបុរេវិនិច្ឆ័យជាមុនថា

ជននោះត្រូវតែជាជនមានតម្រុយពិរុទ្ធភាព។ តាមរយៈនេះ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានញែកដាច់ពីគ្នាយ៉ាងច្បាស់ចំពោះបញ្ហានេះ ដោយមិនអនុញ្ញាតឲ្យមានវត្តមានរបស់ចៅក្រមអយ្យការក្នុងសវនាការ ក្នុងតួនាទីជាចៅក្រមជំនុំជម្រះឡើយ[44]។

### ៣.៤ .រយៈពេលដែលអាចធ្វើបណ្តឹងតវ៉ា

ការគិតគូររយៈពេលសម្រាប់ដាក់ពាក្យប្តឹង គឺមានពីរករណីដោយសារតែអ្នកប្តឹងមានពីរប្រភេទដែលខុសពីច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ មិនមានចែងពីរយៈពេលនេះទេសូមពិនិត្យះ

- **អ្នកប្តឹងនោះបានទទួលបណ្តឹងះ**

  អំពីការសម្រេចតម្កល់រឿងទុកឥតចាត់ការពីព្រះរាជអាជ្ញារយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលដំណឹងនោះ ជនរងគ្រោះមានសិទ្ធិក្នុងការប្តឹងតវ៉ាពីការមិនចោទប្រកាន់។

- **អ្នកប្តឹង តែមិនបានទទួលដំណឹងះ** មានន័យថា បណ្តឹងស្ថិតនៅគ្មានចម្លើយពីព្រះរាជអាជ្ញាក្នុងន័យនេះ ច្បាប់ក៏បានផ្តល់សិទ្ធិក្នុងការប្តឹងដែរ។ ដោយខ្លួនមិនបានទទួលដំណឹងពីការតម្កល់រឿងទុកឥតចាត់ការ ដូច្នេះរយៈពេលពីរខែ គិតចាប់ពីពេលជូនដំណឹងនោះ មិនតម្រូវឲ្យអ្នកប្តឹងនោះគោរពនោះទេ។ ការអះអាងបែបនេះ ព្រោះថាមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតប្តឹងនោះគោរពនោះទេ។ ការអះអាងបែបនេះ ព្រោះថាមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌអនុញ្ញាតឲ្យមានការប្តឹងរបស់ជនរងគ្រោះប្រភេទនេះ ដោយអនុលោមទៅតាមរបៀបដែលមានចែងក្នុងមាត្រា ៤១ នៃក្រមនីតិវិធីដោយកម្រិតរយៈពេល ២ (ពីរ) ខែ គិតពីពេលជនរងគ្រោះបានទទួលដំណឹងតែប៉ុណ្ណោះ។ ដោយសារតែមិនមានការកម្រិតរយៈពេល

[44] មាត្រា ៥៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣

ចំពោះជនរងគ្រោះដែលមិនបាននាំឲ្យជននោះអាចប្ដឹងពេលណា ក៏បានឲ្យតែខ្លួនយល់ថា បណ្ដឹងរបស់ខ្លួនស្ថិតនៅគ្មានចម្លើយ។

## ៤. អំណាចអធិបញ្ញាតាមឋានានុក្រមនៃអង្គការអយ្យការ

ជាទូទៅ រចនាសម្ព័ន្ធរបស់អង្គការអយ្យការមានបីថ្នាក់ ៖ នេះឋានានុក្រមតាមថ្នាក់តុលាការដែលខ្លួននៅអមជាមួយ ឬ ឋានានុក្រមរដ្ឋបាលតុលាការនៃយុត្តិធម៌ដែលថៅក្រមអយ្យការមាន៖

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូល
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។

អំណាចអធិបញ្ញា គឺវាមានកម្លាំងក្នុងការបញ្ជាដល់ព្រះរាជអាជ្ញាក្នុងការចោទប្រកាន់អំពីបទល្មើសដែលអាចមានស្ថានភាពមួយចំនួនអាចប៉ះពាល់ដល់សេរីភាពរបស់ជនដែលទទួលរងនូវការចោទប្រកាន់ និងជះឥទ្ធិពលដល់ការកសាងនីតិរដ្ឋ។

សូមបញ្ជាក់ថា ឋានានុក្រមនៃអង្គការអយ្យការនេះ មិនសំដៅដល់ប្រភេទឋានានុក្រមកំណត់ដោយមាត្រា ២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ គ្រាន់តែឋានានុក្រមតាមថ្នាក់តុលាការដែលខ្លួនអមនៅជាមួយ ឬឋានានុក្រមតាមរដ្ឋបាលតុលាការ។ សញ្ញាណនេះជាការបង្កើតថ្មីឲ្យមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ត្រង់មាត្រា ២៩ ដែលកំណត់ពីអំណាចក្នុងការប្រើអំណាចអធិបញ្ញា ដែលពីមុនមកយើងពុំឃើញមានចែងក្នុងច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣។ ការបង្កើតអំណាចអធិបញ្ញានេះ មិនចាំបាច់មានបណ្ដឹងរបស់ជនណាមួយ ទើបខ្លួនចាត់ការនោះទេ តែជាតួនាទីត្រួតពិនិត្យក្នុងនាមជាអាជ្ញាធរដែលច្បាប់កំណត់ប្រគល់សិទ្ធិផ្ដាច់មុខក្នុងការចូលរួមអនុវត្តន៍ច្បាប់ និងទប់ស្កាត់ការប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ព្រះរាជអាជ្ញាដែលគ្មានហេតុផលមិនសមស្របនឹងស្ថានភាពសង្គម។

### ៤.១. លក្ខខណ្ឌនៃការប្រើអំណាចអធិបញ្ញា

ជាស្មារតីមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់នូវលក្ខខណ្ឌចំនួនពីរ។ ដើម្បីធានាបាននូវសណ្ដាប់ធ្នាប់សង្គម គ្មានការបំពានអំណាច គេអនុញ្ញាតឲ្យបុគ្គលមួយចំនួនតែប៉ុណ្ណោះ ដែលទទួលស្គាល់ដោយក្រមនីតិវិធីព្រហ្មទណ្ឌជាអាទិ៍៖

- **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាមុខនាទីមួយដែលជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងវិស័យច្បាប់ក្នុងសង្គម ។ ម្យ៉ាងវិញទៀត ក្នុងករណីបទល្មើសធ្ងន់ធ្ងរ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវរាយការណ៍ទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីជូនព័ត៌មាន [45] ។ ដូចនេះ នៅពេលដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានដឹងអំពីបទល្មើស គាត់អាចធ្វើសកម្មភាពក្រោមទម្រង់ជាការប្តឹងបរិហារបទល្មើស ឬធ្វើអធិបញ្ញាតាមការណែនាំក្នុងការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រី យល់ឃើញថាជាការគួរទៅដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬទៅដល់អគ្គព្រះរាជអាជ្ញាដោយផ្ទាល់[46]។

- **អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានតួនាទីឃ្លាំមើលការអនុវត្តច្បាប់ក្នុងសមត្ថកិច្ចដែនដីនៃសាលាឧទ្ធរណ៍ តែដោយសារកម្ពុជាមានសាលាឧទ្ធរណ៍ តែមួយ ដូច្នេះអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ចលើចៅក្រមអយ្យការ ក្នុងប្រទេសកម្ពុជាទាំងមូល ។ មាត្រា ២៩ ដដែល ដូចជាមិនបានរំឮកដល់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូលនោះទេ។ មូលហេតុនៃការមិនចែងពីអំណាចរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ព្រោះថាគាត់ត្រូវបានកម្រិតតួនាទីដោយមាត្រា ៣២ ដែលចែងថាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលចូលរួមក្នុងការសុំឲ្យមានការគោរពច្បាប់។ ការបើកតួនាទីនេះលុះណាតែមានបណ្តឹងសាទុក្ខ បណ្តឹងសើរើ និងបណ្តឹងតវ៉ាផ្សេងៗទៀត ដែលដាក់ជូនតុលាការកំពូល។ តួនាទីដែលកំណត់នេះ ត្រូវបានកម្រិតដោយបញ្ញត្តិមាត្រា បន្តបន្ទាប់របស់ចំណុចស្តីពីបណ្តឹងនីមួយៗ ខុសពីតួនាទីរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សុទ្ធសាធ ដែលអគ្គព្រះរាជអាជ្ញាមានសិទ្ធិអំណាច ក្នុងឃ្លាំមើលការអនុវត្តច្បាប់ អធិការកិច្ចនៅស្ថាប័នអយ្យការ ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន។ ដូច្នោះហើយ

[45] មាត្រា ៣៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[46] មាត្រា ២៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើ អធិបញ្ញាឲ្យចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬធ្វើការសន្និដ្ឋានយ៉ាងណាដែលខ្លួនយល់ថាជាការគួរ[47]។

➢ **ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាទីនេះ មិនសំដៅដល់ព្រះរាជអាជ្ញាតុលាការកំពូល និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទេ ព្រោះអ្នកទាំងនេះគ្មានអំណាចលើអយ្យការណាមួយក្នុងការប្រើអំណាចអធិបញ្ញាទេ។ ហេតុនេះហើយ ព្រះរាជអាជ្ញាសំដៅដល់ព្រះរាជអាជ្ញាអមសាលាដំបូងតែប៉ុណ្ណោះ ដែលមាត្រាបន្តបន្ទាប់អះអាងដោយពាក្យព្រះរាជអាជ្ញា [48] ដែលលាតសន្ធឹងត្រឹមរាជធានី-ខេត្តក្រុងដែលសាលាដំបូងនោះមានសមត្ថកិច្ច។ ព្រះរាជអាជ្ញាក៏អាចធ្វើអធិបញ្ញាឲ្យព្រះរាជអាជ្ញារងទាំងអស់ធ្វើការចោទប្រកាន់ ឬក៏ចាត់ឲ្យចោទប្រកាន់ ឬក៏ធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមដែលខ្លួនយល់ឃើញថាជាការគួរ[49]។

## ៤.២ .អំណាចអធិបញ្ញា

### ៤.២.១ ទម្រង់និងខ្លឹមសារនៃអំណាចអធិបញ្ញា

បើទុកណាជាអាជ្ញាធរពាក់ព័ន្ធខាងលើ អាចមានអំណាចអធិបញ្ញាឲ្យមានការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ តែត្រូវគោរពនូវលក្ខខណ្ឌចំនួន ២សំខាន់៖

➢ ទម្រង់នៃអំណាចអធិបញ្ញា

ជាចាំបាច់ ការធ្វើអធិបញ្ញាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ បើពុំដូច្នោះទេ វាគ្រាន់តែជាការណែនាំមួយទៅព្រះរាជអាជ្ញាតែប៉ុណ្ណោះ ដែលមិនមានអំណាចចាប់បង្ខំព្រះរាជអាជ្ញាឲ្យធ្វើការចោទប្រកាន់តាមការណែនាំនោះទេ។ ប្រសិនបើព្រះរាជអាជ្ញាអនុវត្តតាមអធិបញ្ញា មិនមែនមកពីលិខិតនោះទេ តែពឹងផ្អែកលើមូលហេតុដែលជាមូលដ្ឋានក្នុងការតម្កល់រឿងទុកឥតចាត់ការ តាមការយល់ឃើញរបស់ព្រះរាជាអាជ្ញា។

➢ ខ្លឹមសារនៃអំណាចអធិបញ្ញា

[47] មាត្រា ២៩ កថាខណ្ឌ២ វាក្យខណ្ឌ២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[48] មាត្រា ៣៧ និង ៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[49] មាត្រា ២៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

អំណាចអធិបញ្ញា គឺជាការបញ្ជាណែនាំឲ្យមានការចោទប្រកាន់ តែមិនមែនជាការបញ្ជាឲ្យមានការតម្កល់រឿងទុកឥតចាត់ការទេ។ ដូចនេះ បើជាការបញ្ជាឲ្យមានការតម្កល់រឿងទុកឥតចាត់ការនោះ ព្រះរាជអាជ្ញានៅតែអាស្រ័យលើការថ្លឹងថ្លែងរបស់ខ្លួនដដែល ក្នុងការសម្រេចឈរលើមូលដ្ឋាននៃឆន្ទានុសិទ្ធិរបស់ខ្លួន។

**៤.២.២ .អានុភាពនៃអំណាចអធិបញ្ញា**

អធិបញ្ញាមានអានុភាពជាការបញ្ជា ដល់ចៅក្រមអយ្យការក្រោមឋានានុក្រមនៃអង្គការអយ្យការ ធ្វើឲ្យការចោទប្រកាន់លើបទល្មើសព្រហ្មទណ្ឌ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញា ចាំបាច់ត្រូវតែគោរពជាដាច់ខាតចំពោះការប្រើប្រាស់អំណាចអធិបញ្ញានៃឋានានុក្រមរបស់ខ្លួន។ ការមិនគោរពអំណាចអធិបញ្ញា អាចជាមូលហេតុនាំឲ្យមានទណ្ឌកម្មរដ្ឋបាលពីសំណាក់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម [50] ។ អំណាចអធិបញ្ញា គ្មានអនុភាពលាតសន្ធឹងដល់ការកត់សម្គាល់ផ្ទាល់មាត់របស់ចៅក្រមអយ្យការក្នុងពេលសវនាការនោះទេ។ ចៅក្រមអយ្យការនៅពេលសវនាការអាចធ្វើការកត់សម្គាល់បានដោយសេរីតាមការដែលខ្លួនយល់ឃើញ និងស្របទៅតាមសតិសម្បជញ្ញៈរបស់ខ្លួន [51] ។ លើពីនេះ ដើម្បីធានាសេរីភាពក្នុងការនិយាយស្តីនៅពេលសវនាការ ក្រមនីតិវិធីព្រហ្មទណ្ឌបានធានាថា គ្មានការចោទប្រកាន់ខាងវិន័យណាមួយដល់ចៅក្រមអយ្យការដោយសារតែវាចារនៅពេលសវនាការនោះឡើយ[52]។

**៤.២.៣ .គុណសម្បត្តិនៃការតម្កល់រឿងទុកឥតចាត់ការ**

ឈរលើមូលដ្ឋាននៃប្រយោជន៍សង្គមជាតិ ការតម្កល់រឿងទុកឥតចាត់ការបានផ្តល់នូវលទ្ធផលវិជ្ជមានជាអាទិ៍ៈ

- ដោយសារស្ថានភាពបទល្មើសតូចតាចមួយចំនួន ដែលហុចព្យសនកម្មមានរូបភាពតូចតាចត្រូវបានជម្រះចោលដោយការមិនចោទប្រកាន់ ហើយបានជួយសម្រាលបន្ទុកចំពោះការកកស្ទះពាក្យប្តឹងទៅតុលាការ

[50] មាត្រា ១២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៩៤

[51] មាត្រា ៣០ កថាខណ្ឌ ២ វាក្យខណ្ឌទី ១ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[52] មាត្រា ៣០ កថាខណ្ឌ២ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដោយទុកលទ្ធភាពឲ្យតុលាការយកចិត្តទុក ដាក់លើបទល្មើសដែលស្តែងនូវចរឹតសាហាវឃោរឃៅ និងគ្រោះថ្នាក់ដល់សង្គមជាតិ ដែលនាំឲ្យការកាត់សេចក្តីប្រព្រឹត្ត ទៅប្រកបដោយប្រសិទ្ធិភាព និងធានាបាននូវយុត្តិធម៌។

- ផ្តល់លទ្ធភាពដល់ការកសាងសង្គមជាតិ ព្រោះចំពោះបទល្មើសទាំងអស់ មិនសុទ្ធតែបានបំពានដល់ផលប្រយោជន៍របស់បុគ្គល និងសង្គមជាតិធ្ងន់ធ្ងរនោះទេ។ មនុស្សជាកម្លាំងចលករសម្រាប់ការអភិវឌ្ឍន៍ជាតិ ហេតុនេះហើយ បើយើងមិនចោទប្រកាន់លើអំពើនោះ វាមានន័យថាមនុស្សនៅតែអាចចូលរួមសង្គម ចូលរួមគ្នា ដើម្បីការអភិវឌ្ឍន៍ជាងការដែលទុកជននោះ ក្នុងពន្ធនាគារដែលគ្មានប្រយោជន៍ ថែមទាំងបំផ្លិចបំផ្លាញថវិការដ្ឋទៀតផង។
- ប្រើប្រាស់ធនធានថវិការដ្ឋឲ្យមានប្រសិទ្ធិភាពខ្ពស់បំផុត។
- សំដៅប្រើប្រាស់ទណ្ឌកម្មខាងព្រហ្មទណ្ឌ ឲ្យមានប្រសិទ្ធិភាព ស្របទៅតាមគោលបំណងនៃនីតិព្រហ្មទណ្ឌ។

### ៤.២.៤ .គុណវិបត្តិនៃការតម្កល់រឿងទុកឥតចាត់ការចំពោះសង្គម

បើពិចារណាឲ្យបានកាន់តែស៊ីជម្រៅ ស្របពេលនឹងមានគុណសម្បត្តិ យើងនឹងឃើញថាការតម្កល់រឿងទុកឥតចាត់ការក៏ផ្តល់នូវគុណវិបត្តិដូចខាងក្រោម៖ ជារឿយៗ ការតម្កល់រឿងទុកឥតចាត់ការ ជាហេតុនាំឲ្យសង្គមសម្បូរទៅដោយបទល្មើសកាន់តែច្រើន ដោយសារតែជនល្មើសយល់ថា ខ្លួននឹងមិនត្រូវបានចោទប្រកាន់ ចំពោះទង្វើរបស់ខ្លួនទេ នោះបុគ្គលម្នាក់ៗនឹងមិនខ្លាចការផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌឡើយ។ ការកំណត់ទណ្ឌកម្មតាមរយៈស្មារតីនៃមាត្រានីមួយៗ គឺដើម្បីបង្ការ ឬបំភ័យមនុស្សថា កាលណាជននោះហ៊ានប្រព្រឹត្តនូវអំពើល្មើស ជននោះនឹងទទួលទណ្ឌកម្ម ដោយការចោទប្រកាន់របស់ព្រះរាជអាជ្ញាទៅតុលាការ។

មិនត្រឹមតែប៉ុណ្ណោះ វាអាចជាចំណុចចន្លោះប្រហោងនៃច្បាប់ ដែលទុកឱកាសឲ្យមន្ត្រីអនុវត្តទាញយកផលប្រយោជន៍ណាមួយដែលគាត់ទទួលបានពីការតម្កល់រឿងទុកឥតចាត់ការទៅវិញ។

ជារួមការតម្កល់រឿងទុកឥតចាត់ការ វាជះឥទ្ធិពលដល់ការរីកចម្រើនរបស់សង្គម តែវាក៏ជាចំណុចអន់ថយ ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈដែរ។ ដើម្បីជាគន្លឹះក្នុងការទប់ស្កាត់ចំណុចអវិជ្ជមាននៃនីតិវិធីនេះ គឺពង្រឹងសមត្ថភាពភាពធនធានមនុស្សលើវិស័យច្បាប់

និងធានាការអនុវត្តច្បាប់ប្រកបដោយយុត្តិធម៌។ មិនតែប៉ុណ្ណោះ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ទន្ទឹមគ្នាជាមួយនីតិវិធីតម្កល់រឿងទុកឥតចាត់ការ ក្នុងគោលបំណងធានាការកាត់បន្ថយកម្រិតអវិជ្ជមានឲ្យកាន់តែខ្ពស់មួយកម្រិតទៀត តាមរយៈការបញ្ញត្តិនូវវិធានការដោះស្រាយនូវគុណវិបត្តិនោះដោយបើកសិទ្ធិ ឲ្យមានការប្តឹងឧទ្ធរណ៍ចំពោះដីកាតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាពីសំណាក់ដើមបណ្តឹង ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រសិនបើភាគីដើមបណ្តឹងនៅតែមិនសុខចិត្តនឹងដីការបស់ព្រះរាជអាជ្ញា ក្នុងគោលដៅធានាបាននូវនីតិរដ្ឋយ៉ាងពិតប្រាកដ។

## ផ្នែកទី២: **ការបើកការស៊ើបសួរ**

ការបើកការស៊ើបសួរ គឺជាការប្តឹងរបស់ព្រះរាជអាជ្ញា ទៅចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរតាម រយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ អនុលោមតាមន័យនេះចៅក្រមស៊ើបសួរត្រូវបានប្រគល់អំណាចពីព្រះរាជអាជ្ញា ឲ្យធ្វើការស្រាវជ្រាវទៅលើអង្គហេតុ ដែលចង្អុលបង្ហាញដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហើយការស្រាវជ្រាវទៅលើអង្គហេតុរបស់ចៅក្រមស៊ើបសួរ គឺខុសពីការស្រាវជ្រាវដែលធ្វើឡើងដោយព្រះរាជអាជ្ញា ព្រោះថាព្រះរាជអាជ្ញា នៅពេលដែលគាត់ធ្វើការស្រាវជ្រាវស្វែងរកព័ត៌មាន និងភស្តុតាងទាំងឡាយណាដើម្បីកំណត់ឲ្យឃើញអំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌដើម្បីការពារការចោទប្រកាន់របស់គាត់។ ប៉ុន្តែនៅពេលសំណុំរឿងត្រូវបានបញ្ជូនទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនោះ ចៅក្រមស៊ើបសួរបំពេញកិច្ចធ្វើការស្រាវជ្រាវ ដើម្បីស្វែងរកឲ្យឃើញការពិតអំពីអត្ថិភាព ឬនត្ថិភាពនៃបទល្មើសដែលព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ក្នុងន័យនេះមានន័យថាចៅក្រមស៊ើបសួរ នឹងធ្វើការស្រាវជ្រាវនូវគ្រប់ព័ត៌មានទាំងអស់ដែលមានទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[53]។

### ១. នីតិវិធីនៃការបើកការស៊ើបសួរ

[53] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅក្នុងក្របខណ្ឌនៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់ពីវិធីសាស្ត្រនៃការបើកការស៊ើបសួរតាមរបៀបពីរយ៉ាងគឺៈ

- ការបើកការស៊ើបសួរតាមរយៈពាក្យប្តឹងសាមញ្ញ
- ការបើកការស៊ើបសួរតាមរយៈពាក្យប្តឹង ដែលមានការតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី។

**១-ការបើកការស៊ើបសួរតាមរយៈពាក្យបណ្តឹងសាមញ្ញ**

ពាក្យប្តឹងសាមញ្ញ សំដៅទៅលើពាក្យប្តឹងទាំងឡាយណា ដែលធ្វើឡើងក្នុងគោលដៅបកអាក្រាតពីបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង។ ចំពោះពាក្យប្តឹងសាមញ្ញនេះ នៅក្នុងក្របខណ្ឌនៃនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ អាចស្តែងឡើងតាមរូបភាពពីរយ៉ាងៈ

- **ពាក្យប្តឹងទាមទារ ឬបណ្តឹងទាមទារ** មានន័យថា បណ្តឹងដែលធ្វើឡើងដោយជនណាមួយ ឬច្រើន (ជនរងគ្រោះ) ក្នុងគោលដៅដើម្បីដោះស្រាយ និងទាមទារសំណងជម្ងឺចិត្តពីបទល្មើសព្រហ្មទណ្ឌណាមួយទៅអាជ្ញាធរតុលាការ។ ដូចជា ៖ **ក** ប្តឹងទៅព្រះរាជាអាជ្ញាថា **ខ** បានប្រព្រឹត្តអំពើលួចម៉ូតូរបស់ខ្លួន ដើម្បីទាមទារម៉ូតូ និងការខូចខាតទាំងឡាយដែលបានរង។ ចំពោះពាក្យប្តឹងបែបនេះ គេហៅថា បណ្តឹងទាមទារ។
- **ពាក្យប្តឹងបរិហារ ឬបណ្តឹងបរិហារ** មានន័យថា បណ្តឹងទាំងឡាយណាដែលធ្វើឡើង ដោយជនណាមួយ ឬច្រើន ក្រៅពីជនរងគ្រោះក្នុងគោលដៅបង្ហាញពីបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ទៅអាជ្ញាធរតុលាការ ដែលមិនមានការទាមទារសំណងជម្ងឺចិត្តដូចនឹងបណ្តឹងទាមទារទេ។ ករណី ៖ **ក** បានប្តឹងទៅព្រះរាជអាជ្ញាថាមានអំពើជួញដូរគ្រឿងញៀនមួយបានកើតឡើងក្នុងក្លឹបកំសាន្តណាមួយ។ ចំពោះពាក្យប្តឹងបែបនេះគេហៅថា បណ្តឹងបរិហារ។

គួរកត់សម្គាល់ថា ចំពោះពាក្យប្តឹងសាមញ្ញវាពុំមានអានុភាពនាំឲ្យមានការចោទប្រកាន់ជាបទព្រហ្មទណ្ឌទេ[54] មានន័យថា នៅពេលដែលព្រះរាជអាជ្ញាទទួលពាក្យប្តឹងសាមញ្ញបែបនេះ

[54] មាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នោះព្រះរាជអាជ្ញានឹងធ្វើការថ្លែងទៅលើបទល្មើស នៅក្នុងពាក្យប្តឹងថាគួរចោទប្រកាន់ ឬមិនចោទប្រកាន់។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាបទល្មើស នោះមានចរិតលក្ខណៈដាច់ខាតចាំបាច់ឲ្យមានការចោទប្រកាន់លើលក្ខខណ្ឌនៃនីតិវិធី ហើយលក្ខខណ្ឌនៃនីតិវិធីនៃការបើការស៊ើបសង្កេត ត្រូវបានបំពេញនោះព្រះរាជអាជ្ញា នឹងបើកការស៊ើបសួរ ដោយប្តឹងសុំទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

**២-ការបើកការស៊ើបសួរតាមរយៈពាក្យប្តឹងដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជាធម្មតា ជនរងគ្រោះ ដែលទទួលរងព្យសនកម្ម ពីបទល្មើសព្រហ្មទណ្ឌ តែដាក់ពាក្យប្តឹងទៅអាជ្ញាធរតុលាការដើម្បីទាមទារសំណងជម្ងឺចិត្ត។ តែផ្ទុយទៅវិញ ប្រសិនបើព្រះរាជអាជ្ញាសម្រេចតម្កល់រឿងទុកឥតចាត់ការ នោះជនរងគ្រោះនឹងបាត់បង់ឱកាសក្នុងការទាមទារសំណងជម្ងឺចិត្ត។ ដោយមើលឃើញពីភាពចន្លោះប្រហោង នៃនីតិវិធិព្រហ្មទណ្ឌបែបនេះ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានបញ្ចូលនូវយន្តការថ្មីមួយសម្រាប់ជនរងគ្រោះ ដែលមានបំណងទាមទារ សំណងជម្ងឺចិត្តិពីបទល្មើស ព្រហ្មទណ្ឌ ក្នុងករណីដែលបទល្មើសនោះត្រូវបានព្រះរាជអាជ្ញាធ្វើការសម្រេចចិត្តតម្កល់រឿងទុកឥតចាត់ការ។ យន្តការថ្មីជាយន្តការចុងក្រោយ សម្រាប់ជនរងគ្រោះទាមទារសំណងជម្ងឺចិត្តនោះ គឺការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ។ ពាក្យបណ្តឹងដែលមានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ មានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញាដែលគេហៅថា **"ការដាក់ឲ្យបណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ"**[55] ។ ដូច្នេះចៅក្រមស៊ើបសួរនឹងចាប់ផ្តើមបំពេញកិច្ចចំពោះពាក្យប្តឹងបែបនេះជាអាទិ៍៖

**ក. ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា**

ក្រោយពីចៅក្រមស៊ើបសួរទទួលបានពាក្យប្តឹង ដោយមានការតាំងខ្លួន ជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរនឹងធ្វើការកត់សម្គាល់នូវការដាក់ពាក្យប្តឹងនេះ តាមរយៈដីកាមួយហើយបញ្ជូនបណ្តឹងនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា បន្ទាប់ពីបានឃើញពាក្យបណ្តឹងនោះ ហើយគាត់មិនអាចធ្វើការសម្រេចតម្កល់រឿងទុកឥតចាត់ការ

[55] មាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ម្តងទៀតនោះទេ មានន័យថាគាត់ត្រូវប្តឹងទៅចៅក្រមស៊ើបសួរវិញតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[56] ។ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាកិច្ចស៊ើបសួរអាចបើក ដោយមានការផុតរលត់នៃបណ្តឹងអាជ្ញា ឬអំពើដែលបានប្តឹងមិនមែនជាបទល្មើសព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរ ដោយសរសេរលិខិតរដ្ឋបាលមួយជាលាយលក្ខណ៍អក្សរ រួចដាក់ចូលក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នោះអំណាចនាំការសម្រេចបើកការសើបសួរគឺអាស្រ័យទៅលើចៅក្រមស៊ើបសួរ ដោយមិនមានឥទ្ធិពលពីលិខិតស្នើព្រះរាជអាជ្ញានោះទេ។

ហេតុនេះ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនបើកស៊ើបសួរ នោះចៅក្រមស៊ើបសួរនឹងចេញដីកាសម្រេចដែលមានសម្អាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឲ្យគាត់ធ្វើបណ្តឹងឧទ្ធរណ៍ចំពោះដីកានេះ ប្រសិនបើគាត់មិនសុខចិត្ត។ តែបើចៅក្រមស៊ើបសួរសម្រេចថាបើកការស៊ើបសួរ នោះចៅក្រមស៊ើបសួរក៏ចេញដីកាមួយដែរ ដែលមានសម្អាងហេតុច្បាស់លាស់ ហើយជូនដំណឹងដល់ព្រះរាជអាជ្ញា ដើម្បីឲ្យព្រះរាជអាជ្ញាប្រើប្រាស់សិទ្ធិរបស់គាត់ក្នុងការប្តឹងឧទ្ធរណ៍ចំពោះដីកានេះចំពោះករណីចាំបាច់។

ការសម្រេចបើកការស៊ើបសួរ ចំពោះពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង់ប្រាក់តម្កល់ទុកសម្រាប់ដំណើរនីតិវិធីនៃការស៊ើបសួរបានដែរ។

**ខ. ការបង់ប្រាក់តម្កល់**

នៅពេលដែលចៅក្រមស៊ើបសួរបានទទួលបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះ មុខចៅក្រមស៊ើបសួរនោះ ដោយយល់ឃើញថាការលំបាកចំពោះមុខ ចៅក្រមស៊ើបសួរនឹងកំណត់រយៈពេលសម្រាប់ឲ្យអ្នកប្តឹងបង់ចំនួនទឹកប្រាក់សម្រាប់ធានាលើកិច្ចនីតិវិធី។ បើមិនបង់ទឹកប្រាក់នេះតាមការកំណត់នោះទេ ចៅក្រមស៊ើបសួរនឹងប្រកាសថាមិនអាចទទួលបានចំពោះពាក្យប្តឹងប្រភេទនេះទេ។ ប៉ុន្តែលក្ខខណ្ឌនេះមិនមែនជាលក្ខខណ្ឌដាច់ខាតនោះទេ

[56] មាត្រា ៥ និង មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ព្រោះបើពិចារណាលើធនធានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរអាចសម្រេចដោយអនុញ្ញាតមិនបាច់បង់ក៏បាន។

កាលបើមានការសម្រេចពីការឲ្យបង់ប្រាក់ ហើយបើមានការបង់ប្រាក់នេះ ដើម្បីធានាតម្លាភាពលើចំនួនទឹកប្រាក់ និងជាសញ្ញាសំគាល់ថាមានការបង់ប្រាក់រួចនោះ បង្កាន់ដៃបង់ប្រាក់ត្រូវតែចេញឲ្យជននោះដែលមានហត្ថលេខារបស់ប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។ ប្រាក់នេះត្រូវរក្សាទុកគណនីពិសេសដែលបើកក្នុងធនាគារ ឬរក្សាទុកកន្លែងសុវត្ថិភាពតាមការជ្រើសរើសរបស់ប្រធានតុលាការ និងព្រះរាជអាជ្ញាដើម្បីការពារការបាត់បង់។ ប្រាក់នេះតម្កល់នឹងបង្វិលទៅអ្នកប្ដឹងវិញនៅពេលចប់កិច្ចស៊ើបសួរ។

**គ. ការផ្តន្ទាទោសចំពោះសំណាងរដ្ឋប្បវេណី**

គោលការណ៍នៃការដាក់ឲ្យបណ្ដឹងអាជ្ញាមានចលនាដោយជនរងគ្រោះនេះ មិនត្រឹមតែមានផលប្រយោជន៍ឲ្យជនរងគ្រោះមានឱកាសក្នុងការទាមទារសំណងជម្ងឺចិត្តប៉ុណ្ណោះទេ ហើយវាក៏បានផ្ដល់ផលប្រយោជន៍សម្រាប់សង្គមដែរ នៅពេលដែលបទល្មើសព្រហ្មទណ្ឌត្រូវបានរកឃើញ។ ប៉ុន្តែផ្ទុយទៅវិញប្រសិនបើការបើកការស៊ើបសួរ ដោយធ្វើឡើងតាមរយៈពាក្យប្ដឹងនេះ ហើយបញ្ចប់ទៅវិញដោយដីការដំណោះស្រាយលើកលែងការចោទប្រកាន់(ដីកាលើកលែងចោទប្រកាន់) ហើយចៅក្រមស៊ើបសួរយល់ថា នីតិវិធិនេះស្តែងឡើងដោយរំលោភ ឬអូសបន្លាយពេលវេលានោះចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាមួយ ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង់ប្រាក់ពិន័យរដ្ឋប្បវេណី[57] ។ ដីកានេះត្រូវជូនដំណឹងដល់សាមីខ្លួនជាបន្ទាន់ ដើម្បីជាឱកាសក្នុងការប្ដឹងឧទ្ធរណ៍ទៅសភាស៊ើបសួរ។

ម្យ៉ាងទៀត ដើមបណ្ដឹងរដ្ឋប្បវេណី នឹងត្រូវប្រឈមមុខនឹងការប្ដឹងទាមទារជូសជុលសំណងពីបុគ្គលដែលមានឈ្មោះនៅក្នុងបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះធ្វើឡើងដោយរំលោភឬអូសបន្លាយពេលវេលាដែលធ្វើឲ្យខូចប្រយោជន៍ដល់ភាគី ជាពិសេសជនត្រូវចោទ។ ជនដែលមានបំណងចង់ប្ដឹងទាមទារសំណងជម្ងឺចិត្តក្នុងករណីនេះ

[57] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

គាត់ត្រូវដាក់ពាក្យប្ដឹងទៅតុលាការជាន់ដំបូង ដែលរឿងត្រូវបានស៊ើបសួរ ដោយបញ្ជាក់ឲ្យច្បាស់លាស់ថា ពាក្យប្ដឹងនោះធ្វើឡើងដោយរំលោភ ឬអូសបន្លាយពេលវេលាដែលធ្វើឲ្យខូចប្រយោជន៍របស់ខ្លួន[58]។

១.១.លក្ខខណ្ឌនៃការបើកការស៊ើបសួរក្នុងបទល្មើសព្រហ្មទណ្ឌ

ទោះបីជាការបើកការស៊ើបសួរ អាចធ្វើឡើងតាមវិធីពីរយ៉ាងដូចដែលបានបង្ហាញខាងលើក៏ដោយ ក៏ការបើកការស៊ើបសួរតាមវិធីទាំងពីរត្រូវបំពេញលក្ខខណ្ឌមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចង្អុលបង្ហាញ។ តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ លក្ខខណ្ឌនៃការបើកស៊ើបសួរត្រូវបានបែងចែកជាប្រភេទបទល្មើសដែលក្នុងនោះគេឃើញថា ការបើកការស៊ើបសួរអាចធ្វើឡើងក្នុងករណីបទឧក្រិដ្ឋ និងបទមជ្ឈិម។

**ក. លក្ខខណ្ឌនៃការបើកការស៊ើបសួរនៃបទឧក្រិដ្ឋ**

ការបើកការស៊ើបសួរ គឺជានីតិវិធីមួយដែលមានលក្ខណៈវែងអន្លាយ និងស្មុគស្មាញ ព្រោះនៅក្នុងកាលប្បវត្តិនៃដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរនឹងប្រើប្រាស់វិធានការជាច្រើនដែលបានចង្អុលបង្ហាញដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ ហេតុនេះចំពោះបទឧក្រិដ្ឋ បើព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់នោះ គាត់ត្រូវតែ ជ្រើសរើសយកនីតិវិធីនៃការចោទប្រកាន់ដោយការស៊ើបសួរ[59]។

ការបើកការស៊ើបសួរត្រូវតែធ្វើដោយធ្វើខានមិនបានចំពោះបទឧក្រិដ្ឋ[60] ព្រោះបទឧក្រិដ្ឋជាបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ ហើយអ្នកដែលបានចោទប្រកាន់ចំពោះបទល្មើសនេះ នឹងអាចប្រឈមមុខនឹងការដាក់ពន្ធនាគារច្រើនឆ្នាំ និងដើម្បីជៀសវៀងនឹងការជំនុំជម្រះធ្វើឡើងដោយមានការភ័នច្រឡំ ដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ។ ហេតុនេះលក្ខខណ្ឌនៃការបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ គឺជាលក្ខខណ្ឌចាំបាច់ និងដាច់ខាតខុសពីករណីបទមជ្ឈិម ដែលព្រះរាជអាជ្ញាអាចធ្វើការថ្លឹងថ្លែងធ្វើការចោទប្រកាន់ថាគួរបើកការស៊ើបសួរ ឬចាត់នីតិវិធីចោទប្រកាន់ផ្សេងៗ។

[58] មាត្រា ១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[59] មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[60] មាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

## ខ. លក្ខខណ្ឌនៃការបើកការស៊ើបសួរនៃបទមជ្ឈិម

ចំពោះបទមជ្ឈិម ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានផ្តល់ជាឆន្ទានុសិទ្ធិដល់ព្រះរាជអាជ្ញាក្នុងការថ្លឹងថ្លែងសម្រេចធ្វើការចោទប្រកាន់បើកការស៊ើបសួរ ឬប្រើការចោទប្រកាន់តាមនីតិវិធីផ្សេង [61] ។ ប៉ុន្តែព្រះរាជអាជ្ញាគួរតែបើកការស៊ើបសួរចំពោះបទមជ្ឈិម ទាំងឡាយណាដែលមានលក្ខណៈស្មុគស្មាញ មិនមានភស្តុតាងគ្រប់គ្រាន់ ឬជនល្មើសដែលទទួលរងការចោទប្រកាន់ស្ថិតក្នុងស្ថានភាពជាអញ្ញាតជនដែលគេអាចនិយាយថាសំណុំរឿងមិនទាន់មូល។ ជាក់ស្តែងដូចនៅក្នុងដំណាក់កាលនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម ប្រសិនបើចៅក្រមជំនុំជម្រះយល់ឃើញថាសំណុំរឿងដែលព្រះរាជអាជ្ញាបញ្ជូនមកខ្លួនដែលមានលក្ខណៈស្មុគស្មាញ សំណុំរឿងមិនទាន់មូលនោះ ចៅក្រមជំនុំជម្រះ នឹងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាវិញដើម្បីបើកការស៊ើបសួរក្នុងករណីដែលគាត់យល់ថាវាមិនធូនល្មមនឹងអាចជំនុំជម្រះបានទេនោះ។

ជារួមមកការបើកការស៊ើបសួរ អាចធ្វើឡើងចំពោះបទល្មើសពីរ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ហើយដើម្បីឲ្យការបើកការស៊ើបសួរមាននីត្យានុកូលនោះព្រះរាជអាជ្ញាបំពេញឲ្យបានច្បាស់លាស់នូវទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

### ១.២. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ពេលដែលព្រះរាជអាជ្ញាសម្រេចចោទប្រកាន់តាមរយៈការស៊ើបសួរនោះ ព្រះរាជអាជ្ញាត្រូវរៀបចំលិខិតនីតិវិធី គឺដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរឲ្យបំពេញកិច្ចស៊ើបសួរ។ ព្រះរាជអាជ្ញាត្រូវបំពេញឲ្យបានច្បាស់លាស់នូវទម្រង់ការនៃដីកានេះដែលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចង្អុលបង្ហាញទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលបានកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន[62]។

---

[61] មាត្រា ៩៥ និងមាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[62] មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់អំពីលក្ខណៈដាច់ខាតនៃទម្រង់ការនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលព្រះរាជអាជ្ញាដែលត្រូវគោរព មានន័យថាប្រសិនបើចំណុចនៃទម្រង់ការនៃដីកានេះមិនបានបំពេញ នោះដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវទុកជាមោឃៈ[63] ដោយសភាស៊ើបសួរដែលទទួលពាក្យសុំមោឃភាពពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី[64]។

ជាគោលការណ៍ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបានលុះត្រាតែមានដីការសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការអមសាលាដំបូងជាមុនសិន។

ជាក់ស្តែងកាលពីថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ វេលាម៉ោង ១៧: ០០ នាទី នៅចំណុចផ្ទះឈ្មោះ ក ស្ថិតនៅភូមិទួលស្វាយ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ឈ្មោះ ក នេះ បានទាស់សំដីគ្នាជាមួយឈ្មោះ ខ ហើយឈ្មោះ ខ ក៏បានក្របួចកអាវឈ្មោះ ក ពេលនោះឈ្មោះ គ ក៏បានចូលទៅឃាត់ តែត្រូវឈ្មោះ ខ មិនព្រមស្តាប់ ឃើញដូចនោះឈ្មោះ ឃ ចូលទៅឃាត់បន្ត តែមិនព្រមស្តាប់ដដែល ក៏កើតជារឿងប្រតាយប្រតប់គ្នា ហើយពេលកំពុងប្រតាយប្រតបគ្នានោះ ឈ្មោះ ខ បានទៅទាញកាំបិតប៉ុងតោពីក្រោមផ្ទះកាប់ត្រូវកញ្ជឹងករបស់ឈ្មោះ ក ភ្លាមនោះឈ្មោះ ក មិនទាន់មានការឈឺចាប់ទេក៏នៅបន្តវាយគ្នាទៀត មួយសន្ទុះក្រោយមកឈ្មោះ ក ហូរឈាមច្រើនពេកក៏សន្លប់លើដីក៏ត្រូវក្រុមគ្រួសារដឹកមកមន្ទីរពេទ្យបង្អែកស្រុក និងបញ្ជូនបន្តទៅមន្ទីរពេទ្យរាជធានីភ្នំពេញ។

**អំពើខាងលើជាបទល្មើស៖** ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅភូមិ ទួលស្វាយ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទិ២៤ ខែ មេសា ឆ្នា ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៨ ចំណុច ២ នៃក្រមព្រហ្មទណ្ឌ។

បានឃើញមាត្រា ៨៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

**សម្រេច**

ការបើកការស៊ើបសួរលើអង្គហេតុខាងលើ និង៖

- ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យលើ៖

[63] មាត្រា ៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[64] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

១. ឈ្មោះ ខ អាយុ ២៤ ឆ្នាំ ពីបទ៖ **ហិង្សា**ដោយមានស្ថានទម្ងន់ទោសដោយប្រើប្រាស់អាវុធ ប្រព្រឹត្តនៅភូមិទួលស្វាយ ឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល កាលពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២១៨ចំណុច ២ នៃក្រមព្រហ្មទណ្ឌ។

- ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ៖
- ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្នលើ៖

១. ឈ្មោះ ខ ភេទ ប្រុស អាយុ ២៤ ឆ្នាំ ដើម្បីបញ្ចប់បទល្មើស និងដើម្បីធានារក្សាជននោះទុកជូនតុលាការតាមនីតិវិធីច្បាប់។

ជារួមអយ្យការអមតុលាការជាន់ដំបូងខេត្តកណ្តាល នៅពេលដែលចេញដីកាបញ្ជូនរឿងឲ្យស៊ើបសួរត្រូវតែរៀបចំលិខិតទៅតាមទម្រង់ និងនីតិវិធីដែលបានរៀបរាប់ដូចខាងលើ។

### ១.៣. ការចូលរួមរបស់អង្គការអយ្យការក្នុងការស៊ើបសួរ

ទោះបីជាការបើកការស៊ើបសួរ ព្រះរាជអាជ្ញាត្រូវប្រគល់សំណុំរឿងទាំងអស់ទៅចៅក្រមស៊ើបសួរហើយក្តី ក៏មិនមែនន័យថាព្រះរាជអាជ្ញាអស់សិទ្ធិ ទៅលើសំណុំរឿងនៃរឿងក្តីនោះដែរ។ ប៉ុន្តែការចូលរួមរបស់ព្រះរាជអាជ្ញាមិនមានលក្ខណៈទូលំទូលាយ ដូចទៅនឹងចៅក្រមស៊ើបសួរទេព្រោះថាព្រះរាជ្ញាពុំមានសិទ្ធិស្រាវជ្រាវដូចចៅក្រមស៊ើបសួរទេ គឺព្រះរាជអាជ្ញាគ្រាន់តែជាអ្នកចូលរួមសកម្មភាពស៊ើបសួររបស់ចៅក្រមស៊ើបសួរ។

- .ការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលា ព្រះរាជអាជ្ញាអាចពិនិត្យមើលសំណុំរឿងស៊ើបសួរ ឬស្នើសុំឲ្យបញ្ជូនសំណុំរឿងឲ្យមកពិនិត្យបាន។ នៅពេលដែលចៅក្រមស៊ើបសួរបញ្ជូនទៅព្រះរាជអាជ្ញានោះចៅក្រមនេះត្រូវចេញដីកាបញ្ជូនសំណុំរឿងនោះ [65] ។ដីកានេះមានឈ្មោះថាដីកាបញ្ជូនរឿងឲ្យពិនិត្យក្រោយពេលដែលព្រះរាជអាជ្ញាបានពិនិត្យទៅលើសំណុំរឿងហើយ ហើយយល់ឃើញថាមានប្រយោជន៍ណាមួយដល់នីតិវិធីស៊ើបសួរនោះ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចការណាមួយដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

[65] មាត្រា ២៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញានេះអាចជាការឲ្យពិនិត្យភស្តុតាង ការសាកសួរសាក្សីការសុំឲ្យឃុំខ្លួនការធ្វើកោសល្យវិច័យឬការធ្វើប្រតិកោសល្យវិច័យ។ យ៉ាងណាមិញ បន្ទាប់ពីព្រះរាជអាជ្ញា បានពិនិត្យលើសំណុំរឿងដែលបាន បញ្ជូនមកខ្លួនរួចហើយ ព្រះរាជអាជ្ញាមានកាតកិច្ចបង្វិលសំណុំរឿងនោះទៅឲ្យចៅក្រមស៊ើបសួរវិញក្នុងថិរវេលា២៤ ម៉ោង [66] ។ ថិរវេលា ២៤ ម៉ោងនេះ គិតតែម៉ោងធ្វើការតែប៉ុណ្ណោះ ហើយបើសិនជាថិរវេលាដែលបានកំណត់នេះ ផុតកំណត់ចំថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ឬថ្ងៃបុណ្យ ត្រូវអូសបន្លាយរហូតដល់ថ្ងៃទីមួយ ដែលជាថ្ងៃបើកធ្វើការវិញ [67] ។ ការកំណត់ថិរវេលាជាក់លាក់សម្រាប់ព្រះរាជអាជ្ញាបែបនេះ ដើម្បីជៀសវៀងការយឺតយ៉ាវ និងការរាំងស្ទះដល់នីតិវិធីនៃការស៊ើបសួរ។

ចៅក្រមស៊ើបសួរ នៅពេលដែលទទួលបានពាក្យស្នើសុំនេះ ហើយ គាត់មានសិទ្ធិបីយ៉ាង ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ។

- **សិទ្ធិទីមួយ** គឺគាត់ធ្វើការ តាមស្នើសុំរបស់ព្រះរាជអាជ្ញា ហើយត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាវិញក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់តាំងពីថ្ងៃស្នើសុំ។
- **សិទ្ធិទីពីរ** ចៅក្រមស៊ើបសួរបើមិនព្រមតាមការស្នើសុំនោះទេ គាត់ក៏ត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១៥ ថ្ងៃ ផងដែរ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវបញ្ជាក់ក្នុងសំអាងហេតុ និងមូលហេតុឲ្យបានច្បាស់លាស់ ហើយត្រូវជូនដំណឹងពីដីកានេះទៅព្រះរាជអាជ្ញាឲ្យបានឆាប់រហ័សបំផុត ដើម្បីអាចឲ្យព្រះរាជអាជ្ញាធ្វើការប្តឹងទៅឧទ្ធរណ៍ទៅនឹងដីកាសម្រេចនោះ។ ជាចុងក្រោយ ចៅក្រមស៊ើបសួរមានសិទ្ធិមិនឆ្លើយតបអ្វីទាំងអស់ទៅនឹងការស្នើសុំរបស់ព្រះរាជអាជ្ញា។ នៅក្នុងករណីនេះព្រះរាជអាជ្ញាមានសិទ្ធិប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរបើកាលណាក្នុងរយៈពេល ១៥ ថ្ងៃគិតចាប់ពីថ្ងៃស្នើសុំចៅក្រមស៊ើបសួរមិនបានឆ្លើយតបវិញ។

១.៣.១ .ការសួរ និង ស្តាប់ចម្លើយ

ព្រះរាជអាជ្ញាអាចមានវត្តមាននៅក្នុងពេលសួរចម្លើយជនត្រូវចោទ ឬនៅពេលស្តាប់ចម្លើយដើមបណ្តឹងរដ្ឋបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សី ឬនៅក្នុងពេលសួរតទល់ជាមួយចៅក្រមស៊ើបសួរបាន។ នៅដំណាក់កាលនេះព្រះរាជអាជ្ញាមានសិទ្ធិសួរសំណួរសួរបានផងដែរ

[66] មាត្រា ១៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[67] មាត្រា ២៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

បើកចៅក្រមស៊ើបសួរមិនអនុញ្ញាតចំពោះការលើកសំណួររបស់ព្រះរាជអាជ្ញាទេនោះ ក្រឡាបញ្ជីត្រូវចុះនិទ្ទេសស្តីពីការមិនអនុញ្ញាតនេះទៅក្នុងកំណត់ហេតុ[68]។

**១. ការវាយតម្លៃអំពីស្ថានភាពនៃសំណុំរឿង**

បន្ទាប់ពីទទួលបានបណ្តឹងអាជ្ញាតាមរយៈការប្តឹងបរិហារ ឬកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ មុននិងសម្រេចធ្វើការចោទប្រកាន់នោះព្រះរាជអាជ្ញាត្រូវតែធ្វើការវាយតម្លៃទៅលើស្ថានភាពនៃអង្គហេតុដែលមានក្នុងសំណុំរឿង ព្រមទាំងភស្តុតាង ,ធាតុផ្សំនៃបទល្មើសដែលប្រមូលបានជាមុនសិន។ ការវាយតម្លៃនៃសំណុំរឿងនេះ គឺជានីតិវិធីមួយដែលតម្រូវឱ្យតំណាងអយ្យការធ្វើការថ្លឹងថ្លែងថាតើស្ថានភាព នៃបទល្មើសគោរពតាមលក្ខខណ្ឌ នៃការបញ្ជូនរឿងឱ្យស៊ើបសួរហើយឬនៅ? ក្នុងករណីដែលលក្ខខណ្ឌត្រូវបានបំពេញហើយនោះ ព្រះរាជអាជ្ញានឹងសម្រេចចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។

**២. ការរៀបចំតាក់តែងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

ដើម្បីរៀបចំតាក់តែងដីកាស្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឱ្យបានល្អ ហើយត្រូវតែរៀបចំឈ្មោះជនល្មើស ឬជនសង្ស័យ និងរៀបចំអង្គហេតុ។

ការរៀបចំឈ្មោះជនល្មើស ឬជនសង្ស័យ សំដៅទៅដល់ការរៀបរាប់ឈ្មោះ ជនល្មើស ឬជនសង្ស័យទៅតាមលំដាប់លំដោយនៃការប្រព្រឹត្តបទល្មើស និងការរៀបរាប់អំពីសាវតាជាតិរបស់ជននោះ (បើមាន) តែក្នុងករណីដែលមិនស្គាល់ជនល្មើសអាចដាក់ថា **អញ្ញតជន** បាន។ ចំណែកឯការរៀបចំអង្គហេតុវិញ យើងត្រូវពិនិត្យទៅលើឯកសារមួយចំនួនដូចជា៖

-របាយការណ៍សំយោគរបស់សមត្ថកិច្ច (OPJ) ឬបណ្តឹងរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី។

-ចម្លើយបំភ្លឺរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី,សាក្សី និងជនសង្ស័យ

-ភស្តុតាងជឯកសារផ្សេងៗក្នុងសំណុំរឿង។

[68] មាត្រា ១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ជាគោលការណ៍ ក្នុងការរៀបចំអំពីអង្គហេតុ យើងត្រូវធ្វើយ៉ាងណាឱ្យអង្គហេតុនោះមានលក្ខណៈគ្រប់គ្រាន់ និងស៊ីសង្វាក់ទៅនឹងមាត្រាច្បាប់ដែលកំណត់អំពីបទល្មើសដែលត្រូវចោទប្រកាន់ បញ្ជាក់ឱ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទ និងទីកន្លែងប្រព្រឹត្តបទល្មើស។ បន្ទាប់ពីតំណាងអយ្យការរៀបចំតាក់តែ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររួចហើយ ត្រូវធ្វើការជូនដំណឹងទៅដល់ភាគី។

**៣. ការជូនដំណឹងអំពីកាសម្រេចចេញដីកាសន្និដ្ឋានឱ្យស៊ើបសួរ**

នៅក្នុងច្បាប់នីតិវិធី យើងពុំឃើញមានបញ្ញត្តិជាកាតព្វកិច្ចថា តំណាងអយ្យការត្រូវតែជូនដំណឹងទៅភាគីអំពីការសម្រេចចេញដីកាសន្និដ្ឋានឱ្យស៊ើបសួរទេតែជាទូទៅរាល់សេចក្ដីសម្រេចរបស់អយ្យការដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍របស់ភាគីតម្រូវអោយមានការជូនដំណឹងដល់ភាគី។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាសេចក្ដីសម្រេចរបស់តំណាងអយ្យការក្នុងការបញ្ជូនរឿងឱ្យទៅស៊ើបសួរដល់ចៅក្រមស៊ើបសួរ ដូចនេះការជូនដំណឹងអំពីដីការនេះនឹងបានផ្ដល់ឱ្យជនរងគ្រោះអំពីចំណាត់ការលើបណ្ដឹងរបស់ខ្លួន ហើយម្យ៉ាងទៀតសម្រាប់ជនជាប់ចោទវិញនឹងបានដឹងលក្ខខណ្ឌនៃការចោទប្រកាន់មកលើខ្លួន និងជាផលប្រយោជន៍ក្នុងការត្រៀមខ្លួននៅក្នុងដំណាក់កាលចំពោះមុខចៅក្រមស៊ើបសួរ។

១.៣.២ .ការប្រគល់វត្ថុដែលចាប់យកទៅម្ចាស់ដើមវិញ

ព្រះរាជអាជ្ញាមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុដែលចាប់បានទៅឲ្យម្ចាស់ដើមវិញ បានតែនៅក្នុងដំណាក់នៃការស៊ើបអង្កេតតែប៉ុណ្ណោះ[69]។ នៅពេលដែលសំណុំរឿងបានទៅដល់ដៃចៅក្រមស៊ើបសួរហើយ ព្រះរាជអាជ្ញាលែងមានសមត្ថកិច្ចនេះទៀតហើយ ព្រោះថារាល់ការសម្រេចទាក់ទងនឹងកិច្ចការនេះត្រូវធ្វើឡើងដោយចៅក្រមស៊ើបសួរវិញ។

នៅដំណាក់កាលដែលមិនទាន់ចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់វត្ថុទាំងឡាយណាដែលចាប់បានទៅឲ្យម្ចាស់ដើមវិញ ដោយឆន្ទានុសិទ្ធិ ឬមានអ្នកប្ដឹង។ មុនពេលដែលធ្វើការសម្រេចនេះ

[69] មាត្រា ១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា ដើម្បីទទួលមតិយោបល់ [70] ។ ទោះបីជាព្រះរាជអាជ្ញាមានយោបល់ផ្ទុយពីចៅក្រមស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរមានសិទ្ធិចេញដីកាសម្រេចដោយឆន្ទានុសិទ្ធិរបស់ខ្លួនមួយដោយមានសម្អាងហេតុ រួចឲ្យដំណឹងជាបន្ទាន់ទៅព្រះរាជអាជ្ញា ព្រមទាំងអ្នកប្ដឹង និងមេធាវីអ្នកប្ដឹងប្រសិនបើមាន។

នៅក្នុងករណីខាងលើ ព្រះរាជអាជ្ញា បើយល់ឃើញថាការសម្រេចរបស់ចៅក្រមស៊ើបសួរធ្វើឡើងដោយមិនសមស្រប ព្រះរាជអាជ្ញាអាចប្ដឹងឧទ្ធរណ៍ចំពោះដីកាសម្រេចនោះបានក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង[71]។

១.៣.៣ .ដំណើរការ នៃការឃុំខ្លួន

ក្នុងពេលដែលឃុំខ្លួន ជនត្រូវចោទ ព្រះរាជអាជ្ញាអាចសុំឲ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ហើយចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ០៥ (ប្រាំ)ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេលប្រាំថ្ងៃនេះទេ ព្រះរាជអាជ្ញាអាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[72]។

១.៣.៤ .ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

នៅពេលដែលជនត្រូវចោទកំពុង អនុវត្តវិធានការនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ព្រះរាជអាជ្ញាមានសិទ្ធិសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការនេះបាន។ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវជូនព័ត៌ដល់ព្រះរាជអាជ្ញាឲ្យបានឆាប់បំផុត។ បើផុតរយៈពេល ០៥ (ប្រាំ) ថ្ងៃ ចៅក្រមស៊ើបសួរមិនសម្រេចទេនោះ ព្រះរាជអាជ្ញាអាចធ្វើពាក្យបណ្ដឹងទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ [73] ។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរក៏ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចដោយមានពាក្យស្នើសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការពីជនត្រូវចោទ។

១.៣.៥.ដីកាសន្និដ្ឋានស្ថាពរបញ្ចប់ការស៊ើបសួររបស់អង្គការមហាអយ្យការ

---

[70] មាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[71] មាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[72] មាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[73] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅពេលដែលកិច្ចស៊ើបសួរចប់សព្វគ្រប់ ចៅក្រមស៊ើបសួរនឹងបិទការស៊ើបសួររបស់ខ្លួនតាមរយៈដីកាដំណោះស្រាយ[74]។ ប៉ុន្តែមុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងអំពីការបញ្ចប់ ការស៊ើបសួររបស់ខ្លួននេះទៅដល់ជនត្រូវចោទដើមបណ្តឹងរដ្ឋប្បវេណី មេធាវីជាពិសេសចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញាផ្ទាល់។

ការជូនដំណឹងទៅព្រះរាជអាជ្ញា គឺជាកាតព្វកិច្ចរបស់ចៅក្រមស៊ើបសួរដែលត្រូវបំពេញ។ ចៅក្រមស៊ើបសួរមិនត្រូវបិទការស៊ើបសួរដោយស្ងាត់ៗនោះទេ គឺត្រូវតែជូនដំណឹងដល់ភាគីនៃរឿងក្តីឲ្យបានដឹង ក្នុងគោលបំណងដើម្បីឲ្យភាគីស្នើសុំទៅចៅក្រមស៊ើបសួរ ហើយបំពេញកិច្ចការមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ហើយក៏អាចឲ្យធ្វើការរៀបចំមធ្យោបាយការពារខ្លួនផ្សេងទៀតបានទាន់ពេលវេលាផងដែរ។

ទម្រង់ការនៃការជូនដំណឹងចៅក្រមស៊ើបសួរត្រូវធ្វើតាមរយៈលិខិតរដ្ឋបាលមួយប្រភេទ មានឈ្មោះថាលិខិតជូនដំណឹង ឬជូនព័ត៌មាន។

ក្រោយពីជូនដំណឹងរយៈពេលពីរថ្ងៃរួចមក ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ តាមរយៈដីកាមួយប្រភេទ គឺដីកាបញ្ជូនរឿងឲ្យពិនិត្យ។ ចៅក្រមស៊ើបសួរធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដោយសារមានហេតុផលពីរយ៉ាង៖

- ដើម្បីឲ្យព្រះរាជអាជ្ញាពិនិត្យមើលសំណុំរឿង ថាតើគួរតែមានការយល់ស្របដូចចៅក្រមស៊ើបសួរដែរ ឬមួយក៏ចង់ឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចណាមួយទៀតបើយល់ថាមានប្រយោជន៍។
- ដើម្បីឲ្យព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរលើសំណុំរឿងនោះ។

ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ចៅក្រមស៊ើបសួរត្រូវបំពេញកិច្ចណាមួយដែលចាំបាច់នោះព្រះរាជអាជ្ញាត្រូវធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរដើម្បីបំពេញកិច្ច ដូចដែលមានចែងក្នុងមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។

បើព្រះរាជអាជ្ញាយល់ឃើញថា ការស៊ើបសួរអាចបញ្ចប់បានហើយ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ

[74] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ប្រសិនបើជនត្រូវចោទនៅក្នុងឃុំ និង ០១ (មួយ) ខែ ប្រសិនបើជនត្រូវចោទនៅក្រៅឃុំ [75] ។ ដីកានេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងបញ្ជាក់ពីសម្អាងហេតុ និងមូលហេតុឲ្យបានច្បាស់លាស់។ ដីកានេះត្រូវចេញដោយព្រះរាជអាជ្ញា ហើយនៅក្នុងផ្នែកនៃសេចក្ដីសម្រេចនៃដីកានេះ ព្រះរាជអាជ្ញាអាចប្ដឹងឲ្យចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងចោទប្រកាន់។ ដីកានេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។

ក្រោយពីធ្វើការសន្និដ្ឋានស្ថាពរហើយ ព្រះរាជអាជ្ញាត្រូវបញ្ជូនដីកានេះដាក់ចូលក្នុងសំណុំរឿងហើយផ្ញើជូនទៅចៅក្រមស៊ើបសួរវិញ។ បន្ទាប់ពីទទួលបានសំណុំរឿងពីព្រះរាជអាជ្ញា ដោយភ្ជាប់មកជាមួយដីកាសន្និដ្ឋានស្ថាពរហើយនោះ ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចណាមួយបានទៀតនោះទេ ហើយត្រូវតែបិទការស៊ើបសួរដោយចេញដីកាដំណោះស្រាយតែម្ដង។

ដីកាដំណោះស្រាយនេះ គឺជាដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ក្នុងការសម្រេចបិទកិច្ចស៊ើបសួររបស់ខ្លួន។ ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនេះស្ដែងឡើងតាមរូបភាពពីគឺៈ

**១. ដីកាបញ្ជូនទៅជំនុំជម្រះ ឬ**

**២. ដីកាលើកលែងចោទប្រកាន់។**

ការចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចដោយលក្ខណៈឯករាជ្យ និងដោយឆន្ទានុសិទ្ធិរបស់ខ្លួន ទោះបីជាមានការចង្អុលបង្ហាញព្រះរាជអាជ្ញានៅក្នុងដីកាសន្និដ្ឋានស្ថាពរក៏ដោយ ព្រោះថាចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានដោយព្រះរាជអាជ្ញាទេ។ មានន័យថា ប្រសិនបើនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាធ្វើការលើកលែងចោទប្រកាន់ក៏ដោយ ក៏នៅក្នុងដីកាដំណោះស្រាយចៅក្រមស៊ើបសួរក៏នៅតែមានសិទ្ធិក្នុងការចោទប្រកាន់ដដែល "**ដោយដីកាបញ្ជូនទៅជំនុំជម្រះ**" ប្រសិនបើអង្គហេតុដែលចៅក្រមស៊ើបសួរធ្វើការស៊ើបសួរនោះ គាត់យល់ថាអង្គហេតុនោះបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ។ ម្យ៉ាងវិញទៀត បើសិនជាព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានស្ថាពរក៏ដោយ

[75] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ក៏ចៅក្រមស៊ើបសួរនៅតែមានសិទ្ធិសម្រេចលើកលែងចោទប្រកាន់ ដោយដីកាដំណោះស្រាយរបស់ខ្លួនដែលដីកានោះគេហៅថា "ដីកាលើកលែងចោទប្រកាន់" បើកាលណាចៅក្រមស៊ើបសួរយល់ឃើញថា អង្គហេតុដែលគាត់ធ្វើការស៊ើបសួរនោះ គាត់យល់ថាអំពើប្រព្រឹត្តមិនមែនជាបទល្មើស ឬជនប្រព្រឹត្តបទល្មើសនោះនៅតែមិនស្គាល់ ឬនៅតែគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ទៅលើជនត្រូវចោទ។ ហេតុនេះនៅក្នុងកិច្ចស៊ើបសួរ បើចៅក្រមស៊ើបសួរស្រាវជ្រាវទៅឃើញថា សំណុំរឿងនៅតែមានមូលដ្ឋានសមស្រប ដើម្បីចោទប្រកាន់ទៅលើជនត្រូវចោទ នោះចៅក្រមស៊ើបសួរនឹងធ្វើការលើកលែងចោទប្រកាន់ តាមរយៈដីកាដំណោះស្រាយ។

បន្ទាប់ពីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយរបស់ខ្លួនរួចហើយ គាត់ត្រូវធ្វើការជូនដំណឹងដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា[76] ដើម្បីទុកឱកាសដល់ព្រះរាជអាជ្ញាប្រើសិទ្ធិរបស់ខ្លួនក្នុងការធ្វើពាក្យប្តឹងឧទ្ធរណ៍ ប្រសិនបើគាត់យល់ថា មានចំណុចមិនប្រក្រតីណាមួយ នៅក្នុងដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។

**២.ការបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ដើម្បីចាប់ផ្តើមនីតិវិធីនៃការបញ្ជូនរឿងទៅជម្រះផ្ទាល់បាន ដំបូងព្រះរាជអាជ្ញាត្រូវចេញដីកាមួយដែលមានឈ្មោះថា **ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់**[77]។ ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ គឺជាបញ្ជាឲ្យជនជាប់ចោទឲ្យចូលទៅ បង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង[78]។ លក្ខខណ្ឌដើម្បីដំណើរការនីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាត្រូវគោរពលក្ខខណ្ឌជាច្រើន ដែលត្រូវបានកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ ប៉ុន្តែ មុនឈានទៅដល់ការបកស្រាយអំពីលក្ខខណ្ឌដែលត្រូវបំពេញនៃនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ យើងគួរធ្វើការសិក្សាទៅលើនីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ នៅក្នុងក្របខណ្ឌនៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៩៣ ជាមុខសិន។

---

[76] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[77] មាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[78] មាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

នៅក្នុងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ រដ្ឋអាជ្ញាក៏អាចប្រើប្រាស់នីតិវិធីនៃការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះផ្ទាល់ក្នុងការចោទប្រកាន់ទៅបទល្មើសព្រហ្មទណ្ឌ របស់គាត់បានផងដែរ។ មាត្រា ៦១ នៃច្បាប់នេះបានកំណត់ថា "កាលណាក្នុងករណីបទល្មើសមជ្ឈិមរដ្ឋអាជ្ញាអាចឬចោទប្រកាន់ជនល្មើស ហើយបញ្ជូនផ្ទាល់ទៅតុលាការព្រហ្មទណ្ឌដើម្បីជំនុំជម្រះ"។ បទមជ្ឈិមដែលបានលើកឡើងដោយច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ នេះ នៅក្នុងការប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ គឺមិនសំដៅជាទូទៅដល់បទល្មើសមជ្ឈិមទេ មានន័យថា រដ្ឋអាជ្ញាអាចធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅលើបទល្មើសមជ្ឈិមទាំងឡាយណាដែលត្រូវរងការផ្តន្ទាទោសអតិបរមា មិនលើសពីមួយឆ្នាំ[79]។ ដោយឡែក ចំពោះបទល្មើសលហុវិញ រដ្ឋអាជ្ញាក៏អាចចោទប្រកាន់តាមនីតិវិធីនេះបានដែរ ហើយចំពោះបទលហុនេះរដ្ឋអាជ្ញាអាចចាប់ផ្តើមចោទប្រកាន់ដោយប្រើប្រាស់នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ។ ដោយឡែក នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ក៏បានដាក់បញ្ចូលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ដែរ ប៉ុន្តែនៅក្នុងក្រមនីតិវិធីថ្មីនេះ នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ត្រូវបានដាក់បញ្ចូលនូវលក្ខខណ្ឌថ្មីៗជាច្រើនដែលនាំឲ្យនីតិវិធីនេះមានលក្ខណៈខុសប្លែកទៅនឹងនីតិវិធីចាស់ដែលបានកំណត់នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣។

២.១. លក្ខខណ្ឌនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នៅពេលដែលព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដោយប្រើនីតិវិធី នៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញានឹងចេញដីកាសម្រេចមួយ គឺដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ លក្ខខណ្ឌដើម្បីឲ្យព្រះរាជអាជ្ញាអាចចេញដីកាកោះហៅទៅជំនុំជម្រះផ្ទាល់តាមនីតិវិធីនេះ ព្រះរាជអាជ្ញាត្រូវរកឲ្យឃើញនូវលក្ខខណ្ឌ ២ យ៉ាងចាំបាច់គឺ៖

ក. លក្ខខណ្ឌនៃបទល្មើស និង

ខ. លក្ខខណ្ឌនៃសាវតាជាតិរបស់ជនល្មើស។

២.២. លក្ខខណ្ឌនៃបទល្មើស

[79] មាត្រា ៦៧ នៃច្បាប់ស្តីពីក្រមព្រហ្មទណ្ឌឆ្នាំ ១៩៩៣

ចំពោះប្រភេទនៃបទល្មើសព្រហ្មទណ្ឌ ត្រូវបានបែងចែកជាបីធំៗគឺ បទលហុ បទមជ្ឈិម និងបទឧក្រិដ្ឋ។ ដោយឡែកនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចង្អុលបង្ហាញពីប្រភេទនៃបទល្មើសពីរគឺ បទលហុ និងបទមជ្ឈិម ដែលអាចឲ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់របស់ខ្លួនដោយប្រើប្រាស់នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់។

## ក. បទលហុ

បទលហុសំដៅទៅលើស្ថានភាពនៃបទល្មើសទាំងឡាយណា ដែលត្រូវរងជាទោសដាក់ពន្ធនាគាររយៈពេល អតិបរមាក្រោម ឬស្មើ ០៦ (ប្រាំមួយ) ថ្ងៃ។ ម្យ៉ាងទៀត បទល្មើសដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ ក៏ត្រូវបានចាត់ទុកជាបទលហុផងដែរ [80] ។ នៅពេលដែលអង្គហេតុមួយបង្កើតបានជាបទលហុព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ [81] ។ ចំពោះបទលហុនេះព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់បានតែក្នុងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់តែប៉ុណ្ណោះ ព្រោះថាបទលហុជាបទល្មើសតូចតាច ប្រសិនបើត្រូវរងការចោទប្រកាន់ដោយប្រើប្រាស់នីតិវិធីផ្សេង ដូចជាការបង្ហាញខ្លួនភ្លាម ឬបើកការស៊ើបសួរ វានឹងនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិសេរីភាពរបស់ជនជាប់ចោទ ដោយហេតុថានីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬនីតិវិធីនៃការបើកការស៊ើបសួរ អនុញ្ញាតឲ្យមានការឃុំគ្រងជនជាប់ចោទរហូតដល់បង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។

## ខ. បទមជ្ឈិម

ចំពោះបទមជ្ឈិមវិញ គឺសំដៅទៅលើស្ថានភាពនៃបទល្មើសទាំងឡាយណាដែលត្រូវរងទោសដាក់ពន្ធនាគារ រយៈពេលជាអតិបរមាលើសពី ០៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬស្មើនឹង ០៥(ប្រាំ) ឆ្នាំ[82] ។ ដោយយោងទៅលើក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បទមជ្ឈិមត្រូវបានជាកម្មវត្ថុនៃការចោទប្រកាន់តាម នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ [83] ។ ត្រង់លក្ខខណ្ឌនេះ មានភាពទូលំទូលាយជាងលក្ខខណ្ឌដែលបានកំណត់នៅក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ ដោយហេតុថាមានមាត្រា ៦៧ នៃច្បាប់នេះ បានចែងថា

[80] មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
[81] មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[82] មាត្រា ៤៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩
[83] មាត្រា ៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

រដ្ឋអាជ្ញាអាចធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅលើបទមជ្ឈិមទាំងឡាយណាដែលត្រូវរងការផ្តន្ទាទោសអតិបរមាមិនលើសពីមួយឆ្នាំ។ ដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មិនបានកំណត់ឲ្យបានច្បាស់យ៉ាងនេះទេ មានន័យថាឲ្យតែមានបទល្មើសមួយកើតឡើងដែលជាបទមជ្ឈិម ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់តាមនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន មិនថាបទមជ្ឈិមនោះជាក់ស្តែង ឬមិនជាក់ស្តែងក៏ដោយ។ ម្យ៉ាងវិញទៀត ការកំណត់លក្ខខណ្ឌឲ្យខុសពីនីតិវិធីចាស់បែបនេះ គឺស្ថិតនៅក្នុងគោលដៅដើម្បីទុកឱកាសឲ្យព្រះរាជអាជ្ញាប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការពិចារណាថ្លឹងថ្លែងថា តើបទល្មើសដែលខ្លួនទទួលបានមានភាពធ្ងន់ធ្ងរល្មមនឹងអាចជំនុំជម្រះបានដែរឬទេ។ ហើយដើម្បីបញ្ជាក់អំពីភាពធ្ងន់ល្មមនឹងអាចជំនុំជម្រះបានក្នុងករណីខ្លះ ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យស្រាវជ្រាវបន្ថែមបាន[84]។

**០ លក្ខខណ្ឌសវតាជាតិនៃជនល្មើស**

ក្រៅពីការកំណត់ឲ្យបានអំពីប្រភេទនៃបទល្មើសហើយ ព្រះរាជអាជ្ញាចាំបាច់ត្រូវរកឲ្យឃើញអំពីសាវតាជាតិរបស់ជនល្មើស ដែលនេះជាលក្ខខណ្ឌចាំបាច់នៅក្នុង នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់។ នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ទាមទារការកំណត់ឲ្យបាននូវអនុវត្តសញ្ញាណរបស់ជនល្មើសដោយខានមិនបាន ព្រោះថាបើជនល្មើសស្ថិតនៅក្នុងស្ថានភាពអញ្ញាតជនទេនោះ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាននីតិវិធីនេះបានទេ។

២.៣. នីតិវិធីនៃការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់

នីតិវិធីជំនុំជម្រះផ្ទាល់ ជានីតិវិធីមួយដែលមិនឆ្លងកាត់ ដំណាក់កាលស៊ើបសួរទេ ហេតុនេះព្រះរាជអាជ្ញា នៅពេលដែលទទួលបណ្តឹងហើយ ត្រូវធ្វើការចោទប្រកាន់ភ្លាម ហើយបញ្ជូនសំណុំរឿងនេះតាមរយៈដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ទៅយុត្តាធិការជំនុំជម្រះផ្ទាល់។ ក្នុងន័យនេះមិនមានន័យថា ជនជាប់ចោទត្រូវបានជំនុំជម្រះភ្លាមៗ នៅពេលដែលដីកាបញ្ជូនទៅតុលាការជំនុំជម្រះផ្ទាល់ ទៅដល់ដៃចៅក្រមជំនុំជម្រះនោះទេ

[84] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

គឺព្រះរាជអាជ្ញាត្រូវកោះហៅ
និងប្រាប់អំពីព័ត៌មានដល់ជនជាប់ចោទតាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ម្យ៉ាងវិញទៀត ការចោទប្រកាន់តាមរយៈដីកាកោះហៅបញ្ជូនទៅ ជំនុំជម្រះផ្ទាល់នេះទៀតសោត ព្រះរាជអាជ្ញាត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានចង្អុលបង្ហាញដើម្បីធានាបានថាដីកាកោះហៅរបស់គាត់មានសុពលភាព។

**១-ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ព្រះរាជអាជ្ញាត្រូវធ្វើដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ឡើង ឲ្យមានទម្រង់ការច្បាស់លាស់ ដើម្បីឲ្យចៅក្រមជំនុំជម្រះយល់ឃើញថារឿងក្តីដែលព្រះរាជអាជ្ញាបានចោទប្រកាន់ពិតមានភាពធ្ងន់ល្មមនឹងអាចចោទប្រកាន់បាន។ ម្យ៉ាងវិញទៀត ទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះនេះក៏ជាព័ត៌មានយ៉ាងសំខាន់សម្រាប់ជនជាប់ចោទយល់អំពីមូលហេតុនៃការចោទប្រកាន់របស់ព្រះរាជអាជ្ញា ព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់គាត់ក្នុងការបង្ហាញខ្លួនតាមកាលកំណត់ដូចដែលបានចែងនៅក្នុងដីកានេះ។ ហេតុនេះ ទម្រង់ការនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់រួមមានៈ

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ
- ឈ្មោះបទល្មើស និង
- អត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស។

ក្រៅពីទម្រង់ការខាងលើ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ព្រះរាជអាជ្ញាក៏ត្រូវចង្អុលប្រាប់ដល់ជនជាប់ចោទពីតុលាការ ព្រមទាំងទីកន្លែងចោទប្រកាន់ កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការផងដែរ។ ហេតុដូច្នេះនៅក្នុងនីតិវិធីបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ព្រះរាជអាជ្ញាពុំចាំបាច់ចេញដីកាកោះហៅជនជាប់ចោទចូលសវនាការ ដូចដែលមានចែងនៅក្នុងមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ ទៀតទេ ព្រោះថាទម្រង់ការនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បានបញ្ជាក់ប្រាប់ដល់ជនជាប់ចោទរួចអស់ទៅហើយ។

**២-សុពលភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

ដើម្បីធានាជនជាប់ចោទ មានរយៈពេលសមរម្យដើម្បីឲ្យជនជាប់ចោទរៀបចំខ្លួនត្រៀមឡើងសវនាការ ដូចដែលមានចែងនៅក្នុងមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ បានកំណត់អំពីរយៈពេលខុសៗគ្នា ដែលអាស្រ័យទៅលើស្ថានភាពទីតាំង ដែលជនជាប់ចោទមានវត្តមាន។ រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួននោះគឺៈ

- ១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទនៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង
- ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងមួយទៀតក្នុងដែនដីជាតិ ឬ
- ចំនួន ២ខែប្រសិនបើជននោះរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា[85]។

កាលបើលក្ខខណ្ឌទាក់ទងនឹងរយៈពេលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមមិនត្រូវបានបំពេញ ឬធ្វើឡើងដោយបំពាននោះទេ ហើយបើតុលាការយល់ឃើញថាដីកានោះមានអានុភាពធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ជនជាប់ចោទ តុលាការអាចនឹងប្រកាសអំពីមោឃភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន [86] ។ ម៉្យាងទៀត តុលាការត្រូវបង្គាប់ឲ្យមានការចេញនូវដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ជាថ្មីម្តងទៀត លើកលែងករណីផុតរលត់បណ្តឹងអាជ្ញា[87]។

ជារួមមក នីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីនៃការចោទប្រកាន់មួយដែលធានាការពារដល់សិទ្ធិបុគ្គលដល់ជនជាប់ចោទ ព្រោះថាជានិច្ចកាលជនជាប់ចោទត្រូវនៅក្រៅឃុំជានិច្ច ព្រោះថាជនជាប់ចោទមុននឹងបង្ហាញខ្លួនមុខតុលាការ គាត់ត្រូវបានជូនដំណឹងអំពីពេលវេលាកាលបរិច្ឆេទនៃសវនាការ តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ម្យ៉ាងវិញទៀនៅក្នុងនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះ ជនជាប់ចោទចូលទៅបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ [88] គឺគ្មានការបង្ខំ

[85] មាត្រា ៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[86] មាត្រា ៤៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[87] មាត្រា ៤៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧
[88] មាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ឬត្រូវបានឃុំគ្រងដោយកងការពាររបស់ស្ថាប័នតុលាការ ដូចនីតិវិធីនៃការចោទប្រកាន់ផ្សេងទៀតទេ ដូចជានីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬនីតិវិធីនៃការបើការស៊ើបសួរ។

បើយោងតាមទ្រឹស្តី និងការអនុវត្តផ្ទាល់វិញឃើញថា នៅអយ្យការអមសាលាដំបូងខេត្តកណ្តាលបានធ្វើការទៅលើរឿង ដែលទាក់ទងនឹងការជំនុំជម្រះផ្ទាល់នេះជាច្រើនមកហើយ។ ហើយនីតិវិធីនៃការជំនុំជម្រះផ្ទាល់នេះ គឺអាចធ្វើទៅលើប្រភេទរឿងមជ្ឈឹមជាក់ស្តែងដូចជា ៖

កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៦ វេលាម៉ោង ៦ល្ងាច ឈ្មោះ ក បានមកពីផឹកស្រាថ្នាំជាមួយមិត្តភក្តិ ឈ្មោះ ខ និង គ រហូតដល់ម៉ោងប្រហែល ៧ យប់ ឈ្មោះ ក បានត្រឡប់មកផ្ទះវិញ ស្ថិតនៅភូមិព្រែករាំង ១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល ទាំងក្នុងស្ថានភាពស្រវឹង។ ពេលមកដល់ផ្ទះ ឈ្មោះ ក បានដួសបាយ និងបានសួរម្តាយរបស់ខ្លួនឈ្មោះ ញ ដើម្បីរកម្ហូបហូបបាយ ភ្លាមនោះម្តាយឆ្លើយថា គ្មានម្ហូបទេ ឈ្មោះ ក ខឹងក៏បានស្រែកជេរ ឡូឡា រករឿងម្តាយ ព្រមទាំងយកចានបាយ និងស្លាបព្រាបោះចោលទៅក្នុងទឹកក្រោយផ្ទះហើយបានស្ទុះទៅទាញទ្វារទូដាក់ម្ហូបបណ្តោយឲ្យបាក់ធ្លាក់ ពេលនោះម្តាយឈ្មោះ ក ក៏ប្តឹងសមត្ថកិច្ចឲ្យឃាត់ខ្លួនឈ្មោះ ក តែម្តង។

ចំពោះសំណុំរឿងនេះ បន្ទាប់ព្រះរាជអាជ្ញាធ្វើការត្រួតពិនិត្យរួចមកឃើញថា ឈ្មោះក នេះពិតជាបានប្រព្រឹត្តបទល្មើសខាងលើពិតប្រាកដមែន។ ដូចនេះ អយ្យការយល់ឃើញថា ៖

- រឿងក្តីនេះជារឿងព្រហ្មទណ្ឌ ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ជនសង្ស័យមានសាវតាជាតិគ្រប់គ្រាន់ សំណុំរឿងមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញឲ្យឃើញ ឲ្យជនសង្ស័យខាងលើបានប្រព្រឹត្តបទល្មើសៈ ធ្វើឲ្យមានការខូចខាតស្រាល ដែលជាបទល្មើសមជ្ឈិមជាក់ស្តែងដែលត្រូវផ្តន្ទាទោសដាក់តាមបញ្ញត្តិមាត្រា ៤១៨ នៃក្រមព្រហ្មទណ្ឌ ហើយសំណុំរឿងនេះ មានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន។
- កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៦ វេលាម៉ោង ៦ ល្ងាច ឈ្មោះ ក មកពីផឹកស្រាវិញក្នុងស្ថានភាពស្រវឹង ពេលមកដល់ផ្ទះបានដួសបាយហូប ពេលដែលដួសបានហើយរកម្ហូបហូបបាយមិនមាន ក បានស្រែកជេរ ឡូឡា រករឿងម្តាយរបស់ខ្លួន ឈ្មោះ ញ ព្រមទាំងយកចានបាយ និងស្លាបព្រាបោះចោលទៅក្នុងទឹកក្រោយផ្ទះ ហើយបានស្ទុះទៅទាញទ្វារទូរដាក់ម្ហូបបណ្តោយឲ្យបាក់ធ្លាក់ខូចខាតយ៉ាងពិតប្រាកដមែន។

- អំពើខាងលើជាបទល្មើសធ្វើឲ្យមានការខូចខាតស្រាលដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១៨ នៃក្រមព្រហ្មទណ្ឌ។
- អំពើខាងលើធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់ជាធរមានរបស់រដ្ឋ។
- មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ ក ភេទប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ ពីបទៈ **ធ្វើឲ្យមានការខូចខាតស្រាល** ប្រព្រឹត្តនៅភូមិព្រែករាំង ១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ៤១៨ នៃក្រមព្រហ្មទណ្ឌ។

ហេតុដូចនេះសម្រេចៈ

បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ......ដែលមានជនជាប់ចោទៈ

១. ឈ្មោះ ក ភេទ ប្រុស អាយុ ២៦ ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិសុភី ឃុំដីឥដ្ឋ ស្រុកកៀនស្វាយខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្ថិតនៅភូមិព្រែករាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល មុខរបរកម្មករសំណង់ កាន់សាសនាព្រះពុទ្ធ កំរិតវប្បធម៌ ថ្នាក់ទី៧ ប្រពន្ធឈ្មោះ ស ឪពុកឈ្មោះ រ ម្តាយឈ្មោះ ញ ជានីតិជន ទោសពីមុនគ្មាន។

ទៅសាលាដំបូងខេត្តកណ្តាលដើម្បីជំនុំជម្រះពីបទៈ ធ្វើឲ្យមានការខូចខាតស្រាល ប្រព្រឹត្តនៅភូមិព្រែករាំង១ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី ២១ ខែមករា ឆ្នាំ ២០១៦ តាមបញ្ញត្តិមាត្រា ៤១៨ នៃក្រមព្រហ្មទណ្ឌ។

សរុបមកនីតិវិធីនៃការជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយដែលព្រះរាជអជ្ញាធ្វើការចោទប្រកាន់ទៅលើជនដែលប្រព្រឹត្តបទល្មើស ហើយបញ្ជូនជននោះទៅកាន់ចៅក្រមជំនុំជម្រះតែម្តង ដោយមិនចាំបាច់មានការឆ្លងកាត់ចៅក្រមស៊ើបសួរនោះឡើយ។ ហើយនីតិវិធីនេះដែរធ្វើដូចទៅនឹងដំណើរការដែលបានរៀបរាប់ខាងលើ លើសពីនេះទៀតសោធបើក្រឡេកមើលទៅលើការអនុវត្តនៅសាលាដំបូងខេត្តកណ្តាលវិញ មានការធ្វើទៅលើរឿងប្រភេទនេះបានជាច្រើន និងគោរពតាមនីតិវិធីច្បាប់ផងដែរ។ ជាក់ស្តែងដូចជាករណី ដែលបានលើកឡើងខាងលើនេះ។

៣ .លក្ខខណ្ឌ និង នីតិវិធីបង្ហាញខ្លួនភ្លាម

៣.១ .លក្ខខណ្ឌនៃការបង្ហាញខ្លួនភ្លាម

នីតិវិធីនេះក៏មិនខុសពី នីតិវិធីនៃការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ដែរ ដើម្បីធ្វើការចោទប្រកាន់ទៅតាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញាត្រូវប្រមែប្រមូលឲ្យបាននូវវត្ថុតាង និងព័ត៌មានទាំងអស់ដែលលក្ខខណ្ឌចម្បងក្នុងការចោទប្រកាន់តាមនីតិវិធីនេះ។

ដោយយោងតាមមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ កំណត់លក្ខខណ្ឌដែលព្រះរាជអាជ្ញាអាចធ្វើចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមមានដូចខាងក្រោម៖

- **ទីមួយ** បទល្មើសដាច់ខាតត្រូវតែជាបទមជ្ឈិមជាក់ស្តែង ៖ បទល្មើសនេះបានបញ្ជាក់បង្ហាញយ៉ាងច្បាស់នៅក្នុងមាត្រា ៨៦ និងមាត្រា ៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ ដូច្នេះក្រៅពីបទមជ្ឈិមជាក់ស្តែងព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមនីតិវិធីនេះបានឡើយ ឬអាចនិយាយម្យ៉ាងទៀតបានថានីតិវិធីមួយនេះមិនអាចអនុវត្តបានឡើយចំពោះករណីបទឧក្រិដ្ឋ មជ្ឈិមមិនជាក់ស្តែង និងបទលហុ។
- **ទីពីរ** បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិចមួយឆ្នាំ និងជាអតិបរមាប្រាំឆ្នាំ៖ មានន័យថាចន្លោះនៃទោសពី ០១ ឆ្នាំ ទៅ ០៥ ឆ្នាំ នេះគឺសំដៅដល់អតិបរមានៃទោសដែលច្បាប់បានកំណត់។
- **ទីបី** ជនជាប់ចោទជានីតិជន ៖ មានន័យថាជាជាប់ចោទត្រូវតែជាបុគ្គលដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ[89] ។ ដូច្នេះ នីតិជន ជាជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ទើបព្រះរាជអាជ្ញាអាចចោទប្រកាន់តាមនីតិវិធីនេះបាន។
- **ទីបួន** រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ៖ មានន័យថា នៅក្នុងសំណុំរឿងត្រូវមានភស្តុតាងគ្រប់គ្រាន់ ដោយពុំមានការសង្ស័យ ដែលមានភាពធ្ងន់ល្មមនឹងអាចបើកសវនាការជំនុំជម្រះបាន។

ជារួមមក លក្ខខណ្ឌទាំងបួនខាងលើនេះ គឺជាលក្ខខណ្ឌមួយដោយមិនអាចខ្វះចំណុចណាមួយបានឡើយ។ ក្រៅពីលក្ខខណ្ឌទាំងបួននេះ ប្រសិនបើយើងធ្វើការសិក្សាទៅលើនីតិវិធីនៃការបង្ហាញខ្លួនភ្លាម នីតិវិធីនេះគឺពឹងផ្អែកទាំងស្រុងទៅលើវត្តមានរបស់ជនល្មើស បើគ្មានជនល្មើសទេ

[89] ផ្អែកតាមស្មារតីមាត្រា ១៧ នៃក្រមរដ្ឋប្បវេណី កំណត់ពីនិយមន័យអនីតិជនថា ជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ

ព្រះរាជអាជ្ញាមិនបង្គាប់ឲ្យជនជាប់ចោទចូលមកបង្ហាញខ្លួនដែរ។ ហេតុដូចនេះ លក្ខខណ្ឌមួយទៀតដែលយើងគួរបន្ថែមទៅលក្ខខណ្ឌទាំងបួននេះ គឺ វត្តមាននៃជនជាប់ចោទ។ ដូច្នេះ បន្ទាប់ពីព្រះរាជអាជ្ញាបានប្រមូលនូវលក្ខខណ្ឌគ្រប់គ្រាន់ ដូចដែលមានចែងនៅក្នុងមាត្រា៤៧ ហើយព្រះរាជអាជ្ញានឹងធ្វើចំណាត់ការនីតិវិធី នៃការបង្ហាញខ្លួនភ្លាមតាមរយៈកំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាមទៅចំពោះមុខចៅក្រមជំនុំជម្រះ ឬយុត្តាធិការជំនុំជម្រះ។

៣.២. នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

បន្ទាប់ពី ព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមរួចមក ព្រះរាជអាជ្ញាត្រូវធ្វើចំណាត់ការនីតិវិធីរបស់ខ្លួន ដែលត្រូវបានចង្អុលបង្ហាញដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧។ ដោយយោងតាមមាត្រា ៤៨ នៃក្រមនេះយើងអាចធ្វើការបែងចែងនីតិវិធីនៃការបង្ហាញខ្លួនភ្លាមជាពីរះ

- ទី១ ដំណាក់កាលចំពោះមុខព្រះរាជអាជ្ញា និង
- ទី២ ដំណាក់កាលចំពោះមុខតុលាការជាន់ដំបូង

**ក. ដំណាក់កាលចំពោះមុខព្រះរាជអាជ្ញា**

ជំហានដំបូងនៃនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ជនជាប់ចោទត្រូវតែជាជនដែលត្រូវបានឃាត់ខ្លួននៅក្នុងដំណាក់កាលនៃមន្ត្រីនគរបាលយុត្តិធម៌ជាមុនសិន រួចទើបជននោះត្រូវបញ្ជូនមកចំពោះមុខព្រះរាជអាជ្ញានៅពេលដែលរយៈនៃការឃាត់ខ្លួនត្រូវបានបញ្ចប់[90]។ នៅពេលដែលជនជាប់ចោទត្រូវបានបញ្ជូនមកបង្ហាញចំពោះមុខព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាត្រូវពិនិត្យមើលពីអត្តសញ្ញាណបុគ្គលដែលបង្ហាញខ្លួននោះ ដើម្បីធានាឲ្យប្រាកដថាជននោះ គឺពិតជាជនប្រព្រឹត្តបទល្មើសមែន និងជៀសវៀងការចាប់ខ្លួនបុគ្គលច្រឡំដែលមិនមែនជាអ្នកប្រព្រឹត្ត។

បន្ទាប់ពីពិនិត្យអំពីអត្តសញ្ញាណជនជាប់ចោទហើយ ព្រះរាជអាជ្ញាត្រូវឲ្យដំណឹងដល់ជននោះអំពីអង្គហេតុនៃការចោទប្រកាន់ និងឈ្មោះបទល្មើស។ ក្នុងករណីដែលជនជាប់ចោទចង់និយាយទាក់ទងទៅនឹងការចោទប្រកាន់ ព្រះរាជអាជ្ញាក៏ត្រូវទទួលចម្លើយរបស់បុគ្គលនោះផងដែរ។

[90] មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

ព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមដាក់ចូលក្នុងសំណុំរឿងរបស់ខ្លួន រួចបញ្ជូនទៅតុលាការជាន់ដំបូងដើម្បីចាត់តាំងចៅក្រមជំនុំជម្រះ (ដោយប្រធានតុលាការ) ក្នុងការបើកសវនាការ។ ព្រះរាជអាជ្ញាក៏ត្រូវប្រាប់ជនជាប់ចោទថាគេមានសិទ្ធិពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬតាមការចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ នៅក្នុងករណីដែលជនជាប់ចោទមានមេធាវីការពារខ្លួននោះព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់មេធាវីនោះដើម្បីឲ្យមេធាវីរបស់ជនជាប់ចោទអាចពិនិត្យលើសំណុំរឿងទាក់ទងទៅ នឹងជនជាប់ចោទបាន។

នៅពេលដែលកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមត្រូវបានធ្វើការចប់សព្វគ្រប់រួចហើយជនជាប់ចោទនឹងត្រូវបានបង្ខាំងទុកដោយកងកម្លាំងការពារ និងបញ្ជូនជននោះព្រមទាំងសំណុំរឿងទៅចំពោះមុខតុលាការដែលត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។

**ខ. ដំណាក់កាលចំពោះមុខតុលាការជាន់ដំបូង**

នៅពេលដែលជនជាប់ចោទត្រូវបានបង្ហាញខ្លួននៅមុខតុលាការហើយជាដំបូងតុលាការត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់អំពីអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបអំពីអង្គហេតុនៃការចោទប្រកាន់ ហើយត្រូវប្រាប់ជនជាប់ចោទថាគេអាចមានរយៈពេលដើម្បីរៀបចំការពារខ្លួនបាន។ ប្រសិនបើជនជាប់ចោទមិនទាមទាររយៈពេលដើម្បីរៀបចំការពារខ្លួនទេនោះ តុលាការនឹងបើកសវនាការជំនុំជម្រះ និងប្រកាសសាលក្រមនៅថ្ងៃនោះតែម្តង។

ផ្ទុយទៅវិញប្រសិនបើជនជាប់ចោទសុំរយៈពេលដើម្បីរៀបចំការពារខ្លួន ឬតុលាការយល់ឃើញថារឿងក្តីនោះ មិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងនឹងត្រូវលើកទៅពេលសវនាការក្រោយ។ ក្នុងករណីនេះតុលាការត្រូវបើកសវនាការតូចមួយដែលហៅថា សវនាការជំនុំជម្រះមុនអង្គសេចក្តីដើម្បីសម្រេចរឿងឃុំខ្លួន ឬមិនឃុំខ្លួនជនជាប់ចោទ ហេតុនេះតុលាការនឹងចេញសាលក្រមសម្រេចរឿងឃុំខ្លួនជនជាប់ចោទ ដែលគេហៅថាសាលក្រមមុនអង្គសេចក្តី។ សាលក្រមនេះតុលាការ ត្រូវយោងទៅតាមស្មារតីនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន (ក្រៅពីសាលក្រមនេះ តុលាការក៏ត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួនដែរ ក្នុងករណីសម្រេចឲ្យឃុំខ្លួន

ព្រោះថាដីកាបង្គាប់ឲ្យឃុំខ្លួនគឺជាបញ្ជាដល់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួលនិងឲ្យឃុំខ្លួន [91] ។ ប្រសិនបើគ្មានដីកាបង្គាប់ឲ្យឃុំខ្លួនទេ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនមិនអាចមានសិទ្ធិធ្វើការឃុំខ្លួនជននោះបានឡើយ ទោះបីជាមានសាលក្រមហើយក៏ដោយ។ គួរកត់សម្គាល់ថារយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ននេះមាន លក្ខណៈខុសគ្នាទៅនឹងការឃុំខ្លួនបណ្តោះ អាសន្ននៅក្នុងដំណាក់កាលនៃការស៊ើបសួរ ពីព្រោះថាការសម្រេចឃុំខ្លួននៅក្នុងនីតិវិធីនេះកម្រិតរយៈពេលតែពីរសប្តាហ៍តែប៉ុណ្ណោះ។ ក្នុងរយៈពេលពីរសប្តាហ៍គិតចាប់ពីពេលថ្ងៃចេញសាលក្រមមុនអង្គសេចក្តី តុលាការត្រូវបើកសវនាការលើអង្គសេចក្តី ដើម្បីជំនុំជម្រះទៅលើជនជាប់ចោទ ដោយចេញសាលក្រមលើអង្គសេចក្តី ដែលប្រកាសអំពីពិរុទ្ធភាពទៅជនជាប់ចោទ ឬជនជាប់ចោទត្រូវបានរួចពីបទចោទ ប្រសិនបើតុលាការយល់ឃើញថាអំពើនោះមិនមែនជាបទល្មើស ឬក៏ជនជាប់ចោទគ្មានកំហុសទេ [92] ។ ប្រសិនបើក្នុងរយៈនៃការឃុំខ្លួនពីរសប្តាហ៍នេះ តុលាការមិនបានបើកសវនាការលើអង្គសេចក្តីទេនោះ ជនជាប់ចោទនឹងត្រូវដោះលែងឲ្យនៅក្រៅឃុំឲ្យមានសេរីភាពដោយពេញច្បាប់ មាត្រា[93]។

៣.៣ .ភាពមិនអាចដំណើរការទៅបាននៃនីតិវិធីបង្ហាញខ្លួនភ្លាម

ប្រសិនបើតុលាការដែលបានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឲ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃនីតិវិធីបង្ហាញខ្លួនភ្លាមដែលបានកំណត់នៅក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មិនបានបំពេញ ឬក៏ដោយភាពសាំញ៉ាំនៃសំណុំរឿងនោះ នីតិវិធីនោះមិនអាចអនុវត្តបានឡើយ។ ក្នុងករណីបែបនេះតុលាការត្រូវធ្វើការស្រាវជ្រាវបន្ថែមជាចាំបាច់ ដោយតុលាការត្រូវធ្វើការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីបើកការស៊ើបសួរ [94] ។ ក្នុងការបើកការស៊ើបសួរព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿង

[91] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[92] មាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[93] ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

[94] មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

និងជនជាប់ចោទនោះទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តងនៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នោះទេ ជនជាប់ចោទត្រូវដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង[95]។

ពាក្យថាសេរីភាពនៅទីនេះ មិនមានន័យថាជនជាប់ចោទត្រូវរួចខ្លួនពីការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះទេ គឺគ្រាន់តែឲ្យជននោះនៅក្រៅឃុំតែប៉ុណ្ណោះ ព្រះរាជអាជ្ញានៅតែអាចធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរបានជាធម្មតា។

ប៉ុន្តែចំពោះនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមនេះ នៅអយ្យការអមសាលាដំបូងខេត្តកណ្តាលគឺមិនដែលបានអនុវត្តទៅលើនីតិវិធីនេះទេ ពីព្រោះថានីតិវិធីនេះអាចធ្វើបានទាល់តែមានគ្រប់លក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ៤៧ នៃក្រមនីតិវិធី។ ដោយលក្ខខណ្ឌទាំងនោះមាន៖

- បទល្មើសជាបទល្មើសជាក់ស្តែង
- ផ្តន្ទាទោសយ៉ាងតិច ១ (មួយ )ឆ្នាំ យ៉ាងច្រើន ៥(ប្រាំ) ឆ្នាំ (ពន្ធធនាគារ)
- ជនល្មើសជា នីតិជន
- បទល្មើសមានលក្ខណៈគ្រប់គ្រាន់។

អយ្យការមិនដែលអនុវត្តទៅនីតិវិធីនេះគឺព្រោះតែនីតិវិធីនេះវាមានលក្ខណៈតឹងរឹង ពេលខ្លះវាមិនមានលក្ខខណ្ឌគ្រប់គ្រាន់ ដោយមានការខ្វះនូវលក្ខខណ្ឌណាមួយ ដូចជាមានជនជាប់ចោទជាអនីតិជនជាដើម ប៉ុន្តែអ្វីផ្សេងគឺត្រឹមត្រូវអស់ហើយ ស្រាប់តែជនល្មើសជាអនីតិជនទៅវិញ។

[95] មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ខ្ញុំអាចសន្និដ្ឋានបានថាអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត-ក្រុង បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងលំហូរនីតិវិធីចោទប្រកាន់ខាងបទព្រហ្មទណ្ឌ ឬមិនចោទប្រកាន់ទៅលើបទលើបទល្មើសណាមួយ ហើយយើងក៏អាចសង្កេតឃើញយ៉ាងច្បាស់ពីតួនាទីរបស់អយ្យការ ដែលត្រូវបានផ្តល់សិទ្ធិតាមរយៈរដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងជាពិសេសមានចែងក្នុងច្បាប់នីតិវិធី។ អយ្យការធ្វើការចោទពីបទល្មើសព្រហ្មទណ្ឌ ហើយការចោទប្រកាន់នេះទៀតសោធច្បាប់នៃប្រទេសកម្ពុជាយើង បានប្រកាន់យកនូវគោលការណ៍ នីត្យានុកូលភាពនៃការចោទប្រកាន់ ដែលព្រះរាជអាជ្ញាត្រូវធ្វើការចោទប្រកាន់នូវរាល់បទល្មើសដែលកើតមានឡើងមិនថាអំពើនោះ បង្កព្យសនកម្មដល់សណ្តាប់ធ្នាប់សាធារណៈមានកម្រិតធ្ងន់ធ្ងរ ឬតិចតួចយ៉ាងណាក៏ដោយ។ ការកំណត់យកគោលការណ៍នេះ ដើម្បីបញ្ឈប់រាល់បទល្មើសកុំឲ្យកើតមានឡើង ប៉ុន្តែវាហាក់ដូចជាព្រៃផ្សៃចំពោះទង្វើដែលមានកម្រិតគ្រោះថ្នាក់តិចតួចហើយធ្វើការចោទប្រកាន់ លើសពីនេះទៅទៀតវាក៏កើតមាននូវផលវិបាកយ៉ាងច្រើនផងដែរនៅក្នុងសង្គម។ ហេតុនេះហើយបានជាកម្ពុជាធ្វើការផ្លាស់ប្តូរទៅតាមបរិបទសង្គមដោយងាកមកយកគោលការណ៍ កាលានុវត្តភាពនៃការចោទប្រកាន់វិញ មានន័យថាព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើគួរចោទប្រកាន់ ឬយ៉ាងណាចំពោះអំពើដែលបង្កើតជាបទល្មើស។ គោលការណ៍នេះផ្តល់អត្ថប្រយោជន៍យ៉ាងច្រើន ក្នុងការជួយសម្រេចដល់ដំណើរការរឿងក្តីក្នុងតុលាការ ឲ្យ បានឆាប់រហ័សដើម្បីជៀសវាងការកកស្ទះសំណុំរឿង បន្ថែមពីលើនេះទៅទៀតវាក៏ជួយសម្រួលដល់បទល្មើសណាមួយដើម្បីធ្វើការផ្តន្ទាទោសជនល្មើស ក្នុងគោលបំណងធ្វើការអប់រំ និងកែប្រែជនល្មើសនោះ ឲ្យត្រលប់មករស់នៅក្នុងស្ថានភាពដែលសង្គមទទួលស្គាល់វិញ ប៉ុណ្ណោះទេមិនមានការសងសឹកគ្នា។ ដូចនេះស្ថាប័នអយ្យការ គឺចាំបាច់ត្រូវឈរលើការថ្លឹងថ្លែង មួយដែលប្រកបដោយភាពសមហេតុផលនិងពិចារណាយ៉ាងខ្ពស់ ចំពោះអង្គហេតុនីមួយៗដើម្បីធានាថា

ចំណាត់ការមិនខុសលើការ អនុវត្តច្បាប់របស់ស្ថាប័នអយ្យការត្រូវមានកំរិតខ្ពស់ និងមានបទពិសោធន៍យ៉ាងរឹងមាំទាំងវិស័យច្បាប់និងសង្គម។

ទោះយ៉ាងណាក៏ដោយយោងតាមឃ្លាខាងលើគឺមានស្មារតី រួមគ្នាមួយគឺការអភិវឌ្ឍន៍សង្គមជាតិធានាការអនុវត្តច្បាប់ និងទប់ស្កាត់ការរីករាលដាលនៃបទល្មើសព្រហ្មទណ្ឌ។ ការធានាទាំងនេះបើគ្រាន់តែពឹងលើស្ថាប័នអយ្យការតែមួយគោលដៅដែលសង្គមជាតិចង់បាននោះ គឺមិនអាចកើតមានទេ។ ចាំបាច់ត្រូវមានរួមចំនែកពីស្ថាប័នពាក់ព័ន្ធមួយចំនួនដូចជា នគរបាលយុត្តិធម៌ យុត្តាធិការស៊ើបសួរ ក្រឡាបញ្ជី យុត្តាធិការជំនុំជំរះ និងស្ថាបន័ពាក់ពន្ធមួយចំនួនទៀត។ ដូចនេះការពង្រឹងសមត្ថភាពរបស់ស្ថាបន័ទាំងនេះ គឺចាំបាច់ត្រូវតែប្រព្រឹត្តទៅដំណើរគ្នាជាមួយការពង្រឹងសមត្ថភាពរបស់ស្ថាប័នអយ្យការក្នុងការអនុវត្តច្បាប់។

ការបកស្រាយរបស់ជំពូកទាំងពីរខាងលើ គឺនិយាយតែពីការខិតខំឲ្យមានស្ថាប័នដែលអាចធានាការអនុវត្តច្បាប់ព្រហ្មទណ្ឌឲ្យកាន់តែរឹងមាំ ក្នុងគោលដៅធ្វើការបង្ក្រាបបទល្មើស ចាប់ជនល្មើសនឹងដាក់ទណ្ឌកម្មជនល្មើសដោយការផ្តន្ទាទោសរបស់តុលាការប៉ុណ្ណោះ។ ទាំងអស់ត្រូវបានគេយល់ថានេះជាវិធានការមួយ ដែលអាចធ្វើការបំភ័យដល់ជនល្មើសដែលបានប្រព្រឹត្តបទល្មើសពីមុនរួចហើយដែលកំពុងទទួលការដាក់ទណ្ឌកម្ម និងបំភ័យដល់សាធារណៈជនមិនឲ្យជនទាំងនេះហ៊ានប្រព្រឹត្តបទល្មើសដូចជនល្មើសទៀត។ វិធានការនេះជាវិធានការដែលមានប្រសិទ្ធភាពក្នុងការទប់ស្កាត់ការរីករាលដាលនៃបទល្មើស ដោយធ្វើការដាក់ទណ្ឌកម្មជនល្មើស ក្នុងគោលដៅកាត់បន្ថយបទល្មើស។

## ការផ្តល់អនុសាសន៍

ទោះបីជាការខិតខំបំពេញតួនាទីយ៉ាងសកម្មក្តីក៏ការអនុវត្តតាមតួនាទីនៅមានចន្លោះប្រហោង និងអសកម្មមួយចំនួន។ ដើម្បីបំពេញចន្លោះខ្វះខាត និងចំនុចអសកម្មទាំងនោះ គប្បីសាលាដំបូងរាជធានី-ខេត្តក្រុង ស្ថាប័នពាក់ព័ន្ធ និងដៃគូផ្តល់ជំនួយនានាយកចិត្តទុកដាក់មួយចំនួនដូចខាងក្រោមៈ

- ត្រូវមានការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញាឱ្យបានច្រើនបន្ថែមទៀត និងមានការបញ្ជូនចៅក្រម និងព្រះរាជអាជ្ញាទៅសិក្ខាសាលានៅឯក្រៅប្រទេស ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងប្រមូលចំណេះដឹង ដើម្បីយកមកដោះស្រាយ នូវបទល្មើសថ្មីៗ ដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ន ។ ស្របពេលដែលអង្គការនិតិបញ្ញត្តិបានអនុមត័ច្បាប់ថ្មីៗមួយចំនួន ដោយឡែកត្រូវមានការធានាថាចៅក្រមត្រូវបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់ ដ៏ត្រឹមត្រូវប្រកដោយសមត្ថភាព មានបុគ្គលិកលក្ខណៈ និងមានក្រមសីលធម៌។

- គួរតែព្យាយាមក្នុងការស្វែងរកភស្តុតាងដាក់បន្ទុក ដោះបន្ទុក ដូចជាការចុះស្វែងរកសរតាជាតិដោយផ្ទាល់របស់ចៅក្រមស៊ើបសួរ បើសិនជាអាច។

- ស្ថាប័នតុលាការគួរតែត្រូវបានយកចិត្តទុកដាក់ទៅលើទីតាំង អាគារ បន្ទប់ ដែលជាកន្លែងធ្វើការឱ្យមានលក្ខណៈធំល្មម ទីនឹងចំនួនមន្ត្រីដែលបម្រើនៅក្នុងស្ថាប័ននោះ។

- រក្សាបាននូវឯករាជ្យភាពនៃអំណាចតុលាការ ជៀសវាងការទទួលរងនូវឥទ្ធិពលខាងក្រៅពីស្ថាប័នដទៃទៀត ជាហេតុនាំឱ្យមានភាពអយុត្តិធម៌។

- ត្រូវមានការយកចិត្តទុកដាក់បញ្ហាប្រាក់បៀវត្សរបស់មន្ត្រីតុលាការ ដែលជាឫសគល់ដ៏សំខាន់ក្នុងការបង្កើតឱ្យមានអំពើពុករលួយ ដែលធ្វើឱ្យប្រព័ន្ធយុត្តិធម៌កម្ពុជារងគ្រោះ។ ដើម្បីធានាប្រសិទ្ធិភាពនៃការងារ

និងឯករាជ្យភាពនៃប្រព័ន្ធតុលាការ ជាពិសេសការទទួលបានជំនឿទុកចិត្តពីប្រជាពលរដ្ឋ ប្រាក់បៀវត្សមន្ត្រីតុលាការគួរតែផ្តល់ឱ្យបានសមស្របទៅ នឹងស្ថានភាពក្នុងពេលបច្ចុប្បន្ន ដើម្បីទ្រទ្រង់ជីវភាពល្អ ប្រសើសម្រាប់គ្រួសារចៅក្រម និងព្រះរាជអាជ្ញា ជៀសវាងនូវការទទួលសំណូក។

- ត្រូវមានការឧបត្ថម្ភលើសម្ភារៈបច្ចេកទេស និងសម្ភារៈរដ្ឋបាលដើម្បីពន្លឿននៃកិច្ចការតុលការ និងការផ្តល់យុត្តិធម៌ដ៏ពិតប្រាកដជូនប្រជាពលរដ្ឋ។ សម្ភារៈបច្ចេកទេសជាវត្ថុដ៏សំខាន់ក្នុងការធ្វើកោសល្យវិច័យលើវត្ថុតាងនានា ដើម្បីស្វែងរកការពិតជូនគូភាគី។ ដោយឡែកសម្ភារៈរដ្ឋបាលជាឧបករណ៍ជំនួយដល់កិច្ចគ្រប់គ្រងទូទៅតុលាការ ដូចជាកត់ត្រា រក្សាទុកឯកសារសំខាន់ៗ និងការគ្រប់គ្រងសំណុំរឿងក្តីតាមប្រព័ន្ធអេឡិចត្រូនិចជាដើម។

- ត្រូវមានការរសហការពីគ្រប់ស្ថាប័នដែលពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ស្ថាប័នតុលាការក្នុងការអនុវត្តនីតិវិធីឱ្យបានឆាប់រហ័ស។ ដូច្នេះការសហការនេះជាជំនួយដ៏សំខាន់មួយដែលអាចធ្វើឱ្យដំណើរការក្នុងរឿងក្តីបានទទួលនូវយុត្តិធម៌ និងមិនធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់គូភាគី។

- ត្រូវមានការរៀបចំបណ្តាញសន្តិសុខសុវត្ថិភាពជូនចៅក្រម ក្នុងពេលសួរចម្លើយ ដើម្បីធានា និងធ្វើឱ្យប្រាកដថាសុវត្ថិភាពរបស់ពួកគាត់ត្រូវបានធានា ១០០% ជៀសផុតពីគ្រោះថ្នាក់ និងការគំរាមគំហែងក្នុងពេល ដែលពួកគាត់បំពេញការងាររបស់ខ្លួន ដើម្បីធានាបាននូវឯករាជ្យរបស់អង្គចៅក្រម។

ការសហការ ក៏ជាបច្ច័យល្អមួយដែលអាចបង្កើតឱ្យមានវប្បធម៌ក្នុងការជួយគ្នាទៅវិញទៅមកដល់ក្មេងជំនាន់ក្រោយផងដែរ។

ទោះបីជាយ៉ាងណា សាលាដំបូងរាជធានី ខេត្ត-ក្រុង ខិតខំបំពេញតួនាទីរបស់ខ្លួនឱ្យអស់ពីលទ្ធភាព ដើម្បីផ្តល់នូវយុត្តិធម៌ជូនប្រជាពលរដ្ឋទាំងអស់ ដែលនេះជាការបញ្ជាក់អំពីការយកចិត្តទុកដាក់របស់សាលាដំបូងរាជធានី ខេត្ត-ក្រុង ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា និងខិតខំយកចិត្តទុកដាក់ពិនិត្យលើបញ្ហាទាំងអស់ដែលបានកើតឡើងខាងលើផងដែរ ពីព្រោះបញ្ហាទាំងនេះ គឺជាបញ្ហាដ៏សំខាន់ចំពោះមន្ត្រីតុលាការ ហើយវាក៏ជាបញ្ហាដ៏សំខាន់ផងដែរដែលធ្វើឱ្យប្រព័ន្ធយុត្តិធម៌កម្ពុជាមានការធ្លាក់ចុះ។ ការពិភាក្សាទៅលើការសិក្សានៃចក្ខុវិស័យដែល ខ្ញុំបានចុះទៅហាត់ការនៅមហាអយ្យការអមសាលាឧទរណ៍

គឺមានលក្ខណៈត្រឹមត្រូវសមស្របប្រកដ ដោយលក្ខណៈនៃការអនុវត្តនីតិវិធីជាធរមាន។ ទន្ទឹមនឹងការអនុវត្តតាមនីតិវិធីត្រឹមត្រូវជាធរមាន ក៏ពេលខ្លះមានការយោគយល់អធ្យាស្រ័យខ្លះផងដែរ ប៉ុន្តែទោះជាយ៉ាងនេះក្តី កង្វះខាតក៏នៅតែមានចំណុចតិចតួចគួរឱ្យកត់សម្គាល់ដែរ ហើយមានចំណុចខ្វះខាត និងចំណុចអវិជ្ជមានមួយចំនួនពាក់ព័ន្ធជាមួយកត្តាខាងក្នុង និងឥទ្ធិពលពីមជ្ឈដ្ឋានខាងក្រៅមួយចំនួនដែរ ។

# ឯកសារយោង

I. លិខិតបទដ្ឋានគតិយុតជាតិ


១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

២. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១០

៣. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧

៤. ច្បាប់ស្តីពីលារៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤)


II. ឯកសារជាសៀវភៅ


១. នីតិវិធីមុនជំនុំជំម្រះ និងការជំនុំម្រះ (សៀវភៅមគ្គុទ្ទេសន៍ ក៏ស្តីពីនីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជា) បោះពុម្ព ខែកុម្ភៈ ឆ្នាំ២០០៦

២. សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ដោយ Dr . Wilhelm Treiber /Aadrea Behm / Hout Sotheary បោះពុម្ពឆ្នាំ២០០៤

៣. សៀវភៅដំណើរការក្តីនៅក្នុងតុលាការកម្ពុជា រៀបរៀងដោយលោក **កុយ នាម** បោះពុម្ពឆ្នាំ១៩៩៨

៤. មេរៀននីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ **សេង ស៊ីវុត្ថា** អនុប្រធានសាលាឧទ្ធរណ៍ បោះពុម្ពឆ្នាំ ២០១៤

៥. មេរៀននីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៣ រៀបរៀងដោយលោកសាស្ត្រាចារ្យ **គង់ ស្រ៊ីម**

៦. ឯកសារមេរៀន "Research Methods " ដោយសាស្ត្រាចារ្យ **ស៊ិន សង្ហា** និងសាស្ត្រាចារ្យ **ហ៊ិន សុជាតិ** បោះពុម្ពឆ្នាំ ២០០៩

៧. វចនានុក្រម សម្តេចព្រះសង្ឃ **ជួន ណាត**

៨. សៀវភៅមេរៀន នីតិព្រហ្មទណ្ឌទូរទៅ ឆ្នាំទី២ រៀបរៀងដោយលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** បោះពុម្ពឆ្នាំ២០១៦

៩. សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌ ឆ្នាំទី៣ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** បោះពុម្ពឆ្នាំ២០១៧

១០. សៀវភៅមេរៀន នីតិព្រហ្មទណ្ឌ ឆ្នាំទី៣ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត** បោះពុម្ពឆ្នាំ២០១៧

១១. សៀវភៅមេរៀន នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត** បោះពុម្ពឆ្នាំ២០១៣

III. កិច្ចសម្ភាស

១. សួរផ្ទាល់មាត់ពី ព្រះរាជអាជ្ញា លោក **អ៊ឹម សុផាន** នៃមហាអាយ្យកានៃសាលាឧទ្ធរណ៍ ថ្ងៃទី២៥ខែមេសាឆ្នាំ២០១៩

២. សួរផ្ទាល់មាត់ពី លោកចៅក្រម លោក **អិន វ៉ាន់វិបុល** នៃមហាអាយ្យកានៃសាលាឧទ្ធរណ៍ថ្ងៃទី០៥ខែមេសាឆ្នាំ២០១៩

៣. សួរផ្ទាល់មាត់ពី លោកក្រឡាបញ្ជី លោក **ផាន់ មិថុនា** នៃមហាអាយ្យកានៃសាលាឧទ្ធរណ៍ថ្ងៃទី២៩ខែមេសាឆ្នាំ២០១៩

IV. ឯកសារពាក់ព័ន្ធផ្សេងៗទៀត

១. ឯកសារដែលពាក់ព័ន្ធមួយចំនួនបានពី នៃមហាអាយ្យកានៃសាលាឧទ្ធរណ៍

២. សារណាបញ្ចប់របស់និស្សិតគ្រប់ជំនាន់

៣. សៀវភៅដែលពាក់ព័ន្ធមាននៅក្នុងបណ្ណាល័យនានា

៤. អត្ថបទច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧)

៥. ទ្រឹស្តីនានាដែលបានសិក្សាជាមួយសាស្ត្រាចារ្យដែលមានបទពិសោធន៍ជាច្រើនឆ្នាំខាងផ្នែកព្រហ្មទណ្ឌ

៦. កម្មវិធីផ្សព្វផ្សាយច្បាប់ និង យុត្តិធម៌ (ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧)

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អធិការដ្ឋាននគរបាល ក្រុងសៀមរាប
ប៉ុស្តិ៍នគរបាលរដ្ឋបាល សង្កាត់ស្លក្រាម

## ពាក្យបណ្តឹង

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................. ភេទ [illegible] អាយុ [illegible] ឆ្នាំ ជនជាតិ [illegible]
មានអាសយដ្ឋានសព្វថ្ងៃផ្ទះលេខ.................. ផ្លូវ.................. ក្រុមទី.......... ភូមិ [illegible]
សង្កាត់/ឃុំ [illegible] ស្រុក/ក្រុង [illegible] ខេត្ត [illegible]។
មុខរបរ/មុខងារ [illegible] លេខទូរស័ព្ទ..................

## សូមគោរពចូលមក

## លោកប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល សង្កាត់ស្លក្រាម

**កម្មវត្ថុ:** សុំប្តឹងចំពោះឈ្មោះ..............................................................

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូនលោកប្រធានប៉ុស្តិ៍ សង្កាត់ស្លក្រាម មេត្តាជ្រាបថា: ខ្ញុំបាទ/នាងខ្ញុំកើតទុក្ខមិនសុខចិត្តចំពោះព្រឹត្តការណ៍កាលពីថ្ងៃទី១៨.....ខែ [illegible]..........ឆ្នាំ២០១៩.....វេលាម៉ោង.....១៣:៤០..........នាទី។
ត្រង់ចំណុច [illegible]
ចំពោះអំពើរបស់ឈ្មោះ.............................. និង.............................. ដែលបានប្រព្រឹត្ត [illegible] HUAWEI [illegible]

អាស្រ័យហេតុនេះ សូម [illegible] មេត្តាជួយស្រាវជ្រាវ និងមានវិធានការ ចំពោះជនទាំងនោះ តាមច្បាប់ជាធរមាន។
សូម [illegible] ទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ថ្ងៃទី១៨ ខែ [illegible] ឆ្នាំ២០១៩
ស្នាមមេដៃស្តាំ



អយ្យការអម
សាលាដំបូងខេត្តកណ្ដាល
ចូល លេខ 1450 ...
ថ្ងៃទី 17 ខែ 11 ឆ្នាំ ២០17
ម៉ោង 08/15 ...

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្ដឹង

នាងខ្ញុំឈ្មោះ ឃ ភេទស្រី អាយុ ៤៥ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ រស់នៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។

សូមគោរពជូន

លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកណ្ដាល

**កម្មវត្ថុ:** ១.សុំប្ដឹងពីឈ្មោះ ន ភេទស្រី អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ មុខរបរ ជាបុគ្គលិកនៅធនាគារអេស៊ីលីដាក្នុងតាខ្មៅ និង ឈ្មោះ ញ ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ មុខរបរ ជាបុគ្គលិកនៅធនាគារអេស៊ីលីដានៅឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល រស់នៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ពីបទហិង្សាដោយចេតនា និងបទបរិហារកេរ្តិ៍ជាសាធារណៈ និងគំរាមកំហែងសម្លាប់។

តបតាមកម្មវត្ថុដូចបានជំរាបជូនខាងលើ នាងខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាមេត្តាជ្រាបថា:កាលពីថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង៨ព្រឹក នាងខ្ញុំបានធ្វើដំណើរពីផ្ទះនៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ទៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាលដើម្បីទៅទាមទារ ប្រាក់ពីអ្នកម៉ៅផ្លែស្វាយរបស់នាងខ្ញុំ ប៉ុន្តែមិនបានជួបអ្នកម៉ៅផ្លែស្វាយនាងខ្ញុំទេ លុះដល់ម៉ោង១១ថ្ងៃត្រង់ នាងខ្ញុំបានចេញដំណើរត្រឡប់មកផ្ទះវិញ ពេលចេញដំណើរប្រហែល២០ ទៅ៣០ម៉ែត្រស្រាប់តែ ឈ្មោះ ញ បានចេញមកស្ទាក់ផ្លូវនាងខ្ញុំ ហើយនិយាយថាអ្នកឯងមកកន្លែងនឹងធ្វើស្អី នាងខ្ញុំបានឆ្លើយថាមកទារលុយពីអ្នកម៉ៅផ្លែស្វាយ នៅពេលនោះបានលេចមុខឈ្មោះ ន សួរនាំហេតុអ្វីអ្នកឯងដើរនិយាយញុះញង់ឲ្យគ្រួសារវាបែកបាក់គ្នា ហើយក៏ស្ទុះវាយដំមកលើរូបរាងកាយរបស់នាងខ្ញុំបណ្ដាលឲ្យរងរបួសយ៉ាងដំណំ ហើយបានគំរាមនាងខ្ញុំ បើមកជាន់ទឹកដីនឹងទៀតវានឹងសម្លាប់ចោល បន្ទាប់មកបានឈ្មោះ ន បានគេហៅនគរបាលប៉ុស្តិ៍ទឹកឃ្លាំងឲ្យឃាត់នាងខ្ញុំអស់រយៈជិតមួយថ្ងៃ គឺចាប់ពីម៉ោង ១៥រសៀល រហូតដល់ម៉ោង ២៤យប់ ទើបឲ្យនាងខ្ញុំទៅផ្ទះ ក្រោយពីគំរាមសួរចម្លើយពុំមានបទល្មើសអ្វីនគរបាលប៉ុស្តិ៍បានឲ្យនាងខ្ញុំត្រឡប់មកផ្ទះវិញ ប៉ុន្តែមុននឹងឲ្យនាងខ្ញុំចេញទៅនគរបាលប៉ុស្តិ៍បានគំរាមនាងខ្ញុំដោយស្ថានភាពស្រវឹងស្រាមិនឲ្យនាងខ្ញុំជាន់ទឹកដីភូមិទឹកឃ្លាំងបន្តទៀតទេ។ ក្នុងរឿងនេះនាងខ្ញុំមិនដឹងថាឈ្មោះ ន និងឈ្មោះ ញ និងមេប៉ុស្តិ៍ត្រូវគ្នាយ៉ាងណានោះទេ ទើបហ៊ានវាយនាងខ្ញុំហើយនឹងហ៊ានប្ដឹងទៅ មេប៉ុស្តិ៍ឃាត់ខ្លួននាងខ្ញុំ ទាំងនាងខ្ញុំមិនបានដឹងរឿងអ្វីសោះហើយរឿងនេះពុំដឹងមេប៉ុស្តិ៍ចាត់ការយ៉ាងណានោះទេ ក៏ព្រោះចាប់ពីថ្ងៃដែលមេប៉ុស្តិ៍រកត់ជូននាងខ្ញុំរហូតមកដល់ពេលនេះ ពុំមានដំណើរការពីចំណាត់ការនៃរឿងនេះឡើយ។

ក្នុងរឿងនេះនាងខ្ញុំសំណូមពរសូមទាមទារសំណងជម្ងឺចិត្តក្នុងការបាត់បង់កិត្តិយសនិងថ្លៃថ្នាំព្យាបាល

២០ ០០០(ពីរម៉ឺន)ដុល្លារអាមេរិក និងសូមចាប់ខ្លួន និងឃុំខ្លួនឈ្មោះ ន និងឈ្មោះ ញ ដើម្បីផ្តន្ទាទោសតាមផ្លូវច្បាប់។

នាងខ្ញុំសុំបញ្ជាក់ថា នាងខ្ញុំមិនដែលស្គាល់ឈ្មោះ ន នេះទេ ហើយក៏មិនដែលមានទំនាក់ទំនងអ្វីជាមួយគ្នាពីមុនមកដែរ។ នៅក្នុងករណីនេះនាងខ្ញុំមានសាក្សី ២នាក់គឺឈ្មោះ ច ភេទប្រុស រស់នៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និងឈ្មោះ យ រស់នៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

អាស្រ័យហេតុនេះសូម **លោកព្រះរាជអាជ្ញា** មេត្តាទទួលដោះស្រាយបណ្តឹងរបស់នាងខ្ញុំដោយក្តីអនុគ្រោះ ។

សូម **លោកព្រះរាជអាជ្ញា** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ធ្វើនៅកណ្តាល, ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧

**ស្នាមម្រាមដៃ**



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកំពត

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៣៩៧

ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧

<u>ដីកាកោះ</u>

**យើង ខាន់ សុផល ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពត។**

-អញ្ជើញឈ្មោះ ត ភេទស្រី អាយុ៤៧ឆ្នាំ មានទីលំនៅផ្ទះលេខ៣ក ផ្លូវ៣៧១ ភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-អោយចូលទៅកាន់*អយ្យការអមសាលាដំបូងខេត្តកំពត* នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ វេលាម៉ោង 8 : 30. ដើម្បី*សាកសួរ* ។

-ពីដំណើររឿង: ឆបោក តាមពាក្យបណ្តឹងរបស់ឈ្មោះ ត ។

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះ ឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹង រឿងខាងលើមកជាមួយផងប្រសិនបើមាន។

ធ្វើនៅអយ្យការ, ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១៧

ព្រះរាជអាជ្ញារង

ខាន់_សុផល

---

យើង..........................................................................................................

បានប្រគល់ដីកាកោះឲ្យចូលខ្លួនឲ្យឈ្មោះ..............................ទីលំនៅបច្ចុប្បន្ននៅភូមិ..............................

ឃុំ/សង្កាត់.......................................ស្រុក/ខណ្ឌ..........................................................

ខេត្ត/រាជធានី.......................................នៅថ្ងៃទី...........ខែ..............ឆ្នាំ..................ផ្តល់រួចហើយ

ដោយយើងបានទុកចុងដីកាមួយច្បាប់អោយសាមីខ្លួនហើយប្រាប់ថាអោយសាមីខ្លួនប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលខ្លួនចូលទៅដល់សាលាដំបូងខេត្តកំពត។

អ្នកទទួលលិខិត　　　　　　　　អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកំពត
សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៧
ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧

បានចំភ្ជាប់
កំពត ថ្ងៃទី28 ... ខែ ៣ ឆ្នាំ2017

## កំណត់ហេតុសួរចម្លើយ

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែឧសភា ថ្ងៃទីម្ភៃប្រាំបួន វេលាម៉ោង ប្រាំបួន និងសាមសិបនាទីព្រឹក។

យើង **ខាន់ សុផល** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពត

ដោយមានលោក គង់ រ៉ាវន ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់

ឈ្មោះ ល

សួរ-ឆ្លើយ: ល ភេទស្រី អាយុ៤៧ឆ្នាំ ទីកន្លែងកំណើតនៅភូមិអូរច្រនៀង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត និងបច្ចុប្បន្ននៅភូមិទ្រា សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មុខរបរលក់ដូរ កាន់សាសនាព្រះពុទ្ធ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ)ប្តីឈ្មោះ (ស) មានកូន០២នាក់ ទោសពីមុនគ្មាន។

សួរ-ឆ្លើយ: សូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញារង ជ្រាបថា: នាងខ្ញុំពុំដែលធ្លាប់លក់ដី នៅស្រុកកំពង់ត្រាចឱ្យឈ្មោះ លី ទេ។

សួរ-ឆ្លើយ: នាងខ្ញុំ ពិតជាបានប្រគល់សិទ្ធិឱ្យឈ្មោះ ត . ឈរឈ្មោះធ្វើប្លង់ដីឱ្យនាងខ្ញុំ មែន ដោយសារខ្ញុំរស់នៅភ្នំពេញ ពិបាកឡើងចុះ។ សូមបញ្ជាក់ថា: ដីនៅស្រុកកំពង់ត្រាចនេះ គឺជាដីដែលម្តាយខ្ញុំ ចែកឱ្យ។ ខ្ញុំទើបតែដឹងថាឈ្មោះ ល បានបន្លំយកប្លង់ពីឈ្មោះ ត ក្នុងអំឡុងឆ្នាំ២០១៦ គឺនៅពេលខ្ញុំមកលេងស្រុកហើយ ឃើញបិទផ្លូវ និងសង់ផ្ទះលើដីនោះ ហើយខ្ញុំក៏ទៅសួរនោះឈ្មោះ ត ទើបខ្ញុំដឹង។

សួរ-ឆ្លើយ: ចំពោះប័ណ្ណកម្មសិទ្ធិ០២ប័ណ្ណ គឺខ្ញុំពុំដែលបានទទួលទេ គឺខ្ញុំឱ្យឈ្មោះ ត ធ្វើនិងថែរក្សាទុក សូម្បីប្លង់លេខប៉ុន្មាន ក៏ខ្ញុំពុំដឹងដែរ។

សួរ-ឆ្លើយ:សំណូមពរដល់លោកព្រះរាជអាជ្ញារង ជួយរកយុត្តិធម៌ និងទាមទារប្លង់ដីខាងលើ យកមកវិញ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ ។

ឈប់សួរ បានអានឱ្យស្តាប់ សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតម្រាមដៃជាមួយហើយ។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|
| | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

មន្ទីរស៊ើបសួរលេខ(ត)

លេខ ១៣២២.......

## លិខិតជូនដំណឹងដើមបណ្តឹងរដ្ឋប្បវេណី

យើង **ខុន ឌុទ្ធី** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ជូនដំណឹងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទស្រី អាយុ ៤៤ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរសំណុំរឿងលេខ: ១៤៥០ អ.ក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ ពីបទ: **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួរហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាដំណឹង។

ថ្ងៃ............ខែ............ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

កណ្ដាល, ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

ខុន ឌុទ្ធី

យើង..................................បានប្រគល់លិខិត ជូនដំណឹងនេះដល់ឈ្មោះ..................................

ទីលំនៅភូមិ......................ឃុំ......................ស្រុក......................ខេត្ត......................នៅថ្ងៃទី.......

ខែ................ឆ្នាំ...........ផ្ដាល់ដៃរួច ហើយ។

ធ្វើនៅថ្ងៃទី..........ខែ..................ឆ្នាំ២០១៨

អ្នកទទួល អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
មន្ទីរស៊ើបសួរលេខ(គ)
លេខ ១៣៦/ស......

## លិខិតជូនដំណឹងជនត្រូវចោទ

យើង **ខួន ឌុន្នី** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

ជូនដំណឹងជនត្រូវចោទឈ្មោះ           ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារអេស៊ីលីដា ទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរសំណុំរឿងលេខ: ១៤៥០ អ.ក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ពីបទ: **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ចៅក្រមស៊ើបសួរ បានបញ្ចប់ការស៊ើបសួរហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាដំណឹង។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កណ្ដាល, ថ្ងៃទី១២ ខែ...... ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

ខួន ឌុន្នី

យើង.......................................បានប្រគល់លិខិត ជូនដំណឹងនេះដល់ឈ្មោះ..................................
ទីលំនៅភូមិ.......................ឃុំ......................ស្រុក.......................ខេត្ត.......................នៅថ្ងៃទី......
ខែ.................ឆ្នាំ...........ផ្ទាល់ដៃរួច ហើយ។

ធ្វើនៅថ្ងៃទី..........ខែ..................ឆ្នាំ២០១៨

អ្នកទទួល                    អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងលេខ:........................

លេខស៊ើបសួរ:........................

# កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង

(មាត្រា ១៨៣, ១៨៨, ២៨០ និងមាត្រា២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកុម្ភៈ ថ្ងៃទីដប់ប្រាំ វេលាម៉ោង ........................ ។

យើង **គឹម សុគន្ធា** ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប អមដោយលោកស្រី **គុជ មករា** ជាក្រឡាបញ្ជីអមផង ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោម ៖

ឈ្មោះ ស ភេទប្រុស អាយុ២៥ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិជលែង ឃុំមានជ័យ ស្រុក ខេត្តកំពង់ធំ អាស័យដ្ឋាននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប មុខរបរ រើសអេតចាយ ឪពុកឈ្មោះ ស ម្ដាយឈ្មោះ (រ) កំរិតវប្បធម៌ថ្នាក់ទី២ ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

តើអ្នកឯងចេះអាន និង សរសេរភាសាខ្មែរដែរ ឬ ទេ?

☐ ចេះអាន និងចេះសរសេរភាសាខ្មែរ ☐ មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរ

☐ ជននេះបានប្រកាសថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ (ដប់)ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន ។

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះ ឲ្យបានដឹងយ៉ាងច្បាស់អំពីរឿងក្តីនីមួយៗ ដែលព្រះរាជអាជ្ញាបានប្ដឹងមកយើងតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៧៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ដោយជននេះត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: អំពើលួច ប្រព្រឹត្តនៅចំណុចហាងក្រែបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ភូមិឆ្លកអណ្ដូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០១៨ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ។

យើងបានជូនដំណឹងដល់ជននេះថា យើងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងក្តីដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់ ។

លោក-លោកស្រី ........................ ជាមេធាវី[1] នៃជនត្រូវចោទ ដែលត្រូវបានកោះហៅនៅថ្ងៃទី........................ ហើយដើម្បីឲ្យ លោក-លោកស្រីមេធាវី អាចត្រៀមរៀបចំការពារក្តីខ្លួនបាន ។

យើងបានប្រាប់ដល់ជននេះអំពី ៖

- សិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើសតែងតាំងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យតុលាការចាត់តាំងមេធាវីណាម្នាក់ឲ្យ ។

[1] ករណីមានមេធាវី

- ប្រសិនបើមិនធ្វើការជ្រើសរើសពីងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូបនឹងត្រូវចាត់តាំងដោយឯកឯងដោយសារតែជននេះ ជាអនីតិជន ។

ជននេះ បានប្រកាសប្រាប់ថា ៖ □ ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង □ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវី មួយរូបឲ្យខ្ញុំ □ ខ្ញុំបដិសេធជំនួសពីមេធាវី ។

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយ ក៏បាន ឬអាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន ។

ជននេះបានប្រកាសថា ៖ ..........................................................................................

..........................................................................................................................

..........................................................................................................................

លោក-លោកស្រីមេធាវី..........................................................បានផ្តល់សេចក្តីកត់សម្គាល់ការពារថា ៖

..........................................................................................................................

..........................................................................................................................

..........................................................................................................................

យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យ ៖

□ ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង ។

□ ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះអំពីឈ្មោះនៃបទល្មើស

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹងសុំមោឃភាពនៃកិច្ចស៊ើបសួរដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា២៦៧ នៅក្នុងពេលនៃដំណើរការនៃការស៊ើបសួរ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទអំពីសិទ្ធិក្នុងការជ្រើសមេធាវី សម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ និងបើសិនជាមានសំណើសុំយើងនឹងចាត់តាំងមេធាវីមួយរូបជន (សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពីងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីជូន ) ។

ជនត្រូវចោទ បានប្រកាសប្រាប់ថា ៖ □ ខ្ញុំជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង □ ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ □ ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ជនត្រូវចោទថា អ្នកឯងអាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេច ៖ □ ឃុំខ្លួនបណ្តោះអាសន្ន □ មិនឃុំខ្លួនបណ្តោះអាសន្ន □ ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

យើងបានប្រាប់ដល់ជនត្រូវចោទថា ៖

- ត្រូវប្រកាសប្រាប់អំពីអាសយដ្ឋានដែលជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកយកលិខិតដែលបញ្ជូនទៅឲ្យ ប្រសិនបើគាត់អាចផ្តល់ឲ្យភ្ជាប់នូវការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររបស់តតិយជននោះ ។
- អាសយដ្ឋានដែលត្រូវប្រកាសប្រាប់ត្រូវមានទីតាំងស្ថិតនៅ ................................................................................................................................................... ។
- អាសយដ្ឋាននេះជា □ អាសយដ្ឋានផ្ទាល់ខ្លួន □ អាសយដ្ឋានរបស់.................................................................................................................................................. ។
- ហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់ដល់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋានដែលបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ ។
- គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋានដែលជនបានប្រកាសប្រាប់ចុងក្រោយបង្អស់ ត្រូវចាត់ទុកថាជូនដំណឹងដល់បុគ្គលជនត្រូវចោទ ។

□ យើងបានឲ្យជនត្រូវចោទឲ្យអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលកំណត់ហេតុនេះ ហើយបើមិនបដិសេធគ្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ ។

□ បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី ។

□ បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ ។[២]

| ជនត្រូវចោទ | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|---|
| | គុំ បកវ | |

[២] គ្រប់ទំព័រត្រូវអនុវត្តតាមមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ១៧៦៣ ប- ដដ

# ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

យើង ស្វាយ គុញ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក ឈឿន សុខន ជាក្រឡាបញ្ជី ។
-បានឃើញ មាត្រា ២៤៧ មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧២៨ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ។
-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៤៦៩ អយម ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៧ ។
-បានឃើញសំណុំរឿងស៊ើបសួរលេខ ២៤៤០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ។
-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១២១២ អយម ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយ យល់ឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់លើ ៖

-ឈ្មោះ ត ភេទប្រុស អាយុ៤ឆ្នាំ ជាតិខ្មែរ មុខរបរ អាជីវករ ទីកន្លែងកំណើត ភូមិគោកមន ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ ផ្ទះលេខ១៧៨២ ផ្លូវលេខ ១៤៦ ភូមិទី៥ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ "រ" ម្ដាយឈ្មោះ "ស" ប្រពន្ធឈ្មោះ ស្រីពៅ មានកូនចំនួន០៣នាក់ ជានីតិជន ប្រវត្តនៃការផ្ដន្ទាទោសដោយតុលាការពីមុន គ្មាន។ (ក្រៅឃុំ)

-ដោយមានលោកមេធាវី ជា លើ និងលោក ហេង សុធា ជាមេធាវីការពារសិទ្ធិ។

ត្រូវបានដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃនៅក្នុងអំឡុងឆ្នាំ២០១២បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

-បញ្ជូនជនត្រូវចោទខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧២៨ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញ ដើម្បីកំណត់ពេលជំនុំជម្រះ ។

ថ្ងៃសុក្រ ៦ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨

បានទទួលដំណឹង
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨
ជ.ព្រះរាជអាជ្ញា

រឿង សុខ

ក្រឡាបញ្ជី

ឈឿន សុខន

ចៅក្រមស៊ើបសួរ

ស្វាយ គុញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូង ខេត្តកំពត
* * * * * *

លេខ: 241 អ.យ.ខ

## លិខិតជូនដំណឹង

យើង ខាន់ សុផល តំណាងអយ្យការអម សាលាដំបូងខេត្តកំពត ។

ជម្រាបមកឈ្មោះ ត... ជាដើមបណ្តឹងរដ្ឋប្បវេណី មានទីលំនៅសព្វថ្ងៃនៅភូមិអូរច្រនៀង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២២/០៥/២០១៧ របស់ឈ្មោះ ត... ពីបទៈឆបោក ដែលមានក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ២៣/០៥/២០១៧ នោះ យើងបានសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ 240 ចុះថ្ងៃទី 17 ខែសីហា ឆ្នាំ២០១៧ រួចហើយ ។

លោក-លោកស្រី មានសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

ធ្វើនៅកំពត ថ្ងៃទី 17 ខែសីហា ឆ្នាំ២០១៧
តំណាងអយ្យការ

ខាន់_សុផល

---

យើង..........................................................................................................
បានប្រគល់លិខិតជូនដំណឹងនេះឱ្យទៅឈ្មោះ............................................................
..នៅភូមិ.........................................................ឃុំសង្កាត់.......................................................
...ស្រុក-ខណ្ឌ..................................................... ខេត្ត.............................................
កាលពីថ្ងៃទី..................................................... ដោយផ្ទាល់រួចហើយ ។

អ្នកប្រគល់ អ្នកទទួល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកំពត
សំណុំរឿងព្រហ្មទណ្ឌលេខ: ៣៩៧
ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៧
លេខ: 240 អ.យ.ខ/០១៧

## ដីកាតម្កល់រឿងទុកឥតចាត់ការ

*យើង ខាន់. សុផល តំណាងអយ្យការអម សាលាដំបូងខេត្តកំពត ។*

-បានឃើញមាត្រា ៤០, ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស/រក.ម ០៨០៧/០២៤ ចុះថ្ងៃទី ១០/៨/២០០៧ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ២៣/០៥/២០១៧ របស់អយ្យការអមសាលាដំបូង ខេត្តកំពត ។

*ក្រោយពីបានពិនិត្យឯកសារសំណុំរឿងខាងលើ*

*ឃើញថា:* តាមពាក្យបណ្តឹង និងចម្លើយរបស់ឈ្មោះ ត - បានប្តឹងឈ្មោះ ល ពីករណី ឆបោក ។ តាមការស៊ើបអង្កេតនៅដំណាក់កាលអយ្យការឃើញថា: អង្គហេតុខាងលើនេះបង្ហាញពីវិវាទ នៃកម្មសិទ្ធិ និងការកាន់កាប់ផ្ទាល់របស់ភាគី ដែលជាសមត្ថកិច្ច របស់តុលាការរដ្ឋប្បវេណី។

-បានឃើញពាក្យបណ្តឹងរបស់ឈ្មោះ ត ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧។

-បានឃើញចម្លើយរបស់ឈ្មោះ ត និងឈ្មោះ ល ,ឈ្មោះ ល ។

-បានឃើញឯកសារផ្សេងៗ ក្នុងសំណុំរឿង។

*យល់ឃើញថា*

-តាមពាក្យបណ្តឹង និងចម្លើយរបស់ឈ្មោះ ត បង្ហាញថា: ខ្លួនពិតជាបានឈរឈ្មោះ លើ ប្លង់ដី០២ កន្លែង ស្ថិតនៅភូមិអូរច្រនៀង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ជំនួសឱ្យឈ្មោះ លឹម គីមស៊ិន (ត្រូវជាក្មួយ) ដែលរស់នៅភ្នំពេញ ប្រាកដមែន។ ហើយខ្លួនពិតជាបានប្រគល់ប្លង់ដីទាំងពីរនោះឱ្យទៅឈ្មោះ ល ក្នុងអំឡុងឆ្នាំ២០១០ ពិតប្រាកដ ដែលសព្វថ្ងៃនេះឈ្មោះ ល ពិតជាបានកំពុងកាន់កាប់ និងធ្វើផ្ទះស្នាក់នៅលើដីនោះ ប្រាកដមែន។

-តាមចម្លើយរបស់ឈ្មោះ ល បង្ហាញថា: ខ្លួនពិតជាបានប្រគល់សិទ្ធិឱ្យឈ្មោះ ត ឈរឈ្មោះលើប្លង់ដី របស់ខ្លួនមែន(ដីកេរ្តិ៍ម្តាយ) ហើយខ្លួនទើបដឹងថាឈ្មោះ ល បន្ទិយកប្លង់ដី ពីឈ្មោះ ត នៅពេលដែលខ្លួនមកលេងស្រុកកំណើត។ តែមិនដឹងថាប្លង់នោះលេខប៉ុន្មានទេ ព្រោះពុំដែលទទួល។

- តាមចម្លើយឈ្មោះ ល បង្ហាញថា: កាលពីឆ្នាំ២០០៤ ខ្លួនបានទិញដីពីឈ្មោះ ឃ (សព្វថ្ងៃរស់នៅជាមួយឈ្មោះ ល ) ដោយពុំមានលិខិតបញ្ជាក់អ្វីទេ ពេលទិញនោះ ពុំដឹងថាមានប្លង់ ឬពុំមានទេ ក្នុងតម្លៃ៦៥០ដុល្លារអាមេរិក ។ លុះដល់ឆ្នាំ២០០៥ឈ្មោះ ឃ បានឱ្យខ្លួនទៅយកប្លង់ដីចំនួន២ ពីឈ្មោះ ត ដែលពេលនោះមានឈ្មោះ ល ជាអ្នកយកមកឱ្យខ្លួន។ ហើយខ្លួនបានធ្វើផ្ទះតាំងពីឆ្នាំ២០០៧ ដោយគ្មានខរណាតវ៉ាឡើយ។

-ឈ្មោះ ណ បានសាងសង់ផ្ទះ និងស្នាក់នៅលើទីតាំងខាងលើតាំងពីឆ្នាំ២០០៧ មកម្ល៉េះ ដោយគ្មានការតវ៉ា ឬរារាំងពីបុគ្គលណាឡើយ។

-ការកាន់កាប់ និងការរស់នៅរបស់ឈ្មោះ ល គឺធ្វើឡើងដោយសំអាងថា ទិញពីឈ្មោះ ឃ និងគ្មានការជំទាស់ពីភាគីណាឡើយ។

-អង្គហេតុខាងលើបង្ហាញពីវិវាទ នៃកម្មសិទ្ធិ និងការកាន់កាប់ផ្ទាល់របស់ភាគី ដែលជាសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណី។

-អង្គហេតុខាងលើ បង្ហាញពីអវត្តមាននៃបទល្មើស។

-គប្បីតម្កល់សំណុំរឿងព្រហ្មទណ្ឌខាងលើ ទុកឥតចាត់ការ តទៅ។

<u>***ហេតុដូច្នេះ***</u>

១-តម្កល់សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ២៣/០៥/២០១៧ ទុកឥតចាត់ការ តទៅ

២-បង្គាប់ឱ្យក្រឡាបញ្ជីជូនដំណឹងទៅដើមបណ្តឹងរដ្ឋប្បវេណី តាមច្បាប់ ។

ធ្វើនៅកំពត, ថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៧

ព្រះរាជអាជ្ញា

តំណាងអយ្យការ

ខាន់_សុផល

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

កំពត,ថ្ងៃទី 26 ១៣ ឆ្នាំ 2017...

ក្រឡាបញ្ជី

6/3

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តកំពត
លេខ 28 ចុះថ្ងៃទី 13
ខែ 10 ឆ្នាំ 2017
សំណុំរឿងព្រហ្មទណ្ឌលេខ 397
ថ្ងៃទី 23 ខែ 5 ឆ្នាំ 2017

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
កំពត,ថ្ងៃទី 26 ខែ [illegible] ឆ្នាំ 2017
ក្រឡាបញ្ជី

## បណ្ដឹងឧទ្ធរណ៍

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែ [illegible] ថ្ងៃទី [illegible] វេលាម៉ោង [illegible]
យើង ម៉ាន់ បូរេត ប្រធានលេខាធិការដ្ឋានរដ្ឋបាល សាលាដំបូង ខេត្តកំពត ។
បានឃើញឈ្មោះ [illegible]
ចូលមកចំពោះមុខយើង នៅលេខាធិការដ្ឋានរដ្ឋបាល សាលាដំបូង ខេត្តកំពត ហើយសុំប្ដឹងឧទ្ធរណ៍
និង [illegible] លេខ 241 ចុះថ្ងៃទី 17 ខែ 8 ឆ្នាំ 2017
គ្រប់ចំណុច [illegible] លេខ 241 ចុះថ្ងៃទី 17-8-2017
[illegible]

ក្រែងពុំពិតប្រាកដ យើងបានសូត្រសេចក្ដីនេះ ឲ្យឈ្មោះ [illegible]
ស្ដាប់ហើយឲ្យចុះហត្ថលេខា ឬ ផ្ដិតមេដៃជាមួយយើង ។

អ្នកប្ដឹង
ស្នាមមេដៃ ឬ ហត្ថលេខា

ប្រធានលេខាធិការដ្ឋានរដ្ឋបាល
ហត្ថលេខា
ម៉ាន់ បូរេត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
កំពត, ថ្ងៃទី 13 ខែ [illegible] ឆ្នាំ ២០១៧
ប្រធានលេខាធិការដ្ឋានរដ្ឋបាល
ម៉ាន់ - បូរេត

បានឃើញ
ព្រះរាជអាជ្ញា
ឯក ខេមឫទ្ធី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានរដ្ឋបាល សាលាដំបូងខេត្តកំពត
ចូល
លេខៈ 2118
ថ្ងៃទី 13 ខែ 10 ឆ្នាំ 2017
ម៉ោង 10 ព្រឹក នាទី

## បណ្តឹងឧទ្ធរណ៍

នាងខ្ញុំឈ្មោះ ត អាយុ ៧២ ឆ្នាំ ជនជាតិ ខ្មែរ សញ្ជាតិ ខ្មែរ មានទីលំនៅ ភូមិអូរព្រនៀង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។

**សូមគោរពជូន**

**ឯកឧត្តម ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តកំពត**

**សូមជ្រាប** ។

**កម្មវត្ថុ:** សំណើសុំប្តឹងឧទ្ធរណ៍ ។

**យោង:** លិខិតជូនដំណឹងលេខ ២៤១ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៧ របស់លោក ព្រះរាជអាជ្ញារង ខ នៃអយ្យការអមសាលាដំបូងខេត្តកំពត ។

នាងខ្ញុំសុំប្តឹងឧទ្ធរណ៍នឹងដីកាតម្កល់រឿងក្តីខ្ញុំបាទទុកឥតចាត់ការ មានលេខយោងខាងលើ ដោយ ប្តឹងឈ្មោះ ល ពីករណី ឆបោក ដែលមានសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ២៣/០៥/២០១៧ ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមលោក ព្រះរាជអាជ្ញា មេត្តាចាត់បញ្ជូន សំណុំរឿង ខាងលើរបស់នាងខ្ញុំ ទៅសាលាឧទ្ធរណ៍ ដើម្បីចាត់ការបន្តតាមនីតិវិធីដោយក្តីអនុគ្រោះ ។

សូមលោក ព្រះរាជអាជ្ញា ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ធ្វើនៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៧

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
កំពត,ថ្ងៃទី26 ខែ១៣ ឆ្នាំ2017
ក្រឡាបញ្ជី

ស្នាមមេដៃស្តាំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូង ខេត្តកំពត

* * * * * *

លេខ: 241 អ.យ.ខ

## លិខិតជូនដំណឹង

យើង ខាន់ សុផល តំណាងអយ្យការអម សាលាដំបូងខេត្តកំពត ។

ជម្រាបមកឈ្មោះ ត ជាដើមបណ្ដឹងរដ្ឋប្បវេណី មានទីលំនៅសព្វថ្ងៃនៅភូមិអូរច្រនៀង ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត។

ក្បិតពាក្យបណ្ដឹង ចុះថ្ងៃទី ២២/០៥/២០១៧ របស់ឈ្មោះ ត ពីបទ:ឆបោក ដែលមានក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី ២៣/០៥/២០១៧ នោះ យើងបានសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ 240 ចុះថ្ងៃទី 17 ខែសីហា ឆ្នាំ២០១៧ រួចហើយ ។

លោក-លោកស្រី មានសិទ្ធិប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

ធ្វើនៅកំពត, ថ្ងៃទី 17 ខែសីហា ឆ្នាំ២០១៧

តំណាងអយ្យការ

ខាន់ សុផល

---

យើង [illegible]

បានប្រគល់លិខិតជូនដំណឹងនេះឲ្យទៅឈ្មោះ.....

នៅភូមិ..... [illegible] ..... ឃុំសង្កាត់ ..... [illegible] .....

.....ស្រុក-ខណ្ឌ..... [illegible] ..... ខេត្ត ..... [illegible] .....

កាលពីថ្ងៃទី..... 02 . 09 . 2017 ..... ដោយផ្ទាល់រួចហើយ ។

អ្នកប្រគល់

អ្នកទទួល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង

លេខ ៤៤៧៧ ត.៧.

# ដីកាសម្រេច

## ដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង **ជា ខណ្ណៈ** ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តបាត់ដំបង អមដោយលោក **អាំង ម៉ុនធឿន** ជាក្រឡាបញ្ជី។

បានឃើញមាត្រា ២២៣ មាត្រា ២២៦ និងមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៧២៩ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៤២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២១៤ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៥។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

### យល់ឃើញថា

-សំណុំរឿងស៊ើបសួរមិនទាន់ត្រូវបានស៊ើបសួរមូលនៅឡើយទេ ប៉ុន្តែជនត្រូវចោទមិនត្រូវបានឃុំខ្លួន។

-ដើម្បីធានាថា ជនត្រូវចោទមានវត្តមានចំពោះមុខតុលាការ និងដើម្បីជៀសវាងការរាំងស្ទះក្នុងនីតិវិធីស៊ើបសួរ ចៅក្រមស៊ើបសួរគប្បីសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមបញ្ញត្តិមាត្រា ២២៣ មាត្រា ២២៦ និងមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ហេតុដូច្នេះ សម្រេច

១.ឲ្យឈ្មោះ យ ភេទប្រុស អាយុ៤៦ឆ្នាំ ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដូចខាងក្រោម៖

ក.ជនត្រូវចោទឈ្មោះ យ ត្រូវឆ្លើយតប និងការកោះហៅរបស់តុលាការគ្រប់ពេលវេលា។

ខ.បើមានការផ្លាស់ប្តូរទីលំនៅ ត្រូវរាយការប្រាប់ចៅក្រមស៊ើបសួរ។

២.ក្នុងករណីជនត្រូវចោទមិនបានអនុវត្តតាមចំណុចទី១ខាងលើនេះ ចៅក្រមស៊ើបសួរនឹងចាប់ឃុំខ្លួនជនត្រូវចោទ តាមបញ្ញត្តិមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.ដីកាសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តភ្លាមៗ។

បានទទួលដំណឹងហើយ

ថ្ងៃទី ០២ ខែតុលា ឆ្នាំ២០១៥

តំណាងអយ្យការ

B. ...

ក្រឡាបញ្ជី

បាត់ដំបង ថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៥

ចៅក្រមស៊ើបសួរ

ជា_ខណ្ណៈ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

.........

សាលាដំបូងខេត្តកំពត

.........

ក្រុមស៊ើបសួរ (ខ)

លេខ: ៩១៣

# ដីកាបង្គាប់ឲ្យទទួល-ថែរក្សាវត្ថុចាប់យក

- យើង **តុប ឈុនសុខ** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកំពត។
- ដោយមានកញ្ញា ហង់ ចរិយា ជាក្រឡាបញ្ជីនៅក្នុងសំណុំរឿងនេះ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ:២៥៧ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០១៨។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ១៥៦ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១៨។
- បានឃើញសំណុំរឿងស៊ើបសួរលេខ: ១៥០ ចុះថ្ងៃទី២១ ខែ មេសា ឆ្នាំ ២០១៨។
- បានឃើញកំណត់ហេតុប្រគល់-ទទួលវត្ថុតាង ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៨។

**<u>បង្គាប់មក:</u>** លោកប្រធាន លេខាធិការដ្ឋានរដ្ឋបាល នៃសាលាដំបូងខេត្តកំពត ឲ្យទទួលថែរក្សាវត្ថុតាង ដូចមានក្នុងកំណត់ហេតុប្រគល់-ទទួលវត្ថុតាង ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៨ ភ្ជាប់មកជាមួយសំណុំរឿងព្រហ្មទណ្ឌលេខ: ២៥៧ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨ ដែលមានជនត្រូវចោទឈ្មោះ ក ភេទប្រុស អាយុ២៨ឆ្នាំ និងឈ្មោះ ស ភេទប្រុស អាយុ២១ឆ្នាំ ត្រូវចោទប្រកាន់ពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិឃ្លាំងខាងជើង ឃុំភ្នំប្រាសាទ ស្រុកកំពង់ត្រាច ខេត្តកំពត បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០.៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ថ្ងៃច័ន្ទ ៥ កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១

ធ្វើនៅខេត្តកំពត ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៨

| ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|
| ហង់_ចរិយា | តុប_ឈុនសុខ |

| បានទទួល និងបង្គាប់មក | អ្នកទទួល |
|---|---|
| ទទួលគ្រប់គ្រង និង ថែរក្សាទុក ថ្ងៃទី 23 ខែមេសា ឆ្នាំ 2018 ប្រធានលេខាធិការដ្ឋាន | យ៉ែ |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូង..............................
លេខ:................................/អ.យ

# ដីកាបញ្ជូនរឿងទៅជំនុំជំរះផ្ទាល់

យើង ....................................អយ្យការអមសាលាដំបូង............................។

- បានឃើញ សំរឿងព្រហ្មទណ្ឌលេខ:.............ចុះថ្ងៃទី.........ខែ.................ឆ្នាំ២០១.........របស់អយ្យការអមសាលាដំបូង...............................................................................។

- បានឃើញ មាត្រា ៤៦, ៤៩, ២៩៥, ៤៥៧, នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់:

យល់ឃើញថា ..........................................................................................

..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................
..........................................................................................................

## ហេតុដូច្នេះសម្រេច

១/ចោទប្រកាន់លើឈ្មោះ.............................ហៅ........................ភេទ □ប្រុស□ស្រី អាយុ......ឆ្នាំ

ជាតិ...............................មុខរបរ..........................................................................................

ទីកន្លែងកំណើត.............................................ឃុំ-សង្កាត់..................................................

ស្រុក-ខណ្ឌ....................................................ខេត្ត-ក្រុង..................................................។

ទីលំនៅបច្ចុប្បន្ន...............................................ឃុំ-សង្កាត់..................................................

ស្រុក-ខណ្ឌ....................................................ខេត្ត-ក្រុង..................................................។

ទោសពីមុន..........ឪពុកឈ្មោះ..........................□រ-□ស ម្ដាយឈ្មោះ..........................□រ-□ស

ប្ដី ឬ ប្រពន្ធឈ្មោះ........................□រ-□ស មានកូន........នាក់ ឬ □នៅលីវ□អនីតិជន □នីតិជន។

ត្រូវជាប់ចោទពីបទ:...........................................................................................................

ប្រព្រឹត្តនៅ........................................................ឃុំ-សង្កាត់..................................................

ស្រុក-ខណ្ឌ....................................................ខេត្ត-ក្រុង..................................................

កាលពីថ្ងៃទី..........ខែ..................ឆ្នាំ២០១.....តាមបញ្ញត្តិមាត្រា..............................................

នៃ..............................................................................................................................។

២/បញ្ជូនជនជាប់ចោទដូចមានឈ្មោះខាងលើ និងសំណុំរឿងព្រហ្មទណ្ឌលេខ:..........................

ចុះថ្ងៃទី........ខែ.................ឆ្នាំ២០១......... និងវត្ថុតាង ព្រមទាំងបញ្ជីរាយនាមជនដែលទាក់ទិន

ក្នុងសំណុំរឿងនេះ ទៅសាលាដំបូង....................................ដើម្បីជំនុំជំរះតាមច្បាប់។

.......................................,ថ្ងៃទី.........ខែ..............ឆ្នាំ២០១....

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
លេខ ..1201... ដកសមម

# ដីកាសម្រេចមិនឃុំខ្លួន

យើង ទូន ឧុទ្ធី ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ។

បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ១៤៥០ អ.ក/១៧ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ: ០៤៧ ដកសស/១៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញកំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទឈ្មោះ ញ៉េម មីនា ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ ។

ក្រោយពីបានពិនិត្យមើលសំណុំរឿងចប់សព្វគ្រប់ឃើញថា:

ឈ្មោះ ម ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារអេស៊ីលីដា ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល មានប្រពន្ធឈ្មោះ (រ) មានកូន ០១នាក់ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ) ជាតិជន ទោសពីមុន គ្មាន ។

ត្រូវចោទពីបទ: ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃ២៧ ខែសីហា ឆ្នាំ២០១៧ មាត្រា៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

យល់ឃើញថា:

-ជនត្រូវចោទមានទីលំនៅ ,មុខរបរពិតប្រាកដ ហើយជនរងគ្រោះនិងសាក្សី បានឆ្លើយនៅចំពោះមុខចៅក្រមស៊ើបសួររួចហើយ ហើយសម្រេចមិនឃុំខ្លួនជនត្រូវចោទមិនប៉ះពាល់ដល់និតិវិធីនៃការស៊ើបសួរឡើយ។

-ការឃុំខ្លួនតាមបញ្ញត្តិមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនមានភាពចាំបាច់។

## ហេតុដូច្នេះ សម្រេច

១ មិនឃុំខ្លួនជាបណ្ដោះអាសន្នលើឈ្មោះ ម ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារអេស៊ីលីដា ទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ។

២-បង្គាប់អោយឈ្មោះ ម ត្រូវចូលខ្លួនមកតុលាការគ្រប់ពេល នៅពេលមាន ដីកាកោះហៅ ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

កណ្ដាល ថ្ងៃទី ..23.. ខែ[illegible] ឆ្នាំ២០១៨

ចៅក្រមស៊ើបសួរ

[illegible]

បានទទួលដំណឹងរួចហើយ

ថ្ងៃទី[illegible] ខែ ..5...... ឆ្នាំ២០១៨

[illegible]

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
សំណុំរឿងលេខៈ ១៤៥០ អ.ក
ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧
លេខៈ 1382 "ព"

# ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ

យើង **ខួន ឧុទ្ធី** ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល។

-បានឃើញមាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

-បានឃើញសំណុំរឿងស៊ើបសួរដែលទាក់ទងនឹងជនត្រូវចោទៈ

១/ ឈ្មោះ [illegible] ភេទប្រុស អាយុ ៣០ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបុគ្គលិកធនាគារអេស៊ីលីដា ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ប្រពន្ធឈ្មោះ [illegible] មានកូន ០១នាក់ ឪពុកឈ្មោះ [illegible] (រ) ម្ដាយឈ្មោះ [illegible] (រ) ជានីតិជន ទោសពីមុន គ្មាន ។

២/ ឈ្មោះ [illegible] ភេទស្រី អាយុ ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរបុគ្គលិក ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រពន្ធឈ្មោះ [illegible] មានកូន ០១នាក់ ឪពុកឈ្មោះ [illegible] (រ) ម្ដាយឈ្មោះ [illegible] (រ) ជានីតិជន ទោសពីមុន គ្មាន ។

ត្រូវជាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទៈ **ជេរប្រមាថជាសាធារណៈ និងហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៣០៧ និងមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។

បញ្ជាឲ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះ ទៅ**ព្រះរាជអាជ្ញា** ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬ ផ្ដល់យោបល់ទៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
កំពង់ស្ពឺ ថ្ងៃទី 17 ខែ [illegible] ឆ្នាំ២០១៨
**ចៅក្រមស៊ើបសួរ**

ខួន ឧុទ្ធី

បានអនុវត្តន៍
**ក្រឡាបញ្ជី**

ផាន់_ផារិទ្ធិ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អុនខ

សាលាដំបូងរាជធានីភ្នំពេញ

លេខ ២៤៣០ ម-ជជ

## ដីកាសម្រេចលើកលែងចោទប្រកាន់

យើង **ស្វាយ គុញ** ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក **ឈឿន សុខន** ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៥៧២៨ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៤៦៩ អយម ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ ២០១៧ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ២៤៤០ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១២១២ អយម ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់ ៖

### សំអាងហេតុ

១. បច្ចពួក ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃនៅក្នុងអំឡុងឆ្នាំ២០១២បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-តាមដីកាសន្និដ្ឋានស្ថាពរលេខ ១២១២ អយម ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទខាងលើ ។

៣-ជនត្រូវចោទនៅតែពុំអាចរកអត្តសញ្ញាណឃើញ ដូចនេះតាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវចេញដីកាលើកលែងចោទប្រកាន់តាមនីតិវិធី ។

### ហេតុដូច្នេះសម្រេច

-លើកលែងចោទប្រកាន់លើ បច្ចពួក ត្រូវបានតំណាងអយ្យការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីថ្ងៃនៅក្នុងអំឡុងឆ្នាំ២០១២បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

ថ្ងៃ សុក្រ ១ កើត ខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព.ស ២៥៦

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០១៨

លេខ: ១០៦៤ អ.យ.ម

បានទទួលដំណឹង

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨

ជ. ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ឈឿន_សុខន

ចៅក្រមស៊ើបសួរ

ស្វាយ_គុញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តកំពត

លេខ. ៣៦៧.../១៧

# ដីកាតម្កល់រឿងទុកឥតចាត់ការ

**យើង ឯក ឆេងហួត ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តកំពត ។**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៨ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកំពត និង សំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

យល់ឃើញថា:

១. អវត្តមានបទល្មើស

១.១. ☐ អវត្តមានបទល្មើស

២. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

២.១. ☒ ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

៣. មូលហេតុគតិយុត្ត

៣.១. ☐ ការដកពាក្យបណ្តឹង

៣.២. ☐ ការលើកលែងទោសជាទូទៅ

៣.៣. ☐ មរណភាពជនល្មើស

៣.៤. ☐ ផុតអាជ្ញាយុកាល

៣.៥. ☐ និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

៣.៦. ☐ អាជ្ញាអស់ជំនុំ

៣.៧. ☐ ការសម្របសម្រួលជាមួយរដ្ឋ

៣.៨. ☐ ការបង់ប្រាក់ពិន័យសរុប ឬ ប្រាក់ពិន័យសម្របសម្រួល

៣.៩. ☐ អភ័យឯកសិទ្ធិ

៣.១០. ☐ អនិយ័តភាពនៃនីតិវិធី

៣.១១. ☐ ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

---

[1] ដូចជាមូលហេតុវិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

៤/៣

៤. ការចោទប្រកាន់មិនផ្តល់ផលប្រយោជន៍

៤.១. □ ការស្វែងរកមិនបានផល

៤.២. □ ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

៤.៣. □ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

៤.៤. □ ការខកខានរបស់ដើមបណ្តឹង

៤.៥. □ អាកប្បកិរិយារបស់ជនរងគ្រោះ

៤.៦. □ ជនរងគ្រោះមិនចាប់អារម្មណ៍នឹងបទល្មើស

៤.៧. □ និយ័តកម្មដោយឯកឯង[3]

៤.៨. □ ព្យសនកម្ម ឬ ការរំខានតិចតួចបង្កដោយបទល្មើស

៥. នីតិវិធជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា

៥.១. □ ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

៥.២. □ សន្ទានកម្ម[4]

៥.៣. □ អធិបញ្ញាផ្តល់ការព្យាបាល

៥.៤. □ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹងតាមការស្នើសុំរបស់ព្រះរាជអាជ្ញា

៥.៥. □ និយ័តកម្មតាមសំណើរបស់ព្រះរាជអាជ្ញា

៥.៦. □ ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

៥.៧. □ ការកំណត់ទិសដៅចំពោះចេតនាសម្ព័ន្ធនៃសុខភាពនៃសង្គម ឬ វិជ្ជាជីវៈ

៥.៨. □ ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

៦. នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗទៀត

៦.១. □ ការចោទប្រកាន់ ឬ ទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

៧. ជនល្មើសមិនត្រូវបានស្គាល់

៧.១. □ ជនល្មើសមិនត្រូវបានស្គាល់

៨. ជំនួយការអប់រំ

៨.១. □ ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

---

[2] ដើមបណ្តឹងឈប់ប្តឹង

[3] សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និងស្តារស្ថានភាពឡើងវិញ

[4] ករណីចែងដោយច្បាប់

[5] ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើសតាមកំណត់ច្បាប់ និងធ្វើការព្រមានឱ្យឈប់ប្រព្រឹត្ត

[6] ករណីចែងដោយច្បាប់

ការសង្កេតផ្សេងៗ ៖

តាមពាក្យបណ្ដឹង ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់លោក អ៊ូ ប៊ុនវ៉ា ជាមេធាវីតំណាងឱ្យឈ្មោះ អ ស បានបង្ហាញថា: កាលពីឆ្នាំ២០០៨ ឈ្មោះ សា បានមកលួងលោមកូនក្ដីខ្លួន ឈ្មោះ អ ស អោយជួយទិញដីរបស់ខ្លួន ដោយខ្លួនបានអះអាងថា រាជរដ្ឋាភិបាលបានប្រគល់ដីមកឱ្យខ្លួនតាមរយៈ សជណា លេខ ៨១៩ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងសជណា របស់លេខៈ ៩០លស របស់សាលាខេត្តកំពត ដែលមានព្រំប្រទល់ ខាងជើងទល់នឹង អ ស ខាងត្បូងទល់នឹងសមុទ្រ ខាងកើតទល់នឹងព្រែកខ្ជប និងខាងលិចទល់នឹង សា ។

ដោយហេតុថាឈ្មោះ សា បានសន្យានិងធានាអះអាងថា បើខ្លួនគ្មានដីប្រគល់អោយកូនក្ដីខ្លួនទេ ខ្លួនសុខចិត្តប្រគល់ប្រាក់ទាំងអស់មកឱ្យកូនក្ដីរបស់ខ្លួនវិញ គ្រប់ចំនួន ព្រមទាំងការប្រាក់ ៣% ទៀតផង ហេតុនេះទើបកូនក្ដីរបស់ខ្លួនសម្រេចចិត្តប្រគល់ប្រាក់ឱ្យទៅឈ្មោះ សា តាមការទាមទាររបស់គេៗ ក្រោយពីកូនក្ដីរបស់ខ្លួន ប្រគល់ប្រាក់គ្រប់ចំនួន ឱ្យទៅឈ្មោះ សា ហើយ ឈ្មោះ សា មិនបានប្រគល់ដីមកឱ្យកូនក្ដីរបស់ខ្លួនតាមការសន្យាឡើយ ហើយបានគេចវេសពីកូនក្ដីរបស់ខ្លួន រហូតមកទល់សព្វថ្ងៃ។

-តាមចម្លើយរបស់ឈ្មោះ សា បានបញ្ជាក់ថា ខ្លួនពិតជាបានលក់ដីអោយឈ្មោះ អ ស ពិតប្រាកដមែន ដោយក្នុងទំហំ ១១៦៣៩៩ម² តំលៃ ៦៥០០០ដុល្លារ។ ដីនោះជាប្រភេទដីអូ បង្ការ ហើយមានសជណារបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០៨ ប្រគល់សិទ្ធិដល់ខ្លួន និងអ្នកផ្សេងទៀត។ នៅក្នុងការលក់ទិញនេះ គឺយើងធ្វើកិច្ចសន្យាលើកទី១ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ក្នុងទំហំ ១១៦៣៩៩ម² តំលៃ៦៥០០០ដុល្លារ ប៉ុន្តែបានប្រគល់លុយបីដំណាក់កាល គឺលើកទីមួយ ៣០០០ដុល្លារ, លើកទីពីរ ១២០០០ដុល្លារ និងលើកទីបី ២០០០០ដុល្លារ។ ក្រោយមកដោយសជណា ត្រូវបានលុប នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១០ ឈ្មោះ អ ស បានសុំទៅរត់ការ ដើម្បី ស្នើសុំសជណាដោយខ្លួនឯង ហើយអោយខ្លួនប្រគល់សិទ្ធិលើការស្នើសុំ និងកាន់កាប់ដី។ ក្រោយមក ដោយឆ្លងកាត់រយៈពេលពីរឆ្នាំ គាត់រត់ការមិនបាន គាត់ក៏មកជួបខ្លួនម្ដងទៀត ដោយអោយខ្លួនជាអ្នករត់វិញ ក្រោយមកនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ខ្លួនបានទៅខ្ចីប្រាក់គាត់ចំនួន ២០០០០ដុល្លារ ដោយដាក់ប្លង់ដីធានាបំណុល តាមរយៈលិខិតផ្ទេរលក់ដីជាបណ្ដោះអាសន្ន ហើយខ្លួនបានដាក់ប្លង់ដីលេខ AIV ០២៨១ ។ បន្ទាប់មកទៀតខ្លួនបានរត់ការដល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ និងរញ្ញបន្តដល់ ក្រសួងបរិស្ថាន ដូចមានក្នុងលិខិតលេខ ៨៣៣ សជណ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ហើយក៏បាត់ដំណឹងរហូត។ ក្រោយមកទៀតនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៧ ឈ្មោះ អ ស ក៏បានទាមទាររត់ឯកសារម្ដងទៀត ដោយនៅក្នុងកិច្ចសន្យានេះ បានបញ្ជាក់ថាបើគាត់រត់ចេញ ដីចំនួន ២៩ហិកតា នឹងបានទៅលើគាត់ ឈ្មោះ អ ស ដោយឡែក ឈ្មោះ សា គឺបានត្រឹមតែ ៦ហិកតា ប៉ុណ្ណោះ ប៉ុន្តែដោយគ្មានដំណឹង

រហូតមកដល់ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧ ខ្លួនក៏បានរត់ឯកសាររហូតដល់ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី ហើយនៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ខ្លួនក៏ទទួលបានឯកសារ គឺមានដីកាបញ្ជូនរបស់នាយកខុទ្ទកាល័យរបស់សម្តេច គឺឯកឧត្តម បញ្ជូនទៅកាន់ ឯកឧត្តម ។ បច្ចុប្បន្នដីនោះគឺខ្លួននៅគ្រប់គ្រងដដែល មិនមានការបាត់បង់ ឬក៏ផ្ទេរសិទ្ធិឱ្យអ្នកណាផ្សេងទេ។ ទឹកប្រាក់សរុបដែលខ្លួនបានទទួលពីឈ្មោះ អ ស សរុបទាំងអស់ ទាំងប្រាក់សម្រាប់តម្កល់ប្លង់គឺមានចំនួន ៥៥០០០ដុល្លារ (ប្រាំម៉ឺនប្រាំពាន់ដុល្លារ)។ ខ្លួនពុំបានអរម្ភោក ហើយក៏មិនបានទទួលប្រាក់ពីឈ្មោះ អ ស រហូតដល់ ២០០.០០០ដុល្លារនោះដែរ។

ឆ្លងតាមការស៊ើបអង្កេតបឋមរួចមក ឃើញថា វិវាទខាងលើ គឺជាវិវាទនៃទំនាក់ទំនងកិច្ចសន្យាទិញលក់ ហើយអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទខាងលើ គឺពុំទាន់មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់នោះទេ ដែលវាពុំមែនជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនោះឡើយ។

បានឃើញ: លិខិតបញ្ជាក់បញ្ចូលភស្តុតាងលេខ: ០១៥/១៧ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧ របស់មេធាវី អ៊ូ ប៊ុនរ៉ា។

បានឃើញ: ឯកសារពាក់ព័ន្ធផ្សេងៗក្នុងសំណុំរឿង។

យល់ឃើញថា: តាមពាក្យបណ្តឹងរបស់លោកមេធាវី អ៊ូ ប៊ុនរ៉ា និងចម្លើយរបស់ឈ្មោះ សា ព្រមទាំងឯកសារភស្តុតាងពាក់ព័ន្ធផ្សេងៗក្នុងសំណុំរឿង បានបញ្ជាក់ថា: ឈ្មោះ សា និងឈ្មោះ អ ស ពិតជាបានចុះកិច្ចសន្យាទិញលក់ដី មួយកន្លែង ជាមួយគ្នាពិតប្រាកដមែន ហើយការមិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យា ទើបធ្វើអោយភាគីមានវិវាទកើតឡើង។

យល់ឃើញថា: វិវាទខាងលើ គឺជាវិវាទនៃទំនាក់ទំនងកិច្ចសន្យាទិញលក់ ហើយអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទខាងលើ គឺពុំទាន់មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ម្ចាស់អចលនវត្ថុនោះទេ ដែលវាពុំមែនជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌនោះឡើយ។

យល់ឃើញថា: ឆ្លងតាមការស៊ើបអង្កេតបឋមរួចមក ជាហេតុគប្បីតម្កល់រឿងទុកឥតចាត់ការ។

<u>ហេតុដូច្នេះសម្រេច</u>

-តម្កល់រឿងនេះទុកឥតចាត់ការ ។

ធ្វើនៅកំពត, ថ្ងៃទី.០១..ខែ.ធ្នូ.......... ឆ្នាំ ២០១៧

ព្រះរាជអាជ្ញា

សាលាឧទ្ធរណ៍-ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦០០

ចុះថ្ងៃទី០៧-០៧-២០១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚

## __របាយការណ៍__

## __សំណុំរឿងព្រហ្មទណ្ឌមាន៖__

១-ឈ្មោះ ស. ហៅ ឬ ភេទប្រុស អាយុ ៥៩ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីកន្លែងកំណើតនៅ ភូមិទឹកល្អក់ សង្កាត់លេខ៥ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន នៅភូមិ ១ ឃុំព្រៃកខ្សាយ (ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង ប្រពន្ធឈ្មោះ មានកូន ០៤នាក់ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (ស) ទោសពីមុនគ្មាន (ក្រៅឃុំ) ។

ជាប់ចោទពីបទ: **ជេរប្រមាថ** ប្រព្រឹត្តនៅភូមិ១ ឃុំព្រៃកខ្សាយ (ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ តាមបញ្ញត្តិមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ ផ ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ មានទីកន្លែងកំណើតនៅភូមិសំរោងធំ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានទីលំនៅបច្ចុប្បន្ននៅភូមិ៤ ឃុំព្រៃកខ្សាយ (ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង ប្តីឈ្មោះ មានកូន ០៤នាក់ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (ស) ទោសពីមុនគ្មាន (ក្រៅឃុំ)។

ជាប់ចោទពីបទ: **ធ្វើឲ្យខូចខាតដោយចេតនា និងជេរប្រមាថ** ប្រព្រឹត្តនៅភូមិ១ ឃុំព្រៃកខ្សាយ (ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ តាមបញ្ញត្តិមាត្រា ៥២ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

### __អង្គហេតុនៃរឿងមានដូចតទៅ__

កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ នៅចំណុច ភូមិ១ ឃុំព្រៃកខ្សាយ (ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង មានករណីធ្វើឲ្យខូចខាតដោយចេតនាមួយបានកើតឡើង បង្កដោយឈ្មោះ ផ ភេទស្រី បានទាំគ្នាទៅដាំបបង្គោលរបងថ្មីនិងធ្វើឲ្យបាក់របងព័ទ្ធដីរបស់ឈ្មោះ ស. នៅពេល

នោះដែរឈ្មោះ ខែម សុខា បានឃាត់ និងបានជេរប្រមាថគ្នាទៅវិញទៅមកទៀតផង ។ នៅពេលកើតហេតុនោះ ឈ្មោះ ខែម សុខា ទៅឃាត់ឈ្មោះ ផាន់ សាក់ ព្រមានរកវាយបំបែកក្បាលចំណែកឈ្មោះ ផាន់ សាក់ ជាមេកញ្ចាស់ សាក់ តែម្តង ។

១-<u>អំពីលទ្ធផលអង្កេត</u>

-ជនជាប់ចោទឈ្មោះ ផ បានឆ្លើយថា: ដំបូងខ្លួនបានទៅប្រាប់ឈ្មោះ ស ឲ្យយករបងចេញដែលដាក់ចូលក្នុងដីរបស់ខ្លួន តែមិនព្រមលើកទេ ។ ហើយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ គឺរូបខ្លួនបានទៅលើករបងនោះមួយកន្លែង ដើម្បីដឹកដាំបង្គោល ដើម្បីឲ្យអ្នកអនុវត្តសាលក្រមស្រួលមើល ពេលនោះឈ្មោះ ស បានយកកាំបិតប៉ុងតោមកកាប់ខ្លួន ព្រមទាំងយកចបបម្រុងកាប់ខ្លួនទៀតផង ក្នុងពេលនោះឈ្មោះ ស បានជេរប្រមាថរូបខ្លួន និងកូនរបស់ខ្លួនដែរនៅឯផ្ទះច្រើនទៀតផង នៅពេលដែលជេរប្រមាថខ្លួន ដូចជាប្រើពាក្យ មេចោរកាចុយ ជាដើម ហើយក្នុងពេលនោះ គឺឈ្មោះ ស បានយកគ្រួសថ្ម ដែលខ្លួនយកទៅបម្រុងចាក់ដាំរបងចោលទាំងអស់ទៀតផង ។

-ជនជាប់ចោទឈ្មោះ ស បានឆ្លើយថា: កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ នៅវេលាម៉ោងប្រហែលជា ៣រសៀល ឈ្មោះ ផ ភេទស្រី បាននាំបក្សពួក មកដឹក បំបាក់របងឬស្សីរបស់ខ្លួន បាក់អស់ប្រហែលជា ១០ម៉ែត្រ ពេលនោះខ្លួនបានទៅឃាត់ដែរតែពេក្វះនេះអត់ស្តាប់ខ្លួនគឺនៅតែប្រព្រឹត្តបន្ត ពេលនោះខ្លួនក៏ទៅហៅ បេអ៊ីម ស្រុកពាមរក៍មកជួយឃាត់ ក៏នៅតែមិនស្តាប់ទៀត ហើយត្រូវឈ្មោះផ ស្រែកជេរថា បើអាអែងហៅ បេអ៊ីម មកនេះ អញនិងកាប់ក្បាលពួកអាអែង នៅនិងមុខ បេអ៊ីមឲ្យអាយៈក្បាលតែម្តង ។

២-<u>អំពីឯកសារពាក់ព័ន្ធ</u>

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤០ "ខ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រៃវែង ។

៣-<u>អំពីអង្គច្បាប់</u>

រឿងក្តីនេះ **សាលាដំបូងខេត្តព្រៃវែង** បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌ ៤០(ខ) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ ដែលមានខ្លឹមសារដូចខាងក្រោម ៖

១-កែប្រែបទចោទប្រកាន់លើឈ្មោះ ផ   ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ ពីបទ **ធ្វើឲ្យខូចខាតដោយចេតនានិងជេរប្រមាថ** តាមមាត្រា ៥២ និងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកជាបទ **ធ្វើឲ្យមានការខូចខាតស្រាលនិងជេរប្រមាថជាសាធារណៈ** តាមមាត្រា ២១៨និងមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

២-កែប្រែបទចោទប្រកាន់លើឈ្មោះ   ស ហៅ   ហៅ   ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ ពីបទ **ជេរប្រមាថ** តាមមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ទៅជាបទ **ជេរប្រមាថជាសាធារណៈ** តាមមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌវិញ ។

៣-ផ្តន្ទាទោសលើឈ្មោះ ផ   ភេទស្រី អាយុ៦០ឆ្នាំ ជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ១.១០០.០០០៛ (មួយលានមួយសែនរៀល) ពីបទ **ធ្វើឲ្យខូចខាតស្រាល និងជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅភូមិ១ ឃុំព្រៃខ្លាយ (ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ តាមបញ្ញត្តិមាត្រា ២១៨ និងមាត្រា៣០៧ នៃក្រមព្រហ្មទណ្ឌ ។

៤-ផ្តន្ទាទោសលើឈ្មោះ   ស ហៅ   ហៅ   ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ ពិន័យជាប្រាក់ចំនួន ១.០០០.០០០៛ (មួយលានរៀល) ពីបទ **ជេរប្រមាថជាសាធារណៈ** ប្រព្រឹត្តនៅភូមិ១ ឃុំព្រៃខ្លាយ(ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ តាមបញ្ញត្តិមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ។

៥-បង្គាប់ឲ្យឈ្មោះ ផ.   ភេទស្រី សងសំណង ការខូចខាតនិង ជម្ងឺចិត្តជាទឹកប្រាក់ចំនួន ២.០០០.០០០៛ (ពីរលានរៀល) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ   សុ. ហៅ   ហៅ   ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៦-បង្គាប់ឲ្យឈ្មោះ   ស ហៅ   ហៅ   ភេទប្រុស សងសំណងជម្ងឺចិត្តជាទឹកប្រាក់ចំនួន ១.៥០០.០០០៛ (មួយលានប្រាំសែន រៀល) ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ផ.   ។ ការទាមទារលើសពីនេះត្រូវច្រានចោល ។

៧-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិឲ្យជនចោទជាប់ឈ្មោះ ស និង ដើមរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

៤-<u>អំពីនម្រង់ច្បាប់</u>

ពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះឌ បានប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤០ (ខ) ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៥.<u>អំពីគតិច្បាប់</u>

ក្រុមប្រឹក្សានឹងពិចារណា និងសម្រេច ក្រោយបញ្ចប់កិច្ចពិភាក្សាដេញដោលរួច ។

ថ្ងៃ ពុធ ១០រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១៨

ប្រធានក្រុមប្រឹក្សា

**ចាយ ច័ន្ទតារាវណ្ណ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

- ស្នើ ... 07/02/18

សំណុំរឿងព្រហ្មទណ្ឌលេខ១៥៥០អក
ចុះថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ២០១៧
លេខ: 097 ដកសស

## ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

យើង **លាង_ស្រេង** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ពាក្យបណ្ដឹងរបស់ឈ្មោះស្រួយ-យ៉ាង ភេទស្រី អាយុ៥៥ឆ្នាំ ចុះថ្ងៃទី១០-១១-២០១៧ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ:**

**យល់ឃើញថា មានតម្រុយសន្មត់បានថា:**

| | | |
|---|---|---|
| នាម-គោត្តនាម | : | ម- ភេទប្រុស |
| កើតថ្ងៃទី | : | អាយុ៣០ឆ្នាំ |
| ទីកន្លែងកំណើត | : | ភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល |
| អាស័យដ្ឋាន | : | ភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល |
| មុខរបរ | : | បុគ្គលិកធានាគារអេស៊ីលីដា |
| នៅលីវ ☐ ឬ រៀបការ ☑ | | ឈ្មោះប្រពន្ធ : (រ) កូនគ្មាន |
| សញ្ជាតិ | : | ខ្មែរ |
| ឪពុកឈ្មោះ | : | (រ) ម្ដាយឈ្មោះ : (រ) |
| អនីតិជន ☐ ឬនីតិជន ☑ | | |



អាស័យដ្ឋាន: ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

នាម-គោត្តនាម : ច- ភេទស្រី
កើតថ្ងៃទី : អាយុ២៨ឆ្នាំ
ទីកន្លែងកំណើត : ភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល
អាសយដ្ឋាន : ភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្តាល
មុខរបរ : បុគ្គលិកធានាគារអេស៊ីលីដា
នៅលីវ ☐ ឬ រៀបការ ☑ ឈ្មោះប្តី : (រ) កូនគ្មាន
សញ្ជាតិ : ខ្មែរ
ឪពុកឈ្មោះ : (រ) ម្តាយឈ្មោះ : (រ)
អនីតិជន ☐ ឬនីតិជន ☑

**បានប្រព្រឹត្តអំពើដូចតទៅ:** នៅថ្ងៃទី២៧-៨-២០១៧ ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ៥៤ឆ្នាំ បានជិះម៉ូតូម្នាក់ឯង ទៅទារលុយពីអ្នកម៉ៅស្វាយចំការរបស់ខ្លួននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល ពេលទៅនោះមិនជួបអ្នកម៉ៅស្វាយនោះទេ ហើយជនរងគ្រោះក៏ជិះត្រលប់មកផ្ទះវិញនៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដោយជិះកាត់ភូមិទឹកឃ្លាំង ពេលជិះមកដល់ភូមិនេះ ស្រាប់ជនសង្ស័យឈ្មោះ ម- ភេទប្រុស អាយុ៣០ឆ្នាំ បានហៅជនរងគ្រោះឱ្យឈប់ម៉ូតូ ហើយជនរងគ្រោះឈ្មោះ - ក៏ឈប់ម៉ូតូ ហើយជនសង្ស័យបានសួរជនរងគ្រោះថា អ្នកឯងមកកន្លែងនេះធ្វើស្អី ហើយជនរងគ្រោះថា មកទារលុយពីអ្នកម៉ៅផ្លែស្វាយ មានដើរនិយាយដើមពីគ្រួសារម្តាយក្មេកខ្លួនអត់ ស្រាប់តែពេលនោះជនសង្ស័យឈ្មោះ ច- ជាប្រពន្ធសង្ស័យឈ្មោះ ម- បានមកដល់កន្លែងកើតនេះព្រមទាំងមានប៉ូលីស មកជាមួយផង និងមានអ្នកស្រុកជាច្រើន ក៏បានចោមរោមមើល ពេលនោះជនសង្ស័យឈ្មោះ ច- បានជេរមកលើជនរងគ្រោះនៅពាក្យប្រមាថជាច្រើន ព្រមទាំងបានទាត់ធាក់ជនរងគ្រោះចំចង្កេះ ៣ទៅ៤ជើង និងទះកំភ្លៀង៣ទៅ៤ដៃ ឯជនសង្ស័យឈ្មោះ ម- ឈរមើលប្រពន្ធវាយជនរងគ្រោះ ។

អំពើខាងលើជាបទល្មើស **ជេរប្រមាថជាសាធារណៈ** និង **បទ: ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី២៧-៨-២០១៧ តាមបញ្ញតិមាត្រា ៣០៧ និងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ។

-**បានឃើញ** មាត្រា ៨៤ និងមាត្រា ១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>សម្រេច</u>

បើកការស៊ើបសួរលើអង្គហេតុខាងលើនិង :

☑ ដាក់ឱ្យស្ថិតនៅក្រោមពិនិត្យ

១-ឈ្មោះ ម- ភេទប្រុស អាយុ៣០ឆ្នាំ (ក្រៅឃុំ)
២-ឈ្មោះ ច- ភេទស្រី អាយុ២៨ឆ្នាំ (ក្រៅឃុំ)

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ:........................................................

..............................................................................................................។

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន:........................................................

..............................................................................................................។

ថ្ងៃ[illegible] ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

កណ្ដាល ថ្ងៃទី 01 ខែ 02 ឆ្នាំ២០១៨

ចៅក្រមស៊ើបសួរ

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តព្រៃវែង
លេខ...១១០.៣./២០១៧

## ដីកាកោះហៅឲ្យជនជាប់ចោទចូលរួមសវនាការ

យើង ..ម៉ាស...សុភក្តិ.. តំណាងអយ្យការ អមសាលាដំបូងខេត្តព្រៃវែង ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ៥៥២/០៧ ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៧ ដែលមានជនជាប់ចោទ:

១./ ឈ្មោះ ផាន់ សាក់ ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ ។

ជាប់ចោទពីបទ: *ធ្វើឲ្យខូចខាតដោយចេតនា* ប្រព្រឹត្តនៅភូមិ០១ ឃុំព្រែកខ្សាយ(ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៥២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

### ហេតុដូច្នេះសម្រេច

បង្គាប់មក: ឈ្មោះ . .ក់ ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃនៅភូមិ០៤ ឃុំព្រែកខ្សាយ(ខ) ស្រុកពាមរក៍ ខេត្តព្រៃវែង ឲ្យចូលទៅកាន់សាលាដំបូងខេត្តព្រៃវែង <u>នៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង០២រសៀល</u> ជាកំហិត ដើម្បីឆ្លើយដោះសារពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

### សមាសភាពជំនុំជម្រះ

-លោក **កែ សាខន** ចៅក្រមជំនុំជម្រះ

-លោក **ម៉ាស...សុភក្តិ** តំណាងអយ្យការ

-លោក **ស សំនិត** ក្រឡាបញ្ជីសវនាការ

+សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:

សិទ្ធិទទួលដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះហៅឲ្យចូលរួមសវនាការ
សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី និងធ្វើសំណូមពរផ្សេងៗ
សិទ្ធិប្តឹងបដិសេធចៅក្រមជំនុំជម្រះ
សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងមេធាវីឲ្យជួយការពារ
សិទ្ធិនិយាយជំជឺចុងក្រោយបង្អស់

ធ្វើនៅព្រៃវែង ថ្ងៃទី...០៤...ខែ...ឧសភា.... ឆ្នាំ២០១៧

តំណាងអយ្យការ

ម៉ាស សុភក្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៣*៤៤៤

សាលាដំបូងខេត្តសៀមរាប
.........
លេខ: ៧០៤ ឃ-/១៩

# ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

យើង គីម សុគន្ធា ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។
បានឃើញមាត្រា២២៣, មាត្រា២២៦ និង មាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១៥០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។
បានឃើញសំណុំរឿងស៊ើបសួរលេខ ១២០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។
បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ១៧៤ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។
បានឃើញដីកាសម្រេចមិនឃុំខ្លួន លេខ: ២៨២ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។

## សំអាងហេតុ

ដើម្បីធានាដល់កិច្ចស៊ើបសួរបន្ត និងបង្ការមិនឲ្យជនត្រូវចោទរត់គេចខ្លួន ធ្វើសកម្មភាពផ្សេងៗប៉ះពាល់ដល់ការស៊ើបសួរ គប្បីតុលាការសម្រេចដាក់ជនត្រូវចោទដែលនៅក្រៅ ឃុំឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

## ហេតុដូច្នេះសម្រេច

១. ដាក់ជនត្រូវចោទ ឈ្មោះ សា ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិកំលែង ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ អាសយដ្ឋានបច្ចុប្បន្នភូមិចុងកៅស៊ូ សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ ឿន (រ) ។

២.បង្គាប់មកឈ្មោះ សា ដូចខាងក្រោម:

ក.មិនត្រូវចេញក្រៅ ព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

ខ. មិនត្រូវផ្លាស់ប្ដូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

គ.ត្រូវចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការនៅពេលមានដីកាកោះហៅ។

ឃ-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៣.ក្នុងករណីជនត្រូវចោទរូបនេះគេចខ្លួនមិនគោរពកាតព្វកិច្ច ដូចបានកំណត់ខាងលើ យើងនឹងសម្រេចឃុំខ្លួនជនត្រូវចោទ ជាបណ្ដោះអាសន្ន។

បានចម្លងដំណើររឿងរួចហើយ
នៅថ្ងៃទី ... ខែកុម្ភៈ ឆ្នាំ២០១៩
ព្រះរាជអាជ្ញារង

[illegible]

ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
សៀមរាប ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩
ចៅក្រមស៊ើបសួរ

គីម សុគន្ធា

យើង ..........................................................................................................................................

បានប្រគល់ដីកានេះឲ្យទៅឈ្មោះ ........................... ទីលំនៅភូមិ.......................................ឃុំ/សង្កាត់............................ ស្រុក/ខណ្ឌ/ក្រុង..........................ខេត្ត/រាជធានី..............................
នៅថ្ងៃទី.............ខែ...........ឆ្នាំ................ ដោយផ្ទាល់ហើយ ដោយយើងបានទុកចុងសន្លឹកដីកានេះមួយច្បាប់ឲ្យសាមីខ្លួន ហើយប្រាប់ថា ឲ្យសាមីខ្លួនប្រគល់ ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅចំពោះមុខសាលាដំបូងខេត្ត-រាជធានី............................................................ ។

| **អ្នកទទួល** | **អ្នកប្រគល់** |
| --- | --- |
| ហត្ថលេខា ឬផ្តិតមេដៃ | ហត្ថលេខា ឬផ្តិតមេដៃ |

<u>កំណត់សំគាល់:</u> អ្នកប្រគល់ដីកានេះ ក្រោយពីអ្នកទទួលដីកាបានចុះហត្ថលេខា ឬផ្តិតមេដៃលើដីកានេះទាំងពីរសន្លឹករួចហើយត្រូវប្រគល់ "ចុងដីកា" ទៅឲ្យអ្នកទទួល និងបង្វិល "ដើមដីកា" ទៅសាលាដំបូង ឬអយ្យការវិញឲ្យបានមុនថ្ងៃកំណត់ចូល ។

យើង **គុជ មករា** ក្រឡាបញ្ជីនៃសាលាដំបូងខេត្តសៀមរាប។

បានប្រគល់ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឲ្យទៅ ឈ្មោះ ញៀន សាម៉ៃ មានទីលំនៅសព្វថ្ងៃនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី.១៥.....ខែកុម្ភៈ ឆ្នាំ២០១៩ រួចហើយ។

ក្រឡាបញ្ជី

គុជ មករា

អ្នកទទួល

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប, ថ្ងៃទី២៣..ខែ០៦..ឆ្នាំ២០១៩
**ក្រឡាបញ្ជី**

គុជ មករា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តសៀមរាប

*********

លេខ:.........ឃ.../១៩

## ដីកាសម្រេចមិនឃុំខ្លួន

យើង គឹម សុគន្ធា ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

បានឃើញ បញ្ញត្តិមាត្រា ២០៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ១៥០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ១២០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ១៧៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

បានឃើញ កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។

បានឃើញ កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៩។

ឈ្មោះ សា ភេទស្រី អាយុ ២៥ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិជលែង ឃុំមានជ័យ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ អាស័យដ្ឋាននៅភូមិចុងកៅស៊ូ សង្កាត់គោកចក សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្ដីឈ្មោះ ។ មានកូន ០៤នាក់ ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ។

ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: អំពើលួច ប្រព្រឹត្តនៅចំណុចហាងក្រែបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅភូមិផ្លូកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

មិនឃុំខ្លួនជនត្រូវចោទឈ្មោះ សា ខាងលើនេះ ដោយអនុញ្ញាតឲ្យមានសេរីភាពធម្មតាវិញ តែត្រូវឲ្យឈ្មោះ សា គោរពកាតព្វកិច្ចដែលមានចែងក្នុងដីកាសម្រេចដាក់ជននេះនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជានិច្ច។

សេចៈ...០២ . ១៩ ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

បានទទួលដំណឹងរួចហើយ សៀមរាបថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៩ **ចៅក្រមស៊ើបសួរ**

**ព្រះរាជអាជ្ញារង**

គឹម ស...

បានថតចម្លងត្រឹមត្រូវចេញពី
ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី
សៀមរាប, ថ្ងៃទី២៣ ខែ០៦ ឆ្នាំ២០២៥

**ក្រឡាបញ្ជី**

គួជ មករា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង
លេខ ...៧៣១... ដ.ជ.ស

## ដីកាបញ្ជូនទៅជំនុំជម្រះ

### យើង ឆាំ ម៉ុណ្ណា ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបាត់ដំបង

បានឃើញមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៧ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៦៦៩ ដស.បស/១៨ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៨៣ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៣៩០ ដស.សព/១៨ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ។

ក្រោយពីបានពិនិត្យ និងពិចារណាចប់សព្វគ្រប់អស់ហើយ:

### យល់ឃើញថា

មានភស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើឈ្មោះ ក ហៅ ស ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ កើតនៅភូមិចែងក្តា ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង ទីលំនៅសព្វថ្ងៃនៅភូមិកែវមុនី ឃុំបាសាក ស្រុករុក្ខគីរី ខេត្តបាត់ដំបង នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "ស" ទោសពីមុនគ្មាន ។ (សម្រេចឃុំលេខ ៨៧៣/១២-០៥-១៨, បង្គាប់ឃុំលេខ ២៩៨/កខ-០៥-១៨)

ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រព្រឹត្តនៅភូមិអូរខ្វាយ ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ ។

### ហេតុដូច្នេះសម្រេច

១-បញ្ជូនជនជាប់ចោទឈ្មោះ ក ហៅ ស ភេទប្រុស អាយុ ២០ឆ្នាំ (សាវតាជាតិគ្រប់គ្រាន់ខាងលើ)

ទៅជំនុំជម្រះ ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រព្រឹត្តនៅភូមិអូរខ្វាយ ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ ។

២-រក្សាជនជាប់ចោទឈ្មោះ ក ហៅ ស ឲ្យនៅជាប់ឃុំរហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៧ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨ និងជនដែលជាប់ទាក់ទិនក្នុងសំណុំរឿងនេះទៅ ប្រធានសាលាដំបូងខេត្តបាត់ដំបង ដើម្បីចាត់ការតាមច្បាប់ ។

ថ្ងៃព្រហស្បតិ៍ ១រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅបាត់ដំបង, ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨

**ចៅក្រមស៊ើបសួរ**

ឈុំ ប៊ុណ្ណា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តសៀមរាប
លេខៈ ១៧៤........../២០១៩

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

## យើង ថេង សំណាង តំណាងអយ្យការអមសាលាដំបូង ខេត្តសៀមរាប

-បានឃើញ មាត្រា២៨ មាត្រា១២៨ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៥០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

-បានឃើញ[1]៖ របាយការណ៍សំយោគលេខ ០០៨/២០១៩ នប.សសក្រ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**-យល់ឃើញថា** មានតម្រុយសន្និដ្ឋានលើ៖

-នាម និងគោត្តនាម៖ . សា ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជលែង ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្តីឈ្មោះ : _ មានកូន០៤នាក់ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ)។ (ឃាត់ខ្លួន)

**-បានប្រព្រឹត្តអំពើដូចតទៅ៖**

កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង០៣និង៤០នាទីរសៀល នៅចំណុចហាងក្រេបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅក្នុងភូមិឆ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប មានជនសង្ស័យឈ្មោះ សា ភេទស្រី អាយុ២៥ឆ្នាំ បានធ្វើសកម្មភាពលួចយកទូរស័ព្ទដៃមួយគ្រឿង ម៉ាក HOAWEI ពណ៌ខ្មៅ ដែលជារបស់ជនរងគ្រោះឈ្មោះ , ធ ភេទប្រុស អាយុ៣៣ឆ្នាំ ប៉ុន្តែត្រូវបានជនរងគ្រោះឃើញទាន់ ហើយស្រែកឲ្យគេជួយ និងបានឃាត់ខ្លួនជនសង្ស័យឈ្មោះ សា បានភ្លាមៗ និងប្រគល់ឲ្យសមត្ថកិច្ចចាត់ការតាមនីតិវិធីច្បាប់។

អំពើ ខាងលើជាបទល្មើស អំពើលួច ប្រព្រឹត្តនៅចំណុចហាងក្រេបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅក្នុងភូមិឆ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

---

[1] បណ្តឹងទាមទារ ឬបណ្តឹងបរិហារ(របាយការណ៍សំយោគរបស់អង្គភាពនគរបាលយុត្តិធម៌)។

[2] សេចក្តីសង្ខេបអង្គហេតុ (កាលបរិច្ឆេទ ទីកន្លែងប្រព្រឹត្ត អ្នកចូលរួមប្រព្រឹត្ត សកម្មភាពប្រព្រឹត្ត មូលហេតុប្រព្រឹត្ត និងសកម្មភាពពាក់ព័ន្ធសំខាន់ៗ)។

## សម្រេច

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

□ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ។លើ៖

-ឈ្មោះ សា ភេទស្រី អាយុ២៥ឆ្នាំ ពីបទ៖ រំលោភលួច ប្រព្រឹត្តនៅចំណុចហាងក្រែបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

□ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន[4] ៖ លើឈ្មោះខាងលើ ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតមានជាថ្មី និងធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើសតាមបញ្ញត្តិមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ថ្ងៃសុក្រ ១១កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

អយ្យការសៀមរាប, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

ព្រះរាជអាជ្ញារង

[illegible]

បានថតចម្លងត្រឹមត្រូវចេញពី

ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប, ថ្ងៃទី២៣ ខែ០២ ឆ្នាំ២០១៩

ក្រឡាបញ្ជី

[illegible]

[3] ឈ្មោះជនត្រូវចោទ

[4] មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្នដែលបានចែងនៅក្នុងមាត្រា ២០៥។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ១៨៥០អក
ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧
លេខៈ 1058 ដកសព

# ដីកាសន្និដ្ឋានស្ថាពរ

យើង **លាវ-ស្រេង** ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៩៧ ដកសស ចុះថ្ងៃទី០១-០២-២០១៨ របស់ អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** សំណុំរឿងស៊ើបសួរលេខ០៣៨ សស ចុះថ្ងៃទី០៧-០២-២០១៨ របស់សាលាដំបូងខេត្តកណ្ដាល។

-**បានឃើញ** ដីកាជូនព័ត៌មាន បិទបញ្ចប់ការស៊ើបសួរលេខ១៣៦៧ ចុះថ្ងៃទី១២-៩-២០១៧ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ ១៣៥២ ចុះថ្ងៃទី១៧-០៩-២០១៨ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

**យល់ឃើញថា:**

នាម-គោត្តនាម : [illegible] ម-[illegible] ភេទប្រុស (ក្រៅឃុំ)
កើតថ្ងៃទី : អាយុ ៣០ឆ្នាំ
ទីកន្លែងកំណើត : ភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល
អាស័យដ្ឋាន : ភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល
មុខរបរ : បុគ្គលិកធានាគារអេស៊ីលីដា
នៅលីវ ☐ ឬ រៀបការ ☑ ឈ្មោះប្រពន្ធ: [illegible] (រ) មានកូន០១នាក់
សញ្ជាតិ : ខ្មែរ
ឪពុកឈ្មោះ : [illegible] (រ) ម្ដាយឈ្មោះ : [illegible] (រ)
អនីតិជន ☐ ឬនីតិជន ☑



អាស័យដ្ឋានៈ ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal Province

នាម-គោត្តនាម : ច- ភេទស្រី (ក្រៅឃុំ)

កើតថ្ងៃទី : អាយុ ២៨ឆ្នាំ

ទីកន្លែងកំណើត : ភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល

អាសយដ្ឋាន : ភូមិផ្លូវត្រី ឃុំថ្មគរ ស្រុកល្វាឯម ខេត្តកណ្ដាល

មុខរបរ : បុគ្គលិកធានារ៉ាប់រងអេស៊ីលីដា

នៅលីវ ☐ ឬ រៀបការ ☑ ឈ្មោះប្ដី : - មានកូន០១នាក់

សញ្ជាតិ : ខ្មែរ

ឪពុកឈ្មោះ : (រ) ម្ដាយឈ្មោះ : (រ)

អនីតិជន ☐ ឬនីតិជន ☑

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ : **ជេរប្រមាថជាសាធារណៈ** និងបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧-៨-២០១៧ តាមមាត្រា៣០៧ និងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ។

**ឃើញថា** នៅថ្ងៃទី២៧-៨-២០១៧ ជនរងគ្រោះឈ្មោះ ភេទស្រី អាយុ៤៤ឆ្នាំ បានជិះម៉ូតូម្នាក់ឯងទៅទារលុយពីអ្នកម៉ៅស្វាយ ចំការរបស់ខ្លួននៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល ពេលទៅនោះមិនជួបអ្នកម៉ៅស្វាយនោះទេ ហើយជនរងគ្រោះក៏ជិះត្រលប់មក ផ្ទះវិញនៅភូមិព្រៃបាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដោយជិះកាត់ភូមិទឹកឃ្លាំង ពេលជិះមកដល់ភូមិនេះស្រាប់ជនសង្ស័យឈ្មោះ ម- ភេទប្រុស អាយុ៣០ឆ្នាំ បានហៅជនរងគ្រោះឱ្យឈប់ម៉ូតូ ហើយជនរងគ្រោះឈ្មោះ ក៏ឈប់ម៉ូតូហើយជនសង្ស័យបានសួរជនរងគ្រោះថា អ្នកឯងមកកន្លែងនេះធ្វើស្អី ហើយជនរងគ្រោះថា មកទារលុយពីអ្នកម៉ៅផ្លែស្វាយ មានដើរនិយាយដើមពីគ្រួសារម្ដាយ ក្មេកខ្លួនអត់ស្រាប់តែពេលនោះជនសង្ស័យឈ្មោះ ច- ជាប្រពន្ធសង្ស័យឈ្មោះ ម- បានមកដល់កន្លែងកើតហេតុនេះ ព្រមទាំងមានប៉ូលីស មកជាមួយផង និងមានអ្នកស្រុកជាច្រើន ក៏បានចោមរោមមើល ពេលនោះជនសង្ស័យឈ្មោះ ច- បានជេរមកលើជនរងគ្រោះនៅពាក្យប្រមាថជាច្រើន ព្រមទាំងបានទាត់ធាក់ជនរងគ្រោះចំចង្កេះ ៣ទៅ៤ជើង និងទះកំភ្លៀង៣ទៅ៤ដៃ ឯជនសង្ស័យឈ្មោះ អ- ឈរមើលប្រពន្ធវាយជនរងគ្រោះ ។

## I–ដំណាក់កាលស៊ើបអង្កេតនៅអយ្យការអមសាលាដំបូងខេត្តកណ្ដាល

យោង ពាក្យបណ្ដឹង ចុះថ្ងៃទី១០-១១-២០១៧របស់ឈ្មោះ ភេទស្រី អាយុ៤៤ឆ្នាំ ហើយអយ្យការបានកសាងសំណុំរឿង និងបានកត់ត្រាសួរយកចំលើយ:

-ជនរងគ្រោះឈ្មោះ      ភេទស្រី អាយុ៤៤ឆ្នាំ បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានទៅទារលុយពីអ្នកម៉ៅដើមស្វាយខ្លួនមួយចំការ តែមិនស្គាល់ឈ្មោះអ្នកម៉ៅដើមស្វាយនោះទេ ពេលទៅដល់ចំការមិនបានជួបអ្នកម៉ៅស្វាយទេ ខ្លួនក៏ជិះម៉ូតូត្រលប់មកវិញ ពេលនោះស្រាប់តែឈ្មោះ ម-    បានហៅខ្លួនឱ្យឈប់ ពេលឈប់នោះមានមនុស្ស៥នាក់រួមទាំងប៉ូលីសក៏នៅទីនេះដែរ ហើយឈ្មោះ ម-    បានគេហៅឈ្មោះ ច-    ពេលមកដល់ឈ្មោះ ច-    និយាយថា ខ្លួនដើមនិយាយដើមគាត់ ខ្លួនមិនដែលស្គាល់បងឯងទេ ហើយឈ្មោះឡាច-ណារី មិនស្តាប់ ជេរខ្លួនតែម្តង ដោយមានពាក្យមិនសមរម្យជាច្រើន ហើយបានវាយខ្លួន ដោយទាត់ធាក់ខ្លួន៣ទៅ៤ជើងចំចង្កេះ និងទះកំភ្លៀង៣ទៅ៤ដៃ ហើយបានគំរាមខ្លួនថាឈប់ឱ្យជិះម៉ូតូកាត់ផ្លូវនេះទៀត (ឯ-៣)។

-ជនត្រូវចោទឈ្មោះ ម-    ភេទប្រុស អាយុ៣០ឆ្នាំ បានឆ្លើយបញ្ជាក់ថា នៅមុនពេលកើតហេតុម្តាយក្មេកខ្លួន បានជិយាយប្រាប់ខ្លួនថា មានមនុស្សម្នាក់មិនស្គាល់ឈ្មោះបានចូលមកផ្ទះគាត់ មក៣ទៅ៤ដងដោយស៊ើបពីអ្នកជិតខាងពីរឿងគ្រួសារខ្លួន។ លុះនៅថ្ងៃកើតហេតុ ខ្លួនក៏បានឃើញភិនភាគមនុស្សស្រី ដែលម្តាយក្មេកបានប្រាប់កំពុងជិះម៉ូតូ ហើយខ្លួនបានហៅគាត់ឱ្យឈប់ ហើយសួរគាត់ថាមកពីណា មកពីភូមិទឹកឃ្លាំង មកមានការអី មកទារលុយគេជំពាក់ថ្លៃស្វាយ ហើយខ្លួនសួរបន្ថែមទៀតថា ហេតុអីបានចូលផ្ទះម្តាយក្មេកខ្លួនមើលរូបថតការខ្លួន មានបានដើរនិយាយដើមពីស្ថានភាពគ្រួសារម្តាយក្មេកខ្លួន និងខ្លួនទេ ហើយស្ត្រីនោះឆ្លើយថាមិនបាននិយាយទេ ហើយគាត់និយាយខ្លាំងៗដាក់ខ្លួនថា ខ្លួននិយាយបំភ្លើសទៅលើគាត់ ពេលនោះប៉ូលីសប៉ុស្តិ៍បានជិះល្បាតម្នាក់ឈ្មោះ  បានសួរខ្លួនថាមានរឿងអី ខ្លួនថា (និយាយរឿងប្រាប់ពីស្ថានភាពដែលខ្លួនបាននិយាយជាមួយគាត់) ហើយប៉ូលីសបានសួរទៅគាត់ៗ វាងតឹងសរសៃក ដាក់ប៉ូលីសៗ បានគេទៅមេប៉ុស្តិ៍ ហើយមេប៉ុស្តិ៍មកដល់ ក៏បានសួរនាំឈ្មោះ   មកកន្លែងនឹងធ្វើអី ហើយគាត់ឆ្លើយថា មកយកលុយថ្លៃស្វាយពីអ្នកម៉ៅស្វាយ ក្រោយមេប៉ុស្តិ៍ បានហៅគាត់ទៅប៉ុស្តិ៍ខ្លួនក៏ទៅដែរ ហើយខ្លួនក៏បានធ្វើពាក្យបណ្តឹងប្តឹងគាត់នៅប៉ុស្តិ៍ ពីបទ បរិហាកេរ្តិ៍។ រឿងនេះខ្លួន មិនបានវាយទៅលើឈ្មោះ   ទេ ប្រពន្ធខ្លួនក៏មិនបានវាយដែរ (ឯ-៥)។

-ជនត្រូវចោទឈ្មោះ ច-    ភេទស្រី អាយុ២៨ឆ្នាំ បានឆ្លើយបញ្ជាក់ថា ខ្លួនមិនបានស្គាល់ឈ្មោះ   (អ្នកប្តឹង)នេះទេ ពេលប្រកែកឈ្លោះគ្នានោះគឺនៅជិតផ្ទះប្តីខ្លួន ពេលកើតហេតុនោះខ្លួនទៅដល់មានប៉ូលីស២នាក់នៅទីនោះហើយ និងអ្នកភូមិជាច្រើនទៅមើល ទៅដល់កន្លែងកើតហេតុនោះខ្លួនមិនបានឈ្លោះជាមួយឈ្មោះ   នោះទេ ខ្លួនបានសួរទៅគាត់ថាហេតុអីបានជាសួរនាំរឿងគ្រួសារខ្លួន ថាឪពុកខ្លួនលែងលះគ្នា ឪពុកខ្លួនមានស្រី ដឹងពីណាមកថាខ្លួន និងប្តីខ្លួនឈ្លោះតែគ្នា តែឈ្មោះនេះប្រកែកថាមិនបាននិយាយ ហើយខ្លួនក៏ដើរចេញពីកន្លែងនេះ ដោយខ្លួនមិនវាយឬទះកំភ្លៀងទៅលើឈ្មោះនេះទេ រឿងសមត្ថកិច្ចជាអ្នកដោះស្រាយបន្ត(ឯ-៤)។

ក្រោយពីបានស្តាប់ចំលើយជនរងគ្រោះឈ្មោះ   និងចំលើយជនត្រូវចោទឈ្មោះ ម-

និងឈ្មោះ ច- និងឯកសារផ្សេងៗរួចមក តំណាងអយ្យការបានសម្រេចចោទប្រកាន់លើឈ្មោះ ង- និងឈ្មោះ ចេ- តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ០៩៧ ដកសស ចុះថ្ងៃទី០១-០២-២០១៨ របស់អយ្យការអមសាលាដំបូង ខេត្តកណ្ដាល ពីបទ: ជេរប្រមាថជាសាធារណៈ និងបទ: ហិង្សាដោយចេតនា ទៅចៅក្រមស៊ើបសួរចាត់ការបន្ត ។

## II- ដំណាក់កាលស៊ើបអង្កេតនៅចៅក្រមស៊ើបសួរ

-ជនរងគ្រោះឈ្មោះ ម- ភេទស្រី អាយុ៤៥ឆ្នាំ បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុវេលាម៉ោង១០ម៉ោង ខ្ញុំបានជិះម៉ូតូចេញពីភូមិព្រៃប្រាំង ឃុំស៊ីធរ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ដើម្បីទៅទារប្រាក់ពីអ្នកម៉ៅស្វាយរបស់ខ្ញុំនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ពេលទៅដល់ពុំបានជួបអ្នកម៉ៅស្វាយនោះទេ ខ្ញុំរង់ចាំជួបអ្នកម៉ៅស្វាយរហូតដល់ម៉ោង១៥រសៀលនៅតែមិនជួប ក៏ជិះត្រលប់មកផ្ទះវិញ លុះជិះបានប្រហែលមួយគីឡូម៉ែត្រដី ស្រាប់តែឈ្មោះ ម- បានហៅឱ្យខ្ញុំឈប់ ខ្ញុំក៏ឈប់ ស្រាប់តែឈ្មោះនេះបានគេទូរសព្ទ ហៅប្រពន្ធរបស់គេឈ្មោះឡាច-ណារី ឱ្យមកមើលមុខខ្ញុំ ហើយឈ្មោះ ច- បានមកដល់មាននគរបាលប៉ុស្តិ៍ទឹកឃ្លាំងមកជាមួយផង ពេលមកដល់ឈ្មោះនេះបានស្រែកឱ្យខ្ញុំដោះមួកការពារចេញ និងដោះម៉ាស់មុខ ពេលនោះនគរបាលបានចាប់ដៃខ្ញុំទាំង២ទៅក្រោយ ហើយឈ្មោះ ចេ- បានដោះមួយ និងដោះម៉ាស់មុខខ្ញុំចេញ ហើយបានសួរខ្ញុំជាច្រើន ពីនេះពីនោះ តែខ្ញុំមិនឆ្លើយព្រោះមិនដែលស្គាល់គ្នា ពេលនោះឈ្មោះឡាច-ណារី បានជេរបញ្ជោរមកលើខ្ញុំដូចជាពាក្យ ដើងមកដេញប្រុស មីសំផឹង មីអាយ: និងពាក្យអាសអាភាសជាច្រើនមិនអាចនិយាយបាន និងបានទះកំភ្លៀងខ្ញុំចំនួន៦ដៃ និងធាក់មួយជើងដួលទៅដី ពេលនោះនគរបាលបានចាប់គ្រៀកខ្ញុំយកទៅប៉ុស្តិ៍ ទៅអធិការស្រុកល្វាឯមដោយឃាត់ខ្ញុំរហូតដល់ម៉ោង១២យប់ទើបឱ្យខ្ញុំមកផ្ទះ (៦-៨)។

-ជនត្រូវចោទឈ្មោះ ម- ភេទប្រុស អាយុ៣២ឆ្នាំ បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះខ្ញុំពិតជាបានស្ទាក់ផ្លូវឈ្មោះ - ដើម្បីសួរនាំគាត់ឈ្មោះ រ- រ ដើម្បីសួរនាំគាត់ថាហេតុអ្វីបានជាគាត់មកសួរប្រវត្តិគ្រួសារប្រពន្ធរបស់ខ្ញុំ មកផ្ទះប្រពន្ធខ្ញុំមើលរូបថតរៀបការរបស់ខ្ញុំ, ហើយគាត់បានឆ្លើយថា គាត់មិនដឹងរឿងទេ គាត់មកនេះដើម្បីទារលុយគេជំពាក់ថ្លៃស្វាយទេ កំពុងសួរនាំគ្នាប្រពន្ធ និងម្ដាយក្មេកខ្ញុំក៏មកដល់ អ្នកទាំង២ មិននិយាយអ្វីទេ ពេលនោះក៏មានប៉ូលីសទឹកឃ្លាំង៤នាក់បានមកដល់កន្លែងកើតហេតុ ហេតុ បានសួរនាំខ្ញុំ និងឈ្មោះ - ដោយសួរមិនច្បាស់លាស់ នគរបាលបានហៅខ្ញុំ ប្រពន្ធខ្ញុំ និងឈ្មោះ - ទៅប៉ុស្តិ៍ដើម្បីសាកសួររឿងហេតុដែលបានកើតឡើង រហូតដល់ទៅអធិការស្រុកល្វាឯម ល្វាឯមរហូតដល់ម៉ោង១១យប់ ទើបត្រលប់មកផ្ទះវិញទាំងអស់គ្នា (៦-២២)។

-ជនត្រូវចោទឈ្មោះ ច- ភេទស្រី អាយុ២៨ឆ្នាំ បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះខ្ញុំរៀបទៅភ្នំពេញ មុនទៅខ្ញុំបានគេទូរសព្ទរកប្ដី ពេលនោះប្ដីបានប្រាប់ខ្ញុំថា បានឃាត់ឈ្មោះ - ហើយខ្ញុំបានទៅកន្លែងនោះ ពេលទៅដល់ខ្ញុំមិនបានទៅជិតឈ្មោះ - ទេ ដោយប្ដីខ្ញុំ និងសមត្ថ

កិច្ចកំពុងស្ទូវគាំ ដោយខ្លួនមិនបានជេរ ឬវាយទៅលើឈ្មោះ [illegible] (ឯ-៣៥។

-សាក្សីឈ្មោះ [illegible] ភេទស្រី អាយុ៣៩ឆ្នាំ (ដើមបណ្តឹង) បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានឃើញមនុស្សស្រី-ប្រុស ២នាក់កំពុងប្រគាយប្រគប់វាយទៅលើឈ្មោះស្រួយ-ឃាង និងជេរបញ្ជោរ ឃើញដូចនេះខ្លួនចូលទៅឃាត់ ស្រាប់តែមានមនុស្សប្រុស២ទៅ៣នាក់ ចាប់ក្រៀកឈ្មោះ [illegible] យកទៅឱ្យនគរបាល (ឯ-១៣)។

-សាក្សីឈ្មោះ [illegible] ភេទស្រី អាយុ២៨ឆ្នាំ (ដើមបណ្តឹង) បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានឃើញមនុស្សស្រី-ប្រុស ២នាក់កំពុងប្រគាយប្រគប់វាយទៅលើឈ្មោះស្រួយ-ឃាង និងជេរបញ្ជោរ ឃើញដូចនេះខ្លួនចូលទៅឃាត់ ស្រាប់តែមានមនុស្សប្រុស២ទៅ៣នាក់ ចាប់ក្រៀកឈ្មោះ [illegible] យកទៅឱ្យនគរបាល (ឯ-១២)។

-សាក្សីឈ្មោះ [illegible] ភេទស្រី អាយុ៤៦ឆ្នាំ (ចុងបណ្តឹង) បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ មានការជជែកគ្នានៅមុខផ្ទះខ្លួន ដោយឈ្មោះញៀម-មីនា និងឈ្មោះឡាច-ណារី កំពុងជជែកគ្នាជាមួយស្រ្តីម្នាក់មិនស្គាល់ឈ្មោះជាអ្នកស្រុកផ្សេង ដោយនិយាជែកគ្នាខ្លាំងៗ ដូចជាធ្លាប់មានទំនាស់ជាមួយគ្នាពីមុនមក ប៉ុន្តែខ្លួនមិនបានឃើញវាយគ្នាទេ (ឯ-៣២)។

-បានឃើញ កំណត់ហេតុយកចំលើយសាក្សីឈ្មោះ [illegible] ភេទប្រុស អាយុ៣១ឆ្នាំ ជាមេប៉ុស្តិ៍ទឹកឃ្លាំង (ឯ-៣៣)។

-ជនត្រូវចោទឈ្មោះ [illegible] ត្រូវបានចៅក្រមស៊ើបសួរ បានចេញដីកាសម្រេច មិនឃុំខ្លួន តាមដីកាលេខ១២០១ ដកសមយ ចុះថ្ងៃទី២៣-៥-២០១៨ (ឯ-២៥)។

-ជនត្រូវចោទឈ្មោះ [illegible] ត្រូវបានចៅក្រមស៊ើបសួរ បានចេញដីកាសម្រេច មិនឃុំខ្លួន តាមដីកាលេខ១៨៨២ ដកសមយ ចុះថ្ងៃទី១៨-៦-២០១៨ (ឯ-៣៧)។

-ជនត្រូវចោទឈ្មោះ [illegible] ត្រូវបានចៅក្រមស៊ើបសួរ បានចេញដីកាសម្រេចឱ្យជាប់កាតព្វកិច្ច នៃការត្រួតពិនិត្យតាមផ្លូវតុលាការ តាមដីកាលេខ១២០២ សដកព ចុះថ្ងៃទី២៣-៥-២០១៨ និងបង្កាន់ដៃទទួលប្រាក់លេខ ០២២ ចុះថ្ងៃទី២៨-៥-២០១៨ (ឯ-២៣)។

-ជនត្រូវចោទឈ្មោះ [illegible] ត្រូវបានចៅក្រមស៊ើបសួរ បានចេញដីកាសម្រេចឱ្យជាប់កាតព្វកិច្ច នៃការត្រួតពិនិត្យតាមផ្លូវតុលាការ តាមដីកាលេខ១៨៨៣ សដកព ចុះថ្ងៃទី១៨-៦-២០១៨ និងបង្កាន់ដៃទទួលប្រាក់លេខ ០២៣ ចុះថ្ងៃទី១៨-៦-២០១៨ (ឯ-៣៦)។

<u>តំណាងអយ្យការយល់ឃើញថា:</u>

-តាមចំលើយជនរងគ្រោះឈ្មោះ [illegible] , ជនត្រូវចោទឈ្មោះ [illegible] ,ឈ្មោះ [illegible] , ចំលើយសាក្សីឈ្មោះ [illegible] ,ឈ្មោះ [illegible] ,ឈ្មោះ [illegible] និងឈ្មោះ [illegible] ព្រមទាំងឯកសារផ្សេងៗបញ្ជាក់ថាពិតជាមាន អង្គហេតុនៃបទល្មើស ជេរប្រមាថជាសាធារណៈ និងបទ ហិង្សា

ដោយចេតនា ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧-៨-២០១៧។

-ជនរងគ្រោះឈ្មោះ ម- បានឆ្លើយបញ្ជាក់ដូចថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានជិះម៉ូតូទៅទារប្រាក់ពីអ្នកម៉ៅស្វាយរបស់ខ្លួន ពេលទៅដល់ពុំបានជួបអ្នកម៉ៅស្វាយនោះទេ ហើយខ្លួន ក៏ជិះត្រលប់មកផ្ទះវិញ ស្រាប់តែឈ្មោះ - បានហៅខ្លួនឱ្យឈប់ ខ្លួនក៏ឈប់ ហើយបានគេទូរសព្ទ ហៅប្រពន្ធរបស់គេឈ្មោះ ច- ឱ្យមកវាយខ្លួនដោយទះកំភ្លៀង៦ដៃ និងជេរខ្លួននូវពាក្យអាសអាភាសជាច្រើន។

-ជនត្រូវចោទឈ្មោះ ម- បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុ ខ្លួនពិតជាបានហៅឈ្មោះ - ដើម្បីសាកសួរ ថាហេតុអីបានសួរនាំរឿងគ្រួសារម្ដាយក្មេកខ្លួន តែឈ្មោះនេះបដិសេធថា មិនបាននិយាយពីរឿងគ្រួសារម្ដាយក្មេកខ្លួន ហើយខ្លួនក៏មិនបានជេរ ឬវាយទៅលើឈ្មោះ - នោះទេ។

-ជនត្រូវចោទឈ្មោះ ច- បានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ ខ្លួនមិនបានជេរ ឬវាយទៅលើឈ្មោះ - នោះទេ ។

-ជនត្រូវចោទឈ្មោះ ម- និងឈ្មោះឡាច-ណារី បានឆ្លើយបដិសេធ ថាខ្លួនមិនបានជេរ ឬវាយទៅលើឈ្មោះ - នោះទេ នេះគ្រាន់តែជាចំលើយឆ្លើយដោះសារឱ្យរួចផុតពីការចោទប្រកាន់តែប៉ុណ្ណោះ ដោយពុំមានភស្តុតាងផ្សេងណាមួយមកបញ្ជាក់គួរឱ្យជឿបានឡើយ។

-ផ្អែកតាមចំលើយជនរងគ្រោះ ,ចំលើយសាក្សី ឯកសារផ្សេងៗ បញ្ជាក់ឱ្យឃើញថា ជនត្រូវចោទឈ្មោះ ម- និងឈ្មោះឡាច-ណារី ពិតជាបានធ្វើសកម្មភាពរួមគ្នា ជេរប្រមាថ និងវាយទៅលើទៅលើជនរងគ្រោះឈ្មោះ - ពិតប្រាកដមែន។

-ជនត្រូវចោទឈ្មោះ ម- និងឈ្មោះ ច- ពិតជាមានចេតនា ជេរប្រមាថ និងវាយជនរងគ្រោះ ក្នុងចំណោមមនុស្សជាច្រើន ដែលធ្វើឱ្យជនរងគ្រោះអាប់អោនកិត្តិយស និងសេចក្ដីថ្លៃថ្នូរ ដែលអំពើនេះច្បាប់ បញ្ញត្តិជាបទល្មើស ជេរប្រមាថជាសាធារណៈ និងបទៈហិង្សាដោយចេតនា ត្រូវផ្ដន្ទាទោស តាមមាត្រា៣០៧ និងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ។

-ជនត្រូវចោទឈ្មោះ ម- និង ច- ជានីតិជន មានស្មារតីយល់ដឹងខុសត្រូវ ពេលហេតុការណ៍កើតឡើង ជនត្រូវចោទដឹងច្បាស់ អំពីព្យសនកម្ម ដែលកើតចេញពីអំពើរបស់ខ្លួន ។

-មានភស្តុតាង ដាក់បន្ទុកទៅលើជនត្រូវចោទឈ្មោះ ម- ភេទប្រុស អាយុ៣០ឆ្នាំ និងឈ្មោះ - ភេទស្រី អាយុ២៨ឆ្នាំ ពីបទៈ **ជេរប្រមាថជាសាធារណៈ** និងបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧-៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣០៧ និងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ។

<u>ហេតុដូច្នេះ</u>

<u>ប្ដឹងសុំឱ្យចៅក្រមស៊ើបសួរសម្រេច:</u>

☑ **<u>បញ្ជូនជនត្រូវចោទ:</u>**

១-ឈ្មោះ ម- ភេទប្រុស អាយុ៣០ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ច- ភេទស្រី អាយុ២៨ឆ្នាំ (ក្រៅឃុំ)

ពីបទៈ ជេរប្រមាថជាសាធារណៈ និងបទៈហិង្សាដោយចេតនា ប្រព្រឹត្តនៅភូមិទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម ខេត្តកណ្ដាល កាលពីថ្ងៃទី២៧-៨-២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោស តាមមាត្រា៣០៧ និងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌ ព្រមទាំងសំណុំរឿងព្រហ្មទណ្ឌលេខ១៤៥០អក ចុះថ្ងៃទី១៧-១១-២០១៧ **ទៅជំនុំជំរះ** ។

ថ្ងៃ.............................ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

កណ្ដាល ::: ថ្ងៃទី 26 ខែវិច្ឆិកា ឆ្នាំ២០១៨

**តំណាងអយ្យការ**

ឈាង [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តកំពត

លេខ: ..... ចុះថ្ងៃទី .....
ខែ ..... ឆ្នាំ២០១.....
សំណុំរឿង ..... លេខ .....
ទី ..... ខែ ..... ឆ្នាំ .....

## សេចក្តីសុំប្តឹងតវ៉ា

ឆ្នាំ ..... ខែ ..... ថ្ងៃទី ..... វេលាម៉ោង ..... ។
យើង **ម៉ាន់ បូរេត** ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តកំពត។
បាន .....
ចូលមកចំពោះមុខយើងនៅ លេខាធិការដ្ឋានរដ្ឋបាលនៃ សាលាដំបូងខេត្តកំពត ហើយសុំប្តឹង .....
នឹង ..... លេខ .....
ចុះថ្ងៃទី ..... ខែ ..... ឆ្នាំ ..... ត្រង់ចំណុច: .....

ឈ្មោះនេះទទួលថា នឹងធ្វើពាក្យប្តឹងបន្ថែមឱ្យទាន់ពេលវេលា។
ក្រែងពុំប្រាកដ យើងបានសូត្រសេចក្តីនេះឱ្យ ..... ស្តាប់ហើយចុះហត្ថលេខាឬផ្តិតមេដៃជាមួយយើង។

អ្នកប្តឹង
ស្នាមមេដៃ ឬហត្ថលេខា

ប្រធានលេខាធិការដ្ឋានរដ្ឋបាល
ម៉ាន់ បូរេត

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ..... ព.ស ២៥៥៦
ថ្ងៃទី ..... ខែ ..... ឆ្នាំ២០១.....
ប្រធានលេខាធិការដ្ឋានរដ្ឋបាល

បានឃើញ
ប្រធានសាលាដំបូង

ឡុង គេសផល្លី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ពន្ធនាគារខេត្តកំពត
លេខ ៣១៣/៣
ថ្ងៃទី ១៨ ខែ ១២ ឆ្នាំ ២០១៨
ម៉ោង ១៤ ០០

<u>ពាក្យបណ្តឹងឧទ្ធរណ៍</u>

ខ្ញុំបាទឈ្មោះ ឃ. (ហៅ ៥) ភេទ ប្រុស អាយុ២១ឆ្នាំ ជនជាតិ ខ្មែរសញ្ជាតិ ខ្មែរ បច្ចុប្បន្នកំពុងឃុំខ្លួនក្នុងពន្ធនាគារខេត្តកំពតពីបទជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

<u>សូមគោរពជូន</u>

លោកប្រធានសាលាដំបូងខេត្តកំពត

<u>កម្មវត្ថុ</u>: សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមលេខ ៦០៦ (គ) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ គ្រប់សេចក្តីសម្រេចរបស់សាលាដំបូងខេត្តកំពតទាំងមូល ។

យោង: សំណុំរឿងព្រហ្មទណ្ឌលេខ ២៥៧ ចុះថ្ងៃទី ២០ ខែមេសាឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពត ។

- សាលក្រមលេខ ៦០៦ (គ) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្តកំពត ។

ខ្ញុំបាទមានកិត្តិយស សូមជំរាបជូនលោកប្រធានមេត្តាជ្រាបថា ៖ ដោយសារខ្ញុំបាទមានការកើតទុក្ខមិនសុខចិត្ត ចំពោះការសម្រេចសេចក្តី របស់សាលាដំបូងខេត្តកំពត កាលពីថ្ងៃទី ២៨ ខែវិច្ឆិកាឆ្នាំ២០១៨ដែលសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២(ពីរ)ឆ្នាំ និង៦(ប្រាំមួយ)ខែ ។ ការសម្រេចនេះ ពុំមានភាពយុត្តិធម៌ចំពោះខ្ញុំបាទឡើយព្រោះខ្ញុំបាទមិនបានប្រព្រឹត្តខុសដូចការចោទប្រកាន់របស់លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពតឡើយ ។ ដែលជាហេតុធ្វើអោយមានកា''ះពាល់ដល់សិទ្ធ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ ។

អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាជួយអន្តរាគមន៍បញ្ជូនរឿងក្តីរបស់ខ្ញុំបាទ ទៅកាន់សាលាឧទ្ធរណ៍ដោយក្តីអនុគ្រោះ ។

សូមលោកប្រធានមេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃ អង្គារ៍១១កើត ខែមិគសិរឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

កំពត.ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៨

ស្នាមមេដៃស្តាំ

លេខ: ៤៥..........ពគ.កព

បានឃើញ និងបញ្ជាក់ថា

ស្នាមមេដៃនេះពិតជារបស់ឈ្មោះឃ ពិតប្រាកដមែន ។

ថ្ងៃ អង្គារ៍១១កើត ខែមិគសិរឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២

កំពត.ថ្ងៃទី១៨ ខែ ធ្នូ ឆ្នាំ ២០១៨

ប្រធានពន្ធនាគារ

[illegible] ២ [illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប
ពាក្យបណ្តឹងលេខ: ០១
ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩
សំណុំរឿងរដ្ឋប្បវេណី លេខ ១៥០
ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩

# សេចក្តីសុំប្តឹងឧទ្ធរណ៍

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែកុម្ភៈ ថ្ងៃទីដប់ប្រាំបី វេលាម៉ោង ដប់ ព្រឹក។

យើង ឈឹម ណារម្យ ក្រឡាបញ្ជី ជាមន្ត្រីទទួលបន្ទុកចុះបណ្តឹងឧទ្ធរណ៍។

បានឃើញ ឈ្មោះ ថេង សំណាង ជាព្រះរាជអាជ្ញារង បានមកចំពោះមុខយើង សុំប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចមិនឃុំខ្លួនលេខ ២៨២ ឃ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ ត្រង់ចំណុចៈ សេចក្តីសម្រេចទាំងមូលនៃដីកាសម្រេច។

យើងបានចុះបណ្តឹងនេះ ធ្វើឡើងតាមរយៈ ៖

-ការដាក់ពាក្យបណ្តឹង ☐ -សាមីខ្លួនមកប្តឹងផ្ទាល់ ☑

ក្រែងពុំប្រាកដ យើងសូត្រសេចក្តីនេះឲ្យលោក ថេង សំណាង ស្តាប់ហើយឲ្យចុះហត្ថលេខា ឬផ្តិតមេដៃ ជាមួយយើង។

| | |
|---|---|
| អ្នកប្តឹង | មន្ត្រីចុះបណ្តឹង |
| តំណាងអយ្យការ(លោក ថេង សំណាង) | ហត្ថលេខា ឈឹម ណារម្យ |

---

| | |
|---|---|
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| ជ.ប្រធានសាលាដំបូង | ថ្ងៃចន្ទ ១៤កើត ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ |
| អនុប្រធាន | ខេត្តសៀមរាប ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ |
| | ក្រឡាបញ្ជី |
| អ៊ុំ.ចាន់ថុល | គុជ មករា |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអមសាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៧
ចុះថ្ងៃទី ២៨-១១-២០១៨

# ដីកាកោះ

## យើង ព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍

បង្គាប់មកឈ្មោះ ឈ ភេទស្រី អាយុ ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅសព្វថ្ងៃភូមិ៣ សង្កាត់លេខ៤ ក្រុងមិត្តភាព ខេត្តព្រះសីហនុ (**ជនសង្ស័យ**) ឱ្យចូលមកកាន់មហាអយ្យការអមសាលាឧទ្ធរណ៍ នៅថ្ងៃ**ទី២៧ ខែធ្នូ ឆ្នាំ២០១៨** វេលាម៉ោង **១៥:០០នាទីរសៀល** ដើម្បី **សាកសួរបំភ្លឺបន្ថែម** ពីដំណើរបណ្តឹងឧទ្ធរណ៍របស់លោកស្រី ស មេធាវីការពារឱ្យដើមបណ្តឹងឈ្មោះ ថ ប្តឹងលោកស្រី ពីបទៈ **ឆបោក និងលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ។**

សាមីខ្លួនត្រូវអញ្ជើញមកឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨

**ព្រះរាជអាជ្ញា**

**ខៀត _ សារ៉ាត**

យើង..........................................................
បានប្រគល់ដីកាកោះនេះឲ្យឈ្មោះ ..............................
ទីលំនៅសព្វថ្ងៃនៅ...........................ឃុំ.សង្កាត់..............
ស្រុក.ខណ្ឌ.......................ខេត្ត.រាជធានី......................
នៅថ្ងៃទី.............ខែ............ឆ្នាំ២០១៨ ហើយប្រាប់ថា ឲ្យប្រគល់ដីកាកោះនេះដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅដល់។

អ្នកទទួល អ្នកប្រគល់

សាលាឧទ្ធរណ៍ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

សំណុំរឿងរដ្ឋប្បវេណី
លេខ៖ ១៤៧
ចុះថ្ងៃទី ០២-០៣-២០១៨
សាលដីកា
លេខ៖ ២០ "ក្រVII៦"
ចុះថ្ងៃទី ២០-៧-២០១៨

**គាថនាមប្រជារាស្ត្រខ្មែរ**
**សាលាឧទ្ធរណ៍ភ្នំពេញ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃសុក្រ ៩រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ ។

**សមាសភាពក្រុមប្រឹក្សា**

| | | |
|---|---|---|
| លោក | **ខូន អ៊ីម** | ជាប្រធាន |
| លោក | **ឌូ ពៅស៊ិន** | ជាចៅក្រមប្រឹក្សា |
| លោក | **ឡូ មណី** | ជាចៅក្រមប្រឹក្សា |

**ក្រឡាបញ្ជីសវនាការ**

| | |
|---|---|
| លោក | **អ៊ុច កែវបូ** |

**-អត្តសញ្ញាណរបស់គូភាគី**

-ដើមចោទឈ្មោះ ង ភេទស្រី អាយុ៤១ឆ្នាំ មានលំនៅភូមិជ្រោយមេត្រីក្រោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ។

-មេធាវីតំណាងដោយអាណត្តិឲ្យភាគីដើមចោទលោក ក ។

-ចុងចម្លើយឈ្មោះ ម ភេទប្រុស អាយុ៥២ឆ្នាំ មានទីលំនៅភូមិជ្រោយមេត្រីក្រោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ។

**-ខ្លឹមសារនៃការទាមទារ**

ដើមចោទទាមទារឲ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១-សុំឈប់រស់នៅជាអនីតិសង្វាសជាមួយចុងចម្លើយឈ្មោះ ម ។

២-សុំសិទ្ធិអំណាចមេបាលើកូនទាំង០៤នាក់ កូនទី១ ឈ្មោះ ភេទប្រុស អាយុ ២៥ ឆ្នាំ, កូនទី២ ឈ្មោះ ភេទប្រុស អាយុ ២១ឆ្នាំ, កូនទី៣ ឈ្មោះ ភេទស្រី អាយុ ១៧ឆ្នាំ និងកូនទី៤ ឈ្មោះ ភេទប្រុស អាយុ ១២ឆ្នាំ ។

៣-សុំសោហ៊ុយចាំបាច់តាមលទ្ធភាពរបស់ចុងចម្លើយដែលមាន ។

៤-សុំបែងចែកទ្រព្យសម្បត្តិរួមជា២ចំណែកស្មើគ្នា
មានផ្ទះមួយកន្លែងស្ថិតនៅភូមិជ្រោយមេត្រីក្រោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល សង់លើដីដែលមានទំហំ ៣៦៦ម៉ែត្រការ៉េ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ ក.ណ០១៩៦១៥ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៥ (បែងចែកតែផ្ទះទេ) ។

-<u>អង្គហេតុបញ្ជាក់ពីការទាមទារ</u>

ដើមចោទបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយចុងចម្លើយនៅឆ្នាំ១៩៩៤ ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ។ ក្នុងពេលរួមរស់ជាមួយគ្នាមានកូនចំនួន០៤នាក់ ទ្រព្យសម្បត្តិរួមមានផ្ទះ និងដីមួយកន្លែងស្ថិតនៅភូមិជ្រោយមេត្រីក្រោម ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្ដាល មានទំហំ ៣៦៦ម៉ែត្រការ៉េ មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ ក.ណ០១៩៦១៥ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ និងដីមួយកន្លែងទៀតស្ថិតនៅភូមិមេសរប្រចាន់ ឃុំសប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង ។ ចំពោះបំណុលរួមគ្មាន។ លុះដល់ឆ្នាំ២០១៤ ដើមចោទ និងចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា ក៏បានដាក់ពាក្យបណ្ដឹងមកតុលាការ ។

-**បានឃើញ** សាលក្រមរដ្ឋប្បវេណីលេខៈ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល បានសម្រេចថាៈ

១-លើកចោលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ ខ ត្រង់ចំណុចសុំឈប់រស់នៅបែបអនីតិសង្វាសពីចុងចម្លើយឈ្មោះ ម ។ គូភាគីមានសិទ្ធិរៀបអាពាហ៍ពិពាហ៍គូស្រករថ្មី និងចុះបញ្ជីអាពាហ៍ពិពាហ៍តាមច្បាប់។

២-ប្រគល់សិទ្ធិអំណាចមេបាឲ្យទៅដើមចោទឈ្មោះ ខ ជាម្ដាយលើកូនចំនួនពីរនាក់ៈ

២.១-ឈ្មោះ ៖ ខ ភេទស្រី អាយុ ១៧ឆ្នាំ ។

២.១-ឈ្មោះ ស ភេទប្រុស អាយុ ១២ឆ្នាំ ។

ទុកសិទ្ធិឲ្យចុងចម្លើយដែលមិនបានទទួលសិទ្ធិអំណាចមេបាទៅសាកសួរសុខទុក្ខ និងប្រាស្រ័យទាក់ទងជាមួយនឹងកូន និងឲ្យផ្ដល់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព។

៣-<u>បែងចែកទ្រព្យសម្បត្តិរួមមានៈ</u>

៣.១-ផ្ទះទំហំ ៨ម៉ែត្រ គុណនឹង ១៦ម៉ែត្រ និងដីមួយកន្លែងមានទំហំ ៣៦៦ម៉ែត្រការ៉េ ស្ថិតនៅភូមិជ្រោយមេត្រីក្រោម ឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្ដាល មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ក.ណ ០១៩៦១៥ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៥ ត្រូវបែងចែក<u>ជាពីរចំណែកស្មើគ្នា</u> (គិតតាមតម្លៃលក់ជាក់ស្ដែង)។

៣.២-ដីមួយកន្លែង ស្ថិតនៅភូមិមេសរប្រចាន់ ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង មានកិច្ចសន្យាទិញ-លក់ដីធ្លី ដែលមានការបញ្ជាក់លេខ ២១៣/០៧ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៧ របស់មេឃុំមេសរប្រចាន់ ត្រូវប្រគល់ឲ្យទៅចុងចម្លើយឈ្មោះ ម គ្រប់គ្រង ។

៣.៣-ម៉ូតូមួយគ្រឿង ម៉ាកហុងដាសេ១២៥ ពាក់ស្លាកលេខ កណ្ដាល 1E-1953 ត្រូវប្រគល់ឲ្យចុងចម្លើយឈ្មោះ ម គ្រប់គង ។

៣.៤-ម៉ូតូមួយគ្រឿង ម៉ាកហុងដាសេ១២៥ ពាក់ស្លាកលេខ ភ្នំពេញ 1FH-0905 ត្រូវប្រគល់ឲ្យចុងចម្លើយឈ្មោះ ខ គ្រប់គង ។

ច្រានចោលការសុំទាមទារបែងចែកទ្រព្យសម្បត្តិលើសពីនេះ ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់គូភាគីម្នាក់ពាក់កណ្ដាល ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០១៧ ។

-មុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-**ទានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ១០១ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ របស់ ឈ្មោះ តាំង ចន្ទីសុភាព ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខៈ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុច ទី៣.១ និងចំណុច៣.២ នៃសេចក្តីសម្រេចបញ្ចប់ ។

<u>**ការអះអាងរបស់គូភាគី៖**</u>

-ដើមចោទឈ្មោះ ង (អវត្តមាន)

-ចុងចម្លើយឈ្មោះ ម (វត្តមាន)

-លោកមេធាវី ប៊ុន កែវលីម តំណាងដោយអាណត្តិឲ្យភាគីដើមចោទ (វត្តមាន)

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានថ្លែងការណ៍ថាៈ កូនក្តីខ្លួនបានប្តឹងឧទ្ធរណ៍ ត្រង់ចំណុចទី៣.១ នៃសាលក្រមរដ្ឋប្បវេណីលេខៈ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ដោយដីនេះ គឺជាអំណោយដែលឪពុកកូនក្តីខ្លួនបានធ្វើអំណោយមកឲ្យកូនក្តីខ្លួននៅអំឡុងឆ្នាំ២០០៤ គឺមុនពេលដែលកូនក្តីបានរួមរស់នៅជាមួយចុងចម្លើយ ហើយការឲ្យនោះ គឺឲ្យមកកូនក្តីខ្លួនដើម្បីសង់ផ្ទះរស់នៅលើដីដែលមានទំហំ ៣៦៦ម៉ែត្រការ៉េនោះ ។ ចំពោះការសាងសង់ផ្ទះនេះដែរ កូនក្តីខ្លួនទទួលស្គាល់ថា ជាទ្រព្យរួម ប៉ុន្តែដោយសារសព្វថ្ងៃកូនក្តីខ្លួនកំពុងរស់នៅ និងត្រូវគ្រប់គ្រងលើកូនទាំងអស់នោះ កូនក្តីខ្លួនសុំទាមទារយកផ្ទះ និងដីសង់ផ្ទះនេះ ដោយសុខចិត្តប្រគល់ប្រាក់បន្ថែមឲ្យភាគីចុងចម្លើយចំនួន ៣០ ០០០(បីម៉ឺន) ដុល្លារអាមេរិក ហើយចំពោះអាហារកិច្ចវិញ កូនក្តីខ្លួនមិនទាមទារឡើយ ។ រីឯចំណុច៣.២ នៃសាលក្រមរដ្ឋប្បវេណីលេខ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តកណ្តាល កូនក្តីខ្លួនសុំប្រគល់ឲ្យចុងចម្លើយ ។

-កូនឈ្មោះ (កូនពៅ) បានអះអាងថាៈខ្លួនមិនចង់ឲ្យម៉ាក់ប៉ានៅជាមួយគ្នាទេ ព្រោះប៉ាបានគម្រាមម៉ាក់ និងបានជេរម៉ាក់ ព្រមទាំងបានគម្រាមសម្លាប់ទៀត ។

-កូនឈ្មោះ (កូនទី២) បានអះអាងថាៈប៉ាម៉ាក់មិនអាចនៅបន្តជាមួយគ្នាទៀតទេ ព្រោះពួកគាត់រស់នៅមិនចុះសម្រុងនឹងគ្នាទេ ។

-កូនច្បង បានអះអាងថាៈ ខ្លួនធ្លាប់បាននិយាយហេតុផលទៅម៉ាក់ប៉ារួចអស់ហើយ ប៉ុន្តែជាក់ស្តែងម៉ាក់របស់ខ្លួនមទួលយកមិនបាន ព្រោះការរស់នៅជាមួយគ្នា តែងតែមិនចុះសម្រុងគ្នា ។ ម៉ាក់របស់ខ្លួនមានការផ្គត់ផ្គង់គ្រួសារបានច្រើនជាងប៉ា ហើយប៉ាតាំងពីបែកលំនៅពីម៉ាក់ ក៏ដែលបានជួយលុយដល់ពួកខ្លួនដែរ ។

-ចុងចម្លើយឈ្មោះ ម បានអះអាងថាៈ ខ្លួនចង់នៅជួបជុំគ្រួសារ ហើយចិត្តខ្លួនមិនចង់បែកបាក់ពីគ្រួសារទេ ។ ខ្លួនយល់ព្រមប្រគល់ផ្ទះ និងដីដែលសង់ផ្ទះឲ្យទៅដើមចោទគ្រប់គ្រង ប៉ុន្តែខ្លួនសុំទាមទារប្រាក់ចំនួន ៣៥ ០០០ ដុល្លារអាមេរិក ។

-ដើមចោទឈ្មោះ ង បានអះអាងថាៈ ខ្លួនព្រមប្រគល់ប្រាក់ចំនួន ៣៥ ០០០ ដុល្លារអាមេរិកឲ្យទៅចុងចម្លើយ ហើយខ្លួនសុំទាមទារយកផ្ទះនិងដីសង់ផ្ទះនេះ ។ ចំពោះដីមួយកន្លែងស្ថិតនៅភូមិមេសរប្រចាន់ ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្ត ព្រៃវែង ខ្លួនយល់ព្រមប្រគល់ឲ្យទៅចុងចម្លើយដដែល ។

## សំអាងហេតុ

## យល់ឃើញថា៖

-ពាក្យបណ្តឹងឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃ១៣ ខែធ្នូ ឆ្នាំ២០១៧ របស់ឈ្មោះ ង ជាដើមចោទបានប្តឹងឧទ្ធរណ៍និងសាលក្រមរដ្ឋប្បវេណីលេខ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាលត្រង់ចំណុចទី៣.១ និងចំណុច៣.២ នៃសេចក្តីសម្រេចបញ្ចប់ បានធ្វើឡើងក្នុងកំណត់ សាលាឧទ្ធរណ៍អាចលើកយករឿងក្តីនេះ ដើម្បីទាញហេតុផលផ្ទាល់មាត់បាន យោងតាមមាត្រា៤៨នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានបញ្ជាក់ថា: ការប្តឹងឧទ្ធរណ៍របស់ដើមចោទ ត្រង់ចំណុចទី៣.១ ទាក់ទងនឹងផ្ទះ និងដីដែលសង់ផ្ទះ ដោយសារភាគីដើមចោទត្រូវគ្រប់គ្រងលើកូនទាំងអស់នោះ ដើមចោទសុំទាមទារយកផ្ទះ និងដីសង់ផ្ទះនេះ ដោយសុខចិត្តប្រគល់ប្រាក់បន្ថែមឲ្យភាគីចុងចម្លើយចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ចំណែកដីស្រែនៅចំណុច៣.២ ដើមចោទសុំប្រគល់ឲ្យចុងចម្លើយដដែល។

-ចំណែកភាគីចុងចម្លើយបានអះអាងថា:សុំទាមទារប្រាក់ចំនួន ៤០០០០ (បួនម៉ឺន)ដុល្លារអាមេរិក ។

-ឆ្លងតាមលទ្ធផលនៃការសម្រុះសម្រួលគ្នា ភាគីទាំងពីរបានព្រមព្រៀងដូចតទៅ៖

ក.ចំណុច ៣.១

-ចុងចម្លើយយល់ព្រមប្រគល់ផ្ទះ និងដីដែលសង់ផ្ទះឲ្យទៅដើមចោទគ្រប់គ្រង។

-ដើមចោទយល់ព្រមប្រគល់ប្រាក់ចំនួន៣៥០០០(បីម៉ឺនប្រាំពាន់)ដុល្លារអាមេរិកទៅឲ្យចុងចម្លើយ។

ខ.ចំណុច ៣.២

-ដើមចោទយល់ព្រមប្រគល់ដីមួយកន្លែងស្ថិតនៅភូមិមេសរប្រចាន់ ឃុំមេសរប្រចាន់ ស្រុកពារាំង ខេត្តព្រៃវែង ឲ្យទៅចុងចម្លើយដដែល។

គប្បីក្រុមប្រឹក្សាពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-សាលក្រមរដ្ឋប្បវេណីលេខ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាលត្រង់ចំណុចទី៣.១ និងចំណុចទី៣.២ ដែលបានសម្រេចមក មានលក្ខណៈត្រឹមត្រូវ ហើយត្រង់ចំណុចទី៣.២ លើកលែងតែចំណុចទី៣.១ ត្រូវតែប្រែឡើងវិញតាមការព្រមព្រៀងរបស់គូភាគី ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ យោងតាមបញ្ញត្តិមាត្រា៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សេចក្តីសម្រេចបញ្ចប់

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៧ របស់ដើមចោទឈ្មោះ តាំង ចន្ទីសុភាព ទុកជាត្រឹមត្រូវតាមច្បាប់មួយផ្នែក ។

២-តម្កល់ចំណុចទី៣.២ នៃសាលក្រមរដ្ឋប្បវេណីលេខ ១១៥ "ញ" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាលទុកជាបានការ លើកលែងតែចំណុចទី៣.១ ត្រង់ឃ្លាចុងក្រោយដែលបានសម្រេចថា: ត្រូវបែងចែកជាពីរចំណែកស្មើគ្នា (គិតតាមតម្លៃលក់ជាក់ស្តែង) ត្រូវកែមកជា "ត្រូវប្រគល់ឲ្យដើមចោទឈ្មោះ ង គ្រប់គ្រង "វិញ និងសម្រេចបន្ថែមដូចខាងក្រោម៖

-បង្គាប់ឲ្យដើមចោទឈ្មោះ ង ប្រគល់ប្រាក់ចំនួន ៣៥០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក

ឲ្យទៅចុងចម្លើយឈ្មោះ ម តាមការព្រមព្រៀងរបស់គូភាគី។

ចំណាចផ្សេងទៀតនៃសាលក្រម ត្រូវរក្សាទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុក របស់ដើមចោទ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ ។

-បើកសិទ្ធិប្តឹងសាទុក្ខក្នុងអំឡុងពេល១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកា ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក **អ៊ុច អែនបូ** | លោក **តូ ពៅស៊ុន** ,លោក **ឆូ មណី** | លោក **ឡូន អ៊ុម** |

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-

ថ្ងៃ សុក្រ ៨កើត ខែ ទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៨

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

**ក្រឡាបញ្ជី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍
លេខ ២៣២ ឧ.ជ.ណ/០១៨
សំណុំរឿងតម្កល់ទុកឥតបាត់ការលេខ
១៦៦ ចុះថ្ងៃទី ០៥-០៧-២០១៨

## លិខិតជូនដំណឹង

## យើង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

## ជម្រាបមក

ឈ្មោះ អ៊ុ ប៊ុនរ៉ា អត្តលេខ ៥៥៥ ជាសមាជិក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ ក្រុមមេធាវី សហការីកម្ពុជា និងអន្តរជាតិ និងជាមេធាវីតំណាងដោយអាណត្តិឱ្យលោក អ៊ឹង សាន ផ្ទះលេខ (PRM1-LC1-100-P18) អាគារលេខ២៦៦ បុរីដីស្ពានព្រែកមៀរ (ប៉េង ហួត) ផ្លូវ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

អំពីបណ្ដឹងតវ៉ារបស់លោក ប្ដឹងពីដីកាតម្កល់រឿងទុកឥតបាត់ការលេខ ៣៦៧/១៧ ចុះថ្ងៃទី ០១-១២-២០១៧ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៨ ចុះថ្ងៃទី ១២-០៧-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកំពត អំពីដំណើររឿងបទៈ ឆបោក ។

យើងបានតម្កល់សេចក្ដីសម្រេចរបស់អយ្យការអមសាលាដំបូងខេត្តកំពត ទុកជាបានដដែល ដោយសេចក្ដីសម្រេចនេះ មានលក្ខណៈត្រឹមត្រូវតាមនីតិវិធី និងគតិច្បាប់ហើយ តាមសេចក្ដីសម្រេចរបស់យើងលេខ ២៣២ សត.ប្រក.០១៨ ចុះថ្ងៃទី ២៤ ខែ ៥ ឆ្នាំ២០១៨ ។

មូលហេតុនេះ សូមលោកជ្រាប ។

ថ្ងៃ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៥ ឆ្នាំ២០១៨
អគ្គព្រះរាជអាជ្ញា

អ៊ិត_សាវុធ

យើង..........................មុខងារ..........................បាន
ប្រគល់លិខិតជូនដំណឹងនេះឱ្យឈ្មោះ..........................
ទីលំនៅសព្វថ្ងៃ..........................ឃុំសង្កាត់..........................
ស្រុក.ខណ្ឌ..........................ខេត្ត.រាជធានី..........................
ធ្វើនៅថ្ងៃទី..........................ខែ..........................ឆ្នាំ២០១៨ រួចហើយ ។

អ្នកទទួល　　　　អ្នកប្រគល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំដកពាក្យបណ្តឹង

<u>ដើមចោទ:</u> ឈ្មោះ ធ ភេទប្រុស ជាតិខ្មែរ អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិព្រៃធំ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

សូមគោរពជូន

**លោកស្រីគម សុគន្ធា ជាចៅក្រមសាលាដំបូងខេត្តសៀមរាប**

<u>កម្មវត្ថុ</u> ស្នើសុំដកពាក្យបណ្តឹង ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ១៥០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប។

តបតាមកម្មវត្ថុខាងលើនាងខ្ញុំ សូមជំរាប **លោកស្រីចៅក្រម** មេត្តាជ្រាបថា: កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ ខ្ញុំបាទបានដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តសៀមរាបពីបទអំពើលួច បានប្តឹងលើឈ្មោះ ស ហើយពេលនេះខ្ញុំបាទសូមដកពាក្យបណ្តឹងវិញ ដោយមូលហេតុថាខ្លួនអាណិតឈ្មោះ ស ដោយសារមានកូនតូចៗ និងត្រូវបំបៅដោះ ហើយថែមទាំងយល់ព្រមសងសំណងមកខ្លួន ហើយរូបគេបានដឹងនូវកំហុសដែលគេបានប្រព្រឹត្តិ ព្រមទាំងសន្យាថានឹងកែប្រែនូវកំហុសដែលគេបានប្រព្រឹត្តិកន្លងមក និងឈប់ប្រព្រឹត្តិតទៅទៀត ហេតុដូច្នេះទើបខ្ញុំបាទមកសុំដកពាក្យបណ្តឹងវិញ។ ដូចនេះសុំ **លោកស្រីចៅក្រម** មេត្តាយោគយល់ និងកែសម្រួលឲ្យខ្ញុំបាទដកពាក្យបណ្តឹង ។

ដូចនេះសូម **លោកស្រីចៅក្រម** សុំតុលាការមេត្តាជួយសំរបសំរួល ឲ្យខ្ញុំបាទដកពាក្យបណ្តឹងដោយក្តីអនុគ្រោះ។

សូម **លោកស្រីចៅក្រម** មេត្តាទទួលយកក្តីគោរពដ៏ខ្ពង់ខ្ពស់ពីពូកខ្ញុំ។

សៀមរាប, ថ្ងៃទី...១៥.....ខែកុម្ភៈ ឆ្នាំ២០១៩

ស្នាមមេដៃស្តាំ

ព្រះរាជាណាចក្រកម្ពុជា

មហាអយ្យការអមសាលាឧទ្ធរណ៍ ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៧៣២ សក.ប្រក០១៨

សេចក្តីសម្រេចតម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការ

បានឃើញ មាត្រា ៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០-០៨-២០១៧ ស្តីពី ការតម្កល់រឿងទុកឥតចាត់ការ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៨ ចុះថ្ងៃទី ១២-០៧-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកំពត ។

បានឃើញ សំណុំរឿង-តម្កល់រឿងទុកឥតចាត់ការ-ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍ លេខ ១៦៦ ចុះថ្ងៃទី ០៥-០៧-២០១៨ ។

បានឃើញ ពាក្យបណ្តឹងលេខ ១៤៣១ ចុះថ្ងៃទី ១១-០៧-២០១៧ របស់ឈ្មោះ អ៊ូ ប៊ុនរ៉ា អត្តលេខ ៥៥៥ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីតំណាងដោយអាណត្តិឱ្យលោក អ៊ឹង សាន អាយុ ៤៣ឆ្នាំ ដែលមានទីលំនៅ ភូមិ ២៥ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ប្តឹងចោទប្រកាន់លើឈ្មោះ សា ភេទប្រុស អាយុ ៥៣ឆ្នាំ មានទីលំនៅភូមិទ្វីខាងជើង ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ពីបទៈឆបោក ។

បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៣៦៧/១៧ ចុះថ្ងៃទី ០១-១២-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកំពត ។

បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១១ ចុះថ្ងៃទី ០២-០៤-២០១៨ របស់មេធាវីឈ្មោះ អ៊ូ ប៊ុនរ៉ា ប្តឹងតវ៉ានឹងដីកាតម្កល់រឿងឥតចាត់ការខាងលើ ។

បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះអ៊ូ ប៊ុនរ៉ា លេខ១៤៣១ ចុះថ្ងៃទី ១១-០៧-២០១៧ បញ្ជាក់ថាៈ កាលពីឆ្នាំ ២០០៨ ឈ្មោះ សា បានមកលួងលោមកូនក្តីរបស់ខ្លួនឱ្យជួយទិញដីរបស់គាត់ ដោយគាត់អះអាងថា រាជរដ្ឋាភិបាលបានប្រគល់ដីមកឱ្យទៅគាត់តាមរយៈ សជណ លេខ ៥១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១១-០៤-២០០៨ និង សជណ របស់សាលាខេត្តកំពតលេខៈ ៩០ ល.ស ដែលមានព្រំប្រទល់ជាប់ ខាងជើងទល់និង អ ខាងត្បូងទល់និង សមុទ្រ ខាងកើតទល់និងព្រែកខ្លប ខាងលិចទល់ សា ។ ដោយហេតុថា ឈ្មោះ សា បានសន្យាធានាអះអាងថា បើគាត់គ្មានដី ប្រគល់ឱ្យកូនក្តីខ្លួនទេ គាត់សុខចិត្តប្រគល់ប្រាក់ទាំងអស់មកឱ្យខ្លួនវិញគ្រប់ចំនួនព្រមទាំងការប្រាក់៣%(បីភាគរយ) ទៀតផង ហេតុនេះទើបកូនក្តីរបស់ខ្លួនបានសម្រេចចិត្តប្រគល់ប្រាក់ឱ្យឈ្មោះ សា តាមការទាមទាររបស់គេ ។ ក្រោយពីកូនក្តីរបស់ខ្លួនបានប្រគល់ប្រាក់គ្រប់ចំនួនឱ្យទៅឈ្មោះ នាក់ សាម៉េត ហើយឈ្មោះនេះ មិនបានប្រគល់ដីមកឱ្យកូនក្តីរបស់ខ្លួនតាមការសន្យាទេ ហើយបានគេចវេសពីកូនក្តីរបស់ខ្លួនរហូតដល់សព្វថ្ងៃ ។

បានឃើញ កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ ភូ ប៊ុនរ៉ា ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ អ៊ឹង សាន នៅរយៈការអមសាលាដំបូងខេត្តកំពតបញ្ជាក់ថា: ខ្លួនសូមរក្សាចម្លើយ ដូចនៅក្នុងពាក្យបណ្តឹងរបស់ខ្លួនកាលពីថ្ងៃទី ១១-០៧-២០១៧ ទុកជាបានការដដែល ។ សជណ រាជរដ្ឋាភិបាល គឺឈ្មោះ ឌ . ។ មិនដែលបានប្រគល់ឱ្យកូនក្តីរបស់ខ្លួននោះទេ ហើយបន្ទាប់ពីកូនក្តីរបស់ខ្លួនបានសាកសួរទៅសាលាខេត្ត គឺអាជ្ញាធរបានបញ្ជាក់ថា សជណ នោះត្រូវរាជរដ្ឋាភិបាលលុបចោលយូរហើយ កូនក្តីរបស់ខ្លួនបានទិញដីពីឈ្មោះ សា សរុបចំនួន ៣៥ហិកតា និងបានប្រគល់ប្រាក់សរុបប្រហែល ២០ម៉ឺនដុល្លារ ។ ខ្លួនបានដាក់ឯកសារភស្តុតាងជូន លោកព្រះរាជអាជ្ញាពិនិត្យពេលក្រោយ ។ សូមលោកព្រះរាជអាជ្ញាមេត្តាផ្តន្ទាទោសជនល្មើសតាមច្បាប់ និងទាមទារនូវប្រាក់ដើមគ្រប់ចំនួនបន្ថែមជំងឺចិត្ត ១០០.០០០ ដុល្លារ (មួយសែនដុល្លារ) ។

បានឃើញ កំណត់ហេតុសួរចម្លើយរបស់ឈ្មោះ សា នៅអយ្យការអមសាលាដំបូងខេត្តកំពតបញ្ជាក់ថា: ក្រោយពីបានដឹងនូវបណ្តឹងរបស់ឈ្មោះ អ៊ឹង សាន រួចមកខ្លួនសូមជម្រាបជូន អគ្គព្រះរាជអាជ្ញាថា ខ្លួនពិតជាបានលក់ដីឱ្យឈ្មោះ អ៊ឹង សាន ពិតប្រាកដមែន ដោយក្នុងទំហំ ១១៦៣៩៩ ម៉ែត្រការ៉េ ក្នុងតម្លៃ ៦៥០០០ ដុល្លារ ដីនោះជាប្រភេទដីអុី បង្ការ ហើយមាន សជណ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១១-០៤-២០១៨ ប្រគល់សិទ្ធិដល់ខ្លួន និងអ្នកផ្សេងទៀត នៅក្នុងការលក់ទិញដីនេះ គឺយើងធ្វើកិច្ចសន្យាលើកទី ១ នៅថ្ងៃទី ១៥-០៩-២០១៨ ក្នុងទំហំ ១១៦៣៩៩ ម៉ែត្រការ៉េ ក្នុងតម្លៃ ៦៥០០០ ដុល្លារ ប៉ុន្តែប្រគល់លុយបីដំណាក់កាល គឺលើកទីមួយ ៣០០០ ដុល្លារ ,លើកទីពីរ ១២០០០ ដុល្លារ និងលើកទីបី ២០០០០ ដុល្លារ ។ ក្រោយមកដោយ សជណ ត្រូវបានលុបនៅថ្ងៃទី ២៤-០១-២០១០ ឈ្មោះ អ៊ឹង សាន បានទៅរត់ការដើម្បីស្នើសុំ សជណ ដោយខ្លួនឯង ហើយឱ្យខ្លួនប្រគល់សិទ្ធិលើការស្នើសុំកាន់កាប់ដី ក្រោមមកឆ្លងកាត់រយៈពេលពីរឆ្នាំក្រោយមកគាត់រត់ការមិនបាន គាត់ក៏មកជួបខ្លួនម្តងទៀត ដោយឱ្យខ្លួនជាអ្នករត់វិញ ក្រោយមកនៅថ្ងៃទី ១៦-០៩-២០១០ ខ្លួនបានទៅខ្ចីប្រាក់គាត់ចំនួន ២០០០០ ដុល្លារ ដោយបង់ដីថ្លៃធានាបំណុល តាមរយៈលិខិតផ្ទេរលក់ដីជាបណ្តោះអាសន្ន ហើយខ្លួនបានដាក់ប្លង់ដីលេខ AIV ០២៨១ បន្ទាប់មកទៀតខ្លួនបានរត់ការដល់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ចុះថ្ងៃទី ០៤-០៥-២០១១ និងរុញបន្តដល់ក្រសួងបរិស្ថានដូចមានក្នុងលិខិតលេខ ៥៣៣ សជណ ចុះថ្ងៃទី ១៨-០៤-២០១១ ហើយក៏បាត់ដំណឹងរហូត ។ ក្រោយមកទៀត នៅថ្ងៃទី១៧-០៥-២០១៧ ឈ្មោះ អ៊ឹង សាន ក៏បានទាមទាររត់ឯកសារម្តងទៀត ដោយនៅក្នុងកិច្ចសន្យានេះ បានបញ្ជាក់ថាបើគាត់រត់ចេញ ដីចំនួន ២៩ ហិកតា នឹងបានទៅលើគាត់ឈ្មោះ អ៊ឹង សាន ដោយឡែកឈ្មោះ សា គឺបានត្រឹមតែ ៦ ហិកតាប៉ុណ្ណោះ ប៉ុន្តែដោយគ្មានដំណឹងរហូតមកដល់ថ្ងៃទី ២៩-០៦-២០១៧ ខ្លួនក៏បានរត់ឯកសាររហូតដល់ខុទ្ទកាល័យរបស់សម្តេចនាយករដ្ឋមន្ត្រី ហើយនៅថ្ងៃទី ២៥-០៨-២០១៧ ខ្លួនបានទទួលឯកសារ គឺមានដីកាបញ្ជូនរបស់នាយកខុទ្ទកាល័យរបស់សម្តេច គឺឯកឧត្តម ប៊ិន ឈិន ។ បច្ចុប្បន្នដីនោះ គឺខ្លួននៅគ្រប់គ្រងដដែលមិនបាត់បង់ ឬក៏ផ្ទេរសិទ្ធិឱ្យអ្នកណាផ្សេងទេ ។ ទឹកប្រាក់សរុបដែលខ្លួនបានទទួលពីឈ្មោះ អ៊ឹង សាន សរុបទាំងអស់ទាំងប្រាក់សម្រាប់តម្កល់ប្លង់គឺមានចំនួន៥៥០០០ ដុល្លារ (ប្រាំម៉ឺនប្រាំពាន់ដុល្លារ) ។ ខ្លួនពុំបានឆបោក ហើយក៏មិនបានទទួលប្រាក់ពីឈ្មោះ អ៊ឹង សាន រហូតដល់ ២០០.០០០ដុល្លារនោះដែរ ។

បានឃើញ ឯកសារផ្សេងៗដែលពាក់ព័ន្ធសំណុំរឿងខាងលើ ។

យល់ឃើញថា៖ សំអាងហេតុ និងសេចក្តីសម្រេចនៃដីកាតម្កល់រឿងទុកឥតចាត់ការរបស់អយ្យការអមសាលាដំបូងខេត្តកំពត មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

ហេតុដូច្នេះសម្រេច

តម្កល់ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ៣៦៧/១៧ ចុះថ្ងៃទី ០១-១២-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តកំពត ទុកជាបានការដដែល ។

ថ្ងៃសុក្រ ៦រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ០៩ ឆ្នាំ២០១៨

អគ្គព្រះរាជអាជ្ញា

អ៊ុក សាវុធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍
រាជធានីភ្នំពេញ
សំណុំរឿងសភាស៊ើបសួរលេខ ៨៧
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩

## សេចក្តីសន្និដ្ឋាន

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៥០ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-បានឃើញ ដីកាដំណោះស្រាយ ... គំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប សម្រេចចោទប្រកាន់លើ៖

## សាមគារជាតិជនត្រូវចោទ

ឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ ។ ទីកន្លែងកំណើតភូមិជលែង ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ។ ទីលំនៅបច្ចុប្បន្នមុនពេលឃាត់ខ្លួននៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ។ ប្តីឈ្មោះ មានកូនចំនួន៤នាក់ ។ ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "រស់" ជាទីតិជន ទោសពីមុន គ្មាន ។

ចៅក្រមស៊ើបសួរដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការពីបទ លួច ប្រព្រឹត្តនៅត្រង់ចំណុចហាងក្រែបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ** ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ ឆ្នាំ មុខរបរសន្តិសុខ មានទីលំនៅបច្ចុប្បន្ននៅភូមិព្រៃធំ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

## អង្គហេតុ

កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង៣ និង៤០នាទីទាបភ្លឺ នៅត្រង់ចំណុចហាងហាងក្រែបស៊ីហ្វូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅក្នុងភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប មានជនត្រូវចោទឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ បានធ្វើសកម្មភាពលួចយកទូរស័ព្ទដៃមួយគ្រឿង ម៉ាក HUAWEI ពណ៌ខ្មៅ ដែលជារបស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៣៣ឆ្នាំ ប៉ុន្តែ

ត្រូវជនរងគ្រោះឃើញទាន់ ហើយក៏បានស្រែកអោយគេជួយ និងបានឃាត់ខ្លួនជនត្រូវចោទឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ បានភ្លាមៗនិងប្រគល់អោយសមត្ថកិច្ចចាត់ការតាមនីតិវិធី ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៧៤/២០១៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ២០១៩ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

បើកការស៊ើបសួរលើអង្គហេតុខាងលើ និងស្នើសុំ៖

-ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ៖

ឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ ពីបទ លួច ប្រព្រឹត្តនៅត្រង់ចំណុចហាងក្រែបស៊ីហ្គូត ផ្លូវ៦០ម៉ែត្រ ស្ថិតនៅក្នុងភូមិថ្លុករលួង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-ស្នើសុំដាក់ឲ្យឃុំខ្លួនជាបណ្ដោះអាសន្នលើឈ្មោះខាងលើ ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំអោយកើតមានជាថ្មី និងធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំអោយមានភាពច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើសតាមបញ្ញត្តិមាត្រា **២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

## <u>លទ្ធផលស៊ើបអង្កេត</u>

**បានឃើញ** ចម្លើយជនត្រូវចោទឈ្មោះ ល្បើ ស បានឆ្លើយសារភាពនៅដំណាក់កាលចៅក្រមស៊ើបសួរ ឆ្លើយរៀរាប់ថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ។ នៅថ្ងៃកើតហេតុថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោងប្រហែលជា៣យប់ទាបភ្លឺ ពេលនោះខ្លួនបានដើររើសអេតចាយ ហើយពេលទៅដល់ហាងក្រែបស៊ីហ្គូត ផ្លូវ៦០ម៉ែត្រ ក៏ឃើញមានទូរស័ព្ទសាកថ្មនៅលើតុ ខ្លួនក៏បានយកទូរស័ព្ទរបស់គេ (សង្ហិសុខ) ហើយក៏ត្រូវបានគេចាប់បាន និងប្រគល់អោយសមត្ថកិច្ចតែម្ដង ។ សុំអោយតុលាការដោះលែង ព្រោះខ្លួនមានកូនតូចចំនួន៤នាក់ ហើយមានកូនខ្ចីអាយុ ៥ខែ ត្រូវបៅដោះ គ្មានលុយទិញទឹកដោះគោ គ្មានអ្នកមើលកូនទាំងអស់ និងប្ដីជាប់គុកទៀត ។

**បានឃើញ** ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្នលេខ **២៨២ "ឃ"/១៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩** របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

មិនឃុំខ្លួនជនត្រូវចោទឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ដោយអនុញ្ញាតអោយមានសេរីភាពធម្មតាវិញ តែត្រូវអោយឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ គោរពនូវកាតព្វកិច្ច ដែលមានចែងនៅក្នុងដីកាសម្រេចដាក់ជននេះនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជានិច្ច ។

បានឃើញដីកាសម្រេចដាក់ជនត្រូវចោទអោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៧០៤ "ឃ"/១៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ដាក់ជនត្រូវចោទឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) ។

២.បង្គាប់មកឈ្មោះ ស ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ ដូចខាងក្រោម៖

ក.មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ខ.មិនត្រូវផ្លាស់ប្តូរលំនៅដ្ឋានដោយគ្មានលិខិតអនុញ្ញាតពីចៅក្រមស៊ើបសួរ ។

គ.ត្រូវចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការនៅពេលមានដីកាកោះហៅ ។

ឃ.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គល ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ ។

៣.ក្នុងករណីជនត្រូវចោទរូបនេះគេចខ្លួនមិនគោរពកាតព្វកិច្ច ដូចបានកំណត់ខាងលើ យើងនឹងសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ។

បានឃើញ លិខិតដកពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ធ ភេទប្រុស អាយុ៣៣ឆ្នាំ ។

បានឃើញ សេចក្តីថ្លែងបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់លោក ថេង ស៊ំណាង ជាព្រះរាជអាជ្ញារង ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ២៨២ "ឃ"/១៩ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ត្រង់ចំណុចទាំងមូលនៃដីកាសម្រេច ។

## <u>ទម្រង់ច្បាប់នៃបណ្តឹងឧទ្ធរណ៍</u>

យល់ឃើញថា ពាក្យបណ្តឹងឧទ្ធរណ៍ខាងលើ បានធ្វើឡើងក្នុងកំណត់ច្បាប់ គប្បីសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ទទួលជំនុំជម្រះ យោងមាត្រា ២៦៦ មាត្រា ២៧០ និងមាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## <u>អង្គច្បាប់</u>

យល់ឃើញថា បទល្មើសខាងលើជាបទមជ្ឈិម ដែលត្រឹមត្រូវតាមបទចោទរបស់តំណាងអយ្យការ ។

យល់ឃើញថា ប្រសិនបើជនត្រូវចោទ បានបំពេញតាមលក្ខខណ្ឌរបស់ច្បាប់ គួរអោយដាក់ក្រោមការពិនិត្យរបស់តុលាការ ដែលមានលក្ខណៈតឹងរឹងក្រោមការយល់ឃើញរបស់សភាស៊ើបសួរ ។

យល់ឃើញថា ដើមបណ្តឹងបានដកពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៩ រួចរាល់ហើយ ។

## ហេតុដូច្នេះ

## ប្ដឹងសុំ

តំណាងមហាអយ្យការ សូមសន្និដ្ឋានប្ដឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ គប្បីពិចារណា និងសម្រេចតាមការយល់ឃើញខាងលើ ។

ថ្ងៃ.[illegible] ១១ [illegible] ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី...10...ខែមេសា ឆ្នាំ២០១៩

ព្រះរាជអាជ្ញា

តាន់ សេណារ៉ុង

[illegible]
05/05/19
[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍

លេខ ៤២៤ ម.ហ.ក/០១៨

# ដីកាបញ្ជូន

## គោរពជូន: លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប

| រាយឈ្មោះលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
| --- | --- | --- |
| បញ្ជូនសំណុំរឿងតម្កល់ទុកឥតចាត់ការលេខ ៧៨ ចុះថ្ងៃទី ២០-០៣-២០១៧ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ទៅអយ្យការអមសាលាដំបូងខេត្តសៀមរាប ។ | ០១ រឿង | ដើម្បីចាត់ការជាសមត្ថកិច្ច ។ |
| សរុប | ០១រឿង | |

ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨

អគ្គលេខាធិការរង

ខៀវ ស៊ុនណារិទ្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មហាអយ្យការអមសាលាឧទ្ធរណ៍
លេខ ០០៦ ស.ឋ.ប្រ.០១៨

# សេចក្តីសម្រេចអនិបញ្ញាឱ្យចោទប្រកាន់

-បានឃើញ មាត្រា៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៨១ ចុះថ្ងៃទី ០៥-១២-២០១៦ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-បានឃើញ សំណុំរឿង "តម្កល់ទុកឥតចាត់ការ" ចុះបញ្ជីនៅមហាអយ្យការអមសាលាឧទ្ធរណ៍លេខ ៧៨ ចុះថ្ងៃទី ២០-០៣-២០១៧ ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ២២-១១-២០១៦ របស់លោក យឹង សុជាថា ជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ , ឈ្មោះ , ឈ្មោះ និង ឈ្មោះ មានការិយាល័យស្ថិតនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ប្តឹងចោទប្រកាន់លើឈ្មោះដូចខាងក្រោម៖

០១. ឈ្មោះ ភេទប្រុស អាយុ ៤៩ឆ្នាំ
០២. ឈ្មោះ ភេទប្រុស អាយុ ៥៦ឆ្នាំ
០៣. ឈ្មោះ ភេទស្រី អាយុ ៦៨ឆ្នាំ
០៤. ឈ្មោះ ភេទស្រី អាយុ ២១ឆ្នាំ
០៥. ឈ្មោះ ភេទស្រី អាយុ ៥១ឆ្នាំ
០៦. ឈ្មោះ ភេទស្រី អាយុ ២៦ឆ្នាំ
០៧. ឈ្មោះ ភេទស្រី អាយុ ៤៨ឆ្នាំ
០៨. ឈ្មោះ ភេទស្រី អាយុ ៥៧ឆ្នាំ
០៩. ឈ្មោះ ភេទស្រី អាយុ ៤៧ឆ្នាំ
១០. ឈ្មោះ ភេទស្រី អាយុ ៨៨ឆ្នាំ
១១. ឈ្មោះ ភេទប្រុស អាយុ ២៧ឆ្នាំ
១២. ឈ្មោះ ភេទស្រី អាយុ ៣២ឆ្នាំ
១៣. ឈ្មោះ ភេទស្រី អាយុ ៥៨ឆ្នាំ
១៤. ឈ្មោះ ភេទស្រី អាយុ ៥៨ឆ្នាំ
១៥. ឈ្មោះ ភេទស្រី អាយុ ៤៩ឆ្នាំ
១៦. ឈ្មោះ ភេទស្រី អាយុ ៣៨ឆ្នាំ
១៧. ឈ្មោះ ភេទប្រុសអាយុ ២៥ឆ្នាំ
១៨. ឈ្មោះ ភេទស្រី អាយុ ៥០ឆ្នាំ

មានទីលំនៅសព្វថ្ងៃភូមិនគរភាស២ ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប ។

១៩. ឈ្មោះ ភេទប្រុស អាយុ ៧០ឆ្នាំ
២០. ឈ្មោះ ភេទស្រីអាយុ ៦៩ឆ្នាំ

២១. ឈ្មោះ ភេទប្រុស អាយុ ៥៨ឆ្នាំ

២២. ឈ្មោះ ភេទប្រុសអាយុ ៥៨ឆ្នាំ

មានទីលំនៅសព្វថ្ងៃនៅភូមិនគរភាស១ ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប ។

ពីបទៈ ផ្តើមគំនិត និងសមគំនិតក្នុងអំពើហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស និងលួចដោយមានស្ថានទម្ងន់ទោស ។

-បានឃើញ ដីកាតម្កល់រឿងទុកឥតចាត់ការលេខ ២១៥ អ.យ ចុះថ្ងៃទី ១៣-០២-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ៣២ អ.ក ២០១៧ ចុះថ្ងៃទី ០២-០៣-២០១៧ របស់លោក ឃឹង សុជាថា មេធាវីការពារឱ្យដើមបណ្តឹង សុំប្តឹងឧទ្ធរណ៍នឹងដីកាតម្កល់រឿងទុកឥតចាត់ការខាងលើ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់ដើមបណ្តឹងឈ្មោះ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាបថាៈ ខ្លួនជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ។ កាលពីថ្ងៃទី ៣០-១០-២០១៦ វេលាម៉ោងប្រហែល ០១រសៀល ខ្លួនបានទូលត្រៃហែរកឋិនទាននៅក្នុងវត្តនគរភាស ស្រាប់តែមានឈ្មោះ បានមកវាយខ្លួនត្រូវដោះខាងឆ្វេងចំនួន០៣ដៃ និងចាប់ហែកអាវរបស់ខ្លួនអស់ ។ ខ្លួនពុំដឹងពីមូលហេតុពិតប្រាកដទេ ប៉ុន្តែនៅពេលខ្លួនកំពុងទូលត្រៃនោះ ស្រាប់តែឈ្មោះ មកទាញត្រៃពីក្បាលខ្លួន ពេលខ្លួនមិនឱ្យទើបគេវាយខ្លួនតែម្តង ខ្លួនពុំដែលមានគំនុំអ្វីជាមួយគាត់ពីមុនមកទេ តែបើតាមខ្លួនដឹង គឺគាត់មានគំនុំជាមួយព្រះចៅអធិការវត្តព្រះនាម ។ នៅពេលកើតហេតុនោះក្រុមរបស់ឈ្មោះ ដែលមានឈ្មោះ និងបក្សពួកផ្សេងទៀត ហើយពួកគាត់ទាំងអស់នេះបានវាយអ្នកផ្សេងៗទៀតដែលបានហែរត្រៃជាមួយនឹងខ្លួនផងដែរ តែចំពោះអ្នកដែលវាយខ្លួនផ្ទាល់នោះ គឺឈ្មោះ ។ ឈ្មោះ នេះ ក្រោយពីវាយខ្លួនរួច គឺគាត់បានស្ទុះទៅវាយឈ្មោះ ដែលកំពុងឡើងព្រះវិហារ ត្រូវចំស្មាខាងឆ្វេង និងក្បាលបណ្តាលឱ្យរបួសជាទម្ងន់ ។ រីឯឈ្មោះ និងឈ្មោះ បានស្ទុះទៅវាយឈ្មោះ ដែលជាអ្នកទូលត្រៃចំក្បាលជាច្រើនដៃ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់ដើមបណ្តឹងឈ្មោះ នៅអយ្យការអមតុលាការដំបូងខេត្តសៀមរាបថាៈខ្លួនជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ។ កាលពីថ្ងៃទី ៣០-១០-២០១៦ វេលាម៉ោង ០២រសៀល ខ្លួនកំពុងរាំមុខក្បួនហែរកឋិននៅវត្តនគរភាស ស្រាប់តែមានឈ្មោះ និងឈ្មោះ បានដឹកនាំបក្សពួករបស់គាត់ជាច្រើននាក់មកអុកឡុកក្បួនដង្ហែកឋិនទានចូលមកវត្ត និងមានឈ្មោះ ជាអ្នកកាន់ដបទឹកនោមយកមកបាចលើអ្នកហែរកឋិនឱ្យប្រឡាក់ជាច្រើននាក់ ។ លុះពេលដែលកំពុងតែហែរប៉ុងឡើងលើព្រះវិហារ ស្រាប់តែមានឈ្មោះ និងឈ្មោះ បាននាំគ្នាស្ទុះចូលមកអុកឡុក និងវាយទៅលើមនុស្សនៅក្នុងក្បួនដង្ហែរងរបួសជាច្រើននាក់បណ្តាលឱ្យមានភាពវឹកវរយ៉ាងខ្លាំង ហើយក្នុងខណៈនោះឈ្មោះ និងកូនប្រុសឈ្មោះ អាយុ ២៥ឆ្នាំ បានវាយបកលើខ្លួនដែលជាអ្នករាំមុខត្រៃត្រូវចំក្បាល

ពក, ច្របាច់ក, ហែកអាវ និងបានឆក់យកខ្សែកមាសទម្ងន់ ៥,៥ជី និងក្រវិលមាសមួយគូទម្ងន់ ០១ជី ។ ក្នុងខណៈនោះ ខ្លួនក៏បានស្រែកឱ្យសមត្ថកិច្ចជួយអន្តរាគមន៍ផងដែរ តែខាងសមត្ថកិច្ចហាក់ដូចជាមិនអើពើជួយឡើយ ហើយឈ្មោះ ក្រោយពីវាយខ្លួនរួចហើយ ក៏បានស្ទុះទៅវាយលើឈ្មោះ ទៀតផង ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់ដើមបណ្តឹងឈ្មោះ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាបថា៖ កាលពីថ្ងៃទី ៣០-១០-២០១៦ វេលាម៉ោង ០២ និង ៣០នាទីរសៀល ខ្លួនកំពុងនៅលើព្រះវិហារ ហើយកូនរបស់ខ្លួនឈ្មោះ ក៏បានចូលរួមហែរកឋិនទានជាមួយអ្នកភូមិ ស្រាប់តែឈ្មោះ និងឈ្មោះ បានមកវាយកូនខ្លួនត្រូវចំក្បាលជាច្រើនដៃ បណ្តាលឱ្យឈឺក្បាលជាច្រើនថ្ងៃ តែពុំមានវិក្កយបត្រថ្លៃព្យាបាលនោះទេ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយរបស់ដើមបណ្តឹងឈ្មោះ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាបថា៖ខ្លួនជាជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ។ កាលពីថ្ងៃទី ៣០-១០-២០១៦ វេលាម៉ោង ០២ និង៣០រសៀល ខ្លួនកំពុងតែហែរកឋិនទាន ស្រាប់តែឈ្មោះ បានស្ទុះមកកាច់កខ្លួន និងវាយត្រូវចំស្មាខាងឆ្វេង ក្បាលជាច្រើនដៃ បណ្តាលឱ្យមានរបួសជាទម្ងន់ ។ នៅពេលវាយពួកខ្លួននោះមិនត្រឹមតែមានឈ្មោះ តែម្នាក់នោះទេ គឺមានទាំងបក្សពួករបស់គាត់ជាច្រើននាក់ទៀតដូចខ្លួនបានរៀបរាប់នៅក្នុងពាក្យបណ្តឹងនេះស្រាប់ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយលើជនសង្ស័យឈ្មោះ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាបថា៖ ខ្លួនពុំបានដឹងថាអ្នកណាជាអ្នកប្តឹងខ្លួនឱ្យពិតប្រាកដនោះទេ ប៉ុន្តែខ្លួនបានឃើញអ្នកប្តឹងនៅក្នុងដីកានោះមានឈ្មោះខ្លះខ្លួនស្គាល់ និងឈ្មោះខ្លះទៀត ខ្លួនពុំស្គាល់ទេ គ្រាន់តែដឹងថាអ្នកប្តឹងទាំងអស់នោះរស់នៅក្នុងភូមិនគរភាស១ ។ នៅថ្ងៃទី៣០-១០-២០១៦ វេលាម៉ោងប្រហែល ០២ជាង ខ្លួនពុំបានចូលរួមដង្ហែរកឋិនទាននៅក្នុងវត្តនគរភាស ទេ តែខ្លួននៅក្នុងបរិវេណវត្តនោះដែរ គឺនៅសាលាធម៌សុភា (សាលាឆាន់) មានចំងាយប្រហែល ១០០ម៉ែត្រ ពីកន្លែងហែរនោះ ហើយស្រាប់តែពួកវាយប្រកែកគ្នារវាងស្រី និងស្រី ក៏មានមនុស្សប្រុសខ្លះដែរ តែតាមខ្លួនដឹងថាពេលនោះមិនបានវាយគ្នានោះទេ ហើយខ្លួនក៏មិនបានមកកន្លែងកើតហេតុដែរ ។ ចំណែកអ្នកធ្វើកឋិនចូលវត្តពេលនោះ គឺអ្នកភូមិឈូក ឃុំក្រញ៉ូវ ស្រុកពួក ហើយក៏មានអ្នកភូមិនគរភាស១ បានចូលរួមដែរ ។ តាមខ្លួនដឹងដំបូងឡើយ នៅក្នុងវត្តនោះគ្មានអ្នកណាដាក់ពាក្យចូលធ្វើអង្គកឋិនទានទេពេលនោះក្នុងនាមខ្លួនជាគណៈកម្មាធិការវត្ត ខ្លួនក៏បានពិភាក្សាជាមួយលោកអាចារ្យវត្ត និងគណៈកម្មការទាំងអស់ថានឹងធ្វើកឋិនទានសាមគ្គី នៅថ្ងៃទី០៥ ទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោយពីពិភាក្សាហើយ ខ្លួនក៏បានពិតលោកចៅអធិការវត្តព្រះនាម ព្រះអង្គក៏បានយល់ព្រម រួចខ្លួនក៏បានដាក់កម្មវិធីកឋិនជូនប្រជាពលរដ្ឋជិតឆ្ងាយ ប៉ុន្តែក្រោយមកទៀតស្រាប់តែឃើញមានកម្មវិធីផ្សេងពីពួកខ្លួន គឺកម្មវិធីរបស់អ្នកភូមិឈូក ដោយកំណត់ហែរចូលនៅថ្ងៃទី៣០-១០-២០១៦ ទៅវិញ ពេលនោះខ្លួនក៏បានទាក់ទងទៅមេឃុំ និងជម្រាបទៅលោកអនុគុណ និងធម្មការស្រុក ។ លុះមកដល់ថ្ងៃទី ២៨-១០-២០១៦ ក៏មានគណៈកម្មការរបស់ស្រុកមកសម្របសម្រួលថា ឱ្យហែរអង្គកឋិនទានរបស់ភូមិឈូកចូលមកក្នុងវត្តចុះ តែមិនឱ្យហែរចូលព្រះវិហារទេ ចាំដល់ថ្ងៃទី០៥, ទី០៦ ចាំហែរចូលទាំងអស់គ្នា

Rat

ប៉ុន្តែនៅថ្ងៃទី ៣០-១០-២០១៦ អង្គកឋិនទានរបស់អ្នកភូមិឈូក និងមានអ្នកភូមិនគរភាស១ ចូលរួមដែរ ហើយពុំព្រមស្តាប់តាមការណែនាំតាមគណៈកម្មការស្រុក បានហែរចូលព្រះវិហារ ក៏មានរឿងហេតុកើតឡើងតែម្តងទៅ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយលើជនសង្ស័យឈ្មោះ ពាន់ ពាង នៅអយ្យការអមសាលាដំបូងខេត្តសៀមរាបថា៖ ខ្លួនគឺជាគណៈកម្មការវត្តនគរភាស ហើយនៅថ្ងៃទី ៣០-១០-២០១៦ វេលាម៉ោងប្រហែល ០២រសៀល មានអ្នកភូមិឈូកបានដង្ហែរកឋិនទានចូលក្នុងវត្ត ហើយក៏ឮថាមានបញ្ហានៅកន្លែងដង្ហែរកឋិនទាននោះ តែខ្លួនមិនបានចូលរួមទេ ខ្លួននៅសាលាធម៌ខាងជើង មានចម្ងាយពីកន្លែងដង្ហែរប្រហែល១០០ម៉ែត្រ ។ ខ្លួនមិនបានដឹកនាំកម្លាំងទៅឡុកឡុកក្នុងក្បួនដង្ហែរកឋិនទានរបស់អ្នកភូមិឈូកទេ ហើយក៏មិនបានចូលរួមវាយទៅលើអ្នកភូមិនគរភាស១ ដូចការចោទប្រកាន់នោះដែរ ។ ចំពោះអ្នកប្តឹងមកលើពួកខ្លួននោះ ខ្លួនធ្លាប់ស្គាល់ព្រោះពួកគាត់រស់នៅភូមិនគរភាស ហើយពួកនោះខ្លួនពុំធ្លាប់មានទំនាស់អ្វីជាមួយគ្នាពីមុនមកដែរ ។ នៅថ្ងៃទី ៣០-១០-២០១៦ វេលាម៉ោងប្រហែល ០២ជាង ក្បួនដង្ហែររបស់អ្នកភូមិឈូកបានប្រឆាំងនឹងកឋិនទានរបស់អ្នកភូមិនគរភាស២ បន្ទាប់មកក៏មានការសម្រុះសម្រួលពីគណៈកម្មការរបស់ស្រុកអង្គរជុំ ថាឱ្យកឋិនរបស់អ្នកភូមិឈូក ហែរចូលនៅថ្ងៃទី ៣០-១០-២០១៦ តែមិនឱ្យចូលទៅព្រះវិហារ ទេ ទុកត្រឹមវត្តចុះ ចាំដល់ថ្ងៃទី ០៦-១១-២០១៦ ចាំហែរចូលទាំងអស់គ្នា ជាកឋិនរបស់អ្នកភូមិនគរភាស២ តែពេលវេលាដង្ហែរនោះថ្ងៃទី ៣០-១០-២០១៦ ពួកគេមិនព្រមស្តាប់ ក៏ដង្ហែរសម្រុកចូលទៅព្រះវិហារ ក៏មានអ្នកភូមិនគរភាស២ ព្រមទាំងកម្លាំងសមត្ថកិច្ចបានទៅហាមមិនឱ្យហែរចូលព្រះវិហារ ក៏មានបញ្ហានេះតែម្តង ។ ខ្លួនមិនបានដឹកនាំអ្នកភូមិទៅហាមឃាត់ទេ ហើយខ្លួនក៏មិនបានដឹងថាអ្នកណាចូលរួមទៅហាមឃាត់ក្បួនកឋិននោះដែរ ព្រោះខ្លួននៅឆ្ងាយពីកន្លែងកើតហេតុនោះ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយលើដើមបណ្តឹងឈ្មោះ [redacted] នៅមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ខ្លួនសូមរក្សាកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៧-០១-២០១៨ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ដោយពុំមានការកែប្រែអ្វីឡើយ ។ ខ្លួនសូមបញ្ជាក់ថានៅថ្ងៃកើតហេតុគឺឈ្មោះ [redacted] ជាអ្នកឈរបញ្ជាដោយផ្ទាល់មាត់របស់គាត់ឱ្យឈ្មោះ [redacted] វាយមកលើរូបខ្លួនរបួសត្រង់ករហូតដល់សព្វថ្ងៃនេះ ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយលើដើមបណ្តឹងឈ្មោះ [redacted] នៅមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ខ្លួនសូមរក្សាកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៧-០១-២០១៨ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ដោយពុំមានការកែប្រែអ្វីឡើយ ។ ខ្លួនសូមបញ្ជាក់ថានៅថ្ងៃកើតហេតុនោះ គឺឈ្មោះ [redacted] ជាអ្នកឈរបញ្ជាដោយផ្ទាល់ហាត់ឱ្យឈ្មោះ [redacted] និងឈ្មោះ [redacted] វាយមកលើរូបខ្លួន និងវាយទៅលើអ្នកភូមិនៅលើព្រះវិហាររងរបួសគ្រប់ៗគ្នា ។

-បានឃើញ កំណត់ហេតុសួរយកចម្លើយលើដើមបណ្តឹងឈ្មោះ [redacted] នៅមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ ខ្លួនសូមរក្សាកំណត់ហេតុសួរយកចម្លើយ ចុះថ្ងៃទី ១៧-០១-២០១៨ នៅអយ្យការអមសាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល ដោយពុំមានការកែប្រែអ្វីឡើយ ហើយខ្លួននៅតែប្រកាន់ជំហរប្តឹងចោទប្រកាន់លើឈ្មោះ [redacted] និងបក្ខពួកទាំងអស់ ពីបទៈ ប្រើអំពើហិង្សាមកលើរូបខ្លួនដដែល ។ សូមបញ្ជាក់ថា នៅថ្ងៃកើតហេតុនោះ

ក្នុងខណៈខ្លួនកំពុងតែចូលរួមក្នុងការហែរកឋិននៅវត្តនគរភាស ស្រាប់តែមានឈ្មោះ [illegible] ហើយនឹងបក្ខពួកជាច្រើនបានស្ទុះមកវាយខ្លួន និងប្រជាពលរដ្ឋផ្សេងទៀត ដែលកំពុងតែហែរកឋិននោះត្រូវរបួសជាទម្ងន់ ដោយខ្សែក្រវ៉ាត់ខ្លួនត្រូវបានឈ្មោះ [illegible] មកវាយត្រូវជាច្រើនដៃ ហើយនិងត្រូវជាច្រើនកន្លែង ជាពិសេសត្រូវត្រង់តល់ដោះខាងឆ្វេងរងរបួសជាដំណំរហូតមកដល់សព្វថ្ងៃ ។

-បានឃើញ ឯកសារផ្សេងៗពាក់ព័ន្ធក្នុងសំណុំរឿងខាងលើ ។

## យល់ឃើញថា

-ក្រោយពីមហាអយ្យការអមសាលាឧទ្ធរណ៍ បានពិនិត្យលើចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះ, ចម្លើយរបស់ជនសង្ស័យ និងភស្តុតាងជាវីដេអូខ្លីប ព្រមទាំងបានសាកសួរបន្ថែមទៅលើដើមបណ្តឹងរដ្ឋប្បវេណីរួចមក ឃើញថាកាលពីថ្ងៃទី ៣០-១០-២០១៦ ពិតជាមានករណីហិង្សាមួយកើតឡើងនៅក្នុងវត្តឥន្ទរង្សីពោធិញាណ ហៅ វត្តនគរភាស ប្រាកដមែន ដែលបង្កើតឡើងដោយមនុស្សមួយក្រុមមានឈ្មោះ [illegible], ឈ្មោះ [illegible] យ៉ន, ឈ្មោះ [illegible] និងឈ្មោះ [illegible] ព្រមទាំងបក្ខពួកមួយចំនួនជាច្រើននាក់ទៀត ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះមានឈ្មោះ [illegible], ឈ្មោះ [illegible] និងឈ្មោះ [illegible] បានឆ្លើយស្របគ្នាក្នុងការដាក់បន្ទុកទៅលើឈ្មោះ [illegible], ឈ្មោះ [illegible], ឈ្មោះ [illegible] និងឈ្មោះ [illegible] ព្រមទាំងបក្ខពួកថាបានវាយទៅលើពួកគាត់រងរបួសជាទម្ងន់ ដែលមានភស្តុតាងជាវីដេអូខ្លីបបានបង្ហាញពីសកម្មភាពរបស់ក្រុមជនសង្ស័យចូលទៅអុកឡុក និងវាយទៅលើភាគីដើមបណ្តឹងដែលកំពុងហែរអង្គកឋិនទានចូលក្នុង វត្តឥន្ទរង្សីពោធិញាណ ហៅ វត្តនគរភាស ព្រមទាំងមានសំបុត្រអត្ថរបស់ពេទ្យបញ្ជាក់អំពីស្ថានភាពជម្ងឺ ដែលបណ្តាលមកពីអំពើហិង្សារបស់ក្រុមជនល្មើស ។

-ចម្លើយរបស់ឈ្មោះ [illegible] និងឈ្មោះ [illegible] ក៏បានទទួលស្គាល់ថាពិតជាករណីហិង្សាប្រតាយប្រតប់គ្នាក្នុងវត្តឥន្ទរង្សីពោធិញាណ ហៅ វត្តនគរភាស រវាងអ្នកហែរកឋិនទាន (អ្នកភូមិនគរភាស) និងអ្នកហែរកឋិនទាន (អ្នកភូមិឈ្នក) ប្រាកដមែន តែចំណុចដែលអ្នកទាំងពីរនាក់នេះបានលើកឡើងថា ពួកគាត់ពុំបាននៅនឹងកន្លែងកើតហេតុទេ គឺនៅក្នុងសាលាធម៌ មានចម្ងាយប្រហែល ១០០ម៉ែត្រ ពីកន្លែងកើតហេតុនោះ គឺពុំសមហេតុផលទេ ហើយក៏ពុំមានសាក្សីណាអាចបញ្ជាក់បានដែរ ។ ដូច្នេះ ចម្លើយរបស់ឈ្មោះ [illegible] ឈ្មោះ [illegible] ពិតជាស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់ដើមបណ្តឹងប្រាកដមែន ។

-ពិតជាមានអង្គហេតុអំពើហិង្សាដោយចេតនា ដែលបង្កឡើងដោយជនល្មើសឈ្មោះ [illegible], ឈ្មោះ [illegible], ឈ្មោះ [illegible] និងឈ្មោះ [illegible] ទៅលើជនរងគ្រោះឈ្មោះ [illegible], ឈ្មោះ [illegible], ឈ្មោះ [illegible] និងឈ្មោះ [illegible] ក្នុងអំឡុងពេលហែរកឋិនចូលវត្តឥន្ទរង្សីពោធិញាណ ហៅ វត្តនគរភាស កាលពីថ្ងៃទី ៣០-០៦-២០១៦ ពុំទាន់បានធ្វើការស៊ើបអង្កេតនៅឡើយ ដូចនេះ គប្បីចាត់ការតាមនីតិវិធីច្បាប់បន្តទៀត ។

-មានតម្រុយពិរុទ្ធភាពលើឈ្មោះ [illegible] ភេទប្រុស, ឈ្មោះ [illegible] ភេទស្រី, ឈ្មោះ [illegible] ភេទស្រី និងឈ្មោះ [illegible] ភេទស្រី ព្រមទាំងតួកន ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវត្តឥន្ទរង្សីពោធិញាណ ហៅ វត្តនគរភាស ស្ថិតនៅភូមិនគរភាស២ ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប កាលពីថ្ងៃទី ៣០-០៦-២០១៦ ដែលគប្បីបើកការស៊ើបសួរតាមនីតិវិធីច្បាប់ ។

-សំអាងហេតុ និងសេចក្តីសម្រេចនៃដីកាតម្កល់រឿងទុកឥតចាត់ការលេខ ២១៥ អ.យ ចុះថ្ងៃទី ១៣-០២-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប សម្រេចមានលក្ខណៈមិនត្រឹមត្រូវតាមគតិច្បាប់ គប្បីបដិសេធចោល រួចសម្រេចជាថ្មីឡើងវិញ ។

**ហេតុដូច្នេះសម្រេច**

១-បដិសេធដីកាតម្កល់រឿងទុកឥតចាត់ការលេខ ២១៥ អ.យ ចុះថ្ងៃទី ១៣-០២-២០១៧ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ចោលជាអសារបង់ ។

២-ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប ឱ្យធ្វើការចោទប្រកាន់លើឈ្មោះ [illegible] ភេទប្រុស, ឈ្មោះ [illegible] ភេទស្រី, ឈ្មោះ [illegible] ភេទស្រី និងឈ្មោះ [illegible] ភេទស្រី (មានសាវតាជាតិដូចខាងលើ) ព្រមទាំងតួកន ពីបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចវត្តឥន្ទរង្សីពោធិញាណ ហៅ វត្តនគរភាស ស្ថិតនៅភូមិនគរ ភាស២ ឃុំនគរភាស ស្រុកអង្គរជុំ ខេត្តសៀមរាប កាលពីថ្ងៃទី ៣០-០៦-២០១៦ ។

៣-បង្វិលសំណុំរឿងតម្កល់ទុកឥតចាត់ការលេខ ៧៨ ចុះថ្ងៃទី ២០-០៣-២០១៧ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ទៅអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមផ្លូវច្បាប់តទៅ ។

ថ្ងៃ.................... ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី......... ខែ......... ឆ្នាំ២០១៨

អគ្គព្រះរាជអាជ្ញា

និត_សុទ្ធី